ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការកកើតនៃខ្មែរក្រហមនិងរបបកម្ពុជាប្រជាធិបតេយ្យ
- លទ្ធភាពថវិកាវិភាគទានឯកជន...

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ ៨៦ ខែកុម្ភៈ ឆ្នាំ២០០៧

**ស្វែងរកការពិត**

លេខ៨៦ ខែកុម្ភៈ ឆ្នាំ២០០៧

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ ការកកើតនៃខ្មែរក្រហមនិងរបបកម្ពុជាប្រជាធិបតេយ្យ .........១

**ផ្នែកឯកសារ**

◆ ព្រឹទ្ធាចារ្យ គង់ ណៃ ៖ អ្នកចម្រៀងចាប៉ីដើងចាស់..............................២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម.......................................................................១១

◆ គីមយន ចង់សួរ នួន ជា ថា ហេតុអ្វីបានជាបងប្រុសរបស់ខ្ញុំ ..............១៧

◆ កុមារទន្រ្ទានខែត្រ .................................................................១៨

◆ បន្ទត់ដូចអ្នកជាប់ទោស ............................................................២១

◆ ទួលស្លែងរំឭករឿងអតីតកាល ....................................................២៣

◆ ដំណើរទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញលើកទីបីរបស់មេឃុំ ..........២៥

◆ ភាពអន្ទការនៃរបបខ្មែរក្រហម....................................................៣៤

◆ ប្រទេសស៊ុយអែតផ្តល់ឯកសារខ្មែរក្រហមដល់មជ្ឈមណ្ឌល .................៣៦

**ផ្នែកច្បាប់**

◆ អំពីស្ថានភាពនិងដំណើរការនៃសាលាក្តីខ្មែរក្រហម.........................៣៨

◆ លទ្ធភាពថវិកាវិភាគទានឯកជនផ្តល់ដល់អង្គជំនុំជម្រះវិសាមញ្ញ ........៤០

**វេទិកាពិភាក្សាសាធារណៈ**

◆ ការបង្ហាញអំពីការរំលោភច្បាប់របស់ខ្មែរក្រហម ..........................៤៦

◆ ឧបសគ្គអ្វីខ្លះដែលធ្វើឲ្យការកាត់សេចក្តីពន្យារពេល .......................៥៣

◆ សេចក្តីប្រកាសព័ត៌មាន...........................................................៥៦

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ ប្រវត្តិគ្រួសារខ្ញុំ .....................................................................៥៧




ផែនទីប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ឆ្នាំ១៩៧៧

ឆ្នាំ១៩៧៨



ពិធីបង្សុកូលនៅវាលពិឃាតបឹងជើងឯក

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាដៃលេខនេះ ៖** ផេង ពង្សរ៉ាស៊ី, ឆាយ ណារឿន, ទង ឧត្តរារា, ហ៊ុន សុធានី, ប៉ិង ពីវ៉ន, កែវ ដាស៊ីល, ចន ផរតីអារី, អាលីសុន ខេមហាយ, ជូលា ហ្វ្រមហូលស៍, វ៉ាន់ថាន់ ពៅដារ៉ា, អៀ ហុង **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ណយ សុដារី, ឌី ខាំបូលី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុខល **ក្រាហ្វិកកុំព្យូទ័រ ៖** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** វ័ន្ត តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ការកកើតនៃខ្មែរក្រហមនិងរបបកម្ពុជាប្រជាធិបតេយ្យ

*នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងប្រមុខរដ្ឋ ។ ថ្វីបើរដ្ឋប្រហារនេះទទួលបានប្រជាប្រិយភាពពីសំណាក់អភិជននិងបញ្ញវន្តខ្មែរក៏ដោយ ប៉ុន្តែ ប្រជាជននៅតាមតំបន់ស្រុកស្រែនៅតែគោរពស្មោះស្ម័គ្រនឹងសម្តេចព្រះ នរោត្តម សីហនុ ដដែល ហើយមិនយល់ស្របចំពោះការធ្វើរដ្ឋប្រហារនេះឡើយ ។ ប្រជាជនកម្ពុជាជាច្រើនរត់ចូលព្រៃរួមចលនាជាមួយខ្មែរក្រហមដើម្បីប្រមូលកម្លាំងប្រឆាំងនឹងរបប លន់ នល់ ដែលឈ្មោះជាផ្លូវការហៅថា "របបសាធារណរដ្ឋខ្មែរ" ។ ដោយមានការដឹកនាំជាចម្បងពីក្រុមឆ្វេងនិយមដែលទទួលការអប់រំពីប្រទេសបារាំងក្រោមឥទ្ធិពលនៃលទ្ធិម៉ៅ ខ្មែរក្រហមបានសាប ព្រោះបណ្តុះបដិវត្តន៍នៅតាមតំបន់ជនបទផ្តើមឡើងដំបូងក្នុងចុងទសវត្សរ៍ឆ្នាំ១៩៤០ (កងទ័ពឈ្លបខ្មែរគាំទ្រដោយអ្នកកុម្មុយនីស្ត ដែលទទួលការទំនុកបម្រុងបន្តពីកងទ័ពវៀតមិញបានកាន់កាប់ជាងពាក់កណ្តាលនៃទឹកដីកម្ពុជាក្នុងឆ្នាំ១៩៥៤) ។*

*ចលនាខ្មែរក្រហមបានរីកសាយភាយយ៉ាងលឿននៅតាមជនបទពាសពេញផ្ទៃប្រទេស ។ រហូតមកដល់ពាក់កណ្តាលឆ្នាំ១៩៧២ ចលនាខ្មែរក្រហមបានត្រួតត្រាប្រទេសកម្ពុជាស្ទើរតែទាំងស្រុង លើកលែងតែរដ្ឋធានីភ្នំពេញទឹកដីប្រមាណ២០ភាគរយនៃភូមិភាគនិរតីនិងតំបន់តាមច្រកផ្លូវធំៗប៉ុណ្ណោះ ។ របប លន់ នល់ ទទួលរងការយាយីពីអំពើពុករលួយ ទាហានលួចរត់ចោលជួរ និងការទម្លាក់គ្រាប់បែកនៅតាមជនបទ ។ ដោយហេតុនេះហើយ របបនេះពុំមានកម្លាំងគ្រប់គ្រាន់នឹងតទល់ជាមួយកងទ័ពខ្មែរក្រហមដែលមានអ្នកដឹកនាំថ្នាក់លើប្រកបដោយវិន័យ និងការហ៊ឹកហ៊ឺនជាអ្នកជ្រើសរើសប្រមូលកម្លាំងទ័ពតាមរយៈសកម្មភាពបង្ខំនិងស្ម័គ្រចិត្ត ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានដើរក្បួនដង្ហែចូលទីក្រុងភ្នំពេញ ខណៈពេលដែល លន់ នល់ និងសម្ព័ន្ធមិត្តរបស់ខ្លួនបានភៀសខ្លួនទៅបរទេស ។*

*ខ្មែរក្រហមចង់បានបដិវត្តន៍មួយ ដែលមានសុទ្ធតែកសិករក្រីក្រ និងមានការបែងចែកដីធ្លី ទ្រព្យសម្បត្តិស្មើៗគ្នា ។ ដើម្បីទទួលបានបដិវត្តន៍បែបនេះ សកម្មភាពដំបូងរបស់ខ្មែរក្រហមគឺតម្រូវឲ្យទីក្រុងទទេគ្មានមនុស្សរស់នៅ (ចំនួនប្រជាជនសរុបនៅទីក្រុងភ្នំពេញឡើងដាង៣លាននាក់ គឺកើនឡើង បីដងក្នុងរបប លន់ នល់ ដោយសារមានជនភៀសខ្លួនពីជនបទមករស់នៅទីក្រុង ដើម្បីគេចពីការទម្លាក់គ្រាប់បែក) ។ ខ្មែរក្រហមបង្ខំឲ្យប្រជាជនធ្វើការហួសកម្លាំងនៅតាមជនបទ ។ បន្ទាប់មកទៀត ខ្មែរក្រហមបិទច្រកចេញចូលតាមព្រំដែននិងបំផ្លាញចោលទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធប្រទេសកម្ពុជា (ឧទាហរណ៍ ដូចជា សាលារៀន ទីកន្លែងសក្ការបូជា ធនាគារ គ្រឹះស្ថានពាណិជ្ជកម្ម ប៉ុស្តិ៍ប្រៃសណីយ៍ និងប្រព័ន្ធគមនាគមន៍) និងធ្វើសមូហភាវូបនីយកម្មទ្រព្យសម្បត្តិ ។ សម្ភារបន្តិចបន្តួចដែលខ្មែរក្រហមអនុញ្ញាតឲ្យប្រជាជនទុកជាប់នឹងខ្លួនគឺមានតែចាននិងស្លាបព្រាបាយប៉ុណ្ណោះ ។*

*ខ្មែរក្រហមយល់ឃើញថា អ្នកដែលមានវិជ្ជាជីវៈ មានចំណេះដឹង អ្នករស់នៅទីក្រុង និងអ្នកនិយាយភាសាបរទេស លើកលែងតែខ្មែរក្រហមខ្លួនឯងផ្ទាល់គឺសុទ្ធតែជាជនគួរឲ្យសង្ស័យ ។ ខ្មែរក្រហមចង់លុបបំបាត់ចោលសង្គមដែលមាន"សមាសភាពអាក្រក់" និងចាប់ផ្តើមកសាងសង្គមថ្មីមួយទៀត ។*

*ក្រុមចម្បងទីមួយនៃ"សមាសភាពអាក្រក់" ដែលខ្មែរក្រហមដៅបម្រុងនឹងលុបបំបាត់ចោល គឺមន្ត្រីរាជការនិងទាហានពីសម័យ លន់ នល់ ។ នៅពេលដែលខ្មែរក្រហមចូលទីក្រុងភ្នំពេញ ទោះបីជាអតីតទាហាន លន់ នល់ បានជម្រុះចោលឯកសណ្ឋានមកស្លៀកពាក់ស៊ីវិលវិញក៏ដោយ ក៏អ្នកទាំងនោះភាគច្រើនត្រូវខ្មែរក្រហមប្រមូលផ្តុំដាក់ដោយឡែកបម្រុងយកទៅសម្លាប់ ។ ក្រុមបន្ទាប់គឺជាប្រជាជនថ្នាក់ខ្ពស់ (បញ្ញវន្តនិងម្ចាស់ដីធ្លី) ប្រជាជនដែលជាប់សាច់ញាតិនិងអតីតមន្ត្រីរាជការ ឬទាហាន លន់ នល់ និងសូម្បីតែប្រជាជនរស់នៅតំបន់គ្រប់គ្រងដោយសាធារណរដ្ឋខ្មែរ ។ នៅក្នុងអំឡុងដែលខ្លួនកាន់អំណាចខ្មែរក្រហមធ្វើការបោសសម្អាតទាំងនេះឡើងដោយគ្មានតុលាការវិនិច្ឆ័យឬផ្សះផ្សាជាតិទេ ។ ទន្ទឹមនឹងនោះមានភ័ស្តុតាងបង្ហាញឲ្យឃើញថា ក្នុងប្រទេសកម្ពុជាដែល៩៥ភាគរយជាប្រជាជនខ្មែរក្រហុមជនជាតិមួយចំនួនត្រូវបានចាត់ជា*

មុខសញ្ញាដែរ ។ ជាក់ស្តែងដូចជា ជនជាតិចិនក្លាយជាមុខសញ្ញា នៅពេលដែលខ្មែរក្រហមចងសម្ព័ន្ធមិត្តជាមួយវៀតណាម ។ ក្រោយមកជនជាតិវៀតណាមក្លាយជាមុខសញ្ញាវិញម្តង ពេលដែលខ្មែរក្រហមចងសម្ព័ន្ធមិត្តជាមួយចិន ។ រីឯសហគមន៍ចាម ក៏ស្ថិតនៅក្នុងមុខសញ្ញារបស់ខ្មែរក្រហមដែរ ដោយសារប្រជាជនទាំងនោះបដិសេធមិនព្រមឱនលំទោនចំពោះនយោបាយសមូហភាពរបស់របបខ្មែរក្រហម ។ ហេតុនេះហើយ ខ្មែរក្រហមយល់ឃើញថា សកម្មភាពសហគមន៍ចាមគឺជាការគំរាមកំហែងដល់បដិវត្តន៍របស់ខ្លួន ។

បន្ទាប់ពីបានកាន់កាប់អំណាចអស់រយៈពេលពីរបីឆ្នាំ របបខ្មែរក្រហមចាប់ផ្តើមងាកមកវាយប្រហារខ្លួនឯង ដោយចេះតែឃើញ“ខ្មាំងបង្កប់”គ្រប់ទីកន្លែង ជាពិសេសកម្មាភិបាលបម្រើក្នុងជួរខ្មែរក្រហមផ្ទាល់តែម្តង ។ ទោះបីជាកំហុសឆ្គងតូចតាច ដូចជាធ្វើឲ្យខូចខាតសម្បត្តិរួមបន្តិចបន្តួច ឬក៏បដិសេធមិនព្រមរៀបការ ទាំងនេះអាចល្មមគ្រប់គ្រាន់ជាលេសចាប់ខ្លួនបាន ។ ការចាប់ដាក់គុក ការបង្អត់អាហារនិងទារុណកម្មនាំឲ្យមានចម្លើយសារភាព ដោយបង្ខំនិងត្រូវចោទថា “ជនយុបយិត” និងខ្សែបណ្តាញដទៃភាគច្រើនចោទថាជា“សេអ៊ីអា ឬ កា.ហ្សេ.បេ ឬ គិញវៀត-ណាម” ។ បញ្ហារាលដាលនៃការចាប់ខ្លួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា រួមទាំងកម្មាភិបាលថ្នាក់ក្រោម ធ្វើឲ្យរបបខ្មែរក្រហមចុះអន់ខ្សោយដែលជាកត្តាចម្បងនាំមកនូវការដួលរលំនៃរបបនោះ ។ នៅថ្ងៃបុណ្យណូអែល ឆ្នាំ១៩៧៨ កម្លាំងទ័ពប្រឆាំងខ្មែរក្រហមរួមទាំងទ័ពវៀតណាមបានធ្វើការវាយលុកប្រទេសកម្ពុជា ។ របបខ្មែរក្រហមត្រូវបានដួលរលំពេលដែលកងទ័ពវាយលុកចូលដល់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺរយៈពេលជិតបួនឆ្នាំ បន្ទាប់ពីថ្ងៃខ្មែរក្រហមឡើងកាន់អំណាចដំបូងនៅកម្ពុជា ។

នៅពេលដែលធូលីលែងហុយ យើងនឹងឃើញវត្ថុមួយកាន់តែច្បាស់ ។ បើគិតជាអត្រាភាគរយប្រទេសកម្ពុជារងទុក្ខវេទនាពីរបបប្រល័យពូជសាសន៍ដ៏ឃោរឃៅបំផុត ។ ប្រជាជនប្រមាណពីមួយ២០ទៅ៣០ភាគរយនៃចំនួនប្រជាជនសរុបស្លាប់បាត់បង់ជីវិតក្នុងរវាងបួនឆ្នាំប៉ុណ្ណោះ ។ ប្រជាជនដែលនៅរស់រានមានជីវិតតែប្រមាណបីភាគបួនជាស្ត្រី ។ ដោយគ្មានជំនាញ ឬការសិក្សាអ្វី រួមផ្សំនឹងកង្វះអាហារ ការរស់នៅក្នុងភាពភ័យខ្លាចនិងអស្ថិរភាពនយោបាយ ប្រជាជនទាំងនោះខំប្រឹងជម្នះ ការបាត់បង់ដ៏ធំធេងដែលខ្លួនទទួលរងគ្រោះ និងព្យាយាមកសាងជីវិតក៏ដូចជាប្រទេសជាតិទាំងមូល ។

**ឆាង យុ**

# ព្រឹទ្ធាចារ្យ គង់ ណៃ : អ្នកចម្រៀងចាប៉ីជើងចាស់

នៅលើរានហាលខាងមុខខ្ទមតូចមួយដែលបាំងជញ្ជាំងបន្ទះក្តារតូចៗនៃសំណង់អនាធិបតេយ្យក្នុងសង្កាត់ទន្លេបាសាក់ បុរសចំណាស់ម្នាក់ពាក់វ៉ែនតាខ្មៅដែលកំពុងគេងសម្រាក ដោយយកដៃម្ខាងធ្វើជាខ្នើយ បានក្រោកមកស្វាគមន៍ខ្ញុំយ៉ាងរាក់ទាក់បន្ទាប់ពីគាត់បានឮខ្ញុំហៅគាត់ថា“អ៊ំណៃ” ។ ទោះជាមិនអាចមើលខ្ញុំឃើញក៏ដោយ អ៊ំបានរំកិលខ្លួនសំដៅមករកខ្ញុំដោយមិនឲ្យខុសបន្តិចឡើយ ។ អ៊ំណៃ ពិការភ្នែកតាំងពីកុមារភាព ប៉ុន្តែ អ៊ំជាអ្នកច្រៀងចាប៉ីជើងចាស់ដែលទទួលជ័យលាភីលេខ១ផ្នែកចាប៉ីដងវែង នៅឆ្នាំ១៩៩១ ។ ក្រោយមក អ៊ំណៃ ត្រូវបានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្តល់រហស្សនាមថា “ព្រឹទ្ធាចារ្យ គង់ ណៃ” នៅក្នុងក្រសួងឃោសនាការនិងវប្បធម៌ ។

នៅក្នុងគ្រួសារកសិករ មធ្យមមួយរស់នៅក្នុងខេត្តកំពត គង់ ណៃ គឺជាកូនទី៥ និងជាកូនកម្សត់ជាងគេនៅក្នុងចំណោមបងប្អូន ១០នាក់ដែលមានស្រី៤ នាក់និងប្រុស៦នាក់ ។ ណៃ កើតនៅឆ្នាំ ១៩៤៥ ត្រូវនឹងឆ្នាំច នៅភូមិដូង ឃុំស្វាយទង ស្រុកកំពង់ត្រាច ខេត្តកំពត ។ នៅពេលអាយុ៤ឆ្នាំ កុមារណៃ បានកើតជំងឺអុតធំ ។ សំណាងអាក្រក់រោគសញ្ញានេះបានកើតឡើងនៅក្នុងភ្នែកទាំងពីររបស់ ណៃ ហើយបានញាំញីរូបកាយរបស់គាត់រហូតដល់ពិការ

ក្អែកទាំងគូនិងបន្សល់ទុកនូវស្នាកស្នាមពេញផ្ទៃមុខរបស់គាត់ ។ ដោយសារតែនៅក្មេងខ្ចីពេក កុមារណៃ មិនបានចងចាំថា កាលកើតជំងឺនោះខ្លួនគាត់ឈឺយ៉ាងដូចម្តេចឡើយ ណៃ គិតថា អ្នករាល់គ្នាក៏មើលមិនឃើញដូចជាខ្លួនដែរ ។ នៅពេលធ្វើដំណើរទៅណាមកណា កុមារណៃ តែងតែត្រូវបងប្អូន ឬម្តាយដឹកដៃដើរជានិច្ច ។ ឆេន ដែលបច្ចុប្បន្នជាភរិយារបស់គាត់បានមានប្រសាសន៍ទាំងញញឹមថា កាលណោះគាត់តែងតែឃើញ ណៃ តោងជាយអាវម្តាយដើរតាមពីក្រោយលោតផ្លោតៗ ជួនពេលខ្លះឃើញបងប្អូនដឹកដៃ ណៃ ដើរលេង តែគាត់មិនដែលបាននិយាយលេងជាមួយ ណៃ ទេ ។ បើនិយាយពីសេចក្តីស្រឡាញ់ចំពោះ ណៃ នៅពេលនោះក៏គ្មានដែរ ប៉ុន្តែគាត់ចេះតែមានក្តីចិត្តអាណិត ណៃ ហើយពិចារណានៅក្នុងចិត្តថា ពិការក្អែកទាំងគូបែបនេះ តើធំឡើងនារីណានឹងយកធ្វើគូអនាគតទៅ ។


គង់ ណៃ និងភរិយា ឆ្នាំ២០០០

## ចំណង់ចំណូលនិងការច្រៀងចាប៉ី

នៅពេលចម្រើនវ័យបាន ៧ឆ្នាំ ទើប ណៃ ដឹងថាខ្លួនពិការ ។ ណៃ មិនបានរៀនសូត្រដូចកុមារដទៃឡើយ ប៉ុន្តែ ណៃ បែជាមានចំណង់ចំណូលចិត្តខាងចាប៉ី ទៅវិញ ដោយគាត់គិតថាអាជីពមួយនេះអាចនឹងជួយឲ្យគាត់ចិញ្ចឹមជីវិតបានប្រសើរនៅថ្ងៃអនាគត ។ ណៃ មានចំណាប់អារម្មណ៍ខាងចាប៉ីនេះគឺតាំងពីថ្ងៃដែលគាត់បានឮចម្រៀងចាប៉ីនៅក្នុងពិធីបុណ្យមួយដែលប្រារព្ធឡើងនៅក្នុងភូមិមួយក្បែរភូមិរបស់គាត់ ។ នៅពេលស្តាប់ឮចម្រៀងចាប៉ី ណៃ បានទទូចសុំឲ្យម្តាយជូនទៅស្តាប់ជាមួយគេ ។ ណៃ ជក់ចិត្តយ៉ាងខ្លាំងជាមួយនឹងចម្រៀងចាប៉ីនេះ ។ នៅពេលត្រឡប់មកផ្ទះវិញ ណៃ តែងតែហាត់ច្រៀងដោយខ្លួនឯង ។ ពិតជាមានការលំបាកណាស់សម្រាប់ ណៃ ក្នុងការហាត់ច្រៀងចាប៉ី ប៉ុន្តែ ណៃ នៅតែព្យាយាមជម្នះឧបសគ្គ លត់ដំខ្លួនឯងដោយផ្អាកការច្រៀងមួយរយៈ ហើយសុំឪពុកម្តាយទៅស្នាក់នៅវត្តដើម្បីរៀនសូត្រពីព្រះចៅអធិការព្រះនាម អាត់ លឿង ។ ក្រោមការបង្ហាត់បង្រៀនរបស់លោកគ្រូ អាត់ លឿង ណៃ បានរៀនចេះចាំពាក្យកាព្យ «ល្បើកតាជូជក់» មួយចប់សាច់រឿង ។

*ចាប៉ីដងវែង ជាឧបករណ៍តន្ត្រីបុរាណខ្មែរ ដែលភាសាសំស្ក្រឹតហៅថា «ពិន» ភាសាបាលីហៅថា «វីណា» ។ ចាប៉ីដងវែង ផ្សំឡើងដោយឈើច្រើនប្រភេទ ។ ស្នូកធ្វើអំពីដើមរាំង, សន្ទះធ្វើអំពីដើមស្វាយ, ដងធ្វើអំពីដើមក្រសាំង, អង្គក់ធ្វើអំពីដើមអង្គោល, ប្រកៀនធ្វើអំពីដើមអង្កាញ់, ខ្ទង់ធ្វើអំពីដើមឫស្សី, បំពួតធ្វើអំពីដើមឫស្សីនិងខ្សែសូត ។*

នៅរដូវបុណ្យភ្ជុំបិណ្ឌចាស់ៗនៅក្នុងភូមិតែងតែឲ្យ ណៃ សូត្រល្បើកជូជក់ឲ្យស្តាប់ អ្នកភូមិខ្លះបានផ្តល់ជាលុយកាក់បន្តិចបន្តួចមួយកាក់ ប្រាំកាក់ (ក្រដាសមួយរៀលហែកជាពីរដើម្បីចាយ) ឬមួយរៀលទៅតាមលទ្ធភាពរៀងៗខ្លួន ។

ក្នុងវ័យ១៣ឆ្នាំ ណៃ សាកល្បងច្រៀងចាប៉ីដោយប្រើចាប៉ីមាត់(ធ្វើភ្លេងចាប៉ីដងនិងច្រៀងដង) ឲ្យកសិករនៅក្នុងភូមិស្តាប់ក្នុងពេលសម្រាកពីការងារច្រូតកាត់ ហើយក៏បានទទួលលុយកាក់បន្តិចបន្តួចដែរ ។ ដោយមានការលំបាកក្នុងការធ្វើបទភ្លេងដោយមាត់ ណៃ បានសុំឪពុកទិញចាប៉ីចាស់មួយគ្រឿងដែលមានតម្លៃមួយរយរៀលពីអ៊ំម្នាក់ដែលរស់នៅភូមិក្បែរគ្នា ហើយបានយកចាប៉ីនោះទៅឲ្យឪពុកធំ គង់ ទិត្យ ដែលជាតន្ត្រីករដែរ ជួយដេញភ្លេងឲ្យស្តាប់ដើម្បីឲ្យខ្លួនទន្ទេញមាត់តាមបទភ្លេង ។ ដោយមានការប៉ិនប្រសប់តាំងពីកំណើតផង ណៃ ទន្ទេញចាំនូវទម្រង់បទភ្លេងរហូតចេះចាំ ហើយយកមករាវខ្ទង់ដោយខ្លួនឯង ។ ណៃ ចាប់ផ្តើមដំបូង គឺលេងបទជាត់ជាយ ។

នៅពេលចម្រើនវ័យ១៨ឆ្នាំ ម្តាយរបស់ ណៃ ឈ្មោះ ណុប ផែង បានធ្លាក់ខ្លួនឈឺរ៉ាំរ៉ៃ ។ យាយ ផែង តែងតែព្រួយបារម្ភអំពី

ដោកវាសនារបស់ ណៃ ជាងគេ ។ មានថ្ងៃមួយពេលឪពុកមិននៅផ្ទះណៃ នៅច្របាច់ដៃច្របាច់ជើងឲ្យម្តាយ ។ យាយ ដែង បាននិយាយ ផ្តែផ្តាំកូនយ៉ាងច្រើន ហើយអ្វីដែល ណៃ ចាំមិនបំភ្លេចនោះគឺ ពាក្យសម្តីចុងក្រោយរបស់ម្តាយដែលពោលថា "កូនអើយម្តាយមើលទៅបែបមិនបាននៅចិញ្ចឹមកូនដល់កូនអស់ជីវិតទេ ព្រោះម្តាយមួយថ្ងៃកាត់មួយថ្ងៃការ រូបកូនពិការភ្នែកមិនអាចមានប្រពន្ធទេគេមិនយកទេ ។ ពេលម្តាយស្លាប់ទៅ បើឪពុកកូនយកប្រពន្ធទៀត កូនកុំរស់នៅជាមួយ ព្រោះខ្លាចម្តាយចុងធ្វើបាបកូនត្រូវតែទៅនៅវត្តស្វាយជ្រុំជាមួយលោកគ្រូព្រះនាម អាត់ លឿង ទៅ" ។ ណៃ ស្រក់ទឹកភ្នែកដោយមិនដឹងខ្លួនពេលឮម្តាយផ្តែផ្តាំ ហើយគិតថាខ្លួនប្រហែលមានវាសនាអាក្រក់ដូចម្តាយនិយាយហើយ ។ សព្វថ្ងៃ អ៊ំណៃ នៅសោកស្តាយដែលម្តាយរបស់គាត់មិនបានរស់នៅនិងឃើញពីជីវភាពគាត់នៅពេលនេះ ប្រសិនបើគាត់បានឃើញកូនមានសុភមង្គលគាត់មិនដឹងសប្បាយចិត្តយ៉ាងណានោះទេ ។

ដោយខ្លាចប្រពន្ធចុងធ្វើបាបកូនៗឪពុករបស់ ណៃ ឈ្មោះ គង់ ឡាយ សុខចិត្តនៅពោះម៉ាយចិញ្ចឹមកូនទាំង១០នាក់ ។ ក្នុងវ័យ១៥ឆ្នាំ ណៃ ចេះដេញចាប៉ីតាំងពីបទដាត់ដាយ ដាត់ដាយក្លាយ សំពោង នគររាជ និងបទបំពេ ។ ប៉ុន្តែពេលច្រៀងនោះ ណៃ នៅតែមិនទាន់អាចចាប់ចុងជួនបានវែងដូចអ្នកចាប៉ីជើងចាស់ឡើយ ។ ណៃ បានពិភាក្សាជាមួយឪពុកធំអំពីរឿងនេះដើម្បីជួយរកវិធីដោះស្រាយ ឪពុកធំមានយោបល់ថា លុះត្រាតែទន្ទេញកាព្យចាំឲ្យបានច្រើនទើបអាចបំបែកចុងជួនបានល្អ ។ ណៃ សុំឪពុកទិញសៀវភៅរឿងជាពាក្យកាព្យពីររឿងគឺ រឿង "សុវណ្ណវង្ស" និង "ផ្កាវាំទឹកវាំ" មកឲ្យឪពុកធំជួយអានឲ្យស្តាប់ ។ ណៃ ស្តាប់សាច់រឿងនិងទន្ទេញចង្វាក់កាព្យរហូតដល់ចាំសាច់រឿងទាំងមូលដែលអាចឲ្យខ្លួនបំបែកកាព្យបានកាន់តែច្រើនប្រសើរឡើងជាងមុន ។

## អាជីពជាអ្នកច្រៀងចាប៉ី

ដំណឹងនេះបានលេចឮពីមាត់មួយទៅមាត់មួយពេញទាំងភូមិ ។ ណៃ ត្រូវបានអ្នកភូមិកំពង់ត្រាច អញ្ជើញទៅច្រៀងនៅក្នុងពិធីបុណ្យផ្សេងៗ ដូចជាបុណ្យកឋិនទាននិងបុណ្យដាលានជាដើម ។ ក្នុងឱកាសបង្ហាញ ស្នាដៃ ណៃ បានយករឿង"សុវណ្ណវង្ស"មកច្រៀង ។ ក្រោយមកកេរ្តិ៍ឈ្មោះរបស់យុវជន ណៃ បានល្បីរន្ទឺពេញទូទាំងខេត្តនិងស្រុកទាំង៦ នៅក្នុងខេត្តកំពត ដូចជាស្រុកឈូក ស្រុកកំពង់ត្រាច ស្រុកអង្គជ័យ និងស្រុកបន្ទាយមាសជាដើម ។ ណៃ ត្រូវបានអ្នកស្រុកឆ្ងាយៗ ហៅឲ្យទៅច្រៀងនៅក្នុងពិធីបុណ្យផ្សេងៗ ដែលនេះក៏ជាឱកាសមួយដែល ណៃ អាចរកកម្រៃមកព្យាបាលជំងឺម្តាយដែរ ។ នៅពេលទៅច្រៀងម្តងៗ ណៃ តែងមានអារម្មណ៍មិននឹងនរខ្លាចពេលត្រឡប់មកពីច្រៀងមិនទាន់ដង្ហើមម្តាយ ។ ក៏ប៉ុន្តែ កត្តញ្ញូតាធម៌របស់ ណៃ មិនអាចជួយសង្គ្រោះជីវិតម្តាយឲ្យបានយូរអង្វែងឡើយ អស់រយៈពេល២ឆ្នាំម្តាយរបស់ ណៃ ក៏បានលាចាកលោក ។

រយៈពេលមួយឆ្នាំបន្ទាប់ពីមរណភាពរបស់ម្តាយ ណៃ ចាប់ផ្តើមល្បីឈ្មោះជាអ្នកច្រៀងចាប៉ីដងវែង ។ ណៃ ត្រូវបានអញ្ជើញឲ្យទៅច្រៀងនៅតាមស្រុកនានាក្នុងខេត្តកំពតនិងខេត្តតាកែវ ហើយថែមទាំងបានប្រកួតច្រៀងឆ្លើយឆ្លងជាមួយអ្នកច្រៀងចាប៉ីវ័យចំណាស់ម្នាក់ដែលពិការភ្នែកម្ខាងព្រះនាម ភិរម្យជា ។ ការច្រៀងឆ្លើយឆ្លងគ្នានេះពុំមានព្រាងទុកឡើយ ម្នាក់ៗត្រូវតែពឹងផ្អែកបញ្ញារៀងៗខ្លួនដើម្បីច្រៀងឆ្លើយឆ្លងឲ្យទាន់ បើមិនដូច្នេះអ្នកនោះនឹងត្រូវចាញ់ ។ មុនច្រៀងភាគីទាំងពីរមានលក្ខខណ្ឌមួយ ប្រសិនបើភាគីណាមួយច្រៀងរកចម្លើយមិនឃើញ ហើយសំណូមពរឲ្យភាគីម្ខាងទៀតច្រៀងបកស្រាយចម្លើយនោះ ភាគីដែលចាញ់ត្រូវតែទទួលយកការច្រៀងតាមសំណូមពររបស់អ្នកឈ្នះ ។ អ៊ំណៃ បានរំឭកអំពីការច្រៀងនោះថា ភិរម្យជា បានច្រៀងលក់គាត់ថា "សត្វពីរឈ្មោះវាដូចគ្នាប៉ុន្តែមានក្បាលបីជើងមានប្រាំបួន" ហើយគាត់បានច្រៀងឆ្លើយទៅវិញថា "ជាសត្វដំរី ដំរីទឹកជើងបួន ដំរីគោកជើងបួន ហើយដែលគេរៀបកណ្តាប់ជើងដំរីមួយទៀត រីឯក្បាលបី សត្វទាំងពីរនោះមានក្បាលពីរហើយ និងប្រភេទផ្លែឈើ គឺស្វាយក្បាលដំរី" ។ បន្ទាប់មកគាត់ក៏បានដាក់សំណួរមួយឲ្យ ភិរម្យជា វិញថា "តើក្នុងចំណោមអ្នកដែលចូលស្តាប់ច្រៀងចាប៉ីនេះតើមានប៉ុន្មានក្រុម? ចម្លើយគឺមាន៨ក្រុម ក្រុមទី១ ក្រុមក្មេង ទីពីរក្រុមចាស់ ទីបីក្រុមអាចារ្យនិងព្រះសង្ឃ ទី៤ក្រុមកំលោះ ទី៥ក្រុមក្រមុំ ទី៦ក្រុមមេម៉ាយ

ទី៧/ក្រុមពោះម៉ាយ ទី៨គឺ ក្រុមចាប៉ីយើងពីរនាក់» ។ ភិរម្យជារកមិនឃើញ ណៃ ក៏លក់គាត់ឲ្យច្រៀងបទនគររាជ ។ ក្រោយពីនោះ ណៃ បានធ្វើដំណើរទៅច្រៀងនៅតាមស្រុកនានា ក្នុងខេត្តកំពតនិងខេត្តតាកែវ ដូចជាស្រុកគិរីវង្ស ទន្សាប់ ចៅគាវ និងផ្នែកខ្លះនៅទឹកដីកម្ពុជាក្រោមដែលមានខ្មែររស់នៅទីនោះ ។

## ជីវិតគូស្រករ

កើតមកមួយជាតិតែងតែមានគូអនាគត មានគ្រួសារនេះជាពាក្យពិតដែលផុសចេញពីបេះដូងយុវជន ណៃ ។ មនុស្សលោកកើតមកត្រូវតែមានស្នេហា មានគូស្រករនេះជាច្បាប់ធម្មជាតិ ។ ទោះបីជាមិនបានឃើញមុខនារីណាម្នាក់ ប៉ុន្តែស្តាប់តាមការពិពណ៌នារបស់មនុស្សពីមាត់ទៅមាត់មួយ ណៃ ក៏អាចស្រមៃឃើញពីលក្ខណៈសម្បត្តិរបស់នារីដែរ ។ ណៃ បានចាប់ចិត្តស្រឡាញ់នារីម្នាក់ឈ្មោះ ហែម យេន រស់នៅភូមិតាខ្វាវ ហើយបានពឹងបងជីដូនមួយឲ្យជួយសួរនាំចិត្តនារីនោះមុននឹងឲ្យឪពុកចូលស្តីដណ្តឹង ។ ណៃ ធ្វើគ្រប់បែបយ៉ាងតាមតែបងជីដូនមួយតម្រូវឲ្យធ្វើដើម្បីបំពេញចិត្តនារីដែលខ្លួនស្រឡាញ់ ។ ទីបំផុត បងជីដូនមួយរបស់គាត់បានស្តីដណ្តឹង យេន ធ្វើជាប្រពន្ធរបស់ខ្លួនឯងទៅវិញ ។ ណៃ រំឭកថា «ពឹងបងជីដូនមួយឲ្យទៅសួរបងជីដូនមួយ ខ្ញុំបានឲ្យយោបល់ថា បើចង់ទៅសួរលុះត្រាតែយកចាប៉ីទៅច្រៀង ប៉ុន្តែតាមការពិតគាត់ស្តីដណ្តឹងយកខ្លួនឯង គាត់កុហកថាមិនទាន់បានសួរ ។ ក្រោយមកស៊ើបដឹងថាគាត់យកខ្លួនឯងទៅវិញ» ។

ក្រោយមក ណៃ បានស្រឡាញ់នារីម្នាក់ទៀតឈ្មោះ គាត ឆេន រស់នៅភូមិស្វាយទង (ភូមិដូងនិងភូមិស្វាយទងមានព្រំប្រទល់ជាប់គ្នា) តាមរយៈសំឡេងប៉ុណ្ណោះ ។ ណៃ ចាប់ចិត្តស្រឡាញ់ ឆេន នៅថ្ងៃទី៨កើត ខែមាឃ ខណៈពេលដែល ឆេន មកលេងផ្ទះបងស្រីដែលរស់នៅភូមិខាងជើងផ្ទះរបស់គាត់ ។ ពេលធ្វើដំណើរឆ្លងកាត់មុខផ្ទះ ឆេន តែងសួរនាំអំពីសុខទុក្ខ និងការងាររបស់ ណៃ ជានិច្ច ។ ភាពរួសរាយរាក់ទាក់និងសំឡេងដ៏ស្រទន់នេះបានធ្វើឲ្យ ណៃ ទប់ចិត្តមិនបាន ហើយចិញ្ចឹមចិត្តថានឹងស្តីដណ្តឹងចិត្ត ឆេន ដោយលែងពឹងពាក់បងប្អូនដូចមុនទៀតហើយ ។ រំឭកដល់ថ្ងៃដែលគាត់បានសាកសួរចិត្តប្រពន្ធរបស់គាត់ អ៊ំណៃ និយាយដោយមិនរារែកក្នុងចិត្តថា «កាលណោះថ្ងៃ១៣កើត ខែមាឃ ឆ្នាំ១៩៦៣ ។ ខ្ញុំសួរគាត់ថា បង ខ្ញុំនិយាយប្រាប់ឯងត្រង់ទៅ ខ្ញុំស្រឡាញ់បង ខ្ញុំចង់បានបងឯងធ្វើជាប្រពន្ធតើបងឯងយល់យ៉ាងណា? បើបងយល់ព្រមសូមបងឆ្លើយ បើមិនយល់ព្រមក៏ឆ្លើយ ហើយយើងបាត់ស្វាត់ត្រឹមហ្នឹងទៅដើម្បីកុំឲ្យព្រួយខ្វល់ខ្វាយតទៅទៀត» ។ អ៊ំស្រី ឆេន ក៏បានឆ្លើយថាព្រមនៅពេលនោះដែរ ។ ឆេន និយាយថា «ពេលគាសួរចិត្តខ្ញុំនោះ អត់មានចាំពិចារណាទេ ទឹកឃើញក្នុងចិត្តអាណិតគាត់ ហើយក៏ឆ្លើយថា មានទាស់អី» ។

ជាការពិត ឆេន អាណិតអាសូរ ណៃ កាន់តែខ្លាំងនៅថ្ងៃដែល ណៃ មកច្រៀងចាប៉ីនៅផ្ទះរបស់គាត់ ក្នុងថ្ងៃបុណ្យប្រមូលភោគផល ។ ពេលព្រឹឪពុកនិងបងប្រុសពិភាក្សាគ្នាថានឹងអញ្ជើញ ណៃ ឲ្យមកច្រៀងដើម្បីឲ្យពិធីនេះមានភាពអធឹកអធម ឆេន បានសុំឪពុកទៅហៅ ណៃ ដោយខ្លួនឯង ។ ចំណែក ណៃ នៅថ្ងៃនោះគាត់ក៏ត្រូវទៅច្រៀងនៅឯរោងបុណ្យមួយទៀតចម្ងាយពីរគីឡូ-ម៉ែត្រពីភូមិដែរ ប៉ុន្តែដោយសារចិត្តជាប់ជំពាក់ជាមួយ ឆេន ណៃ សុខចិត្តលះបង់ការច្រៀងនៅឯរោងបុណ្យនោះដោយច្រៀងតែកន្លះម៉ោងប៉ុណ្ណោះ ដើម្បីប្រញាប់វិលត្រឡប់មកច្រៀងនៅផ្ទះបុណ្យរបស់ ឆេន វិញ ។

ក្រោយពីបានយល់ចិត្តគ្នា ណៃ បានសុំឲ្យឪពុកចូលស្តីដណ្តឹងដល់ចាស់ទុំ ។ ឪពុករបស់ ណៃ ជំទាស់ការស្តីដណ្តឹងនេះដោយខ្លាចថាខាងស្រីបដិសេធ ។ ជាការពិតឪពុកនិងមាមីងរបស់ ឆេន បានបដិសេធដាច់អហង្ការចំពោះការស្តីដណ្តឹងនេះ ។ ក៏ប៉ុន្តែក្រោយមកដោយមានការជ្រោមជ្រែងពីពូថ្លៃ បងប្រុសនិងមាមីងមួយចំនួនទៀត គួបផ្សំនឹងការតស៊ូព្យាយាមផងនោះ ឪពុកខាងស្រីក៏យល់ព្រម ។ ថ្វីបើមានការព្រមព្រៀងពីខាងស្រីក៏ដោយ ណៃ ត្រូវប្រឈមមុខជាមួយមនុស្សដែលតាមស្រឡាញ់ ឆេន ។ យុវជនម្នាក់បានគំរាមជីវិត ណៃ ទៀតផង តែ ណៃ ឆ្លើយតបដោយក្លាហានថា «មិនខ្លាចស្លាប់ទេ ព្រោះជាតិមុនមិនដឹងធ្វើអ្វីបានជាងងឹតភ្នែក បើខ្ញុំបានព្យាបាទជីវិតគេ ឲ្យខ្ញុំស្លាប់ទៅចុះ ខ្ញុំមិនចង់ពៀរទេ ។ បើសិនជាបងសួរនាង ហើយនាងយល់ព្រមខ្ញុំជូនលុយថែម» ។ យុវជនម្នាក់ទៀតដែលស្រឡាញ់ ឆេន ដែរបានបោះពាក្យសម្តីថា «ដែកគង់រលាយទម្រាំត្រឹម ណៃ» ។

ទោះយ៉ាងណា ណៃ នៅតែតាំងចិត្តមិនខ្លាចស្លាប់ដដែល ។ ដោយមានការការព្រួយបារម្ភអំពីសន្តិសុខក្នុងពេលរៀបមង្គលការ ណៃ បានពឹងឪពុកមានិងឈ្លបភូមិឃុំឲ្យជួយការពារពិធីមង្គលការរបស់ខ្លួនក្រែងមានហេតុការណ៍អាក្រក់កើតឡើង ។ មង្គលការអ្នកទាំងពីរបានប្រព្រឹត្តឡើងនៅថ្ងៃទី១៣កើត ខែអាសាឍ ឆ្នាំថោះ ឆ្នាំ១៩៦៥ ដោយខាងប្រុសជាអ្នកធានារាល់ការចំណាយទាំងអស់ ។ ក្នុងនាមជាស្វាមី ណៃ ពុំដែលឲ្យប្រពន្ធលំបាកក្នុងការរកស៊ីចិញ្ចឹមគ្រួសារដូចការព្រួយបារម្ភរបស់សាច់ញាតិខាងស្រីឡើយ ។ ណៃ រកប្រាក់កម្រៃបានយ៉ាងច្រើនពីការច្រៀងចាប៉ី រហូតដល់សន្សំប្រាក់ទិញដីស្រែបាន៦ហិកតា និងសង់ផ្ទះក្បឿងបានមួយខ្នង ។ សព្វថ្ងៃ អ៊ឹំណៃ មានកូន១០នាក់ និងចៅ២៨នាក់ ។ កូនៗរបស់ ណៃ ច្រើនប្រកបមុខរបរនេសាទនៅស្ទឹងហាវក្រុងកំពង់-សោម ។

### ជីវិតនៅក្នុងរបបលន់នល់

ក្រោយថ្ងៃទី១៨មីនា ឆ្នាំ១៩៧០ រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ស្រុកកំពង់ត្រាចត្រូវបានកាន់កាប់ដោយទាហានលន់នល់ ។ នៅពេលនោះអ្នកដែលស្មោះស្ម័គ្រនឹងសម្តេចឪបាននាំគ្នារត់ចូលព្រៃ បង្កើតជាចលនាមួយហៅកងទ័ពបដិវត្តបុកងទ័ពខ្មែរក្រហម ។ ជួនពេលខ្លះមានការវាយប្រយុទ្ធគ្នារវាងខ្មែរក្រហមនិងទាហានលន់នល់ ហើយពេលខ្លះខ្មែរក្រហមចូលក្នុងភូមិបំផុសចលនាប្រជាជន ពីព្រោះខ្មែរក្រហមដឹងថា ប្រជាជនស្រឡាញ់សម្តេចឪ ។ ខ្មែរក្រហមឃោសនាថា "ឥឡូវយើងត្រូវរួបរួមដើម្បីវាយ លន់ នល់ និង អាមេរិកាំង រំដោះសម្តេចឪមកវិញ" ។ ឮដូច្នោះប្រជាកសិករទាំងចាស់ក្មេងបានស្ម័គ្រចិត្តចូលក្នុងជួរកងទ័ពក្នុងគោលបំណងទាមទារសម្តេចឪមកវិញ ។

នៅក្នុងឆ្នាំ១៩៧២ ស្ថានភាពក្នុងប្រទេសកាន់តែមានការជ្រួលច្របល់និងអសន្តិសុខ ប្រជាជនដែលរស់នៅតាមជាយក្រុងត្រូវទទួលរងនូវការវាយប្រហាររវាងទាហាន លន់នល់ និងកងទ័ពខ្មែរក្រហម ។ ប្រជាជនខ្លះត្រូវបង្ខំចិត្តចាកចោលស្រុកភូមិដើម្បីរកកន្លែងសុវត្ថិភាព ។ ក្រុមគ្រួសាររបស់ អ៊ឹំណៃ បានភៀសខ្លួនទៅរស់នៅតំបន់រំដោះក្នុងភូមិព្រៃ សំណាង ឃុំខ្លាយ ស្រុកបន្ទាយមាស ខេត្តកំពត អស់រយៈពេលបីឆ្នាំ ។ នៅក្នុងអំឡុងពេលនោះ ណៃ ត្រូវអង្គការខ្មែរក្រហមណែនាំឲ្យច្រៀងចាប៉ី ដែលអត្ថន័យន័យនៃបទចម្រៀងនោះគឺរៀបរាប់តែអំពីការឈឺចាប់របស់ប្រជាកសិករដែលត្រូវវណ្ណៈសក្តិភូមិជិះជាន់ពីរបបមុន និងជីវភាពរស់នៅរបស់ប្រជាជនដោយធ្វើការប្រៀបធៀបទៅនឹងសង្គមមុនៗ អំពីយួនធីវគីនិងទាហានអាមេរិកាំងចូលប្រទេសកម្ពុជា (អង្គការចាត់ទុក"យក្សធីវគីនិងយក្សអាមេរិក") អំពីការដាក់ពិន័យវៃអង្គាស កំណែនហត្ថកម្មការជិះជាន់និងការឈ្លានពានរបស់យក្សធីវគីនិងយក្សអាមេរិកាំងចូលក្នុងប្រទេសកម្ពុជានិងការទម្លាក់គ្រាប់បេ-៥២ ធ្វើឲ្យប្រជាពលរដ្ឋស្លាប់និងភៀសខ្លួនពីស្រុកមួយទៅស្រុកមួយ ។

### ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ក្រោយថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ប្រទេសជាតិត្រូវបានរំដោះទាំងស្រុងដោយកងទ័ពបដិវត្តន៍កម្ពុជា ។ ប្រជាជននាំគ្នាឈរអបអរសាទរនឹងជ័យជម្នះនេះ ដោយសង្ឃឹមថាសង្គ្រាមត្រូវបានបញ្ចប់ហើយ ។ ប៉ុន្តែភាពសប្បាយរីករាយនេះមិនបានប៉ុន្មានម៉ោងផង ស្ថានភាពប្រែក្រឡាប់ចាក់ទៅវិញ ។ កងទ័ពបដិវត្តន៍បានស្រែកតាមខក្សោសនសព្ទឲ្យប្រជាជនចាកចេញពីផ្ទះដើម្បីធ្វើការបោះសម្អាតខ្មាំង ។ សង្គមជាតិត្រូវបានប្រែមុខមាត់ថ្មី ដោយប្តូរឈ្មោះថា"របបកម្ពុជាប្រជាធិបតេយ្យ" ។ ជំហានបន្ទាប់មកខ្មែរក្រហមចាប់ផ្តើមស្រាវជ្រាវប្រវត្តិរូប ទាហាន គ្រូបង្រៀន នាយទុន និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរយកទៅសម្លាប់ចោលទាំងអស់ ។ ជនណាប្រឆាំងនឹងអង្គការត្រូវចាត់ទុកថាជាខ្មាំង ។ នៅក្នុងខេត្តកំពតឯណោះវិញ ខ្មែរក្រហមប្រកាសខ្លាំងៗថា "ឥឡូវពីថ្ងៃនេះទៅសូមបងប្អូនស្តាប់ឲ្យបានអ្នកណាមិនស្មោះត្រង់នឹងអង្គការគឺ ត្រូវតែកម្ទេចចោល អ្នកណាមានបងប្អូនជាប់ពាក់ព័ន្ធ ហើយអង្គការមិនទុកចិត្តគឺត្រូវកម្ទេចចោលទាំងអស់" ។ អ៊ឹំណៃ ដឹងខ្លួនឯងថា ថ្ងៃណាមួយអង្គការនឹងសម្លាប់ខ្លួនមិនខាន ប៉ុន្តែ ទោះជាដឹងក៏គាត់មិនអាចគេចទៅណាបានដែរ ។

ឆ្នាំ១៩៧៥ ណៃ និង ប្រពន្ធ ព្រមទាំងកូន៧នាក់ បានវិលត្រឡប់ទៅរស់នៅភូមិដំណាក់កន្ធួតវិញ ។ ឆ្នាំ១៩៧៦ អង្គការចាប់ផ្តើមចាត់តាំងឲ្យប្រជាជនកាប់ដីដំបូកនិងរែកដាក់ស្រែ ។ នៅពេលសម្រាកពីការងាររម្លងៗ អ៊ឹំណៃ ត្រូវបានចាត់តាំងឲ្យទៅ

ច្រៀងចាប៉ីកំដរអារម្មណ៍កសិករនៅការដ្ឋានរយៈពេលពី៥ ទៅ ១០នាទី ពេលច្រៀងចប់ទើបកុមារជូនគ្រូឡប់មកកន្លែងវិញ ។ ពេលអង្គការរៀបចំឲ្យមានសហករណ៍ហូបបាយសមូហភាព អ៊ឹណៃ ត្រូវអង្គការឲ្យផ្អាកការច្រៀង ។ គណៈកងឈ្មោះ វឿន ប្រជុំប្រាប់ អ៊ឹថា «ឥឡូវអស់មានច្រៀងចាប៉ីនៅខាងស្រែនេះ ហើយមានតែនៅភ្នំពេញប៉ុណ្ណោះ ។ យើងដែលនៅទីនេះសុទ្ធតែត្រូវកសាងប្រទេសទាំងអស់» ។ អ៊ឹណៃ ត្រូវអង្គការផ្អាកពីការច្រៀងចាប៉ី និងចាត់តាំងឲ្យទៅប្រឡេះពោត សណ្តែក នៅក្នុងកងបន្ទៃវិញ ។

ក្រោយពីបង្កើតសហករណ៍ហូបបាយរួមទើប អ៊ឹណៃ ដឹងថាមានការសម្លាប់មនុស្ស ។ ប្រជាជនទាំងគ្រួសារៗត្រូវបានសម្លាប់ក្រោមការឃោសនាថា «បងប្អូនទៅនៅភូមិថ្មីបានបាយឯកជន ចង់ស្ងោរមាន់ហូបក៏បាន ដំឡូង អំពៅ ដាំហូបឯកជនបាន» ។ អ៊ឹស្គាល់ឈ្មោះគណៈស្រុកពីរនាក់គឺ តាស៊ុម និង តាសួស ដែលបានចុះមកឃោសនានៅភូមិរបស់គាត់ ។ អ្នកស្គាល់ជិតដិតម្នាក់ បានខ្សឹបប្រាប់ថា «ណៃ ឯងកុំឆ្ងល់អ្នកទៅភូមិថ្មីហ្នឹងសុទ្ធតែយកទៅវៃចោលទេ» ។ ក្រោយមកកងឈ្លបបានយកខោអាវអ្នកស្លាប់ចែកឲ្យប្រជាជន ហើយប្រាប់ថាជារបស់ជ័យភណ្ឌ ។

នៅឆ្នាំ១៩៧៧ អ៊ឹណៃ ត្រូវអង្គការជម្លៀសចូលភូមិវិញ ។ ណៃ ត្រូវអង្គការចាត់តាំងឲ្យមកវេញខ្សែគោ ដែលជាការងារមួយដ៏លំបាកបំផុតសម្រាប់គាត់ ។ អ៊ឹណៃ បានអង្វរគណៈកងសុំមិនធ្វើការងារនេះ គណៈកងក៏ប្រគល់ការងារមួយទៀតមកឲ្យគាត់ធ្វើគឺធ្វើបង្គី ការងារនេះកាន់តែលំបាកទៅទៀត ពីព្រោះគាត់មិនដែលបានឃើញរូបរាងបង្គីនិងបុស្សីយ៉ាងម៉េចផង ។ គណៈកងបន្តថា «បើចិត្តចង់ធ្វើគឺកើត ហើយបើចិត្តមិនចង់ធ្វើគឺមិនកើតទេ» ។ អ៊ឹណៃ នៅតែបដិសេធទោះបីជាដឹងថាការប្រកែកនេះអាចត្រូវអង្គការយកទៅសម្លាប់ក៏ដោយ ។ យ៉ាងណាក៏ដោយ ក៏នៅមានជម្រើសពីរទៀតដែលគាត់ត្រូវតែជ្រើសរើស ប្រសិនបើធ្វើមិនបានទៀតនោះមានតែផ្លូវមួយប៉ុណ្ណោះគឺ«ស្លាប់» ។ ការងារនោះគឺសប់ស្នប់នៅរោងសិប្បកម្មដំពូថៅ-កាំបិត និងដំផាងត្នោតយកដក់មកវេញជាខ្សែឬធ្វើអំបោស ។ អ៊ឹណៃ បានជ្រើសរើសយកការងារដំផាងត្នោត ពីព្រោះជាការងារដែលមិនចំណាយកម្លាំងច្រើន ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើមានប្រជាជនណាដកសំណាបឲ្យដាច់ ឬកាប់ស្រូវមិនអស់ពីគុម្ព កាត់ស្រូវជ្រុះ ឬបាក់ដងវែក ត្រូវអង្គការចាត់ទុកថាជាខ្មាំង មានបំណងបំផ្លិចបំផ្លាញបដិវត្ត ដូច្នេះដើម្បីចៀសវាងការប្រព្រឹត្តនូវកំហុសដោយអចេតនា អ៊ឹណៃ បានសុំការអនុគ្រោះពីគណៈកង ប្រសិនបើគាត់ដំដក់ត្នោតនោះដាច់បន្តិចបន្តួចសុំកុំយកទោសពៃរ៍ ពីព្រោះគាត់មើលពុំឃើញ ។ គណៈកងក៏អនុគ្រោះឲ្យដោយយោគយល់ថាជាជនពិការ ។ ក្នុងមួយថ្ងៃ អ៊ឹណៃ វៃផាងត្នោតឲ្យបាន២០ ផាងត្នោត (បើគិតជាស្រទាប់បាន៤០ ស្រទាប់) ។ ជួនពេលខ្លះ អ៊ឹណៃ វៃមិនបានគ្រប់តាមផែនការឡើយ ដោយសារផាងត្នោតខ្លះរឹងពេក ។ រៀងរាល់ពេលដែលធ្វើមិនបានគ្រប់ចំនួន អ៊ឹណៃ ត្រូវគណៈកងចោទថា «អាហ្នឹងបែបមានសតិអារម្មណ៍ណាមួយមិនពេញចិត្ត» ។ យ៉ាងណាក៏ដោយ ក៏គាត់មិនត្រូវបានធ្វើទារុណកម្មដោយសារធ្វើការយឺតយ៉ាវនោះទេគឺគ្រាន់តែទទួលការស្តីបន្ទោសប៉ុណ្ណោះ ។ អ៊ឹបានពន្យល់អំពីផលលំបាករបស់គាត់ ហើយតាៗមួយចំនួន ដែលធ្វើការជាមួយក៏ជួយពន្យល់ពីហេតុផលនេះដែរ ។ អ៊ឹណៃ ត្រូវបំពេញការងារដូចប្រជាជនដទៃទៀតដែរ ប៉ុន្តែរបបអាហារទទួលបានមួយវែកដូចអ្នកជំងឺ ពីព្រោះអង្គការចាត់ទុកគាត់ថា ជាមនុស្សបាត់បង់សមត្ថភាពពលកម្ម ។ នៅពេលដល់ម៉ោងទទួលទានអាហារម្តងៗ អ៊ឹត្រូវកូនដឹកដៃឲ្យទៅហូបបបរជាមួយកុមារតូចៗ ។ ប្រពន្ធរបស់គាត់ត្រូវចាត់តាំងឲ្យទៅធ្វើការនៅកន្លែងឆ្ងាយៗនៅក្នុងកងស្ត្រី ។ កូនពីរនាក់របស់ អ៊ឹណៃ ត្រូវអង្គការបញ្ជូនទៅនៅកងកុមារកាប់ទន្រ្ទានខែត្រនិងកាយភក់ពីបឹងដើម្បីយកធ្វើជី ។ ចំណែកកូន៥នាក់ទៀតនៅក្នុងបន្ទុក ។

## ជនពិការជាមុខសញ្ញារបស់ខ្មែរក្រហម

នៅឆ្នាំ១៩៧៧-១៩៧៨ សភាពការណ៍ផ្ទៃក្នុងកាន់តែមានការច្របូកច្របល់ មានការមិនទុកចិត្តរវាងថ្នាក់លើនិងថ្នាក់ក្រោម និងការសង្ស័យអ្នកនៅជុំវិញខ្លួនថាជាជនក្បត់ ។ កម្មាភិបាលរបស់បក្សមួយចំនួនត្រូវបានចាប់ខ្លួននិងសម្លាប់ចោល ។ ដោយសារតែការសង្ស័យនេះ ទើបមានការផ្លាស់ប្តូរប្រព័ន្ធដឹកនាំកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានសម្លាប់ចោលហើយជំនួសតំណែងដោយកម្មាភិបាលមកពីភូមិភាគនិរតី ដែលធ្វើឲ្យការកាប់

សម្លាប់មនុស្សកាន់តែសាហាវនិងច្រើនជាងមុន ។ អ៊ំ ណៃ នៅពេលនោះក៏ស្ថិតនៅក្នុងការតាមដានពីអង្គការដែរ ដោយសារថា ប្អូនរបស់គាត់ម្នាក់ឈ្មោះ គង់ លេន បានរត់ភៀសខ្លួនមកពីស៊ឹងហាវ ហើយត្រូវអង្គការចាប់ដាក់គុកដោយចោទថាជាសេ.អ៊ី.អា ។ ក្រោយពីធ្វើទារុណកម្មអស់រយៈពេលបីខែ ប្អូនប្រុសម្នាក់របស់ អ៊ំណៃ ត្រូវបានដឹកតាមរទេះគោជាមួយមនុស្ស៩នាក់ទៀតយកទៅធ្វើការនៅវាលវង់(វាលយន្តហោះបារាំង) និងសម្លាប់ចោលនៅទីនោះ ។ ក្រុមគ្រួសាររបស់ អ៊ំណៃ ត្រូវបានចាត់ទុកជាកសិករត្រៀម ។ អ្នកជិតខាងដែលធ្លាប់តែរាប់អានពីមុនមក ក៏ពុំសូវហ៊ាននិយាយស្តីជាមួយក្រុមគ្រួសាររបស់អ៊ំឡើយ ពីព្រោះក្រុមគ្រួសាររបស់គាត់ត្រូវបានចាត់ទុកជាសមាសភាពខ្មាំង កូនត្រូវអង្គការយកទៅកម្ទេចចោល ។ ទោះយ៉ាងណាក៏ដោយ អ៊ំណៃ មិនប្រកាន់ខឹងអ្នកភូមិទេ ដោយសារតែអ្នកទាំងនោះមានការភ័យខ្លាចអង្គការយកទៅសម្លាប់ដែរ ប៉ុន្តែ គាត់អាក់អន់ចិត្តចំពោះគណៈកងគណៈស្រុកមិនគួរធ្វើបាបដល់ក្រុមគ្រួសារគាត់ឡើយ ជាពិសេសប្រធានចុងភៅដែលមានសន្តានចិត្តអាក្រក់ចំពោះគាត់និងក្រុមគ្រួសារគាត់ ។ សព្វថ្ងៃ អ៊ំណៃ នៅសល់តែប្អូនស្រីម្នាក់ប៉ុណ្ណោះ រស់នៅក្នុងខេត្តកំពត ។


ព្រឹទ្ធាចារ្យ កង ណៃ ឆ្នាំ២០០៦

ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ គណៈកងឈ្មោះ ឡុង ប្រាប់ឲ្យ អ៊ំណៃ ត្រៀមខ្លួនដើម្បីផ្លាស់ទៅធ្វើការនៅកន្លែងផ្សេង ។ ឡុង ហាមមិនឲ្យ អ៊ំណៃ ប្រាប់ដំណឹងនេះឲ្យនរណាដឹងឡើយ ។ ដោយសង្ស័យ អ៊ំណៃ ក៏បានសួរគណៈកងថា តើនរណាខ្លះទៅជាមួយ? ឡុង បានប្រាប់ថា អ្នកដែលត្រូវទៅជាមួយមាន ជនពិការ ស្ត្រី កូនខ្ចី និងចាស់ជរា ចំណែកអ្នកមានកម្លាំងត្រូវនៅច្រូតកាត់ដដែល ។ អ៊ំណៃ ដឹងខ្លួនថាប្រាកដជាត្រូវអស់ជីវិតនៅពេលនោះ ។ ស្អែកឡើងម៉ោងប្រហែលបីរសៀល គណៈកងបានមកហៅ អ៊ំណៃ ដោយនាំស្ត្រីកូនខ្ចី ជនពិការជើង និងពិការភ្នែកមកជាមួយផង ។ ណៃ ប្រពន្ធ និងកូនទាំង៥ បានធ្វើដំណើរទៅជាមួយគ្នា ។ អ្នកទាំងអស់គ្នាធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលប្រហែលបីម៉ោងទើបទៅដល់ភូមិថ្លូវ ហើយសម្រាកនៅទីនោះដើម្បីដាំបាយហូបថ្ងៃត្រង់ទើបបន្តដំណើរទៅមុខទៀត ។ កូនប្រុសរបស់អ៊ំម្នាក់ មុតបន្លាជើងមិនអាចបន្តដំណើរទៅមុខទៀត ណៃ បានអង្វរគណៈកងឲ្យពន្យារពេលមួយយប់ ។ គណៈកងក៏អនុគ្រោះ ។

នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ក្រុមរបស់ អ៊ំណៃ បម្រុងនឹងចេញដំណើរទៅមុខទៀត ស្រាប់តែស្នូរគ្រាប់កាំភ្លើងបានផ្ទុះលាន់សូរលើយៗ អ្នកភូមិស្រុកដែលកំពុងច្រូតកាត់នៅឯវាលស្រែនាំគ្នារត់ឡើងពីស្រែយ៉ាងប្រញាប់ប្រញាល់ ដែនការសម្លាប់ជនពិការនិងចាស់ជរានៅពេលនោះ ត្រូវអាក់ខានទៅវិញ ។ ខ្មែរក្រហមបានកៀរប្រជាជនយ៉ាងច្រើនទៅដល់ភូមិចម្ការដូងបម្រុងនឹងបោកគ្រាប់បែកសម្លាប់ចោលទាំងអស់ ។ ជួនពេលនោះ កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាចូលមកដល់ដែនការនេះក៏ត្រូវបរាជ័យទៀត ។ ខ្មែរក្រហមបាននាំគ្នារត់ខ្ចាត់ខ្ចាយអស់ចំណែកប្រជាជនបានបំបែកគ្នាធ្វើដំណើរទៅតាមស្រុកភូមិរបស់ខ្លួន

រៀងៗខ្លួន ហើយអ៊ឹនិងក្រុមគ្រួសារបានវិលត្រឡប់មកភូមិកំណើតវិញដែរ ។ ផ្ទះសម្បែងរបស់អ៊ឹបានត្រូវរុះរើធ្វើជារោងបាយសហករណ៍និងរោងស្នាក់នៅរបស់កងទ័ព ។

## ជីវភាពថ្មីនៅលើលំនៅដ្ឋានចាស់

ប្រពន្ធរបស់ អ៊ឹណៃ បានដើរប្រមូលកំណាត់ឈើដែលនៅសេសសល់មកសង់ជាខ្ទមស្នាក់នៅបណ្តោះអាសន្ន ចំណែកអ៊ឹបានចាប់ផ្តើមអាជីពច្រៀងចាប៉ីម្តងទៀត ។ អ៊ឹណៃ សហការជាមួយបងជីដូនមួយដើរច្រៀងនៅតាមភូមិក្បែរនោះដើម្បីដោះដូរយកស្រូវអង្ករមកដោះស្រាយជីវភាពគ្រួសារ ។

ក្រោយមកអ្នកភូមិដែលរស់នៅឆ្ងាយៗបានមកអញ្ជើញ អ៊ឹណៃ ទៅច្រៀង ។ ឆ្នាំ១៩៧៩ រដូវវស្សា បានចូលមកដល់ប្រជាជនគ្រប់រូបប្រញាប់ដែដកស្ទូងឲ្យទាន់ពេលវេលា ដូច្នេះនៅក្នុងភូមិពុំសូវមានបុណ្យទានប៉ុន្មានទេ អ៊ឹណៃ និងប្អូនជីដូនបានធ្វើដំណើរទៅច្រៀងនៅស្រុកឆ្ងាយៗដូចជា ព្រៃមាន់ និងវាលរេញ ។ ការធ្វើដំណើរដោយរទេះគោត្រូវចំណាយពេលអស់ជាច្រើនថ្ងៃទម្រាំទៅដល់វាលរេញ ។ អ៊ឹណៃ ត្រូវបានអ្នកស្រុកវាលរេញជួលឲ្យច្រៀងក្នុងពិធីបុណ្យមួយដោយសន្យាថានឹងឲ្យអង្ករ៤០គីឡូក្រាម ប៉ុន្តែពេលច្រៀងចប់អ្នកសន្យាបានគេចខ្លួន ដូច្នេះអ៊ឹទទួលបានតែអង្ករតែ១៧គីឡូក្រាមប៉ុណ្ណោះ គាត់ត្រូវបង្ខំចិត្តទទួលយកអង្ករបន្តិចបន្តួចនេះ ដើម្បីជាសោហ៊ុយត្រឡប់មកភូមិវិញ ។ តាមផ្លូវ អ៊ឹណៃ ត្រូវបានអ្នកភូមិអញ្ជើញច្រៀងនៅក្នុងពិធីបុណ្យមួយទៀត ដោយសន្យាថានឹងឲ្យថ្លៃឈ្នួលជាអង្ករ១៧គីឡូក្រាម ដូចអ្នកមុនដែរ ក៏ប៉ុន្តែអ្នកសន្យានោះបានរត់បាត់ទៀត ។ ទីបំផុត អ៊ឹណៃ រកបានអង្ករតែ២០គីឡូក្រាមត្រឡប់មកផ្ទះវិញ ។

នៅរដូវចេញវស្សា ដោយឮថានៅទឹកដីកម្ពុជាក្រោមមានចាយលុយ អ៊ឹណៃ និងកូនអាយុ៩ឆ្នាំ(ដើម្បីនាំផ្លូវ) បានធ្វើដំណើរទៅច្រៀងនៅទីនោះក្រែងរកបានកម្រៃខ្លះ ។ ធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលជាច្រើនម៉ោង អ៊ឹណៃ និងកូនបានទៅដល់ផ្សាររហាទៀងនៅម៉ោង៩ព្រឹក ហើយសម្រាកស្រស់ស្រូបអាហារថ្ងៃត្រង់នៅទីនោះមួយស្របក់ទើបបន្តដំណើរទៅមុខទៀតដោយម៉ូតូឌុបឆ្ពោះទៅកាន់វត្តថ្មុក ក្នុងខេត្តក្រមួនស ដែលនៅវត្តនោះមានប្រារព្ធពិធីបុណ្យចេញវស្សា ។ ព្រះចៅអធិការវត្តបានសុំឲ្យអ៊ឹច្រៀងចាប៉ីនៅក្នុងពិធីបុណ្យរយៈពេលពីរម៉ោងក្នុងតម្លៃមួយរយពាន់ដុងលុយធីវគឺស្មើនឹង២៥០ដុង(លុយដុងខាងជើង,៥០០ធីវគឺស្មើនឹង១រៀល) ។ បន្ទាប់ពីនោះមក អ៊ឹណៃ ទៅច្រៀងនៅភូមិមួយទៀតគឺភូមិក្រពើហែ ហើយទទួលបានប្រាក់ឧបត្ថម្ភពីប្រជាជនចំនួន៥០ដុងទៀត ។ ក្រៅពីនេះ អ៊ឹត្រូវបានអ្នកភូមិអញ្ជើញទៅច្រៀងតាមផ្ទះទៀត ។ អ៊ឹណៃ ច្រៀងនៅទឹកដីកម្ពុជាក្រោមអស់រយៈកន្លះខែ សន្សំអង្ករបានមួយកន្ត្រកនិងថវិកាចំនួន៤០០ដុង ហើយក៏បានវិលត្រឡប់មកផ្ទះវិញ ។ បីខែក្រោយមក អ៊ឹណៃ បាន វិលត្រឡប់ទៅច្រៀងនៅទឹកដីកម្ពុជាក្រោមម្តងទៀត ដោយពេលនោះ អ៊ឹរកកម្រៃបានចំនួន៣០០ដុង និងត្រូវឆ្នោតបាន៧០០ដុង ដែលសរុបទាំងអស់១០០០ដុង ហើយក៏សម្រេចចិត្តត្រឡប់មកផ្ទះវិញ ។ ថវិកានិងអង្ករដែលបានមកពីច្រៀងបានជួយដោះស្រាយជីវិភាពគ្រួសារពេញមួយរដូវដកស្ទូងនិងច្រូតកាត់ ។ មិនយូរប៉ុន្មានរដូវច្រូតកាត់បានចប់សព្វគ្រប់ ប្រជាជនបានសម្រាកពីការនឿយហត់នាំគ្នាធ្វើបុណ្យទានប្រចាំភូមិតាមប្រពៃណីយខ្មែរបុរាណក្រោយពីនឿយហត់អស់ជិតពេញមួយឆ្នាំ ហើយក៏ជាពេលវេលាមួយអាចឲ្យអ៊ឹរកប្រាក់ចំណូលបានច្រើនសម្រាប់គ្រួសារដែរ ។

នៅឆ្នាំ១៩៨៣ នៅស្រុកកំពង់ត្រាចមានរៀបចំមហោស្រពមួយដើម្បីប្រឡងជ្រើសរើសចាប៉ីដងវែង ។ អ៊ឹណៃ ក៏បានចូលរួមប្រឡងច្រៀងដែរ ហើយទទួលជ័យលាភីលេខមួយក្នុងការប្រកួតប្រជែងនេះ ។

នៅថ្ងៃរំឭកខួបជ័យជម្នះ ថ្ងៃ៧មករា ក្នុងឆ្នាំ១៩៨៤ អ៊ឹណៃ ត្រូវបានអញ្ជើញឲ្យច្រៀងនៅក្នុងពិធីនេះ ក្រោមអធិបតីភាពរបស់សម្តេច ហ៊ុន សែន និងឯកឧត្តម យុន ឈី រដ្ឋមន្ត្រីក្រសួងគមនាគមន៍ ។ មួយឆ្នាំក្រោយ អ៊ឹត្រូវបានឯកឧត្តម យុន ឈី អញ្ជើញមកច្រៀងនៅគេហដ្ឋានរបស់គាត់នៅទីក្រុងភ្នំពេញ ។ នៅពេលនោះ មាស សំណាង (ស្លាប់) ក៏បានហៅទៅលេងផ្ទះគាត់ដែរ ហើយថែមទាំងប្រគល់ផ្ទះតូចមួយឲ្យស្នាក់នៅប្រសិនបើអ៊ឹព្រមមករស់នៅភ្នំពេញ ។ ដោយភ័យខ្លាចស្រុកទេសចលាចលម្តងទៀត អ៊ឹណៃ បានសម្រេចចិត្តបន្តរស់នៅភូមិរបស់ខ្លួនដដែល ។

នៅឆ្នាំ១៩៨៧ មានមហោស្រពមួយទៀតជ្រើសរើសអ្នកចម្រៀងចាប៉ីដងវែងប្រចាំខេត្តកំពត ។ អ្នកដែលចូលរួមប្រកួតប្រជែងនៅពេលនោះមកពីស្រុកចំនួនបីគឺ ស្រុកបន្ទាយមាស ស្រុកអង្គជ័យ និងស្រុកកំពង់ត្រាច ។ អ៊ឹបានទទួលចំណាត់ថ្នាក់លេខមួយ ស្រុកបន្ទាយមាសជាប់ចំណាត់ថ្នាក់លេខ២ និងស្រុកអង្គរជ័យជាប់លេខបី ។

នៅឆ្នាំ១៩៩១ គឺជាពេលដែលប្រទេសកម្ពុជាទើបតែទទួលបានសន្តិភាពពេញលេញ ។ បន្ទាប់ពីកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសត្រូវបានបញ្ចប់ដោយជោគជ័យ សម្តេចព្រះ នរោត្តម សីហនុ យាងចូលប្រទេសវិញ ។ នៅក្នុងឆ្នាំដដែលនោះ នៅទីក្រុងភ្នំពេញមានប្រារព្ធពិធីបុណ្យទូកយ៉ាងឱឡារិក ដោយមានទាំងមហោស្រពប្រឡងច្រៀងចាប៉ីអាយ៉ៃឆ្លើយឆ្លងនៅវាលព្រះមេនក្បែរព្រះរាជវាំងផង ។ អភិបាលខេត្តកំពត ក៏បានបញ្ជូន អ៊ឹណៃ មកចូលរួមប្រកួតប្រជែងដែរ ។ អ៊ឹបានទទួលចំណាត់ថ្នាក់លេខមួយទូទាំងប្រទេស ដោយមានលោកតា ប្រាជ្ញ ឈួន អ្នកចម្រៀងចាប៉ីដើមចាស់ប្រចាំក្រសួងឃោសនាការនិងវប្បធម៌ ធ្វើជាគណៈមេប្រយោគក្នុងការប្រឡងនេះ ។

ខែមេសា ឆ្នាំ១៩៩២ ក្រសួងវប្បធម៌បានអញ្ជើញ អ៊ឹណៃ មកធ្វើការខាងផ្នែកចាប៉ីដងវែងប្រចាំនៅក្រសួងវប្បធម៌ និងផ្តល់ដីមួយកន្លែងសម្រាប់សង់ផ្ទះស្នាក់អាស្រ័យនៅម្តុំសំណង់អនាធិបតេយ្យ ។ ជីវភាពរស់នៅទីក្រុងដំបូងដែលមិនទាន់មានប្រាក់ខែ អ៊ឹជួបប្រទះនូវការលំបាកយ៉ាងខ្លាំង កូនស្រីពីរនាក់របស់អ៊ឹ ប្រកបមុខរបរលក់បបរនិងពោតស្ងោរដើម្បីយកកម្រៃមកផ្គត់ផ្គង់គ្រួសារ ។ អស់រយៈពេលមួយឆ្នាំ ទើបអ៊ឹបានទទួលប្រាក់ឧបត្ថម្ភ៤ម៉ឺនរៀលក្នុងមួយខែ ។ ឆ្នាំ១៩៩៧ អ៊ឹណៃ ត្រូវបានអញ្ជើញទៅច្រៀងចាប៉ីអាយ៉ៃខ្មែរនៅមហោស្រពមួយដែលរៀបចំឡើងដោយក្រសួងវប្បធម៌បារាំងនៅទីក្រុងប៉ារីសរយៈពេល២១ថ្ងៃ ។ ប្រហែលក្នុងឆ្នាំ១៩៩៧ អ៊ឹណៃ បានទៅសម្តែងនៅប្រទេសថៃ និងឆ្នាំ១៩៩៨ អ៊ឹចេញទៅច្រៀងចាប៉ីឆ្លងឆ្លើយនៅប្រទេសវៀតណាម ។ មួយឆ្នាំក្រោយ អ៊ឹត្រូវបានចេញទៅសម្តែងនៅប្រទេសនីហ្សេរីយ៉ា២យប់ និងប្រទេសប៉ែលហ្ស៊ិក២យប់ ។ សព្វថ្ងៃ អ៊ឹណៃ ចូលនិវត្តន៍ ហើយទទួលប្រាក់ឧបត្ថម្ភ១០ម៉ឺន៧ពាន់រៀលក្នុងមួយខែ ។ ក្រៅពីនេះ បានទទួលការឧបត្ថម្ភពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ឧកញ៉ា ស៊ឹម វណ្ណា, ឯកឧត្តម មុត ខៀវ និងអង្គការសិល្បៈខ្មែរអមតៈ ។ កូនពៅរបស់គាត់ ឈ្មោះ គង់ បូរាណ ក៏ចាប់យកអាជីពជាច្រៀងចាប៉ីនេះដែរ ក្រោមការជួយឧបត្ថម្ភពីអង្គការសិល្បៈខ្មែរអមតៈ ។ អ៊ឹណៃ សង្ឃឹមថា នៅថ្ងៃអនាគតគាត់នឹងមានអ្នកស្នងត្រកូលហើយ ។

នៅពេលរំឭកដល់របបប៉ុលពត អ៊ឹណៃ នៅមានកំហឹងចំពោះខ្មែរក្រហមជានិច្ច ។ របបនេះបានធ្វើឲ្យប្អូនប្រុសរបស់គាត់ដែលមិនមានកំហុសសោះក៏ត្រូវចាប់ដាក់គុកនៅស្រុកកំពង់ត្រាចរយៈពេលបីខែ ធ្វើទារុណកម្មសួរចម្លើយនិងសម្លាប់ចោល មិនតែប៉ុណ្ណោះ សូម្បីតែអ្នកច្រៀងចាប៉ីក៏ត្រូវបានសម្លាប់ចោលដែរ ដាក់ស្តែងដូចអ្នកចាប៉ីដើមចាស់មួយចំនួនឈ្មោះ តាចង្កូម៨ តាពូថៅដៃ (ឈឺហើមស្លាប់ខេត្តតាកែវ) ស្មៀនយិន, ចិនដៃការ៉េ, ស្មៀនឈៀង, ស្មៀនទាន និងអាចារ្យទ្រី ។ល ។ ក៏ត្រូវបានសម្លាប់គ្មានសល់ ។

ទោះបីជាមិនបានមើលឃើញស្ថានភាពនៃការចរចាក្នុងការបង្កើតឲ្យមានតុលាការមួយកាត់ទោសមេដឹកនាំខ្មែរក្រហមនិងទិដ្ឋភាពរបស់តុលាការមានលក្ខណៈយ៉ាងណានោះក៏ដោយ អ៊ឹណៃ ក៏បានតាមដានព័ត៌មានគ្រប់ពេលអំពីដំណើរការនៃការចរចានេះ ហើយគាត់កំពុងតែទន្ទឹងរង់ចាំស្តាប់អំពីតុលាការ ថាតើការកាត់សេចក្តីខ្មែរក្រហមនោះប្រព្រឹត្តទៅយ៉ាងណាបើមានការចូលរួមពីសហគមន៍អន្តរជាតិនោះ ។ ណៃ នៅមានចម្ងល់ទៀតថា តើការកាត់សេចក្តីនេះសម្រេចបានល្អប្រសើរដែរឬទេ បើពេលវេលានៃការកាត់ទោសមានរយៈពេលខ្លី ហើយចេះតែអូសបន្លាយបែបនេះ ។ ហើយក្នុងការកាត់ទោស ទណ្ឌិតនឹងទទួលទោសកម្រិតណា ឬក៏ការកាត់ទោសនេះគ្រាន់តែជាការបន្ធូរកំហឹងឬក៏មានការសងជាសំណងដែរឬយ៉ាងណា ។ ជារួម អ៊ឹណៃ យល់ថា ការកាត់ទោសមានប្រយោជន៍សំខាន់ពីរ ទី១ឲ្យក្មេងជំនាន់ក្រោយបានដឹងថា ឃាតករដែលសម្លាប់ប្រជាជនឥតត្រាប្រណីត្រូវតែទទួលទោស ទី២) ឲ្យសាច់ញាតិរបស់អ្នកស្លាប់បានស្ងប់ចិត្ត ដោយសាររាជរដ្ឋាភិបាលនឹងផ្តល់នូវយុត្តិធម៌មួយពិតប្រាកដតាមរយៈសាលាក្តីនេះ ។

**លី សុផល**

# គុកខ្មែរក្រហម

**(តពីលេខមុន)**

## ស្រុកកោះធំ

### ៦) មន្ទីរសន្តិសុខពោធិ៍ទន្លេ

មន្ទីរសន្តិសុខពោធិ៍ទន្លេ ជាកន្លែងឃុំឃាំងធំមួយប្រចាំស្រុកកោះធំដែលមានអ្នកទោសរាប់ពាន់នាក់ជាប់គុកនៅទីនោះ ។ មន្ទីរសន្តិសុខពោធិ៍ទន្លេមានអគារមួយខ្នងធ្វើពីឈើប្រក់ក្បឿង និងជញ្ជាំងក្តារ ។ ពោធិ៍ទន្លេជាកោះមួយស្ថិតនៅកណ្តាលទន្លេនិងនៅក្នុងទឹកដីឃុំកោះធំ "ក" ស្រុកកោះធំ ខេត្តកណ្តាល មានចម្ងាយ ៥៨គីឡូម៉ែត្រនៅភាគខាងត្បូងទីក្រុងភ្នំពេញតាមបណ្តោយផ្លូវលេខ២១ ។ នៅភាគខាងជើងស្រុកកោះធំ ចម្ងាយប្រហែល ៥០០ម៉ែត្រពីទន្លេ គឺជាទីតាំងមន្ទីរសន្តិសុខ ។


ពោធិ៍ទន្លេ ភូមិពោធិ៍ទន្លេ ឃុំកោះធំ"ក" ស្រុកកោះធំ ខេត្តកណ្តាល

យែម ខុម អាយុ៦៧ឆ្នាំ អតីតអ្នកទោសនៅមន្ទីរសន្តិសុខពោធិ៍ទន្លេកាលពីឆ្នាំ១៩៧៧ បានរៀបរាប់ថា គាត់ត្រូវកងឈ្លបខ្មែរក្រហមចាប់ខ្លួនជាមួយនឹងកូនប្រុស៦នាក់ទៀតពីបទមានប្តីពាក់ស័ក្តិ៥ ជំនាន់ លន់ នល់ និងជាអនុធននាយទុន ។ នៅចំពោះមុខអង្គការ ខុម បានបដិសេធរឿងនេះទាំងស្រុង ប៉ុន្តែនៅតែគេចមិនផុតពីការជាប់ឃុំឃាំង ។ "ក្នុងឆ្នាំ១៩៧៧ខ្ញុំជាប់គុកអស់រយៈពេល៤ខែ ដោយមានតែកន្ទក់ និងដើមចេកប៉ុណ្ណោះសម្រាប់ហូប ។ ពួកខ្មែរក្រហមបានប្រើរនុកទារត្បកក្បាលពួកយើងនៅពេលពួកវារាប់ចំនួនអ្នកទោសម្តងៗមុននឹងផ្តល់អាហារឲ្យយើងហូប" ។

អ្នកទោសត្រូវដាក់ខ្នោះទាំងអស់ដោយឲ្យស្ត្រីនៅដោយឡែកពីបុរស ។ កងឈ្លបបានបញ្ជូនអ្នកទោសឲ្យធ្វើការនៅពេលព្រឹកវេលាម៉ោង៧ ហើយឲ្យសម្រាកនៅម៉ោងជាង១១ដើម្បីហូបអាហារថ្ងៃត្រង់ ដែលមានតែកន្ទក់ប៉ុណ្ណោះ ។ កងឈ្លបមិនអនុញ្ញាតឲ្យអ្នកទោសហូបទឹកនិងផ្លូតទឹកឡើយ ។ ខុម ត្អូញត្អែរថា "ប្រសិនបើអ្នកទោសណាម្នាក់លួចហូបទឹក ទោះជាទឹកស៊ីងឬថ្នុកត្រពាំងក៏ដោយ ច្បាស់ជាត្រូវពួកវាវាយក្បាលនឹងស្នូកកាំភ្លើងមិនខាន" ។ ក្នុងមន្ទីរឃុំឃាំងមានអ្នកទោសស្លាប់រាល់ថ្ងៃដោយសារតែអត់ឃ្លាននិងគ្មានអនាម័យ ។ សាកសពត្រូវអ្នកទោសដូចគ្នាសែងយកទៅកប់ចោលនៅប៉ែកខាងក្រោយគុក ។ ខុម និយាយថា ក្នុងមួយថ្ងៃៗយ៉ាងហោចណាស់ មានអ្នកទោសស្លាប់ពី៣ទៅ៤នាក់ ។ ក្រៅពីអ្នកទោសស្លាប់ដោយសារជំងឺមានអ្នកទោសជាច្រើននាក់ទៀតត្រូវកងឈ្លបនាំយកទៅសម្លាប់នៅពោធិ៍ទន្លេ ។ អ្នកទោសដែលបានស្លាប់នៅក្នុងមន្ទីរឃុំឃាំងត្រូវអ្នកទោសដូចគ្នាអូសយកទៅកប់នៅខាងក្រោយគុក ។ ខុម ត្រូវកងសន្តិសុខបង្ខំឲ្យយួរលាមកអ្នកទោសយកទៅចាក់ចោល ប៉ុន្តែគាត់ត្រូវខ្មែរក្រហមស្ទុះមកវាយផ្ទប់នឹងដី ព្រោះគាត់លើកធុងលាមកនោះមិនរួច ។ កូនទាំង៦នាក់របស់ ខុម មិនអាចជួយគាត់បានទេ ។ បន្តិចក្រោយមកកូនរបស់ ខុម ត្រូវខ្មែរក្រហមនាំចេញទៅឆ្ងាយ ហើយវៃសម្លាប់ចោលអស់ពីរនាក់ ព្រោះតែសម្រក់ទឹកភ្នែកអាណិតម្តាយ ។

បន្ទាប់ពីការឃុំឃាំងរយៈពេល៤ខែ ខុម ត្រូវបានខ្មែរក្រហមដោះលែងមកវិញ ព្រោះដឹងថាគាត់គ្មានធ្វើអ្វីខុសចំពោះអង្គការទេ ដោយសារអង្គការរកឃើញថាប្តីរបស់គាត់គ្រាន់តែជាជាងជួសជុលឡានម្នាក់ប៉ុណ្ណោះ ។ ទម្រាំតែរកឃើញការពិត ប្តីនិងកូនពីរនាក់របស់គាត់ត្រូវឈ្លបសម្លាប់បាត់ទៅហើយ ។ មកដល់បច្ចុប្បន្ននេះ កូនប្រុសម្នាក់របស់គាត់បានក្លាយជាមនុស្សវិកលចរិតដោយសារតែខ្មែរក្រហមវាយធ្វើបាបខ្លាំងពេក ។ ខុម បាន

ចំណាយពេលវេលាយ៉ាងច្រើនក្នុងការឧទ្ទិសកុសលផលបុណ្យជូនវិញ្ញាណក្ខន្ធប្តី និងកូនៗរបស់គាត់នៅកន្លែងដាក់អដ្ឋិធាតុជនរងគ្រោះពោធិ៍ទន្ទេ ព្រោះអ្នកទាំងនោះបានត្រូវសម្លាប់នៅទីនោះ ។

### ទិន្នន័យសង្ខេប

**ទីតាំង** ៖ ពោធិ៍ទន្ទេ ស្ថិតនៅភូមិពោធិ៍ទន្ទេ ឃុំកោះធំ"ក" ស្រុកកោះធំ ខេត្តកណ្តាល ។

**ស្ថិតិ** ៖ ប្រជាជនរាប់ពាន់នាក់បានត្រូវខ្មែរក្រហមសម្លាប់ដាក់ក្នុងរណ្តៅជាច្រើននៅពោធិ៍ទន្ទេ។ អ្នកទោសភាគច្រើនបំផុតដែលជាប់ក្នុងមន្ទីរសន្តិសុខពោធិ៍ទន្ទេ ជាប្រជាជនថ្មីដែលអង្គការជម្លៀសចេញពីទីក្រុងភ្នំពេញ។ របបអាហារសម្រាប់អ្នកទោសមានតែកន្ទក់ប្រភេទអន់ប៉ុណ្ណោះ ។ អ្នកទោសត្រូវស្លាប់ជារៀងរាល់ថ្ងៃដោយសារជំងឺការអត់អាហារនិងទឹក ។ ចំណែកអ្នកទោសដែលត្រូវកងឈ្លបនាំយកទៅសម្លាប់ក៏ដូច្នេះដែរ ។ ក្រោយឆ្នាំ១៩៧៩ បូជនីយដ្ឋានមួយត្រូវបានកសាងឡើងដើម្បីតម្កល់អដ្ឋិធាតុជនរងគ្រោះដែលប្រជាជនគាស់ចេញពីរណ្តៅ ។

### ៧) មន្ទីរសន្តិសុខក្បាលដីក្រោម

មន្ទីរសន្តិសុខមួយប្រចាំស្រុក១៨"ស្រុកកោះធំ"ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៣ គឺជាផ្ទះក្បឿងបីខ្នង ដែលជាកម្មសិទ្ធរបស់ ហែម ឆឹង បន្ទាប់ពី ឆឹង និងក្រុមគ្រួសារត្រូវខ្មែរក្រហមជម្លៀសទៅកាន់ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

នៅឆ្នាំ១៩៧៤ ឆឹង បានត្រឡប់មកស្រុកកំណើតវិញ ហើយក៏ឈានចូលមើលផ្ទះរបស់ខ្លួន ប៉ុន្តែត្រូវខ្មែរក្រហមហាមឃាត់ព្រោះផ្ទះនេះត្រូវអង្គការយកធ្វើកម្មសិទ្ធរួមទៅហើយ ។ ឆឹង តែងតែបានត្រឡប់មកលបមើលផ្ទះរបស់ខ្លួនជារឿយៗ ។ "អ្នកទោសច្រើនណាស់កំពុងជាប់ចំណងនៅលើផ្ទះរបស់ខ្ញុំ ប៉ុន្តែក្រោយមកអ្នកទោសទាំងនោះបាត់ម្តងមួយៗរហូតអស់ពីលើផ្ទះ" ។ មន្ទីរសន្តិសុខនេះហ៊ុមព័ទ្ធដោយដើមឫស្សីដើម្បីការពារកុំឲ្យអ្នកទោសលួចរត់និងការពារមិនឲ្យប្រជាជនដទៃចេញចូលតាមអំពើចិត្ត។ អ្នកទោសត្រូវឈ្លបយកទៅសម្លាប់នៅក្រោយមន្ទីរសន្តិសុខនេះតែម្តង ហើយការសម្លាប់នេះច្រើនតែប្រព្រឹត្តទៅនៅពេលយប់ ។ ជនរងគ្រោះជាប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី និងប្រជាជនថ្មីដែលជម្លៀសមកពីភូមិកោះទាវ ភូមិឈើខ្មៅ និង អូរយួន។ ឆឹង និយាយថា អ្នកទោសគឺប្រជាជនដែលគ្រាន់តែមានកំហុសបន្តិចបន្តួចប៉ុណ្ណោះ ។



មន្ទីរសន្តិសុខក្បាលដីក្រោម ស្រុកកោះធំ (ស្រុក១៨) ខេត្តកណ្តាល

## ស្រុកគោះខ្មៅ

### ១០) មន្ទីរសន្តិសុខនៅមន្ទីរពេទ្យរិកលចរិត



មន្ទីរសន្តិសុខមន្ទីរពេទ្យវិកលចរិត ភូមិក្រពើហា ឃុំព្រែកឫស្សី ស្រុកគោះខ្មៅ ខេត្តកណ្តាល

មន្ទីរពេទ្យជ័យជម្នះបច្ចុប្បន្ន គឺជាអតីតមន្ទីរពេទ្យវិកលចរិតព្រែកត្នោតពីដើម ។ ពីឆ្នាំ១៩៥៥ ដល់ ឆ្នាំ១៩៦៤ នៅពេលវេជ្ជបណ្ឌិត សុន ម៉ន មកធ្វើជាអ្នកគ្រប់គ្រងមន្ទីរពេទ្យនេះ រាជរដ្ឋាភិបាលបានផ្លាស់ប្តូរឈ្មោះទៅជា"មន្ទីរពេទ្យ សុន ម៉ន"វិញ ។ ក្រោយមកវេជ្ជបណ្ឌិត ចំរើន សំអឿន គ្រប់គ្រងមន្ទីរពេទ្យនេះជំនួសវេជ្ជបណ្ឌិត សុន ម៉ន ដែលបានទទួលមរណភាពដោយជំងឺនៅមន្ទីរពេទ្យកាល់ម៉ែត្រកាលពីឆ្នាំ១៩៦៤។ ក្រោយថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ កន្លែងនេះបានក្លាយទៅជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមរហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

ដោក សុខខៃ អាយុ៦៥ឆ្នាំ រស់នៅភូមិព្រៃកអញ្ចាញ ឃុំព្រែកប្ញស្សី ស្រុកគាខ្សាច់ ខេត្តកណ្តាល បាននិយាយថា គាត់បានឃើញស្នាមទម្ពុះជញ្ជាំងបន្ទប់អគារមន្ទីរពេទ្យ ដើម្បីសឹករនុកដែកសម្រាប់ភ្ជាប់ខ្នោះ ដាក់កជើងជនពិការ ដែលខ្មែរក្រហមប្រមូលមកពីទីក្រុងភ្នំពេញនិងពីកន្លែងផ្សេងៗទៀត ។ អ្នកទោសត្រូវកងឈ្លបនាំយកទៅសម្លាប់ចោលក្រោយពេលធ្វើទារុណកម្មរួច ។ សាកសពត្រូវបានកប់ក្នុងរណ្តៅតូចៗចំនួន១៣០រណ្តៅដោយមានដាំដើមដូងពីលើផង ។ នៅឆ្នាំ១៩៨០ ដោក សុខខៃ និង សាយ ពេញ បានប្រមូលខ្នោះជាច្រើនដែលនៅរាយប៉ាយក្នុងនិងខាងក្រោមបន្ទប់អគារ“ជ”ដែលបច្ចុប្បន្នជាអគារពិនិត្យជំងឺទូទៅរបស់មន្ទីរពេទ្យជ័យជម្នះ យកទៅបោះចោលនៅក្នុងចម្ការចេក និងក្រោមដើមម៉ៃសាក់នៅខាងក្រោយមន្ទីរពេទ្យ ។ អគារ“ជ”មានកម្ពស់ពីរជាន់ និង៣០បន្ទប់ស្ថិតតាមបណ្តោយថ្ងៃ ។ សុខខៃ បានបន្តលបង្ហាញថា កាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ បុគ្គលិកពេទ្យបាននាំគ្នាបូកកន្លែងប្រហោងដាក់ខ្នោះនិងប្រហោងដទៃទៀតជិតទាំងអស់ ។ ស្លាកស្នាមផ្សេងៗទៀតនៅតែមានមិនទាន់លុបបាត់ទាំងស្រុងនៅឡើយ ។ ក្នុងចំណោមបន្ទប់ទាំង៣០មាន ២៤បន្ទប់ដែលខ្មែរក្រហមធ្លាប់ប្រើប្រាស់ធ្វើជាកន្លែងឃុំឃាំងអ្នកទោស ហើយក្រៅពីនេះគឺជាបន្ទប់ចែកថ្នាំនិងបង្គន់ ។

## ទិន្នន័យសង្ខេប

**ទីតាំង** ៖ មន្ទីរពេទ្យវិកលចរិតស្ថិតនៅភូមិក្រពើហា ឃុំព្រែកប្ញស្សី ស្រុកគាខ្សាច់ ខេត្តកណ្តាល ។

**ស្ថិតិ** ៖ មន្ទីរពេទ្យជ័យជម្នះ គឺជាអតីតមន្ទីរពេទ្យវិកលចរិតក្រោយឆ្នាំ១៩៧៥មន្ទីរនេះបានក្លាយជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ យ៉ាងហោចណាស់មានជនរងគ្រោះ១៣០នាក់ដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះត្រូវបានសម្លាប់ចោល ។ ក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះ បានបន្សល់ទុកនូវភស្តុតាងយ៉ាងច្រើន ដូចជា ខ្នោះ គុ និងរំពាត់ សម្រាប់វៃអ្នកទោសសួរចម្លើយ និងស្លាកស្នាមចោះទម្លុះជញ្ជាំងបន្ទប់ដើម្បីសឹករនុកដែក ។

## ស្រុកល្វាឯម

### ១១) មន្ទីរសន្តិសុខវត្តស្វាយអណ្តែត

វត្តស្វាយអណ្តែត ស្ថិតនៅក្នុងភូមិគាស្អរ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល មានចម្ងាយពីសាលាស្រុកប្រហែល ២គីឡូម៉ែត្រ ។ កន្លែងសម្លាប់មនុស្សស្ថិតនៅចម្ងាយប្រហែល ៥០០ម៉ែត្រពីបរិវេណវត្តស្វាយអណ្តែតដែលមានឈ្មោះថា ស-២ ។ អដ្ឋិធាតុនិងរណ្តៅសាកសពទាំងនោះត្រូវរលាយអស់ដោយសារប្រាំងទន្លេបាក់ ។ ខ្មែរក្រហមបានយកព្រះវិហារ សាលាឆាន់ និងសាលារៀនក្នុងវត្តធ្វើជាមន្ទីរឃុំឃាំងអ្នកទោស ។


មន្ទីរសន្តិសុខវត្តស្វាយអណ្តែត ភូមិគាស្អរ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល

ចំណែកកុដិចំនួន៦ទៀត ជាកន្លែងស្នាក់នៅរបស់កម្មាភិបាលខ្មែរក្រហម ។

មូល ភន អាយុ៥៧ឆ្នាំ ជាគណៈកម្មការវត្តស្វាយអណ្តែត បាននិយាយថា មន្ទីរសន្តិសុខនេះបង្កើតឡើងដើមឆ្នាំ១៩៧៧ ។ ជនរងគ្រោះត្រូវកងឈ្លបចាប់ខ្លួនពីគ្រប់ទីកន្លែងទូទាំងស្រុកល្វាឯម មកដាក់ឃុំឃាំងនៅលើព្រះវិហារ សាលាឆាន់ និងសាលារៀន ។ បន្ទប់មន្ទីរឃុំឃាំងនីមួយៗសុទ្ធតែមានចោះប្រហោងដើម្បីសឹកខ្នោះដាក់អ្នកទោស ។ ក្លិនលាមកនិងក្លិនសម្បៀកបំពាក់ដែលមិនដែលបោកគក់បានធ្វើឲ្យមន្ទីរឃុំឃាំងទាំងមូលស្អុយឆ្អេះឆ្អាបស្ទើរតែមិនអាចចូលបាន ។ មូល ភន បាននិយាយថា ខ្លួនប្រាណ

អ្នកទោសមានក្លិនស្អុយខ្លាំងណាស់ ដោយសារប្រឡាក់លាមកខ្លួនឯង ហើយមិនបានដុះលាង។ អ្នកទោសត្រូវបានសួរចម្លើយជារៀងរាល់ថ្ងៃ បន្ទាប់មកទើបនាំយកទៅសម្លាប់ចោលនៅទីតាំងពិឃាតស-២ ដោយចាក់មីក្រូបន្លឺសំឡេងយ៉ាងកងរំពង។ ឡឹក សាលន់ អាយុ៤១ឆ្នាំ រស់នៅក្នុងភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯមបាននិយាយថា គាត់ឃើញកងឈ្លបនាំជនរងគ្រោះយកទៅសម្លាប់ជារៀងរាល់ថ្ងៃ ជាពិសេសនៅពេលល្ងាច។ អ្នកទោសត្រូវកងឈ្លបចងដៃនឹងសរសៃអំបោះបណ្ដើរយកទៅសម្លាប់។ សាលន់ បានបន្ថែមថា ខ្មែរក្រហមបានដោះសម្លៀកបំពាក់ជនរងគ្រោះដែលបានត្រូវសម្លាប់យកមកចែកឲ្យប្រជាជនដែលធ្វើការនៅក្នុងកងភ្ជួរ។ អ្នកទោសនៅក្នុងមន្ទីរសន្តិសុខវត្តស្វាយអណ្ដែត ត្រូវកងសន្តិសុខធ្វើទារុណកម្មតាមវិធីបន្តុតបាយ និងតាមវិធីផ្សេងៗជាច្រើនទៀត។ នៅមុនថ្ងៃរំដោះ ឆ្នាំ១៩៧៩ កងសន្តិសុខបាននាំគ្នារត់ចោលការងារដោយខ្លាចមានការតាមសងសឹកពីប្រជាជន។ ហួន ពៅ បានដឹកនាំប្រជាជនក្នុងភូមិឲ្យងើបឡើងតស៊ូប្រឆាំងនឹងការឃុំឃាំងមនុស្សនៅវត្តស្វាយអណ្ដែត ដើម្បីរំដោះអ្នកទោសឲ្យមានសេរីភាពវិញ។ កងសន្តិសុខមួយចំនួនត្រូវប្រជាជនសម្លាប់និងមួយចំនួនទៀតនាំរត់ប្រាសអាយុ។ សព្វថ្ងៃវត្តស្វាយអណ្ដែតត្រូវបានជួសជុល ហើយវត្ថុតាងដែលនៅសេសសល់ត្រូវបានកម្ទេចចោល។

**ទិន្នន័យសង្ខេប**

**ទីតាំង :** វត្តស្វាយអណ្ដែតស្ថិតនៅភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្ដាល។

**ស្ថិតិ :** ព្រះវិហារ សាលាឆាន់ សាលារៀន និងកុដិចំនួន៦ផ្សេងទៀត ស្ថិតនៅក្នុងបរិវេណវត្តស្វាយអណ្ដែត ត្រូវបានខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងមនុស្សនិងជាទីស្នាក់នៅរបស់កម្មាភិបាលមន្ទីរនោះ។ អ្នកទោសត្រូវនាំយកទៅសម្លាប់នៅទីតាំងមួយឈ្មោះថាស-២។ នៅចុងឆ្នាំ១៩៧៨ កម្មាភិបាល កងឈ្លប និងកងសន្តិសុខមួយចំនួនបានទទួលរងនូវការសងសឹកយ៉ាងខ្លាំងពីប្រជាជនក្រោមការដឹកនាំរបស់ឈ្មោះ ហួន ពៅ បច្ចុប្បន្នជាអាចារ្យវត្តនៅវត្តស្វាយអណ្ដែត។

## ១២) មន្ទីរសន្តិសុខភូមិផ្លូវត្រី

មន្ទីរសន្តិសុខភូមិផ្លូវត្រី គឺជាសាខាមួយរបស់មន្ទីរសន្តិសុខស្រុកល្វាឯម។ កាលពីឆ្នាំ១៩៧៥ ខ្មែរក្រហមបានយកផ្ទះមួយខ្នងធ្វើជាមន្ទីរឃុំឃាំងអ្នកទោសដែលមានប្រមាណ១០០នាក់ ជាប់ក្នុងនោះ បច្ចុប្បន្នជាផ្ទះរបស់ឈ្មោះ ងួន ណាវ។ ចំណែកផ្ទះដែលនៅទល់មុខមន្ទីរឃុំឃាំងនេះ គឺជាទីបញ្ជាការរបស់ខ្មែរក្រហម។ ប្រភេទអ្នកទោសដែលកងឈ្លបចាប់មកដាក់នៅក្នុងមន្ទីរសន្តិសុខភូមិផ្លូវត្រី ជាអ្នកជាប់និន្នាការនយោបាយជិនាទ់លន់នល់ អ្នកជម្លៀសមកពីទីក្រុងភ្នំពេញ និងប្រជាជនមូលដ្ឋានដែលធ្វើខុសវិន័យរបស់អង្គការ និងអ្នកខុសសីលធម៌។ អ្នកទោសប្រភេទនេះត្រូវកងឈ្លបនាំយកទៅសម្លាប់នៅទីតាំងទួលលៀប។ រហូតមកដល់ចុងឆ្នាំ១៩៧៨ ការសម្លាប់បានធ្វើឡើងក្នុងបរិវេណវត្តសំពោងវិញ។


មន្ទីរសន្តិសុខភូមិផ្លូវត្រី ភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្ដាល

អ្នកទោសខ្លះត្រូវបញ្ជូនទៅកាន់មន្ទីរសន្តិសុខភូមិព្រែកតាសរ ដែលស្ថិតនៅក្នុងតំបន់២២ដូចគ្នា មន្ទីរទាំងពីរនេះមានទំនាក់ទំនងគ្នាជានិច្ច។ ជួនកាលកងសន្តិសុខបានបញ្ជូនអ្នកទោសពីភូមិព្រែកតាសរ មកកាន់មន្ទីរឃុំឃាំងនៅភូមិផ្លូវត្រីវិញ។ ម៉ៅ វង្សសារុធ និង ម៉ៅ ឆាយាយុទ្ធ គឺជាអតីតអ្នកទោសនៅមន្ទីរឃុំឃាំងផ្លូវត្រី ដែលត្រូវបានចាប់ខ្លួននៅ

ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៥ ដោយសារកងឈ្លបក្មេងម្នាក់រាយ-ការណ៍ថា អ្នកទាំងពីរបានជជែកគ្នាជាភាសាអង់គ្លេសពេលកំពុងជាន់រហាត់ទឹកបញ្ចូលស្រែនៅខាងក្រោយវត្តថ្នករ ។ សាវុធ និង ឆាយាយុទ្ធ ត្រូវកងសន្តិសុខសួរចម្លើយពីទោសកំហុសដែលគាត់បានប្រព្រឹត្ត ។ សាវុធ បញ្ជាក់ថាកងឈ្លបនោះនៅមានជីវិតរហូតដល់សព្វថ្ងៃ ហើយរស់នៅក្នុងភូមិឃុំជាមួយគាត់ទៀត ។ សាវុធ និងឆាយាយុទ្ធ បានរួចខ្លួនមកវិញនៅឆ្នាំ១៩៧៨ ដោយសារមានការផ្លាស់ប្តូរកម្មាភិបាលដឹកនាំមន្ទីរឃុំឃាំង ។

### ទិន្នន័យសង្ខេប

**ទីតាំង** : មន្ទីរសន្តិសុខភូមិដូវគ្រី ស្ថិតនៅភូមិដូវគ្រី ឃុំថ្នករ ស្រុកល្វាឯម ខេត្តកណ្តាល ។

**ស្ថិតិ** : មន្ទីរសន្តិសុខនៅភូមិដូវគ្រីគឺជាសាខារបស់មន្ទីរសន្តិសុខស្រុកល្វាឯម ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរឃុំឃាំងនេះមានប្រមាណ១០០នាក់ ។ ជនរងគ្រោះត្រូវបានសម្លាប់នៅទួលលៀបក្នុងអំឡុងឆ្នាំ១៩៧៥ និងបរិវេណវត្តសំពោងនៅឆ្នាំ១៩៧៨ ។



មន្ទីរសន្តិសុខវត្តខ្នុរការ ភូមិខ្នុរការ ឃុំបារ៉ុង ស្រុកល្វាឯម ខេត្តកណ្តាល

### ១៣) មន្ទីរសន្តិសុខវត្តខ្នុរការ

មន្ទីរសន្តិសុខមួយប្រចាំស្រុកល្វាឯមត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦នៅក្នុងបរិវេណវត្តខ្នុរការ ហើយផ្ទះមួយខ្នងដែលនៅទល់មុខព្រះវិហារវត្តខ្នុរការ ជាកន្លែងស្នាក់នៅរបស់កម្មា-ភិបាលខ្មែរក្រហម ។ អ្នកទោសជាង២០០នាក់ត្រូវបានឃុំឃាំងនៅក្នុងសាលាឆាន់មួយខ្នងស្ថិតដែលស្ថិតនៅខាងលិចព្រះវិហារ ។ កាលណោះ ខេង ជាប្រធានមន្ទីរសន្តិសុខ, ឯម សាវ៉ាត ជាអនុប្រធាន និងកងសន្តិសុខយ៉ាងតិចពី២០នាក់ ។

អ្នកទោសដែលត្រូវកងសន្តិសុខចាប់មកឃុំឃាំងនៅមន្ទីរសន្តិសុខប្រចាំស្រុកល្វាឯម ជាប្រជាជន១៧មេសា អ្នកជាប់និន្នាការនយោបាយពីសង្គមលន់នល់ កម្មាភិបាលខ្មែរក្រហមដូចជាគណៈភូមិឃុំ និងសហករណ៍ដែលខុសសីលធម៌និងប្រជាជនមូលដ្ឋាន ។ ឃី ហេង អាយុ៥០ឆ្នាំ រស់នៅក្នុងស្រុកល្វាឯម ខេត្តកណ្តាលនិយាយថា គាត់បានឮស្នូរកាំភ្លើងផ្ទុះឡើងក្នុងពេលយប់ ហើយព្រលឹមឡើងទើបដឹងថាមានអ្នកទោសម្នាក់ត្រូវឆ្មាំគុកបាញ់សម្លាប់ដោយសារលួចរត់ចេញពីមន្ទីរសន្តិសុខ ។ អ្នកទោសស្រាលៗត្រូវចាត់តាំងឲ្យជាន់រហាត់ទឹកបញ្ចូលស្រែ និងដកស្ទូងជាប្រចាំទាំងនៅខាងក្នុងនិងក្រៅមន្ទីរសន្តិសុខ ។ ការងារត្រូវធ្វើជាក្រុមៗ ដោយមានកងសន្តិសុខកាន់កាំភ្លើងឈរយាមនៅលើភ្លឺស្រែផង ។ អ្នកទោសធ្ងន់ខ្លះមិនតម្រូវឲ្យធ្វើការងារអ្វីទេ គឺនៅជាប់ខ្នោះទាំងដៃនិងជើងរហូត ។ ប៉ាត គូ អាយុ៥១ឆ្នាំ ជាប្រធានភូមិខ្នុរការ ឃុំបារ៉ុង ស្រុកល្វាឯម បានរៀបរាប់ថា ខ្នោះដែលកងសន្តិសុខយកមកដាក់អ្នកទោស គឺមានរាងជាអក្សរ "អ៊ុយ" ចំណែករនុកសឹកខ្នោះដៃនិងជើងមានទម្រង់ដូចរនុកទ្វារក្រោលគោដែលគាត់ប្រើប្រាស់រាល់ថ្ងៃ ។ ក្នុងដែករនុកនីមួយៗ ខ្មែរក្រហមអាចសឹកអ្នកទោសបានពី៧ទៅ៨នាក់ ។ អ្នកទោសភាគច្រើនស្លាប់ទាំងដៃជើងនៅជាប់ខ្នោះ ។ ប៉ាល់ រ៉ន ហៅ"គប់គ្រាប់បែក" ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខស្រុកល្វាឯម បច្ចុប្បន្នរស់នៅភូមិខ្នុរការ ឃុំបារ៉ុង ស្រុកល្វាឯម និយាយថា អ្នកជាប់ទោសនៅក្នុងមន្ទីរសន្តិសុខវត្តខ្នុរការមានចំនួនច្រើនណាស់ ។ រ៉ន ប្រាប់ថា ការដែលគាត់ជាប់ក្នុងមន្ទីរសន្តិសុខ ដោយសារប្តីរបស់គាត់ទាហានលន់នល់ ។ រ៉ន បន្តថា ក្នុងមួយថ្ងៃយ៉ាងហោចណាស់ ក៏មានអ្នកទោស៣នាក់ដែរត្រូវកងសន្តិសុខនាំ

យកទៅសម្លាប់នៅត្រពាំងតាចាប ។ តាជៅ គឺជាអ្នកសែងខ្មោច យកទៅដាក់តម្រៀបក្នុងរណ្ដៅនៅព្រៃក្រាស់និងត្រពាំងតាចាប សព្វថ្ងៃគាត់រស់នៅឃុំព្រែកឫស្សី ។ អ្នកទោសមួយចំនួនត្រូវកង ឈ្លបបញ្ជូនយកទៅសម្លាប់នៅវត្តស្វាយអណ្ដែត ។ នារី សុខន ជាកម្មាភិបាលដៃដល់ម្នាក់ដែល វ៉ន អះអាងថា បានយកមនុស្ស ពីមន្ទីរសន្តិសុខវត្តខ្នុរការទៅសម្លាប់ចោល ។ សុខន ត្រូវប្រជាជន សម្លាប់នៅពេលកងទ័ពរណសិរ្សចូលមករំដោះប្រទេស ។ ក្រៅពី សុខន នៅមាន ស៊ិន់ ក៏ត្រូវប្រជាជនសម្លាប់ដែរ, ព្រៃ ដែលត្រូវ ជាបងរបស់ សុខន, ផល សព្វថ្ងៃនៅរស់ឯព្រែកជ្រូក ស្រុក ខ្សាច់កណ្ដាល និង អាត សព្វថ្ងៃរស់នៅព្រែកវ៉ៃ ។

អ្នកទោសដែលមិនទាន់ដល់វេនស្លាប់ត្រូវកងសន្តិសុខចាក់ នឹងចំពុះទុងកាំភ្លើងជាការកម្សាន្តលេងក្នុងពេលអ្នកទោសសម្រាក នៅពេលយប់ ប៉ុន្តែពុំមានអ្នកទោសណាម្នាក់ហ៊ានស្រែកឡើយ រហូតដល់សព្វថ្ងៃអ្នកទោសខ្លះបានក្លាយជាជនពិការ ។

ក្រោយឆ្នាំ១៩៧៩ តូ និយាយថា គាត់ឃើញកម្រាល ឥដ្ឋរបស់សាលាឆាន់មានស្នាមសឹក ដោយសារអ្នកទោសអូស ខ្នោះជើងចុះឡើង និងមានស្នាមចោះប្រហោងនៅតាមជញ្ជាំង នីមួយៗផង ។ មេឃុំ រស់ ស៊ុំ បានអធិប្បាយថា គាត់ប្រមូល យកខ្នោះបាន២បាវពីមន្ទីរសន្តិសុខវត្តខ្នុរការទៅធ្វើជាធ្មេញ រនាស់សម្រាប់ប្រើប្រាស់ក្នុងក្រុមសាមគ្គីបង្កបង្កើនផល ។ ប៉ុន្តែ


មន្ទីរសន្តិសុខវត្តរកាកោង ភូមិរកាកោង ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្ដាល

ក្រោយមក គាត់បានយកទៅទម្លាក់ចោលទៅក្នុងទឹកបឹង ព្រោះ គាត់ឃើញមានជ្រាបខ្លាញ់តាមសំបកបាវ ។ បរិវេណវត្តនេះ ត្រូវប្រជាជនគាស់កកាយខ្ទេចខ្ទី ហើយចាប់ផ្ដើមកសាង និង ជួសជុលឡើងវិញ ។ ចំណែកផ្ទះមួយខ្នងដែលខ្មែរក្រហមមកធ្វើ ជាទីកន្លែងស្នាក់នៅរបស់កម្មាភិបាលប្រចាំមន្ទីរក៏ត្រូវប្រជាជន រុះរើទាំងអស់គ្មានសល់ដែរ ។

គ្រោងឆ្អឹងជនរងគ្រោះនៅរាយប៉ាយស្ទើរតែគ្រប់ទីកន្លែង នៃបរិវេណវត្តខ្នុរការ ហើយមួយចំនួនទៀត ផុសឡើងមកលើដី ដោយសារអ្នកភូមិភ្ជួរដីធ្វើស្រែ ។ អដ្ឋិធាតុទាំងនោះគ្មានអ្នកណា រើសយកមកតម្កល់ទុកឲ្យបានត្រឹមត្រូវឡើយ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** : វត្តខ្នុរការ ស្ថិតនៅក្នុងភូមិខ្នុរការ ឃុំបារ៉ុង ស្រុកល្វាឯម ខេត្តកណ្ដាល ។

**ស្ថិតិ** : ជនរងគ្រោះដែលខ្មែរក្រហមប្រមូលមកពីគ្រប់ឃុំ ក្នុងស្រុកល្វាឯម ត្រូវនាំយកទៅឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ ប្រចាំស្រុកមួយកន្លែងដែលបង្កើតឡើងនៅឆ្នាំ១៩៧៦ ។ អ្នក ទោសប្រមាណ២០០នាក់ ត្រូវឃុំខ្លួននៅក្នុងសាលាឆាន់ ។ អ្នក ទោសចំនួនទៀតត្រូវបញ្ជូនទៅមន្ទីរសន្តិសុខវត្តស្វាយអណ្ដែត ទៀត ។

**ផេង ពង្សរ៉ាស៊ី**

# សោ គឹមយន : ចង់សួរ នួន ជា ថា ហេតុអ្វីបានជាបងប្រុសរបស់ខ្ញុំត្រូវចាប់ខ្លួន?

“ចង់សួរ នួន ជា ថាតើហេតុអ្វីបានជាបងប្រុសខ្ញុំត្រូវចាប់ខ្លួន?” នេះជាការចោទសួររបស់ សោ គឹមយន ដែលត្រូវជាក្មួយស្រីសាច់ឆ្ងាយរបស់ នួន ជា អតីតប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាគណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍បក្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គឹមយន មានបងប្រុសម្នាក់ឈ្មោះ សោ សេងលី ដែលបានទទួលអាហារូបករណ៍សិក្សានៅប្រទេសបារាំងនៅសម័យសង្គមរាស្ត្រនិយម ។ បន្ទាប់ពីវិលត្រឡប់ចូលមាតុភូមិវិញ សេងលី ត្រូវអង្គការខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៧ និងបញ្ជូនមកឃុំឃាំងនៅមន្ទីរស-២១ ។ គឹមយន និងម្តាយ ដែលរហូតមកដល់ពេលនេះនៅមិនទាន់ដឹងអំពីមូលហេតុនៃការចាប់ខ្លួនរបស់ សេងលី ឡើយ ។ សេងលី ជានិស្សិតឆ្នើមម្នាក់ប្រចាំប្រទេសដែលបានទទួលអាហារូបករណ៍ពីសម្តេច ព្រះនរោត្តម សីហនុ ទៅបន្តការសិក្សាផ្នែកវិស្វកម្ម នៅប្រទេសបារាំងនៅក្នុងឆ្នាំ១៩៦០ ដែលកាលណោះ សេងលី មានអាយុប្រហែល២០ឆ្នាំ ។ មុនពេលចាកចេញពីមាតុប្រទេស សេងលី បានសន្យាជាមួយម្តាយថានឹងខិតខំរៀនសូត្រ និងរកប្រាក់ឲ្យបានច្រើន ដើម្បីត្រឡប់មកស្រុកខ្មែរវិញ ។


សោ សេងលី និង សោ គឹមយន

ពេលកំពុងសិក្សានៅប្រទេសបារាំង សេងលី តែងតែផ្ញើសំបុត្រសួរសុខទុក្ខម្តាយនិងប្អូនស្រី តាមរយៈមិត្តភក្តិដែលរៀននៅក្រៅប្រទេសជានិច្ច ។ ក្រោយមកស្រុកទេសមានការច្របូកច្របល់ ហើយលទ្ធិកុម្មុយនីស្តបានកំពុងតែរីករាលដាលពាសពេញពីភពលោកនាសម័យនោះ ។ យាយបូយ ដែលត្រូវជាម្តាយព្រួយបារម្ភយ៉ាងខ្លាំងខ្លាចកូនប្រុសរបស់គាត់បោះបង់ចោលការសិក្សា ហើយចូលខាងក្រុមក្រហមដែលត្រូវបានស្គាល់ថា“ជាពួកកុម្មុយនីស្ត” ។ យាយបូយ បានឲ្យកូនស្រីគាត់សរសេរសំបុត្រផ្ញើ សេងលី ឲ្យខិតខំរៀនសូត្រកុំឲ្យប្រឡូកចូលក្រុមក្រហមឲ្យសោះ ។ ប៉ុន្តែ រាល់សំបុត្រដែលផ្ញើមកផ្ទះវិញ សេងលី មិននិយាយអំពីរឿងរបស់ខ្លួនប្រាប់ម្តាយឡើយ គឺមានតែសួរសុខទុក្ខម្តាយនិងជំរុញឲ្យប្អូនស្រីខិតខំរៀនសូត្រប៉ុណ្ណោះ ។ ក្រោយមកទើប គឹមយន ទទួលដំណឹងតាមរយៈមិត្តភក្តិរបស់ សេងលី ឈ្មោះ ចៅ ប៊ុនឡុង និង សេង គ្រី ថា សេងលី មានប្រពន្ធជាជនជាតិស៊ីស ហើយថែមទាំងមានកូនពីរនាក់ (ប្រុសមួយ ស្រីមួយ) ទៀតផង ។ មិនយូរប៉ុន្មាន នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ គឹមយន បានទទួលសំបុត្រពីមិត្តភក្តិរបស់ សេងលី ប្រាប់ថា សេងលី បានចូលជាមួយក្រុមក្រហម ឬក្រុមកុម្មុយនីស្តនោះហើយ ។ ឮដំណឹងនេះភ្លាម យាយបូយ បានប្រាប់ឲ្យ គឹមយន សរសេរសំបុត្រជាបន្ទាន់ផ្ញើទៅ សេងលី ប្រាប់ថាកុំឲ្យចូលក្រុមកុម្មុយនីស្តឲ្យសោះ ។ គឹមយន បានសរសេរសំបុត្រជាច្រើនទៅបងប្រុសប៉ុន្តែគាត់និងម្តាយមិនដែលបានទទួលសំបុត្រតបវិញឡើយ ។ ដោយមិនដែលបានទទួលចម្លើយពីបងប្រុស គឹមយន ក៏សម្រេចចិត្តឈប់សរសេរសំបុត្រទៅទៀត ។ ដូច្នេះ រាល់ការទាក់ទងរវាងម្តាយ កូន និងបងប្អូនត្រូវកាត់ផ្តាច់នាចុងឆ្នាំ១៩៦៩ ។ រាល់រឿងរ៉ាវទាំងឡាយដែលកើតឡើងចំពោះបងប្រុស គឹមយន គឺដឹងតែតាមរយៈមិត្តភក្តិរបស់ សេងលី ឈ្មោះ ចៅ ប៊ុនឡុង និង វ៉ាន់ដេត រស់នៅប្រទេសបារាំង

និង សុង គ្រី រស់នៅប្រទេស អាមេរិក ប៉ុណ្ណោះ ។

តាមរយៈមិត្តភក្តិរបស់បងប្រុស គឹមយន ដឹងទៀតថា ក្រោយពីចូលក្រុមកុម្មុយនីស្ត សេងលី បានលែងលះជាមួយប្រពន្ធ ហើយបានធ្វើដំណើរទៅបន្តការសិក្សានៅប្រទេសចិន ។ នៅប្រទេសចិន សេងលី បានរៀបការជាមួយនារីជនជាតិចិននិងមានកូនប្រុសម្នាក់ ។ នៅក្នុងឆ្នាំ១៩៧៥ អ៊ីលឿត ដែលជាអ្នកភូមិវត្តគរមកប្រាប់ គឹមយន ថាប្រពន្ធរបស់ សេងលី បានមកដល់ស្រុកខ្មែរហើយ ប៉ុន្តែ សេងលី ស្នាក់នៅប្រទេសចិននៅឡើយ ។

នៅឆ្នាំ១៩៧៥ ក្រោយពេលរបបសាធារណរដ្ឋខ្មែរត្រូវបានផ្តួលរំលំ ហើយកងទ័ពខ្មែរក្រហមបានចូលកាន់កាប់ប្រទេសទាំងស្រុង គ្រួសាររបស់ គឹមយន ត្រូវបានជម្លៀសទៅរស់នៅឃុំព្រែកនរិន ។ លុះដល់ឆ្នាំ១៩៧៦ នួន ជា បានឲ្យដំណឹងតាមរយៈប្អូនប្រុសរបស់គាត់ឈ្មោះ វ៉ី ឲ្យមកប្រាប់គ្រួសាររបស់ គឹមយន ថា សេងលី បានមកដល់ស្រុកខ្មែរហើយ និងកំពុងស្នាក់នៅព្រែកអញ្ចាញ ។ គ្រាន់តែឮដំណឹងនេះភ្លាម យាយបួយ បានឲ្យកូនស្រីទៅទាក់ទង នួន ជា ដើម្បីជួយធ្វើយ៉ាងណាឲ្យ សេងលី បានត្រឡប់មកជួបម្តាយនៅបាត់ដំបងផង ។ ដោយសារ នួន ជា ជាកម្មាភិបាលជាន់ខ្ពស់របស់បក្ស គឹមយន និងប្តី បានជួបត្រឹមតែ វ៉ី ដែលជាប្អូនបង្កើតរបស់ នួន ជា និង យាយពាញ ដែលជាម្តាយរបស់ នួន ជា ប៉ុណ្ណោះ ។ គឹមយន បានសុំឲ្យអ្នកទាំងពីរជួយអង្វរ នួន ជា ឲ្យជួយក្មួយម្នាក់នេះផង ។ ក៏ប៉ុន្តែចម្លើយដែល គឹមយន ទទួលបាននោះគឺការបដិសេធរបស់ នួន ជា ដែលនិយាយថា “មិនអាចជួយបានទេ ព្រោះគេមិននិយមបក្សពួកបងប្អូនឡើយ” ។ ដោយមិនអស់ចិត្ត យាយបួយ បានឲ្យកូនគាត់ទៅជួប យាយពាញ ពីរលើកទៀតដើម្បីសុំឲ្យជួយអង្វរ នួន ជា ប៉ុន្តែចម្លើយដែលគាត់ទទួលគឺដូចពីលើកមុន ។ ក្រោយពីពេលនោះមកគ្រួសាររបស់ គឹមយន បាត់ដំណឹងរបស់ សេងលី រហូត ។

គឹមយន និយាយថា ម្តាយរបស់គាត់និង យាយពាញ មានទំនាក់ទំនងគ្នាជិតស្និទ្ធណាស់ ។ យាយពាញ តែងតែមកលេងម្តាយគាត់នៅផ្សារលើនិងហូបបាយនៅផ្ទះម្តាយគាត់ញឹកញាប់ពីព្រោះ យាយពេញ ចូលចិត្តធ្វើម្ហូបជាមួយម្តាយគាត់ ។ ទោះជាយ៉ាងណា ក៏ការរាប់អានរបស់អ្នកទាំងពីរមិនអាចមានឥទ្ធិពលដល់ នួន ជា ឡើយ ពីព្រោះថាសម្រាប់ នួន ជា ដែលចេញពីផ្ទះអស់រយៈពេលជិតហាសិបឆ្នាំ ដូច្នេះមនោសញ្ចេតនាជាមួយសាច់ញាតិរបស់គាត់ហាក់ដូចជាមានតិចតួចណាស់ ។

គឹមយន និងម្តាយ ព្រមទាំងមិត្តភក្តិរបស់ សេងលី ជាច្រើននាក់បានព្យាយាមស៊ើបសួរដំណឹង សេងលី ប៉ុន្តែមិនបានទទួលដំណឹងអ្វីសោះ ។ រហូតដល់ឆ្នាំ២០០៦ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅដល់ផ្ទះរបស់ គឹមយន នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅពេលនោះហើយដែលគ្រួសាររបស់ គឹមយន ដឹងច្បាស់ថា សេងលី ត្រូវខ្មែរក្រហមចាប់ដាក់គុកទួលស្លែង ។ ដំណឹងនេះគឺជាចម្លើយមួយដែល គឹមយន បានទន្ទឹងរង់ចាំអស់រយៈជាង៣០ឆ្នាំមកហើយ ។ ប៉ុន្តែអ្វីដែល គឹមយន មិនអស់ចិត្តនិងអាក់អន់ចិត្តនោះថាតើហេតុអ្វីបាន នួន ជា មិនអាចជួយសង្គ្រោះជីវិតក្មួយម្នាក់នេះបាន? ម្យ៉ាងទៀត គាត់ចង់ដឹងថា មូលហេតុអ្វីបានជាបងប្រុសរបស់គាត់ត្រូវខ្មែរក្រហមចាប់ខ្លួនមកដាក់មន្ទីរស-២១ ។ គឹមយន សង្ឃឹមថា សាលាក្តីខ្មែរក្រហមនឹងជួយរកយុត្តិធម៌ឲ្យបងប្រុសគាត់នៅពេលខាងមុខនេះមិនខាន ។

**ឆាយ ណារឿន**

# សេចក្តីជូនដំណឹង

យោងតាមលិខិតចុះលេខ៥៣ ឆ.ត ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមជម្រាបជូនដំណឹងដល់សាធារណជនដែលមានបំណងចង់សិក្សាស្រាវជ្រាវនិងសិក្សាស្វែងយល់អំពីខ្សែភាពយន្តឯកសារដែលផលិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានអនុញ្ញាតឲ្យចូលធ្វើការស្រាវជ្រាវនៅមជ្ឈមណ្ឌលសោតទស្សន៍កម្ពុជាបានគ្រប់ពេលម៉ោងធ្វើការដោយមិនគិតថ្លៃ ។

សូមអរគុណ!

# កុមារធន្លានខេត្រ

ក្រោយពីចង់បានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីទាមទារយុត្តិធម៌សម្រាប់ជនរងគ្រោះ ដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យឿន សាម៉ុន ចង់ឲ្យប្រទេសកម្ពុជាមានសន្តិភាពពេញលេញដើម្បីឲ្យប្រជាជនរស់នៅនិងប្រកបមុខរបរចិញ្ចឹមជីវិតដោយសុវត្ថិភាព ។ យឿន សាម៉ុន ជាជនរងគ្រោះម្នាក់ដែលមានរឿងរ៉ាវមិនខុសពីប្រជាជនដទៃទៀតដែលបានឆ្លងកាត់របបរាលពិឃាតដែរ ។ សាម៉ុន រំឭកឡើងថា ៖


យឿន សាម៉ុន

អង្គការបង្កើតសហករណ៍នៅក្នុងភូមិរបស់ខ្ញុំ បន្ទាប់មកប្រមូលទ្រព្យសម្បត្តិរបស់ប្រ-ជាជនមកដាក់ក្នុងសហករណ៍រួម ។ ខ្ញុំនៅចាំបានថានៅក្នុងឆ្នាំ១៩៧៦គឺជាពេលដែលគ្រួសារខ្ញុំជួបប្រទះការខ្វះខាតខ្លាំងជាងពេលណាទាំងអស់ ។ ខ្ញុំនិងក្រុមគ្រួសាររបស់ខ្ញុំដើរបេះត្រួយដំឡូងលាយជាមួយបបរសម្រាប់ហូប ។ នៅក្នុងអំឡុងពេលខ្វះខាតនេះប្តីរបស់ខ្ញុំប្រឹងប្រែងធ្វើការកាន់តែខ្លាំងជាងមុន ដោយមូលហេតុថា អង្គការបានចែកដំឡូងមួយគីឡូក្រាមក្នុងមួយគ្រួសារឲ្យដាំយកផល ។ មិនតែប៉ុណ្ណោះ អង្គការថែមទាំងបញ្ជាក់ថា "ខិតខំប្រឹងប្រែងដាំដំឡូងទាំងនេះទៅពេលបានផ្លែផ្កាវាជារបស់មិត្តហើយ" ។ ព្រដូច្នេះប្តីរបស់ខ្ញុំខិតខំធ្វើការគ្មានពេលសម្រាកទេ ដោយសង្ឃឹមថានឹងទទួលបានផលដំណាំទាំងនេះ ។ ពេលទំនេរពីការងារនៅការដ្ឋាន ប្តីរបស់ខ្ញុំតែងតែឆ្លៀតពេលមកដាំដំឡូង ។ ចំណែកខ្ញុំវិញ ខ្ញុំបានទៅកាត់ទងដំឡូងមកទុកដើម្បីដាក់ដាំបន្ថែមទៀត ។ ប្តីរបស់ខ្ញុំប៉ិនប្រសប់នៅក្នុងការដាំដំឡូងណាស់ ។ ដំឡូងរបស់យើងបានចុះមើមយ៉ាងច្រើន ។ យើងគាស់បានរហូតដល់ទៅ៥ ទៅ៦ បាវឆ្លូត ។ ប៉ុន្តែគួរឲ្យស្តាយការខិតខំប្រឹងប្រែងរបស់ពួកយើងបានក្លាយទៅជាអសារបង់ ។ អង្គការបានរឹបអូសដំឡូងទាំងអស់ ដោយគ្មានទុកឲ្យយើងហូបបន្តិចបន្តួចឡើយ ។ ប្តីរបស់ខ្ញុំខកចិត្តយ៉ាងខ្លាំង ។ ខ្ញុំពិតជាយល់ពីជម្រៅចិត្តរបស់ប្តីខ្ញុំណាស់នៅពេលនោះ ។

ខែមិថុនា នៅក្នុងឆ្នាំ ដដែលខ្ញុំធ្លាក់ខ្លួនឈឺជាទម្ងន់ដោយសារតែហូបមិនគ្រប់គ្រាន់ និងធ្វើការងារហួសកម្លាំង ។ អង្គការបានបញ្ជាឲ្យខ្ញុំទៅដេកប្រឡាយនៅក្បាលថ្នល់ដីក្រហម ។ បានមួយអាទិត្យ ខ្ញុំចាប់ផ្តើមឈឺគ្រុនញាក់អស់រយៈពេលមួយយប់មួយថ្ងៃ ហើយខ្ញុំសន្លប់បាត់ស្មារតីចំនួនបីដង នៅក្នុងអំឡុងពេលនោះ ។ អង្គការបានចែកថ្នាំអាចម៍ទន្សាយមកឲ្យខ្ញុំលេប ក៏ប៉ុន្តែថ្នាំនេះដូចជាមិនមានប្រសិទ្ធភាពទាល់តែសោះ ។ ប្តីរបស់ខ្ញុំបានទៅគាស់ឫសឈើនៅឯព្រៃមកដុសជាមួយទឹកអង្កររួចដាំឲ្យខ្ញុំផឹកគ្រាន់បានត្រជាក់ខ្លួន ។ ខ្ញុំយល់ថាថ្នាំឫសឈើនេះ មានប្រសិទ្ធភាពជាងថ្នាំអាចម៍ទន្សាយរបស់អង្គការ ។ ខ្ញុំដឹងខ្លួនវិញនៅវេលាម៉ោង៧ព្រឹកថ្ងៃបន្ទាប់ ក្រោយពីខ្ញុំបានផឹកថ្នាំឫសឈើនោះមក ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំត្រូវលាក់ការណ៍សម្ងាត់មិនឲ្យអង្គការដឹងថាខ្ញុំជាសះស្បើយដោយសារថ្នាំឫសឈើនិងមើមឈើដែលប្តីរបស់ខ្ញុំបានលួចទៅរកឡើយ ។ ប្រជាជនដែលមានជំងឺ ហើយសម្រាកនៅផ្ទះនឹងមិនទទួលបានរបបអាហារហូបទេ ។

អ្វីៗទាំងអស់រួមទាំងខ្ញុំផងសុទ្ធតែត្រូវថ្កោលទោស ព្រោះអង្គការចោទប្រកាន់អ្នកទាំងនោះថាមាន"ជំងឺសតិអារម្មណ៍" ។ ប៉ុន្តែខ្ញុំគិតថាប្រសិនបើខ្ញុំទៅសម្រាកនៅឯមន្ទីរពេទ្យ វាគ្មានអ្វីប្រសើរជាងសម្រាកនៅក្នុងខ្ទមកម្សត់ដែលខ្ញុំនិងប្តីខ្ញុំធ្វើដោយផ្ទាល់ដៃនិងតែងតែលិចទឹកនៅរដូវវស្សានេះឡើយ ។ ខ្ញុំដឹងថាមានមនុស្សជាច្រើនស្លាប់នៅមន្ទីរពេទ្យដោយសារតែការធ្វេសប្រហែសនិងអសមត្ថភាពរបស់ពេទ្យបដិវត្តន៍ទាំងនោះ ។ ជាក់ស្តែងអ៊ំម្នាក់ឈ្មោះ តាសោម ដែលកូនរបស់គាត់ធ្វើជាគ្រូពេទ្យខ្មែរក្រហម ។ តាសោម បានធ្លាក់ខ្លួនឈឺធ្ងន់ដោយសារតែមិនបានទទួលការយកចិត្តទុកដាក់ពីពេទ្យ សូម្បីតែកូនរបស់គាត់ដែលធ្វើការនៅមន្ទីរពេទ្យនោះក៏មិនដែលមកមើលគាត់ផង ។

ឪពុកម្តាយរបស់ខ្ញុំមានវ័យចំណាស់ទៅហើយ ។ នៅក្នុងឆ្នាំ១៩៧៦ ឪពុកខ្ញុំមានអាយុ៧៦ឆ្នាំ ប៉ុន្តែគាត់ក៏ត្រូវធ្វើការដូចប្រជាជនដទៃដែរ ។ អង្គការបានបញ្ជាឲ្យគាត់វេញខ្សែ រីឯម្តាយ

របស់ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅក្នុងកងមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាម៉ុកដែលជាមនុស្សតឹងរ៉ឹងហ្មត់ចត់ និងដាច់អហង្ការក្នុងការងារ ។ ម្តាយរបស់ខ្ញុំត្រូវធ្វើការនៅក្នុងកងស្ទូងដងនិងត្រូវទៅកាប់ទន្ទ្រានខែត្រដង ។ ប៉ុន្តែគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយចំពោះមនុស្សវ័យចំណាស់ៗ ប្រហែលឪពុកម្តាយខ្ញុំនេះ ដែលត្រូវអង្គការបញ្ជាឲ្យធ្វើការធ្ងន់ៗ ព្រោះថាសូម្បីតែក្មេងដែលមានអាយុចាប់ពី៣-៨ប្រាំឆ្នាំឡើង ក៏អង្គការអាចប្រើបានទាំងអស់ ។ កុមារទាំងនោះត្រូវអង្គការបញ្ជាឲ្យទៅដងទឹកជាមួយនឹងធុងឬប៉ោតតូចៗដែលអាចយួរបាន ។ អង្គការបានដាក់ឈ្មោះឲ្យកុមារតូចៗទាំងនេះថាជា"កុមារដីហុយ" ។ ចំណែកឯកុមារជំទង់ដែលមានអាយុច្រើនបន្តិចត្រូវបានអង្គការដាក់ឈ្មោះឲ្យថាជា"កុមារទន្ទ្រានខែត្រ" ។ លើសពីនេះទៅទៀត អង្គការបានកាត់ផ្តាច់មនោសញ្ចេតនារវាងប្តីប្រពន្ធ ឪពុកម្តាយ និងកូនព្រមទាំងសាច់ញាតិបងប្អូនជិតឆ្ងាយនិងមិត្តភក្តិទាំងអស់ ដូចជាពេលមួយដែលឪពុករបស់ខ្ញុំធ្លាក់ខ្លួនឈឺខ្លាំង ខ្ញុំនិងម្តាយរបស់ខ្ញុំបានសុំការអនុញ្ញាតដើម្បីទៅមើលគាត់ ប៉ុន្តែអង្គការបដិសេធសំណើរបស់ខ្ញុំ ហើយនិយាយថា របបនេះគឺជារបបដែលគ្មានការបែងចែកវណ្ណៈ គ្មានការរើសអើង ។ ប៉ុន្តែជាក់ស្តែងអង្គការខ្លួនឯងជាអ្នកបំពារបំពាននូវទ្រឹស្តីទាំងនេះទៅវិញ ។ ហេតុដែលខ្ញុំថា អង្គការមានការបែងចែកវណ្ណៈ ព្រោះថាប្រជាជនថ្មី និងប្រជាជនមូលដ្ឋានត្រូវចាត់នៅក្នុងប្រភេទមនុស្សផ្សេងគ្នានិងរស់នៅដាច់ដោយឡែកពីគ្នា ។ លើសពីនេះទៀត អង្គការបានប្រកាសថា "អង្គការគឺជាឪពុកម្តាយនិងជាអ្នកមើលការខុសត្រូវថែរក្សាពួកយើងទាំងអស់គ្នា" ។ ប៉ុន្តែអង្គការបែរជាបំបរបង់អ្នកដែលមានជំងឺឲ្យទៅរស់នៅដាច់ដោយឡែកពីអ្នកដទៃ ដោយមិនទទួលបាននូវការថែរក្សានិងការព្យាបាលពីអង្គការឡើយ ។ ករណីដូច តាឡូតូ (តារាកំប្លែង) ប្រពន្ធគាត់ និងតាភួង ដែលមានជំងឺឃ្លង់ត្រូវអង្គការបញ្ជូនទៅរស់នៅភ្នំចចក ឋិតក្នុងព្រៃដាច់ស្រយាលពីភូមិរបស់ប្រជាជន ។

នៅក្នុងឆ្នាំ១៩៧៧ គឺជាពេលដែលមានការសម្លាប់យ៉ាងច្រើនបំផុត ។ ខ្ញុំឃើញមនុស្សជាច្រើនត្រូវបានកងទ័ពខ្មែរក្រហមបណ្តើរពីទិសខាងកើតទៅទាំងខ្សែៗ ។ ប្រជាជនខ្លះជាប់ច្រវាក់ ហើយត្រូវអង្គការបង្ខំឲ្យរែកដី ។ ឃើញទិដ្ឋភាពបែបនោះធ្វើឲ្យខ្ញុំចេះតែព្រួយបារម្ភក្នុងចិត្តថា តើខ្ញុំអាចធ្លាក់ទៅក្នុងស្ថានភាពដូចអ្នកនោះដែរឬទេ? មិនយូរប៉ុន្មានអារម្មណ៍ភ័យខ្លាចទាំងនេះបានធ្លាក់មកលើក្រុមគ្រួសារខ្ញុំប្រាកដមែន ។ ថ្ងៃមួយ អ្នកភូមិម្នាក់បានមកខ្សឹបប្រាប់ខ្ញុំថាប្តីរបស់ខ្ញុំត្រូវកងទ័ពខ្មែរក្រហមនាំយកទៅសម្លាប់ហើយ ។ ខ្ញុំស្ទើរតែមិនជឿនូវពាក្យសម្តីដែលអ្នកភូមិម្នាក់នេះប្រាប់ខ្ញុំទេ ។ ភ្លាមនោះខ្ញុំស្រាប់តែខ្ញុំនឹកឃើញពីការខិតខំប្រឹងប្រែងរបស់ប្តីខ្ញុំក្នុងការដាំដំឡូងជាលក្ខណៈគ្រួសារ ប៉ុន្តែមិនបានបរិភោគសូម្បីតែបន្តិច ។ ខ្ញុំនឹកឃើញពេលដែលខ្ញុំនិងគាត់សង់ខ្ទមតូចមួយដែលអង្គការចាត់តាំងឲ្យធ្វើ ។ ទោះបីជា ខ្ទមនោះតូចរហែកធ្លុះធ្លាយនិងលិចទឹកនាពេលរដូវវស្សាក៏ដោយ ក៏ខ្ញុំនៅតែគិតថាវាមានភាពកក់ក្តៅណាស់ ។ ខ្ញុំនឹកឃើញពេលដែលខ្ញុំធ្លាក់ខ្លួនឈឺ គាត់ខំស្វះស្វែងរកថ្នាំឫសឈើ មើមឈើមកដាំឲ្យខ្ញុំផឹក ។ ដោយសារតែសេចក្តីស្រឡាញ់និងការយកចិត្តទុកដាក់ពីប្តីរបស់ខ្ញុំ ទើបធ្វើឲ្យខ្ញុំជាសះស្បើយពីគ្រុនក្តៅនេះយ៉ាងឆាប់រហ័ស ។ ខ្ញុំនឹកឃើញពេលដែលប្តីខ្ញុំ កូនៗខ្ញុំ និងខ្ញុំកំពុងតែរស់នៅជាមួយគ្នាយ៉ាងសប្បាយរីករាយមុនពេលដែលពួកខ្មែរក្រហមមកយាយីសុភមង្គលនិងជីវិតរបស់ក្រុមគ្រួសាររបស់ខ្ញុំឲ្យវិនាស ។

រឿងគួររន្ធត់មួយបានកើតឡើង គឺមួយសប្តាហ៍ក្រោយពីការសម្លាប់ប្តីខ្ញុំមក អ្នកភូមិម្នាក់ដែលប្រាប់ខ្ញុំពីការស្លាប់របស់ប្តីខ្ញុំ គាត់ក៏ត្រូវកងទ័ពខ្មែរក្រហមចាប់យកទៅសម្លាប់ដែរ ។ ហេតុការណ៍នេះ ធ្វើឲ្យខ្ញុំជឿថាប្តីរបស់ខ្ញុំពិតជាមិនអាចនៅរស់រានមានជីវិតបានឡើយ ។ ខ្ញុំដឹងប្រាកដថា ពួកកងទ័ពអាវខ្មៅនេះគឺជាឃាតករដៃឆើតសម្លាប់ប្តីរបស់ខ្ញុំមែន ។

សាម៉ុន បានបន្តថា "ទោះបីជាខ្ញុំស្គាល់អ្នកសម្លាប់ប្តីរបស់ខ្ញុំ ក៏ខ្ញុំមិនចង់សងសឹកដែរ ។ ខ្ញុំគិតថា ឲ្យតែជនដៃដល់ទាំងនោះខិតខំធ្វើអំពើល្អនោះគាត់សប្បាយចិត្តហើយ ។ ខ្ញុំចង់ឲ្យខ្មែរចេះរួបរួមគ្នានិងនាំគ្នា កសាងជាតិទៅមុខទៀត ចៀសវាងកុំឲ្យខ្មែរបែកបាក់សាមគ្គីគ្នាដែលជាមូលហេតុនៃវិនាសកម្មផ្សេងៗ ។ ខ្ញុំឧស្សាហ៍និយាយរឿងរ៉ាវទាក់ទិននឹងរបបកម្ពុជាប្រជាធិបតេយ្យនេះប្រាប់កូនទាំងពីររបស់ខ្ញុំនិងក្មួយៗខ្ញុំណាស់ ។ ក្មួយៗយកចិត្តទុកដាក់ស្តាប់រឿងដែលកើតឡើងនៅសម័យនោះជាទីបំផុត ។ មានពេលមួយ ក្មួយៗរបស់ខ្ញុំបានឃើញការចាក់ផ្សាយនៅក្នុងទូរទស្សន៍

អំពីទិដ្ឋភាពទាំងនោះ ហើយវាបានសួរថា "តើអ្វីដែលកើតឡើងពិតដូច្នេះមែនឬ?" ខ្ញុំបន្ថែមថាអ្វីដែលកើតឡើង វាអាក្រក់ជាងអ្វីដែលបានបញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍ទៅទៀត ។ ក្មួយៗខ្ញុំនាំគ្នាយំ ។ ចំណែកកូនរបស់ខ្ញុំប្រកែកមិនចូលរួមធ្វើបាតុកម្មនានាជាមួយនឹងមិត្តភក្តិឡើយ ព្រោះពួកគេធ្លាប់លំបាកនៅក្នុងសម័យខ្មែរក្រហមឆ្អែតឆ្អន់ហើយ ។ កូនខ្ញុំប្រាប់មិត្តភក្តិទាំងនោះថា ពួកគេនៅចាំច្បាស់ពីព្រឹត្តិការណ៍ទាំងអស់ ពួកគេចង់បានតែសន្តិភាពប៉ុណ្ណោះ ។

**នន ឧត្តតារា**

# បន្ទត់ដូចអ្នកជាប់ទោស


ស៊ាយ សុខ ឆ្នាំ២០០៦

បន្ទត់ដូចជាប់ទោស នេះជាសម្តីរបស់ ស៊ាយ សុខ ដែលជាអតីតយុទ្ធជនម្នាក់បម្រើការនៅសម័យខ្មែរក្រហម មិនខុសពីជនរងគ្រោះដទៃទៀតដែលបានជួបការលំបាក ហូបមិនឆ្អែត និងធ្វើការហួសកម្លាំងដែរ ។ ទោះបីជាការផ្សារនឿយហត់យ៉ាងណាក៏គាត់ពុំមានសិទ្ធិក្នុងការដើរហើរដោយសេរីបានឡើយ ទាំងនេះប្រៀបដូចជា សុខ ជាប់នៅក្នុងពន្ធនាគារដែរ ។ ភាគច្រើនយុវជនដែលបានចូលធ្វើបដិវត្តន៍កម្រនឹងបានទៅលេងផ្ទះណាស់ ហើយបើបានទៅលេងផ្ទះក៏មិនអាចស្នាក់នៅយូរបានដែរ ។

ដោយមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុនៅឆ្នាំ១៩៧០ សុខ ត្រូវបានភៀសខ្លួនមករស់នៅភូមិជំពូង ឃុំគោករកាស ស្រុកអង្គរជុំ ខេត្តសៀមរាប រហូតដល់ឆ្នាំ១៩៧១ ។ កាលណោះនៅភូមិរបស់ សុខ ចាប់ផ្តើមមានសហករណ៍បណ្តើរៗនិងប្រើប្រាស់របស់របររួម ដូច្នេះយុវជនយុវនារីត្រូវតែចូលបម្រើកងទ័ព ។ សុខ បម្រើបដិវត្តន៍ក្រោមការលួងលោមពីគណៈឃុំឈ្មោះ វ៉ាន់ ដែលបានបញ្ចុះបញ្ចូលថា ឲ្យតែចូលធ្វើទាហានក្មេងៗនឹងឲ្យកាន់កាំភ្លើងម្នាក់មួយដើម ។ សុខ ឮដូច្នេះក៏សម្រេចចិត្តទៅជាមួយក្មេងៗជាច្រើនដែលនៅក្នុងឃុំជាមួយ ។ ក្មេងៗទាំងអស់នោះត្រូវគណៈឃុំបញ្ជូនឲ្យទៅធ្វើជាកងទ័ពខ្មែរក្រហមនៅបន្ទាយជ្រាយល្ហួន ។ អ្នកចូលដំបូង បានទទួលកាំភ្លើងម្នាក់មួយដើមតាមការសន្យារបស់គណៈឃុំ ប៉ុន្តែអ្នកទាំងនោះមិនបានហាត់រៀនពីក្បួនយុទ្ធសាស្ត្រទេ ។ កងទ័ពទាំងអស់ត្រូវចែកជាជួរទៅតាមការចាត់តាំងរបស់ប្រធានកងពលនៅតំបន់៤ក្នុងខេត្តសៀមរាប ។ នៅទីនោះរយៈពេល៤ខែ សុខ ត្រូវបញ្ជូនមកភ្នំប្រុសភ្នំស្រីខេត្តកំពង់ចាម ដើម្បីត្រៀមហាត់ហ្វឹកហ្វឺនជាបន្តទៀត ។ សុខ ជាអ្នកដាំបាយពូតឲ្យកងទ័ពដែលនៅត្រៀមសមរភូមិ និងធ្វើជាកងការពារបន្ទាយនៅក្នុងភូមិភាគ៣០៤ពេលដែលកងទ័ពទាំងអស់ឡើងទៅសមរភូមិ ។ សុខ មិនសូវបានចេញទៅប្រយុទ្ធជាមួយសត្រូវទេ ។ ពេលប្រយុទ្ធគ្នាម្តងៗមានកងទ័ពស្លាប់នឹងរបួសជាច្រើន អ្នកដែលរបួសត្រូវបានបញ្ជូនទៅមន្ទីរពេទ្យភូមិភាគ៣០៤ ស្វាយទាប ចម្ការកៅស៊ូ ។ សុខ ប្រចាំការនៅភ្នំប្រុសភ្នំស្រីរយៈពេលមួយឆ្នាំ ដោយសារតែនឹកឪពុកម្តាយពេក គាត់ក៏លួចរត់មកផ្ទះជាមួយ មួន ជាអ្នកស្រុកនៅភូមិទន្លេស និងរស់នៅឃុំដូចគ្នា ។ នៅតាមផ្លូវអ្នកទាំងពីរត្រូវបានកងទ័ពខ្មែរក្រហមតាមចាប់ខ្លួនបញ្ជូនមកអង្គភាពវិញ ។ សុខ បានលួចរត់ជាលើកទី២ ហើយធ្វើដំណើររហូតដល់ស្រុកសាន់គរ ខេត្តកំពង់ធំ ប៉ុន្តែត្រូវអង្គការតាមចាប់ខ្លួនបានដដែល ហើយយកមកដាក់ឃុំឃាំងឲ្យនៅជាមួយសាកសពដែលតម្កល់ក្នុងមឈូសនៅវត្តប្រាសាទ ។ នៅទីនោះ កងទ័ពខ្មែរក្រហមបានចោទសួរគាត់ថា "ឯងរត់ចោលជួរបម្រុងក្បត់ឬ?" ។ មួយសប្តាហ៍ក្រោយមក សុខ និង មួន បានលួចរត់ទៀត ហើយធ្វើដំណើរទៅដល់ខេត្តសៀមរាប ។ សុខ រស់នៅទីនោះបានប្រហែល៤ខែទៅ៥ខែ ក៏ត្រូវអង្គភាពចាស់តាមចាប់ខ្លួនបាន ។ លើកនេះ សុខ ត្រូវបានបញ្ជូនយកទៅដាក់នៅវត្តដងទង់នៅត្រើយម្ខាងទន្លេព្រែកក្តាម ។ សុខ មកនៅក្នុងកងយោធាវរសេនាធំលេខ១៨ វរសេនាតូចលេខ៥១ កងពលលេខ១១ ។ ប្រធានវរសេនាធំឈ្មោះ តាម៉ន ប្រធានវរសេនាតូច ឈ្មោះ សឿន ហើយប្រធានកងពលលេខ១១ ឈ្មោះ តាអឿន ។ នៅវត្តដងទង់បម្រើទ័ពបានមួយឆ្នាំ សុខ ឡើង

សមរភូមិបីដង ហើយត្រូវរបួសដេកនៅមន្ទីរពេទ្យក្រសាំងផ្អែម ៣-៣ នៅខែមេសា ឆ្នាំ១៩៧៤ ។ សុខ ត្រូវរបួសក្នុងខណៈពេលដែលគាត់កំពុងលីក្តារទៅធ្វើលេណដ្ឋាននៅព្រែកញ្ញ ហើយអំបែងគ្រាប់៦០ បានធ្លាក់មកចំក្បាលរបស់គាត់ ។ សុខ សម្រាកនៅមន្ទីរពេទ្យរយៈពេលជិតមួយឆ្នាំរហូតដល់ភ្នំពេញត្រូវកងទ័ពខ្មែរក្រហមដណ្តើមអំណាចទាំងស្រុង ។ សុខ បានដើររកអង្គភាពរបស់ខ្លួននៅវត្តភ្នំត្រង់សាលាជាន់ខ្ពស់សូវៀត ។ នៅទីនោះរយៈពេល ៤ទៅ ៥ខែ ទើប សុខ ត្រូវបានប្រមូលជាអង្គភាពឡើងវិញ ។

សុខ ត្រូវបានចាត់តាំងឲ្យដើរបោសសម្អាតនៅតាមវិថីនានានៅជុំវិញទីក្រុងចាប់ពីម៉ោង៨ព្រឹកដល់ម៉ោង ១ ឬម៉ោង ២ រសៀល ។ ក្រោយមកអង្គការប្រកាសឲ្យកងទ័ពទាំងអស់ចូលរៀនវគ្គហ្វឹកហ្វឺននយោបាយរយៈពេល២ខែក្រោមការបង្ហាត់បង្រៀនពី តាអឿន និងអ្នកធំមួយចំនួនទៀត ។ នៅខែឧសភា ឬមិថុនា សុខ ត្រូវបានរំសាយពីកងទ័ពនិងបញ្ជូនទៅលត់ដំការងារនៅទំនប់កប់ស្រូវ ត្រឡោកបែក និងវត្តអង្គក្រពើ ។ សុខ មិនដឹងពីមូលហេតុច្បាស់ពីការរំសាយកងទ័ពភូមិភាគឧត្តរនិងកងទ័ពមជ្ឈិមទេ គាត់គ្រាន់តែដឹងថា មានកងទ័ពថ្មីដែលមកពីខាងភូមិភាគនិរតីមកជំនួសកងទ័ពរបស់គាត់វិញ ។ នៅទីនោះ សុខ ត្រូវបានចាត់តាំងឲ្យធ្វើស្រែនិងនៅស្តារពើក ។ សុខ និយាយថា «ពេលចុះបារពើកម្តងៗ ខ្ញុំត្រូវទាកខាំពេញខ្លួន ហើយហូបចុកមិនដែលគ្រប់គ្រាន់ទេ» ។ គាត់ធ្វើការនេះរហូតដល់ចុងឆ្នាំ១៩៧៦ ។

ដើមឆ្នាំ១៩៧៧ សុខ និងកងទ័ពដែលត្រូវរំសាយទាំងអស់ត្រូវបានបញ្ជូនទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ។ អង្គការបានឲ្យ សុខ ធ្វើជាអ្នកវាយថ្ម រៀបថ្មក្រាលព្រលានយន្តហោះ យប់ឡើងដេរស្លឹកត្នោតបាំងរោងសម្រាប់រៀបថ្មសាលាព្រលាន ។ សុខ ដឹងត្រឹមតែថា ព្រលានយន្តហោះថ្មីនេះ សម្រាប់ដាក់យន្តហោះខ្នាតធំជាព្រលានយន្តហោះយោធាអន្តរជាតិ ។ ការហូបចុករបស់គាត់នៅទីនោះមិនគ្រប់គ្រាន់ទេ គាត់ហូបបាយបានតែមួយដុំប៉ុណ្ណោះ ។ សុខ និយាយថា គាត់ធ្វើការនៅព្រលានដូចជាអ្នកជាប់ទោសអ៊ីចឹង ពេលគាត់ដើរទៅណាក៏មិនបាន រកថ្នាំជក់ក៏មិនបាន ហ៊ានតែដើរបាត់១ម៉ោងឬ២ម៉ោងក៏មិនបាន យប់ឡើងបើទំនេរដើរបាត់គេតាមដានទៀត បើតាមដានតែ២ទៅ៣ដងនឹងបាត់ខ្លួនដោយមិនដឹងមូលហេតុ ។ ធ្វើការនៅព្រលានយន្តហោះពិតជាមានការពិបាកណាស់បើប្រៀបធៀបទៅនឹងការងារធ្វើស្រែនៅទំនប់កប់ស្រូវ ដែលនៅទីនោះគាត់អាចដើររកអាហារហូបបានខ្លះ មិនដូចនៅព្រលានយន្តហោះទេ សូម្បីតែដំឡូងអ្នកស្រុកក៏គាត់មិនហ៊ានដកហូបដែរព្រោះខ្លាចបាត់ខ្លួន ។ នៅអំឡុងពេលនោះ សុខ បានឃើញជនជាតិចិន៤នាក់ចុះមកមើលការខុសត្រូវនៅកន្លែងគាត់ធ្វើការដោយគ្រាន់តែបញ្ជាពួកគាត់ឲ្យធ្វើនេះធ្វើនោះប៉ុណ្ណោះ ហើយប្រាប់ទៅមេធំៗដូចជា ប្រធានវរៈប្រធានកងធំឲ្យត្រួតពិនិត្យមើលកូនចៅតូចតាចធ្វើខុសអីខ្លះ ។ ជនជាតិចិននោះ មានសម្លៀកបំពាក់ពណ៌ខៀវ ។ សុខ បានត្រឹមតែលួចមើលមុខចិនទាំងនោះម្តងម្កាលប៉ុណ្ណោះ ព្រោះបើតាមទាន់គាត់នឹងត្រូវកាត់បន្ថយរបបអាហារ៤នាក់ដោយហូបបាយមួយកំប៉ុងកន្លះ បន្ថយនៅសល់មួយកំប៉ុង ។ បើនិយាយពីសម្លវិញ មានតែគមត្នោតស្ងោជាមួយត្រី «ត្រីនោះមិនដាក់ច្រើនទេ គ្នា៤នាក់បានត្រីតែ២កង់ទៅ៣កង់ប៉ុណ្ណោះ សម្លច្រើនតែទឹកនិងបន្លែលាយជាមួយដំឡូង» ។ សុខ ធ្លាប់សុំប្រធានក្រុមរបស់គាត់មកលេងផ្ទះ ប៉ុន្តែ ប្រធានក្រុមមិនអនុញ្ញាត ហើយថែមទាំងពោលពាក្យថា «សុំអី ផ្ទះម៉ែឪបងប្អូន អង្គការភូមិឃុំគេគ្រោបគ្រាប់បាយទឹកសមរម្យហើយ មិនបាច់ទៅគិតគូរអីទេ ខំតែកសាងខ្លួនឯងទៅ» ។ យុទ្ធជនខ្លះប្រុងនាំគ្នាលួចរត់ ប៉ុន្តែមិនដឹងរត់ទៅតាមច្រកណា ដូច្នេះក៏នៅធ្វើព្រលានយន្តហោះគ្រប់ៗគ្នាទៅ ។ សុខ ធ្វើការនៅទីនោះរហូតដល់ខ្មែរក្រហមដួលរលំ ។ «ខ្ញុំធ្វើព្រលានយន្តហោះ រហូតទាល់តែបែកភ្នំពេញពេលគ្រាប់ផ្លោងមកដល់កំពង់ឆ្នាំង ខ្ញុំមកផ្ទះភ្លាម ខ្ញុំដើររហូតមកដល់ផ្ទះ» ។

សុខ មិនបានដឹងពីការសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហមឡើយ គាត់បានដឹងនៅពេលដែលគាត់ធ្វើដំណើរត្រឡប់មកផ្ទះវិញនៅឆ្នាំ១៩៨១ ។ នៅតាមផ្លូវចូលអមលាំងគាត់បានឃើញមនុស្សស្លាប់ ក្បាលខ្មោចអណ្តែតតាមស្ទឹងនិងក្លិនស្អុយអសោច ។ ឪពុកម្តាយរបស់ សុខ ស្ទើរតែមិនជឿថា គាត់នៅមានជីវិតរស់ ពីព្រោះគាត់បាត់ដំណឹងអស់រយៈពេលជាង៣ឆ្នាំរហូតដល់ឪពុកម្តាយរបស់គាត់បានធ្វើបុណ្យឧទ្ទិសកុសលឲ្យគាត់ទៀតផង ។

សព្វថ្ងៃ សុខ អាយុ៤៩ឆ្នាំ មុខរបរធ្វើជាកម្មករ ។ ប្រពន្ធ

របស់គាត់ឈ្មោះ ធួន ធន់ និងមានកូន៥នាក់ ប្រុស៤នាក់ស្រី១ ។ សុខ យល់ថា តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់គួរតែធ្វើទៅតាមផ្លូវច្បាប់ «កាត់ទោសអ៊ីចឹង កាត់ឲ្យល្អទៅតាមផ្លូវច្បាប់ដែលយើងកាត់ទោសអ្នកដែលធ្វើខុស ធ្វើអាក្រក់ត្រូវកាត់ទោស» ។ សុខ ធ្លាប់និយាយពីប្រវត្តិរបស់ខ្លួនប្រាប់កូនៗគាត់ ប៉ុន្តែគាត់មិនប្រាកដថា តើកូនរបស់គាត់ជឿបានប៉ុនណាទេ គាត់សង្ឃឹមថាកូនរបស់គាត់នឹងជឿនូវអ្វីដែលគាត់និយាយពីព្រោះអ្នកស្រុកអ្នកភូមិតែងនិយាយរឿងនេះដូចគាត់និយាយដែរ ។ **ហ៊ិន សុធានី**

# ទួលស្លែងរំឭករឿងអតីតកាល

នេះគឺដំណើរទស្សនកិច្ចលើកទី១៣ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជននិងមេឃុំនៅតាមបណ្តាខេត្ត-ក្រុងឲ្យចូលរួមទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតបឹងជើងឯក និងទៅទស្សនាអគារនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅទីក្រុងភ្នំពេញ ។ ថ្ងៃដំបូងគឺដំណើរទស្សនានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ នៅក្នុងចំណោមមេឃុំប្រមាណជា៥០០នាក់ ស្ត្រីវ័យកណ្តាលម្នាក់ឈ្មោះ ប៉ាង សុផាណ្ណា ដែលបច្ចុប្បន្នមានតួនាទីជាមេឃុំព្រែកដាច់ខេត្តកណ្តាល ។ អ្នកស្រីមានចំណាប់អារម្មណ៍យ៉ាងខ្លាំងនៅទីធ្លាខាងមុខអគារ«បេ» ដែលធ្វើឲ្យគាត់នឹកឃើញដល់អតីតកាលរបស់គាត់កន្លងផុតទៅអស់រយៈពេលជាង៣០ឆ្នាំមកហើយ ។


ប៉ាង សុផាណ្ណា

សុផាណ្ណា បានរៀបរាប់ថា កាលពីជំនាន់សង្គមរាស្ត្រនិយម ទីកន្លែងដែលគាត់កំពុងទស្សនានេះ គឺជាវិទ្យាល័យពញាយ៉ាត ។ នៅពេលសេនាប្រមុខ លន់ នល់ ឡើងគ្រប់គ្រងអំណាច វិទ្យាល័យពញាយ៉ាត ត្រូវបានកែប្រែទៅជាវិទ្យាល័យទួលស្វាយព្រៃវិញ ដោយសារ«ពញាយ៉ាត»ជាឈ្មោះស្តេច ។ គ្រប់អគារនីមួយៗរបស់វិទ្យាល័យនេះមានដាក់ឈ្មោះដូចជា ÷ អគារ«អា» អគារ«បេ» អគារ«សេ» និងអគារ«ដេ» ។ នៅខាងមុខអគារ«បេ» គឺជាកន្លែងហាត់កីឡា ហើយនៅទីនោះមានបង្គោលពីរជាកន្លែងដែលគាត់ឡើងខ្សែពួរនៅពេលហាត់កីឡាម្តងៗ ។ រីឯផ្លូវជាប់របងនៅមុខអគារ«បេ» គឺជាកន្លែងសម្រាប់ប្រឡងរត់ ។ ចំណែករបងសាលាមិនមានជាំងសង្កសីទេ គឺមានតែរបងដែក ហើយនៅជាប់របងសាលាគឺជាកន្លែងដាក់កង់-ម៉ូតូរបស់សិស្ស ។ សាលារៀននេះមានបង្រៀនសិស្សចាប់ផ្តើមពីថ្នាក់ទី៦រហូតដល់ថ្នាក់ទី១(ទីបញ្ចប់) សុផាណ្ណា ជាសិស្សម្នាក់ដែលបានរៀននៅទីនោះតាំងពីឆ្នាំ១៩៧០ រហូតដល់ខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។

មុនពេលបែកទីក្រុងភ្នំពេញ សភាពការណ៍ជ្រួលច្របល់ គ្រូនិងសិស្សខ្លះត្រូវអាក់ខានទៅសាលារៀន ហើយនាយកសាលាប្រកាសឲ្យសិស្សដែលមករៀនឲ្យត្រឡប់ទៅផ្ទះវិញដើម្បីជួបជុំគ្រួសារ និងរង់ចាំដល់ពេលណាសភាពការណ៍ប្រសើរទើបចូលរៀនវិញ ។ ប៉ុន្តែសភាពការណ៍កាន់តែតឹងតែងឡើងរហូតដល់ខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញពីទីក្រុងទៅកាន់ទីជនបទ ។

ក្រោយពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ សាលារៀនទួលស្វាយព្រៃ ត្រូវបានប្រែក្លាយទៅជាគុកមួយដ៏ធំនៅទីក្រុងភ្នំពេញដែលមានឈ្មោះថា មន្ទីរគុកទួលស្លែង ហៅ«ស-២១» ។ មន្ទីរស-២១ ឋិតនៅក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យយ៉ាងដិតដល់ពីប្រធានសន្តិសុខគុកឈ្មោះ កាំង ហ្គិចអៀវ ។ ស-២១ មានតួនាទីយ៉ាងសំខាន់នៅក្នុងការឃុំឃាំងអ្នកទោសដែលមកពីគ្រប់បណ្តាអង្គភាពនិងតំបន់នានា ។ អ្នកទោសដែលត្រូវបញ្ជូនមកទីនេះ គឺជាអ្នកទោសដែលត្រូវបានចោទប្រកាន់ថាជាខ្សែ សេ.អ៊ី.អា, ជនក្បត់បដិវត្តន៍ និងមានបំណងប្រឆាំងនឹងអង្គការ ។ អ្នកទោសមួយចំនួនត្រូវអង្គការចាប់ខ្លួនតាមរយៈអ្នកទោសឆ្លើយដាក់ថាបានចូលរួមធ្វើសកម្មភាពជាមួយ(ចាប់តាមខ្សែបណ្តាញ) ។ ស-២១ មានសាខាពីរទៀតគឺ មន្ទីរស-២១គ ស្ថិតនៅក្រុងតាខ្មៅ និងមន្ទីរស-២១ឃ ស្ថិតនៅក្នុងស្រុកដង្កោខាងលិចទីក្រុងភ្នំពេញ ។

នៅឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ សុផាណ្ណា ត្រូវខ្មែរក្រហមជម្លៀសចេញទីក្រុងភ្នំពេញទៅរស់នៅខេត្តព្រៃវែង (ភូមិភាគបូព៌) ។ ដោយសារផ្ទះរបស់គាត់នៅទួលទំពូង ទើបខ្មែរក្រហមបញ្ជាឲ្យចេញទៅតាមផ្លូវអ្នកលឿងឆ្ពោះទៅកាន់ខេត្តព្រៃវែង ។ នៅទីនោះ អង្គការចាត់តាំងឲ្យធ្វើការងារនៅក្នុងកងចល័តលើកប្រឡាយ ស្ទូង ស្រូវនៅក្នុងសហករណ៍ ។ ការហូបចុកនៅទីនោះមានការលំបាក ដោយហូបរួមនៅក្នុងសហករណ៍និងពេលខ្លះលួចដំឡូងហូប ។

នៅឆ្នាំ១៩៧៦ ឪពុកម្តាយរបស់គាត់ត្រូវស្លាប់ដោយសារកង្វះអាហារបរិភោគនិងឈឺគ្មានថ្នាំសង្កូវ ហើយបងប្រុសរបស់ សុផាណ្ណា ឈ្មោះ សុផល ស្លាប់ដោយសារជម្លៀសបែកគ្នានៅខេត្តព្រៃវែង ។

នៅឆ្នាំ១៩៧៨ អង្គការបានបញ្ជូនក្រុមគ្រួសាររបស់គាត់និងអ្នកដែលរស់នៅខេត្តព្រៃវែងទាំងអស់ទៅរស់នៅខេត្តពោធិ៍សាត់ ព្រោះខ្មែរក្រហមចោទប្រកាន់ថា "ពួកបូព៌ាគឺជាពួកក្បត់អង្គការ" ។ សុផាណ្ណា បញ្ជាក់ថា កាលនោះមានអ្នកក្បត់បដិវត្តន៍មែន ដោយមានការប្រមូលផ្តុំគ្នារត់ទៅទឹកដីវៀតណាម ហើយដឹកនាំកងទ័ពត្រឡប់មកវាយបដិវត្តន៍វិញ ចំណែកឯប្រជាជន១៧មេសា ក៏ជាមុខសញ្ញារបស់ខ្មែរក្រហមដែរ ។ គោលការណ៍របស់អង្គការដែលជម្លៀសប្រជាជនទៅខេត្តពោធិសាត់គឺដើម្បីសម្លាប់ ។ មានអ្នកខ្លះមិនទាន់ទៅដល់ខេត្តពោធិ៍សាត់ផងក៏ស្លាប់នៅតាមផ្លូវដោយគ្រោះថ្នាក់នៅពេលធ្វើដំណើរ និងអ្នកខ្លះទៀតត្រូវខ្មែរក្រហមយកទៅសម្លាប់នៅទីនោះ ។ នៅខេត្តពោធិសាត់ អង្គការចាត់តាំងឲ្យលើកដី កាប់គាស់ដំបូក និងចល័តពីកន្លែងមួយទៅកន្លែងមួយទៀត ។ ការរស់នៅទីនោះ កាន់តែលំបាកឡើងៗទាំងការហូបចុកនិងការងារប្រចាំថ្ងៃ ហើយត្រូវរស់នៅទាំងការភិតភ័យ ។ ជារៀងរាល់ថ្ងៃ មនុស្សចេះតែបាត់ខ្លួនជាបន្តបន្ទាប់ ។ អ្នកដែលមានបងប្អូនរត់ចោលជួរកងទ័ព ត្រូវអង្គការយកគ្រួសារអ្នកទាំងនោះទៅសម្លាប់ចោល ។ នៅចុងឆ្នាំ១៩៧៨ អង្គការមានផែនការយកមនុស្សទៅសម្លាប់បន្តទៀត ។ បងថ្លៃប្រុស និងកូនក្មួយរបស់ សុផាណ្ណា ត្រូវអង្គការយកទៅសម្លាប់ចោល ដោយចោទប្រកាន់ថា គាត់ជាអតីតទាហាន លន់ នល់ ។ ចំណែកបងស្រីក្រោយពីប្តីនិងកូនត្រូវខ្មែរក្រហមយកទៅសម្លាប់ គាត់ពិបាកចិត្តរហូតដល់វិកលចរិតមកទល់នឹងសព្វថ្ងៃនេះ ។ ក្រុមការងាររបស់ សុផាណ្ណា ត្រូវចាត់តាំងឲ្យជញ្ជូនអង្ករយកទៅភ្នំ ហើយឈ្មោះរបស់គាត់ត្រូវបញ្ជូនទៅតាមក្រោយ ប៉ុន្តែបើសិនពេលនោះកងទ័ពវៀតណាមចូលមកវាយរំដោះមិនទាន់ពេលវេលាទេម៉្លេះសមគាត់ត្រូវស្លាប់នៅពេលនោះដែរហើយ ។

ក្រោយឆ្នាំ១៩៧៩ សុផាណ្ណា បានវិលត្រឡប់ចូលទីក្រុងភ្នំពេញវិញ ហើយសំដៅទៅរកផ្ទះសម្បែងនៅទួលទំពូង ប៉ុន្តែផ្ទះរបស់គាត់ត្រូវបំផ្លាញខ្ទេចខ្ទីអស់ បន្សល់ទុកតែសាកសពមនុស្សនិងសំរាម ។ សុផាណ្ណា ក៏សម្រេចចិត្តវិលត្រឡប់ទៅស្រុកកំណើតខាងម្តាយនៅឯខេត្តកណ្តាលវិញ ។ ក៏ប៉ុន្តែ មុនពេលធ្វើដំណើរទៅស្រុកកំណើត សុផាណ្ណា បានឆៀងចូលមើលសាលារៀនដែលគាត់ធ្លាប់រៀន ។ ពេលចូលដល់បរិវេណសាលា គាត់បានឃើញសាកសពមនុស្ស និងឈាមនៅស្រស់ៗដែលមើលទៅសាកសពទាំងនោះទើបតែស្លាប់ថ្មីៗ ។ សុផាណ្ណា មានអារម្មណ៍ក្តុកក្តួលក្នុងចិត្តពេលដែលឃើញទិដ្ឋភាពសាលារៀនរបស់គាត់ក្លាយទៅជាអគារគុកនិងកន្លែងធ្វើទារុណកម្មដ៏សាហាវ



មេឃុំទស្សនាអគារឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (ស-២១)

បែបនេះ ។

ដំណើរទស្សនកិច្ចនេះវាជាលើកទី៣ហើយ ដែល សុផាណ្ណា បានមកទស្សនានៅសារមន្ទីរនេះ ។ រាល់លើកដែលគាត់ទៅឃើញទិដ្ឋភាពនៅទីនោះ បានធ្វើឲ្យគាត់នឹកឃើញដល់អនុស្សាវរីយ៍យុវភាពរបស់គាត់ដែលធ្លាប់រៀននិងរត់លេងជាមួយមិត្តភក្តិនៅក្នុងទីធ្លាសាលា ។ បច្ចុប្បន្នសាលារៀន បានក្លាយទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មួយដែលមានផ្នូរសាកសពរបស់ជនរងគ្រោះ១៤នាក់ដែលត្រូវបានសម្លាប់នៅពេលចុងក្រោយគេមុនពេលរបបខ្មែរក្រហមដួលរលំ ហើយបទបញ្ជាផ្ទៃក្នុងនិងវិន័យសន្តិបាលរបស់ខ្មែរក្រហមនៅតែដាក់តាំងនៅតាមផ្លូវទៅកាន់អគារ ។ លើសពីនេះទៅទៀតនៅក្នុងបន្ទប់នីមួយៗនៃអគារមានដាក់តាំងនូវរូបថតមេដឹកនាំនិងរូបជនរងគ្រោះរាប់ពាន់សន្លឹកឧបករណ៍ធ្វើទារុណកម្មជាច្រើនប្រភេទ និងស្លាកស្នាមបាក់បែកដែលបន្សល់ទុកពីរបបនោះ ។ មន្ទីរនេះកំពុងបើកចំហទទួលភ្ញៀវទេសចរគ្រប់ប្រភេទទាំងជាតិនិងអន្តរជាតិដើម្បីទស្សនាស្វែងយល់អំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងអំឡុងពេលកាន់អំណាចរបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

សុផាណ្ណា យល់ថា អ្នកដែលបង្កឲ្យមានអំពើកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម មិនគួរអត់ឱននិងលើកលែងទោសឲ្យជាដាច់ខាត ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគួរតែកាត់ទោសប្រហារជីវិតអ្នកទាំងនោះ ឬធ្វើទារុណកម្មឲ្យឈឺចាប់ដូចដែលវាបានអនុវត្តមកលើប្រជាជនខ្មែរដែរ ។ សុផាណ្ណា សំណូមពរឲ្យកាត់ទោសតែមេដឹកនាំថ្នាក់កំពូលពីព្រោះគាត់យល់ថា ជនដែលដល់ថ្នាក់ក្រោមពិបាកនឹងស្រាវជ្រាវរកឲ្យឃើញថា តើអ្នកណាដែលបានប្រព្រឹត្តអំពើនោះណាស់? ពេលចុះទៅមូលដ្ឋានម្តងៗ គាត់តែងតែបានឮប្រជាជនជជែកគ្នាអំពីតុលាការកាត់ទោសខ្មែរក្រហម ។ សុផាណ្ណា សង្ឃឹមថា ពេលត្រឡប់ទៅផ្ទះវិញ គាត់នឹងប្រាប់ញាតិមិត្តជិតខាងនិងប្រជាជននៅក្នុងឃុំរបស់គាត់ឲ្យបានដឹងអំពីអ្វីដែលគាត់បានមកឃើញនិងបានឮនៅក្នុងដំណើរទស្សនកិច្ចនេះ ។

**ប៊ុន ពីរ័ន**

# ដំណើរទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញលើកទីបីរបស់មេឃុំ

ដំណើរទស្សនកិច្ចលើកទីបីរបស់មេឃុំនៃមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងតែបោះជំហានទៅមុខក្នុងការផ្សព្វផ្សាយព័ត៌មាន និងស្វែងយល់អំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបច្ចុប្បន្នមានរយៈពេលប្រាំមួយខែហើយ ។ ដំណើរទស្សនកិច្ចមេឃុំទាំងពីរលើកកាលពីឆ្នាំ២០០៦ និងដំណើរការទស្សនកិច្ចលើកទីបីកាលពីខែមករាថ្មីៗនេះ មានមេឃុំចំនួន១៣៦២នាក់ដែលមកពីឃុំចំនួន ១៧០០ ទូទាំងប្រទេសកម្ពុជា ដែលបានទស្សនាទីតាំងប្រល័យពូជសាសន៍សំខាន់ៗនិងអគារតុលាការ ។ អង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានគេស្គាល់ជាទូទៅថាសាលាក្តីខ្មែរក្រហមនោះ បានចំណាយពេលចរចារអស់មួយទសវត្សរ៍ក្នុងការធ្វើឲ្យតុលាការនេះលេចចេញជាផ្លែផ្កា ។ បន្ទាប់ពីការពិភាក្សាជាច្រើនលើកត្រូវបានដោះស្រាយ និងអគារតុលាការបម្រុះត្រូវបានផ្លាស់ទៅនៅទីតាំងបញ្ជាការកងទ័ព (អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ) នៅតាមបណ្តោយផ្លូវជាតិលេខ៤ តម្រូវការចាំបាច់ ដើម្បីផ្សព្វផ្សាយព័ត៌មាន និងធ្វើឲ្យតុលាការមានលក្ខណៈស្របច្បាប់ជាធរមានយ៉ាងពេញលេញ ។

ទោះបីជាយ៉ាងណាក៏ដោយ អស់រយៈពេលជាច្រើនឆ្នាំមុនពេលដែលការិយាល័យ និងអគារតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញចាប់លេចចេញរូបរាងឡើង មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងប្រមែប្រមូល ស្រាវជ្រាវ រៀបចំឯកសារ និងវិភាគប្រភពឯកសារដំបូងដែលទាក់ទិននឹងរបបកម្ពុជាប្រជាធិបតេយ្យដែលចាប់ផ្តើមឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបញ្ចប់អស់រយៈពេលបីឆ្នាំ ប្រាំបីខែនិងម្ភៃថ្ងៃ ។ ប្រភពឯកសារសំខាន់ៗទាំងនេះ ជាឯកសាររស់បានមកពីអ្នករស់រានមានជីវិតនៃរបបប្រល័យពូជសាសន៍ ។ ដោយហេតុនេះ អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ដោយយល់អំពីព្រឹត្តិការណ៍និងដោយមានក្តីសង្ឃឹមយ៉ាងខ្លាំង នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ បានបង្កើតគម្រោងឯកសាររស់ដែលជាគម្រោងធំមួយ គឺ

ការធ្វើឲ្យដំណើរទស្សនកិច្ចនេះលេចចេញផ្លែផ្កា ។ អ្នកស្រុកអ្នកភូមិ មេឃុំ បុរសស្ត្រី សិស្សនិស្សិត គ្រូបង្រៀន ព្រះសង្ឃ ជូនជីខ្មែរអ៊ីស្លាម និងមេដឹកនាំសហគមន៍ខ្មែរអ៊ីស្លាម មានការយល់ដឹងច្រើនអំពីសាលាក្តីខ្មែរក្រហមនិងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ការប្រើប្រាស់ទូរលេខនេះដែលរួមផ្សំជាមួយនឹងគម្រោងផ្សព្វផ្សាយនិងគម្រោងជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងកិច្ចការរបស់អង្គការមិនមែនរដ្ឋាភិបាលដទៃទៀតនៅក្នុងប្រទេសកម្ពុជា មានភាពគួរឲ្យជឿទុកចិត្តក្នុងការបង្ហាញថា ប្រជាជនខ្មែរជាច្រើនយល់ដឹងអំពីតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។

ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីតុលាការនេះលេចចេញជារូបរាង ការបង្កើនកម្រិតយល់ដឹងរបស់ប្រជាជនខ្មែរស្តីពីតុលាការ ជាភារកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលជាអ្នកទទួលខុសត្រូវ ។ ដូចដែលលោកនាយក ឆាំង យុ និងអ្នកដទៃទៀត បាននិងកំពុងឃ្លាំមើល អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិនិងអន្តរជាតិមួយចំនួនដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា បាននិងកំពុងតែផ្លាស់ប្តូរនិងកែប្រែសកម្មភាពអង្គការរបស់ខ្លួនដោយមានការព្រួយបារម្ភអំពីបញ្ហាដែលតុលាការទើបតែរីកធំធាត់នេះបង្កើតឡើង ។ មិនថាអារម្មណ៍របស់ប្រជាជនខ្មែរ សេចក្តីត្រូវការចាំបាច់នូវវេទិកា ឬការចង់ឲ្យមានការចូលរួម ឬអ្វីផ្សេងទៀតនោះទេ សហគមន៍ អង្គការមិនមែនរដ្ឋាភិបាលដ៏រឹងមាំមួយ ដែលឈានមុខគេនិងមានការយល់ដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញកំពុងតែធានារ៉ាប់រងកិច្ចការជាច្រើនទៀតដែលមិនមាននៅក្នុងប្រទេសកម្ពុជា ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន រិះគន់យ៉ាងខ្លាំងចំពោះអង្គជំនុំជម្រះវិសាមញ្ញ ក៏ប៉ុន្តែនៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញទទួលមតិរិះគន់នេះ ភាគីទាំងពីរត្រូវសហការគ្នាផ្សព្វផ្សាយព័ត៌មានទៅដល់ប្រជាជនកម្ពុជា ។

ដំណើរទស្សនកិច្ចមេឃុំនៅខែមករាកន្លងទៅថ្មីៗនេះ ឆ្លុះបញ្ចាំងអំពីជោគជ័យនិងចង្អុលបង្ហាញអំពីភាពទន់ខ្សោយក្នុងលក្ខណៈដែលមិនអាចរំពឹងទុកជាមុន ។ រយៈពេលពីរថ្ងៃនេះមេឃុំទាំងអស់មកពីខេត្តក្រុងចំនួន២៤ទូទាំងប្រទេសកម្ពុជាលើកលែងតែខេត្តស្ទឹងត្រែងនិងទីក្រុងភ្នំពេញ ។ ដំណើរទស្សនាកិច្ចនេះបានសម្រេចនូវគោលដៅសំខាន់ក្នុងការផ្តល់ឲ្យអ្នកដែលរស់រានមានជីវិតនៃអំពើប្រល័យពូជសាសន៍ ជាពិសេស ជនរងគ្រោះនូវសំឡេងគាំទ្រដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងអំឡុងពេលនៃទស្សនកិច្ចនេះ មានការធ្វើបទសម្ភាសន៍ មានការត្អូញត្អែរពីសំណាក់មេឃុំមួយចំនួន ការខកខានចូលរួមក្នុងពិធីបង្សុកូលតាមការបានគ្រោងទុក និងព័ត៌មានភ្លាមៗទាក់ទិននឹងអវត្តមានរបស់លោក រាជ សម្បត្តិ ។ ដំណើរទស្សនកិច្ចនេះ បានផ្តល់បទពិសោធន៍ច្រើនដល់ភាគីទាំងបីដែលពាក់ព័ន្ធដោយរាប់បញ្ចូលទាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។


មេឃុំទស្សនាបន្ទប់គុកតូចៗ នៅក្នុងមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ជាមួយនឹងឡានក្រុងជាក់បក់រំភើយៗ ថ្ងៃទស្សនកិច្ចដំបូង ចាប់ផ្តើមឡើងនៅមុនម៉ោង៧ព្រឹក មេឃុំបានឡើងជិះរថយន្តរបស់ខ្លួន និងបានចាកចេញឆ្ពោះទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ មេឃុំចំនួន៤៣៨នាក់ដើរទស្សនារូបថតនៅក្នុងគុកទួលស្លែង«ស-២១» និងបាននឹកឃើញដល់អារម្មណ៍ដែលដក់ជាប់ក្នុងចិត្តនូវ«ម៉ាស៊ីនសម្លាប់»សម្ងាត់របស់មេដឹកនាំបក្សកុម្មុយនីស្ត

កម្ពុជា ប៉ុល ពត ។ បច្ចុប្បន្នគ្មានការលាក់កំបាំងទៀតឡើយ រូបថតទាំងនេះដែលដាក់តាំងបង្ហាញនៅក្នុងគុកទួលស្លែង (អគារនីមួយៗមាន ឈ្មោះ អេ, ប៊ី, ស៊ី និងឌី) នៅនឹងថ្កល់និងជូនកាលធ្វើឲ្យអ្នកទស្សនាដែលសម្លឹងមើលរូបថតទាំងនេះមានអារម្មណ៍ភ័យខ្លាច ។ ដោយជាប់ជាមួយនូវកូនសៀវភៅនិងប៊ិចសម្រាប់កត់ត្រាមេឃុំបានកត់ត្រាចំណាំនៅពេលដែលពួកគាត់សម្លឹងមើលរូបថតអ្នក-ទោស បន្ទប់គុក ខ្នោះជើង និងគំនរលលាដ៍ក្បាលរបស់ជនរង-គ្រោះ ។ ផ្ទាំងរូបភាពដែលដាក់បង្ហាញបានទាក់ទាញអារម្មណ៍អ្នកចូលទស្សនា គឺផ្ទាំងក្តារដែលមានទំហំស្មើជញ្ជាំងដែលឈ្មោះថា "វិន័យសន្តិបាល" ។ មេឃុំជាង៥០នាក់ បានឈរផ្តុំគ្នានៅខាងមុខផ្ទាំងក្តារនេះ កត់ត្រានូវខ្លឹមវិន័យសន្តិបាលដែលមានសរសេរជាបីភាសា (ភាសាខ្មែរ អង់គ្លេស និងបារាំង) ។

បុគ្គលិកផ្នែកកុនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្ភាសន៍មេឃុំនៅសារមន្ទីរទួលស្លែង ។ ពួកគាត់ទាំងអស់ចាប់អារម្មណ៍នឹងការសម្ភាសន៍ដោយមិនគិតថា មានអារម្មណ៍ភ័យខ្លាច ឬមានជំនឿទុកចិត្តប៉ុនណា ឬនិយាយច្រើនប៉ុនណានោះឡើយ ។ ក៏ប៉ុន្តែ មានការសម្ភាសន៍មួយជាពិសេស ដែលបង្ហាញពីការចាប់អារម្មណ៍ជាងបទសម្ភាសន៍ផ្សេងៗទៀត ។

គ្រាន់តែនឹកស្រមៃមួយភ្លែកថា លោកអ្នកវិលត្រឡប់មកកាន់វិទ្យាល័យចាស់របស់លោកអ្នកវិញ និងឃើញថាវិទ្យាល័យនេះបានផ្លាស់ប្តូររូបរាងទៅជាទីកន្លែងសួរចម្លើយនិងទីកន្លែងសម្លាប់ដ៏អាថ៌កំបាំងយ៉ាងឃោរឃៅ ។ ការមិនជឿ គឺជាចម្លើយមិនអស់សេចក្តី ហើយការតក់ស្លុតជាអារម្មណ៍របស់អ្នក ។ ក្នុងវ័យ៨៩ឆ្នាំ លោកស្រី ប៉ាង សុផាណ្ណា បានវិលត្រឡប់មកកាន់ទីកន្លែងនេះវិញដែលគាត់ធ្លាប់បានសិក្សានៅទីនោះអស់រយៈពេលជាងបួនឆ្នាំ ។ បច្ចុប្បន្នលោកស្រី ជាមេឃុំព្រែកដាច់ ខេត្តកណ្តាល និងជាមេឃុំស្ត្រីម្នាក់ក្នុងចំណោមមេឃុំស្ត្រី២៨នាក់ ដែលបានចូលរួមដំណើរទស្សនកិច្ចនេះ ។ លោកស្រី បានមានប្រសាសន៍ថាអក្សរ អេ, ប៊ី, ស៊ី និង ឌី នៃអគារនៅគុកទួលស្លែង "ស-២១" ត្រូវបានប្រើប្រាស់ចាប់តាំងពីសម័យ លន់ នល់ នាដើមទសវត្សរ៍ឆ្នាំ១៩៧០មកម្ល៉េះ ។ លោកស្រី ក៏បានមានប្រសាសន៍ប្រាប់យើងថា អគារខ្ពស់សង់អំពីឈើដែលស្ថិតនៅខាងមុខអគារ"ស៊ី" ក៏មានតាំងពីសម័យ លន់ នល់ ដែរ ។ កាលពីមុន ខ្សែពួរដែលចងនឹងធ្នឹមឈើត្រូវសិស្សសាលាប្រើប្រាស់សម្រាប់ឡើងហាត់កីឡាជាប្រចាំរបស់ពួកគេ ។ ក៏ប៉ុន្តែ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យខ្សែពួរទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីព្យួរកនិងធ្វើទារុណកម្មអ្នកទោសទៅវិញ ។ លោកស្រី រៀននៅថ្នាក់ទី៦ នៅវិទ្យាល័យទួលស្វាយព្រៃ និងបានសិក្សានៅទីនោះរហូតដល់ឆ្នាំ១៩៧៥ ។ នៅក្នុងឆ្នាំ១៩៧៥ លោកស្រី នៅខ្វះតែមួយឆ្នាំទៀតនឹងត្រូវបញ្ចប់ការសិក្សានៅវិទ្យាល័យនេះ ។ ជាអកុសល ភាពចលាចលនៅទីក្រុងភ្នំពេញបានឈានចូលដល់កម្រិតមួយ ដែលមិនអាចធានាបាននូវសុវត្ថិភាពនិងការធ្វើដំណើរទៅសាលារៀន ហើយនៅពេលចុងក្រោយខ្មែរក្រហមបានចូលដល់ទីក្រុងភ្នំពេញ ធ្វើឲ្យលោកស្រីមិនអាចវិលត្រឡប់ទៅបន្តការសិក្សាបានទៀតឡើយ ។ ក្នុងរយៈពេលតែពីរថ្ងៃភូមិកំណើតរបស់លោកស្រីនៅទីក្រុងភ្នំពេញ ឃើញតែផ្ទះ អគារនិងហាងលក់ដូរផ្សេងៗត្រូវបោះបង់ចោល អគារខ្លះនៅសល់តែពាក់កណ្តាល និងខ្លះខ្ទេចខ្ទីរាយប៉ាយនៅលើដងវិថីនានា ។ ការជម្លៀសប្រជាជនដ៏ធំសម្បើមដោយថ្មើរជើង បានប្រព្រឹត្តទៅអស់រយៈពេលជាច្រើន


មេឃុំស្តាប់កំពុងស្តាប់បទឧទ្ទេសនាមរបស់ឯកឧត្តម ម៉ោញ សាផាន នៅក្នុងសាលប្រជុំសកលវិទ្យាល័យភូមិន្ទភ្នំពេញ២

សប្តាហ៍ ។ ទីក្រុងធំទាំងមូលប្រែជាស្ងាត់ជ្រងំ ។

នៅឆ្នាំ១៩៧៥ លោកស្រី ប៉ាង ត្រូវបានជម្លៀសទៅខេត្តព្រៃវែង និងក្រោយមកទៀតត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ ដែលការជម្លៀសនេះគឺជាផ្នែកមួយនៃផែនការធំពីររបស់ខ្មែរក្រហម ។ លោកស្រី បានបកស្រាយប្រាប់បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កញ្ញា ប៉ាង ពីរីន ថាចំពោះអ្នកដែលត្រូវបានជម្លៀសទៅខេត្តព្រៃវែង ត្រូវខ្មែរក្រហមចោទប្រកាន់ថា "ជាបណ្តាញក្បត់" ។ អ្នកដែលត្រូវបានរកឃើញ (ប្រុសស្រី) ថា មានពាក់ព័ន្ធក្នុងបណ្តាញនេះត្រូវយកទៅសម្លាប់ចោល ហើយចំពោះអ្នកដែលត្រូវបានរកឃើញថា គ្មានទំនាក់ទំនងនឹងបណ្តាញនេះត្រូវជម្លៀសទៅខេត្តពោធិ៍សាត់ ។ នៅក្នុងភូមិភាគទាំងពីរនេះ

ក្រហមនិងវៀតណាម កងទ័ពវៀតណាមបានវាយយ៉ាងខ្លាំងក្លាចូលក្នុងទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៩ ហើយបានដណ្តើមជ័យជម្នះពីកងទ័ពខ្មែរក្រហម លោកស្រី ប៉ាង ត្រឡប់មកកាន់ផ្ទះនៅទីក្រុងភ្នំពេញវិញ ។ ពុំមានពាក្យអ្វីដែលអាចបញ្ជាក់អំពីអារម្មណ៍របស់គាត់បានឡើយនៅពេលដែលលោកស្រីវិលត្រឡប់មកកាន់ផ្ទះរបស់គាត់តែម្នាក់ឯង ។ ជាជីវិតឯកោ លោកស្រីបានបកស្រាយប្រាប់បុគ្គលិករបស់មជ្ឈមណ្ឌលថា នៅពេលដែលគាត់បានមកដល់ទីក្រុងភ្នំពេញ គាត់គិតថាជីវិតគាត់គ្មានន័យអ្វីទៀតឡើយនិងគិតថាមិនដឹងគាត់ត្រូវបន្តជីវិតរស់នៅយ៉ាងដូចម្តេចឡើយ ។ ក្រោយមក លោកស្រីបានមកទស្សនាអតីតវិទ្យាល័យរបស់គាត់ដែលបានក្លាយជាអគារសួរចម្លើយ និងសម្លាប់នៅ



សកម្មភាពមេឃុំនៅមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


មេឃុំនៅក្នុងពិធីបង្សុកូល នៅវាលពិឃាតបឹងជើងឯក

លោកស្រីបានជួបការលំបាកដូចជា ការជីកប្រឡាយ លើកដី និងច្រូតកាត់ ។ ទោះបីជាយ៉ាងណាក៏ដោយ លោកស្រីបានបកស្រាយថា ការងារនៅក្នុងខេត្តព្រៃវែងងាយស្រួលជាងការងារនៅក្នុងខេត្តពោធិ៍សាត់ ។ នៅក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ សមាជិកគ្រួសាររបស់គាត់ត្រូវស្លាប់ទាំងអស់ ។ ឪពុកម្តាយរបស់គាត់ស្លាប់ដោយការអត់អាហារនិងជំងឺ ហើយបងប្អូនទាំងបួនរបស់គាត់ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ចោល ខ្លះស្លាប់នៅខេត្តព្រៃវែង និងអ្នកដែលនៅសល់ស្លាប់នៅក្នុងខេត្តពោធិ៍សាត់ បន្សល់ទុកឲ្យលោកស្រីក្លាយជាក្មេងកំព្រា ។

នៅពេលដែលជម្លោះកើនឡើងនៅតាមព្រំដែនរវាងខ្មែរ

ក្នុងសម័យខ្មែរក្រហម ។ លោកស្រីបានឃើញវិទ្យាល័យជាលើកដំបូង បន្ទាប់ពីអគារទាំងនោះត្រូវបានបោះបង់ចោលអស់ជាច្រើនឆ្នាំ លោកស្រីគ្មានឃើញអ្វីក្រៅពីលលាដ៍ក្បាលមនុស្សនិងក្លិនស្អុយយ៉ាងខ្លាំងនេះឡើយ ។ ភ្លាមៗនោះគាត់ស្រាប់តែនឹកឃើញដល់ថ្ងៃដែលគាត់បានសិក្សានៅទីនោះជាមួយនឹងមិត្តភក្តិនិងការរស់នៅជាមួយគ្រួសាររបស់គាត់ ។

ដោយបានឆ្លងកាត់របបខ្មែរក្រហម ជាក់ស្តែងណាស់ថាលោកស្រីមានទស្សនៈផ្ទាល់ថាមិនអាចអត់ឱនមេដឹកនាំខ្មែរ-ក្រហមបានឡើយ គឺត្រូវតែកាត់ទោសមេដឹកនាំខ្មែរក្រហមតាមច្បាប់ ។ លោកស្រីចង់ឲ្យមានការដាក់ទោសប្រហារជីវិត ប៉ុន្តែ

លោកស្រីមិនដឹងថាច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាពុំមានចែងពីទោសប្រហារជីវិតទេ។ លោកស្រី ជឿជាក់ថាក្មេងជំនាន់ក្រោយត្រូវតែដឹងពីទុក្ខលំបាកនិងបទពិសោធន៍ស្ទើរស្លាប់ដែលលោកស្រីនិងអ្នកដទៃទៀតបានឆ្លងកាត់ក្នុងរបបបីឆ្នាំប្រាំបីខែម្ភៃថ្ងៃ។ ប្រជាជនខ្មែរទាំងអស់ដែលបានឆ្លងកាត់ការប្រល័យពូជសាសន៍ដឹងយ៉ាងច្បាស់អំពីពេលវេលានៃអំពើនោះ ពីព្រោះចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនខ្មែរភាគច្រើនបានប្រឹងប្រែងតស៊ូដើម្បីរស់។ លោកស្រីសំណូមពរអង្គជំនុំជម្រះវិសាមញ្ញដាក់ទណ្ឌកម្មមេដឹកនាំទាំងនោះឲ្យបានឆាប់និងម៉ឺងម៉ាត់។ ធ្វើបែបនេះ លោកស្រីជឿថា មេដឹកនាំខ្មែរក្រហមដែលនៅសេសសល់ ឬអ្នកផ្សេងៗទៀត ដែលជាប់ទាក់ទិននឹងអំពើទាំងនោះនឹងមិនប្រព្រឹត្តនូវអំពើឃោរឃៅដទៃទៀតមកលើប្រជាជនខ្មែរទៀតឡើយ។

នៅឯសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ មេឃុំម្នាក់បានសំណូមពរទៅឯកឧត្តម ម៉ោញ សាផាន សមាជិករដ្ឋសភាជាតិកម្ពុជា ឲ្យមានការដាក់ទោសឲ្យបានឆាប់រហ័សនិងម៉ឺងម៉ាត់។ នៅក្នុងបន្ទប់ប្រជុំនៃមហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រ ស្ត្រីមេឃុំម្នាក់បានអំពាវនាវសុំឲ្យមានការជំនុំជម្រះក្តីប្រកបដោយផ្ទៃក្នា ដើម្បីដាក់ទោសឲ្យសមស្របនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង។ បញ្ហាផ្សេងៗទៀត ដែលលើកឡើងនៅក្នុងអង្គប្រជុំ នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា លោក វ៉ាន់ថាន់ ពៅដារ៉ា បានលើកយកចំណុចខ្លះមកបង្ហាញរួមមាន តើមេដឹកនាំខ្មែរណាខ្លះនឹងត្រូវកាត់ទោស (មេដឹកនាំជាន់ខ្ពស់ដែលស្លាប់និងមេដឹកនាំដែលនៅរស់) តើនឹងត្រូវដោះស្រាយដូចម្តេច ក្នុងករណីដែលចៅក្រមបដិសេធ តើហេតុអ្វីបានជាមានការអូសបន្លាយពេលវេលាយូរបែបនេះក្នុងការបង្កើតសាលាក្តីខ្មែរក្រហម តើត្រូវរៀបចំនីតិវិធីសំណុំរឿងនិងការលើកលែងទោស អៀង សារី យ៉ាងដូចម្តេច។ បរិយាកាសបន្ទប់ប្រជុំពោរពេញទៅដោយក្តីសង្ឃឹម។

វគ្គទីបីនៃដំណើរទស្សនកិច្ចរបស់មេឃុំ គឺការទស្សនាវាលពិឃាតបឹងជើងឯក ដែលអ្នកទោសស-២១ត្រូវខ្មែរក្រហមដឹកយកមកសម្លាប់ចោល។ នៅទីនោះ អ្នកចូលរួមបានដើរទស្សនាស្តូបតម្កល់អដ្ឋិធាតុដែលមានដាក់តាំងបង្ហាញលលាដ៍ក្បាលរបស់ជនរងគ្រោះ។ ដោយធ្វើដំណើរឆ្ពោះទៅខាងស្តាំដៃនៃស្តូបនេះ មានផ្លាកសញ្ញាដែលរៀបរាប់អំពីវិធីដែលអ្នកទោសត្រូវបានសម្លាប់។ ផ្លាកដែលពុំសូវគួរឲ្យកត់សម្គាល់ គឺផ្លាកដែលស្ថិតនៅទំនាបដីដែលអ្នកទោសត្រូវបានកប់បន្ទាប់ពីការសម្លាប់។





មេឃុំនៅក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ពិធីបុណ្យប្រពៃណីតាមបែបព្រះពុទ្ធសាសនា "បង្សុកូល" ត្រូវបានរៀបចំធ្វើឡើងដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅទីនោះ។ ព្រះសង្ឃប្រាំអង្គនិងដូនជីជាច្រើននាក់បាននិមន្តគង់និងអង្គុយលើកម្រាលព្រំពណ៌ក្រហមលើកាំជណ្តើរថ្នាក់លើនៃស្តូប។ ព្រះសង្ឃនិងដូនជីបានសូត្ររួមគ្នា ហើយមេឃុំជាង៤០០នាក់អង្គុយខាងក្រោមលើកម្រាលស្មៅរង់ចាំស្តាប់និង

ចូលរួមឧទ្ទិសកុសលដល់អ្នកស្លាប់ដែរ ។ បន្ទាប់ពីមេឃុំបានចាក ចេញពីជើងឯកទើបកម្មវិធីសូត្រមួយទៀតបានចាប់ផ្តើមឡើង ។ អ្នកដែលចូលរួមស្តាប់ការសូត្រនេះ មានតែបុគ្គលិកនិងប្រធាន អង្គការសិល្បៈរស់ខ្មែរ និងអ្នកសម្របសម្រួល បុគ្គលិក និងក្រុម កុននៃមជ្ឈមណ្ឌលឯកសារកម្ពុជាប៉ុណ្ណោះ ។

ព្រះអាទិត្យហៀបអស្តង្គត បញ្ចេញពន្លឺពណ៌លឿងទឹកក្រូច បានលិចចូលទៅក្នុងផ្ទៃមេឃពណ៌ខៀវ ។ ខ្យល់ត្រជាក់នាល្ងាចនោះ បានធ្វើឲ្យអ្នកដែលចូលរួមស្តាប់មានអារម្មណ៍ស្រងូតស្រងាត់ និង ស្ងប់ស្ងាត់ ។ គ្រូសូត្រ ព្រុំ បានសូត្រច្បាស់ៗដែលបង្ហាញនូវ សេចក្តីសោកសៅនិងទុក្ខព្រួយដើម្បីគោរពវិញ្ញាណក្ខន្ធអ្នកដែល


មេឃុំនៅក្នុងសាលប្រជុំសកវិទ្យាល័យភូមិន្ទភ្នំពេញ២


មេឃុំធ្វើទស្សកិច្ចនៅមន្ទីរប្រល័យពូជសាសន៍ទួល

បានស្លាប់នៅវាលពិឃាតបឹងជើងឯក ។ ប៉ុន្តែបរិយាកាសនេះក្លាយ ទៅជាស្នាមញញឹមទៅវិញបន្ទាប់ពីពិធីសូត្រត្រូវបានបញ្ចប់ ។

ដំណើរទស្សនកិច្ចពីរថ្ងៃនេះបានបង្ហាញបញ្ហាតិចតួចដែល ភាគីអង្គជំនុំជម្រះវិសាមញ្ញប្រឈមមុខដោះស្រាយ ។ មជ្ឈ-មណ្ឌលឯកសារកម្ពុជាបានផ្តល់ព័ត៌មានទៅការិយាល័យផ្នែកកិច្ចការសាធារណៈអំពីដំណើរទស្សនកិច្ចនេះតាំងពីមួយខែមុន ក៏ប៉ុន្តែ ក្នុងដំណើរទស្សនកិច្ចមុនៗ មន្ត្រីនាំពាក្យរបស់អង្គជំនុំជម្រះ វិសាមញ្ញលោក រាជ សម្បត្តិ មានវត្តមាននៅក្នុងបន្ទប់សវនាការ គ្រប់ដំណើរទស្សនកិច្ច ទទួលស្វាគមន៍មេឃុំ បានផ្តល់ប្រឹក្សាមេឃុំ អំពីបញ្ហាដែលទាក់ទិនតុលាការ និងឆ្លើយនឹងសំណួររបស់មេឃុំ ។ ប្រការដែលរឹតតែសំខាន់ទៀតទៀតនោះគឺធ្វើឲ្យមេឃុំយល់ថា សំឡេងរបស់ពួកគាត់ត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាផ្តល់តម្លៃ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមកោតសរសើរ លោក រាជ សម្បត្តិ ចំពោះចរិតលក្ខណៈសមរម្យនិងលទ្ធភាពក្នុង ការពន្យល់បញ្ហាស្មុគស្មាញរបស់តុលាការដោយប្រើប្រាស់ពាក្យ សាមញ្ញតាមបែបអាចារ្យដើម្បីឲ្យអ្នកចូលរួមងាយយល់ ។ ក៏ ប៉ុន្តែក្នុងដំណើរទស្សនកិច្ចរបស់មេឃុំលើកនេះលោក រាជ សម្បត្តិ អវត្តមានដោយសារមានកិច្ចការចាំបាច់ផ្ទាល់ខ្លួន ។

នៅក្នុងគ្រប់ដំណើរទស្សនកិច្ចតម្រូវឲ្យមានមន្ត្រីអង្គជំនុំ ជម្រះវិសាមញ្ញពីររូបយ៉ាងតិច ពីព្រោះអ្នកដែលចូលរួមដំណើរ ទស្សនកិច្ចនេះត្រូវបានចាត់ទុកថា ជាមនុស្សសំខាន់ដែលអាចពាំ នាំព័ត៌មានអំពីតុលាការនេះទៅប្រាប់ប្រជាជននៅតាមមូលដ្ឋាន របស់គាត់ ។ ក្នុងចំណោមអ្នកទាំងនោះ មួយរូបត្រូវតែជាលោក រាជ សម្បត្តិ ដើម្បីជួយសម្រួលបញ្ហាស្មុគស្មាញទាក់ទិននឹងការ បកប្រែ និងការសង្ខេបការបកប្រែជាដើម ។

ការប្រជុំនៅពេលនោះ គឺមានតែលោកស្រី ចារីស និងអ្នក បកប្រែម្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះ ។ អ្នកបកប្រែម្នាក់ នោះមិនបានណែនាំខ្លួនឬបង្ហាញអំពីមុខនាទីរបស់ខ្លួននិងស្វាគមន៍ មេឃុំ (ដូចដែលបានធ្វើជាច្រើនលើកនៅក្នុងដំណើរទស្សនកិច្ច មុនៗ) ឡើយ ។ ដោយយល់អំពីស្ថានភាពនៅពេលនោះ លោកស្រី

ចារីស បានពន្យល់បកស្រាយជាភាសាអង់គ្លេសនិងបកប្រែដោយអ្នកបកប្រែអង្គជំនុំជម្រះវិសាមញ្ញថា កិច្ចប្រជុំគណៈកម្មាធិការវិធានផ្ទៃក្នុងបានកើតឡើងដំណាលគ្នា ហើយបុគ្គលិកអង្គជំនុំជម្រះវិសាមញ្ញទាំងអស់ពិតជាមានការមមាញឹកនឹងការងាររបស់ខ្លួន ។ តាមទ្រឹស្តី ពុំចាំបាច់តម្រូវឲ្យមានមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញយ៉ាងតិចពីររូបបង្ហាញខ្លួននៅចំពោះមុខក្រុមមេឃុំជាង៤០០នាក់នោះទេ ក៏ប៉ុន្តែ តាមគោលការណ៍ប្រការបែបនេះបន្តជាបញ្ហាជាច្រើនទៀតវិញ ។

ស្ថានភាពដ៏ចម្លែកមួយទៀតបានកើតឡើងនៅអគារតុលាការនោះ សន្តិសុខម្នាក់ដែលកំពុងឈរនៅខាងក្រៅបន្ទប់បានប្រាប់

នោះបានធ្វើឲ្យបុគ្គលិកមជ្ឈមណ្ឌលមានការភ្ញាក់ផ្អើល ពីព្រោះក្នុងដំណើរទស្សនកិច្ចពីមុនៗមកបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្លាប់បានឮព័ត៌មានបែបនេះទេ ។

ព័ត៌មានដែលចុះផ្សាយលើទំព័រកាសែតអន្តរជាតិជាច្រើនបានចុះផ្សាយទិដ្ឋភាពដែលមិនចាប់អារម្មណ៍នៃដំណើរវិវឌ្ឍអង្គជំនុំជម្រះវិសាមញ្ញ ។ ពិតប្រាកដណាស់ ការខ្វែងគំនិតគ្នារវាងភាគីកម្ពុជានិងអង្គការសហប្រជាជាតិ បានបន្តបង្កើតតុលាការនេះ ហើយប្រហែលជាយើងមិនរំពឹងថាភាគីទាំងពីរនឹងនៅតែបន្តការខ្វែងគំនិតគ្នានោះឡើយ ។ ពាក្យចចាមអារ៉ាមក្នុងស្រុកដំបូងបានបង្ហាញអំពើពុករលួយដែលកើតចេញពីភាគីកម្ពុជា ។


ស្ងួន


មេឃុំនៅអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកសោកស្តាយដែលលោកបានដឹងអំពីព័ត៌មានដំណើរទស្សនកិច្ចរបស់មេឃុំប្រមាណជាង៤០០នាក់មកទស្សនាអគារតុលាការឆាប់ពេក ដោយហេតុនេះបានជាលោកពុំមានពេលគ្រប់គ្រាន់ដើម្បីរៀបចំ ។ សន្តិសុខបានសំណូមពរឲ្យមជ្ឈមណ្ឌលគួរតែផ្តល់ព័ត៌មានឲ្យគាត់បានដឹងមុន ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានឆ្លើយតបវិញថា ខាងមជ្ឈមណ្ឌលបានផ្តល់ដំណឹងទៅការិយាល័យផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញ តាំងពីរបីសប្តាហ៍មុនម៉្លេះ ។ ទោះជាថាតើសន្តិសុខនោះត្រូវអង្គជំនុំជម្រះវិសាមញ្ញផ្តល់ព័ត៌មានឬក៏មិនបានផ្តល់យ៉ាងណាក៏ដោយ ការអត្ថាធិប្បាយរបស់សន្តិសុខ

ពាក្យចចាមអារ៉ាមនេះ ក៏បានបង្ហាញពីកង្វះតួនាទីច្បាស់លាស់របស់បុគ្គលិកអង្គជំនុំជម្រះវិសាមញ្ញមួយចំនួនដែលបានអង្គុយនៅស្ងៀមនិងគិតអំពីកិច្ចការបន្ទាប់របស់ខ្លួន ។ ប្រជាពលរដ្ឋខ្មែរជាច្រើនមិនពេញចិត្តនឹងតុលាការដែលបានចំណាយពេលវេលាយ៉ាងយូរក្នុងការបង្កើតតុលាការនេះទេ ។ ការរង់ចាំរបស់ប្រជាពលរដ្ឋខ្មែររហូតមកទល់ពេលនេះ មានរយៈពេលជិត៣០ឆ្នាំហើយ បើរាប់ចាប់ពីខែមករា ឆ្នាំ១៩៧៩ នៅពេលដែលរបបខ្មែរក្រហមត្រូវបានទម្លាក់ចេញពីអំណាចនិងបានរត់ចូលទៅក្នុងព្រៃភាគខាងលិចជាប់ព្រំដែនថៃ ។ បញ្ហាព្រួយបារម្ភអំពីថវិកាឡើងចុះ ក៏នៅរក្សាការឡើងចុះជានិច្ច ។ ភាពតានតឹងដំបូង មាន

គណៈមេធាវីនៃព្រះរាជណាចក្រកម្ពុជានិងអង្គភាពការពារក្តីអង្គជំនុំជម្រះវិសាមញ្ញ ។ ភាពតានតឹងបច្ចុប្បន្ន គឺទាក់ទិននឹងការឈានទៅដល់ការព្រមព្រៀងគ្នាលើដំណើរការនីតិវិធីផ្ទៃក្នុង ។

មានទស្សនីករណ៍ដែលទទួលស្គាល់តាមផ្លូវច្បាប់ពីភាគីទាំងពីរ និងពុំមានភាគីណាមួយត្រូវទាំងស្រុងនោះឡើយ ។ ជាការពិត វាជាភ័ស្តុតាងដែលការបង្កើតនីតិវិធីប្រតិបត្តិតាមផ្លូវច្បាប់នៃបទដ្ឋានអន្តរជាតិសម្រាប់ភាគីទាំងអស់ទាក់ទិននឹងនិទណ្ឌភាពគឺជាដំណើរការដ៏សំខាន់មួយដែលមិនអាចធ្វើដោយប្រញាប់ប្រញាល់បានឡើយ ។ ពិតប្រាកដណាស់ នៅពេលដែលប្រតិបត្តិការនៅក្នុងប្រទេសមួយផ្សេងទៀត ជនណាម្នាក់ (ឬអង្គការមួយ) ត្រូវតែយកចិត្តទុកដាក់អំពីច្បាប់ដែលមានស្រាប់និងគិតពិចារណាអំពីទំនៀមទម្លាប់នៃប្រទេសនោះ ។ ភាគីទាំងពីរនៃតុលាការកូនកាត់ (ដែលពឹងផ្អែកទៅលើច្បាប់កម្ពុជានិងបញ្ចូលច្បាប់អន្តរជាតិដែលច្បាប់កម្ពុជាពុំមានចែង) ជាអ្នកទទួលខុសត្រូវចំពោះដំណើរការតុលាការ ។ ការអនុវត្ត និងកិច្ចសហប្រតិបត្តិការទាំងសងខាងគឺស្ថិតនៅជាមូលដ្ឋានទំនាក់ទំនងគ្រប់ថ្នាក់ទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញ ។ ដោយបានដឹងពីប្រវត្តិប្រព័ន្ធតុលាការនិងសារជាតិដ៏ស្មុគស្មាញនៃតុលាការរបស់កម្ពុជា គេរំពឹងថានឹងមានការប៉ះទង្គិចគ្នានៅពេលដំណើរការ ។ ការការពារនូវការប៉ះទង្គិចគ្នាគឺជាករណីចាំបាច់សម្រាប់ភាគីទាំងពីរ ។ ម្យ៉ាងទៀត ការដកខ្លួនចេញភាគីណាមួយក្នុងចំណោមភាគីទាំងពីរ មិនមែនជាជម្រើសដែលទទួលយកបាននោះទេ ។ ដោយផ្អែកទៅនឹងមាត្រា២៨នៃច្បាប់កិច្ចព្រមព្រៀង ដែលអនុញ្ញាតឲ្យអង្គការសហប្រជាជាតិដកខ្លួនចេញដោយសារតែការប្រព្រឹត្តមិនត្រឹមត្រូវ ដោយភាគីខ្មែរសេចក្តីសម្រេចចិត្តបែបនេះនឹងត្រូវសហគមន៍អន្តរជាតិនិងមហាសន្និបាតអង្គការសហប្រជាជាតិជាអ្នកចោទសួរ ។ ការដកខ្លួនចេញពីភាគីណាមួយ មិនមែនជាដំណោះស្រាយហើយនឹងប៉ះពាល់ទៅដល់កេរ្តិ៍ឈ្មោះភាគីទាំងពីរ ។

ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាសំខាន់ជាងការប៉ះពាល់កេរ្តិ៍ឈ្មោះ គឺជោគវាសនាក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនខ្មែររាប់លាននាក់ដែលរស់រានមានជីវិតពីសោកនាដកម្មបីឆ្នាំប្រាំបីខែនិងម្ភៃថ្ងៃ និងប្រជាជនខ្មែររាប់លាននាក់ទៀតដែលបានបាត់បង់ជីវិត ។ ជាការពិត អង្គជំនុំជម្រះវិសាមញ្ញមិនអាចប្រតិបត្តិគ្រប់ការងារទាំងអស់បាននោះទេ ។ ទិសដៅរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺការកាត់ទោស“មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម”នៃកម្ពុជាប្រជាធិបតេយ្យ និង“អ្នកទទួលខុសត្រូវខ្ពស់បំផុត” ។ អង្គជំនុំជម្រះវិសាមញ្ញនេះ មិនមែនដាក់ទោសកម្មាភិបាលខ្មែរក្រហមរាប់ពាន់នាក់ដែលទទួលខុសត្រូវការសម្លាប់ និងអ្នកដែលបានប្រព្រឹត្តដោយផ្ទាល់នូវការសម្លាប់នោះទេ ។ ការបិទចោលនូវតុលាការដែលកំពុងឆ្ពោះទៅរកជ័យជម្នះ នឹងបន្សល់ទុកនូវកិច្ចការជាច្រើនសម្រាប់អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការផ្សេងៗទៀតជាអ្នកដោះស្រាយជាមិនខាន ។ យ៉ាងណាក៏ដោយ តុលាការនេះមានសារសំខាន់សម្រាប់ប្រជាជនខ្មែរ ។ យុត្តិធម៌ស្របច្បាប់មានសារសំខាន់ជាងយុត្តិធម៌ជានិមិត្តរូបដែលតុលាការផ្តល់ជូន ។ ការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្ម គឺជាសារដែលប្រជាជនខ្មែរជាច្រើននាក់ចង់ឲ្យតុលាការស្វែងរកជូន ។ ម្យ៉ាងទៀត យុត្តិធម៌ជានិមិត្តរូប ក៏នឹងផ្តល់ជាព័ត៌មានឲ្យប្រជាជនកម្ពុជាថា សហគមន៍អន្តរជាតិ ពិតជាយកចិត្តទុកដាក់នឹងការឈឺចាប់ដ៏ធំធេងដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងដំណើរទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញមុនៗ អ្នកស្រុកអ្នកភូមិជាច្រើននាក់បានសួរថាតើសហគមន៍អន្តរជាតិបានដឹងពីអំពើប្រល័យពូជសាសន៍ដែរឬទេ នៅពេលដែលអំពើប្រល័យពូជសាសន៍បានកំពុងតែកើតឡើង និងប្រសិនបើសហគមន៍អន្តរជាតិបានដឹងថាមានអំពើប្រល័យពូជសាសន៍កើតឡើង តើហេតុអ្វីបានជាមិនចាត់វិធានការ? ទាក់ទិននឹងសំណួរនេះ ពួកគេបានសួរថាតើហេតុអ្វីបានជាមហាសន្និបាតអង្គការសហប្រជាជាតិផ្តល់អាសនៈកម្ពុជាទៅឲ្យខ្មែរក្រហម? ដូចនេះ ការប្តេជ្ញាស្វែងរកយុត្តិធម៌ស្របច្បាប់ដោយអង្គជំនុំជម្រះវិសាមញ្ញត្រូវតែអនុវត្តតាមគ្រប់នីតិវិធីទាំងអស់ ។

នៅថ្ងៃបញ្ចប់នោះដែរ ភាពខុសគ្នានិងការមិនចូលចិត្ត ត្រូវបានរក្សាទុកដោះស្រាយលើកក្រោយ ។ ការប៉ះទង្គិចគ្នាចាប់ផ្តើមហើយចំណុចប៉ះទង្គិចធ្ងន់ធ្ងរជាងនេះអាចបញ្ចប់បញ្ហាដ៏សំខាន់នេះបានប្រកបដោយអត្ថន័យ ។ បញ្ហានេះកើតឡើងចំពោះដំណើរទស្សនកិច្ចរបស់មេឃុំច្រើនដូចគ្នានឹងបញ្ហាកើតឡើងចំពោះតុលាការចម្រុះខ្មែរក្រហមដែរ ។ អ្នកស្រុកអ្នកភូមិបានធ្វើដំណើរ

ដោយមធ្យោបាយផ្ទាល់ខ្លួនមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃអាទិត្យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកចំណាយលើការធ្វើដំណើរនៅក្នុងទីក្រុងដោយរថយន្តក្រុង អាហារ និងការស្នាក់នៅ ។ ដំបូង មានការត្អូញត្អែរពីមេឃុំជាច្រើន អំពីអាហារនិងទីកន្លែងស្នាក់អាស្រ័យ ។ ការត្អូញត្អែរស្រដៀងគ្នា ក៏បានកើតឡើងនៅក្នុងដំណើរទស្សនកិច្ចមេឃុំពីរទៀតកាលពីឆ្នាំ២០០៦ដែរ ។ មេឃុំម្នាក់មកពីក្រុងប៉ៃលិន បានពិភាក្សាអំពីសារសំខាន់នៃដំណើរទស្សនកិច្ចនេះជាមួយប្រធានក្រុមគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក លី សុខឃាង ។ ប៉ៃលិនធ្លាប់ជាមូលដ្ឋានរបស់ខ្មែរក្រហមនៅពេលដែលខ្មែរក្រហមត្រូវវៀតណាមបណ្តេញចេញពីអំណាចនៅក្នុងឆ្នាំ១៩៧៩ ។ ចាប់តាំងពីពេលនោះមក ខ្មែរក្រហមបានធ្វើសង្រ្គាមអស់រយៈពេលជាងមួយទសវត្សរ៍រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ។ បច្ចុប្បន្ននេះ ប៉ៃលិន ក្លាយជាជម្រកដ៏សុខសាន្តរបស់អតីតកម្មាភិបាលខ្មែរក្រហមជាច្រើននាក់ ។ នៅក្នុងកិច្ចសន្ទនារបស់គាត់ជាមួយនឹងលោក លី សុខឃាង លោកមេឃុំបានមានប្រសាសន៍ថា ទោះបីជាគាត់ត្រូវចំណាយថវិការបស់គាត់បន្តិចបន្តួចក្នុងការធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញក៏ដោយ ក៏គាត់សប្បាយរីករាយនឹងធ្វើបែបនេះណាស់ ។ គាត់មានអារម្មណ៍ថាដំណើរទស្សនកិច្ចនេះបានផ្តល់ចំណេះដឹងច្រើនដល់គាត់ ។ មិនមែនមានតែគាត់ទេ ដែលបញ្ចេញប្រតិកម្មបែបនោះ ។ បន្ទាប់ពីបញ្ចប់ដំណើរទស្សនកិច្ចនេះ មានអ្នកស្រុកអ្នកភូមិជាច្រើនដែលចាប់អារម្មណ៍ចូលរួមក្នុងដំណើរទស្សនកិច្ចនេះ បានផ្ញើបញ្ជីឈ្មោះមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីចូលរួមក្នុងដំណើរទស្សនកិច្ចនេះដែរ ។ បន្ថែមលើអាវយឺតនិងទស្សនាវដ្តី ដែលគាត់បានទទួលពីមជ្ឈមណ្ឌល គឺចំណេះដឹងស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងតុលាការនេះដែលមិនអាចកាត់ថ្លៃបានឡើយ ។

នៅថ្ងៃដដែល មេឃុំជាច្រើន បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ឱកាសឲ្យគាត់ចូលរួមដំណើរទស្សនកិច្ចនេះនិងបានទស្សនាសិក្សាខ្សែភាពយន្ត «ស-២១ : ម៉ាស៊ីនសម្លាប់របស់ខ្មែរក្រហម» នៅឯមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ និងស្តាប់ការបកស្រាយរបស់មន្ត្រីតុលាការនៅក្នុងអគារតុលាការ និងលើកសំណួរសំខាន់ជាច្រើនសួរទៅកាន់មន្ត្រីអង្គជំនុំជម្រះវិសាមញ្ញ លោកស្រី ចាវិស ដែលជាប្រធានផ្នែកកិច្ចការសាធារណៈ ។ មេឃុំម្នាក់ៗទទួលបាននូវអាវយឺតមួយនិងទស្សនាវដ្តីស្វែងរកការពិត ។ បុគ្គលិកមជ្ឈ-មណ្ឌលបានប្រគល់ជូនមេឃុំនូវផ្ទាំងគំនូរចំនួន១០០០ផ្ទាំងនិងកូនសៀវភៅចំនួន៥០០ក្បាល ។ ទោះយ៉ាងណាក៏ដោយ មេឃុំមានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំងដែលទទួលបាននូវផ្ទាំងគំនូរនិងកូនសៀវភៅទាំងនេះ ។ មេឃុំដែលបានចូលរួម មន្ត្រីអង្គជំនុំជម្រះវិសាមញ្ញ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានលាគ្នាទាំងស្នាមញញឹម ដោយដឹងថាពួកគេម្នាក់ៗសម្រេចបាននូវគោលបំណងរបស់ខ្លួន ។

**កែវ ជាស៊ីល**

# ដំណឹងស្វែងរកបងប្រុស

នាងខ្ញុំឈ្មោះ ហ្គេចលី អាយុ៤៧ឆ្នាំ បច្ចុប្បន្នរស់នៅប្រទេសអូស្ត្រាលី ។ ឪពុកឈ្មោះ ប៊ុន ឌុក កាលពីឆ្នាំ១៩៧៥ ប្រកបមុខរបរលក់ស្បែកជើង យីហោឈ្មោះ «ណាំយឿង» នៅទីក្រុងកំពង់សោម ។

នាងខ្ញុំសូមស្វែងរកបងប្រុស ប៊ុន ត្រាច ហៅ ជ្រូក (បច្ចុប្បន្នអាយុ៥០ឆ្នាំ) បានចាកចេញពីផ្ទះទៅបម្រើកងទ័ពបដិវត្តន៍តាំងពីឆ្នាំ១៩៧០ និងបងប្អូនជីដូនមួយប្រាំនាក់ ដែលមានឈ្មោះ អ៊ីង ស៊ីណា (ស្រី), អ៊ីង ស៊ីផា (ស្រី), អ៊ីង យ៉ា (ប្រុស) និងប្អូនពីរនាក់ទៀតមិនចាំឈ្មោះ ។ ក្រុមគ្រួសារនេះកាលពីសង្គមចាស់រស់នៅជិតរោងកុនវិមានទិព្វ ប្រកបមុខរបរធ្វើស្បែកជើង ។

ដូច្នេះបើបងៗបានឮឬឃើញសេចក្តីប្រកាសនេះសូមទំនាក់ទំនងតាមទូរស័ព្ទលេខ : ០១២ ៩០៩ ៧៧០ និង ០១២ ៨០៩ ៨៨០ ឬតាមអាសយដ្ឋាន :

Gek Ly, 1 Bracknell Rd, Canley Heights, NSW 2166, Australia
Mobile: 0402 194 182, Home: (02) 9711-7637
Email emmatran90@gmail.com

# “ភាពអន្ធការនៃរបបខ្មែរក្រហម” សៀវភៅពិព័រណ៍អំពីរូបថតក្នុងរបបខ្មែរក្រហម

កាលពីពេលថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយសាកលវិទ្យាល័យរ៉ាត់ហ្គ័របានរៀបចំតាំងពិព័រណ៍រូបថតសម័យខ្មែរក្រហមមួយនៅក្នុងបន្ទប់វិចិត្រសាល ដួល រ៉ូបេស៊ិន នៃមហាវិទ្យាល័យញូវជឺស៊ីសហរដ្ឋអាមេរិក ។ ពិព័រណ៍រូបថតនេះមានរយៈពេលមួយសប្តាហ៍ គឺចាប់ថ្ងៃទី១៦ខែមករាដល់ថ្ងៃ២២ខែកុម្ភៈ ឆ្នាំ២០០៧ ។ ពិព័រណ៍រូបថតដែលមានឈ្មោះថា “ភាពអន្ធការនៃរបបខ្មែរក្រហម” ៖ យុត្តិធម៌និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលព័ណនាពីអំពើទារុណកម្មនិងអំពើប្រល័យពូជសាសន៍ពីសម័យខ្មែរក្រហម ។ ក្រោមការបកស្រាយ និងបង្រៀនដោយវាគ្មិនមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ពិព័រណ៍នេះ បានទទួលការចូលរួមពីនិស្សិតបរទេសជាច្រើននៅក្នុងសហរដ្ឋអាមេរិក ។ នៅពេលនោះដែរក៏មានកម្មវិធីបញ្ចាំងខ្សែភាពយន្តឯកសារមួយមានចំណងជើងថា ៖ “ក្រោយជញ្ជាំងនៃមន្ទីរស-២១ ៖ ប្រវត្តិសាស្ត្រផ្ទាល់មាត់ពីមន្ទីរគុកទួលស្លែង” ដែលផលិតដោយលោក ដាក កាស និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ រូបថតទាំងនេះត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពជាសៀវភៅដែលមានកម្រាស់១២៨ទំព័រក្រោមការការជួយឧបត្ថម្ភពីវិទ្យាស្ថានសង្គមនៃមូលនិធិ សូរ៉ូ ក្រោមគម្រោងអ៊ីហ៊្វីនីធីគ្រុបស្តីអំពីការប្រឈមមុខនឹងរឿងរ៉ាវអតីតកាលនិងឯកសារ ។ កម្មវិធីវិចិត្រសាល ដួល រ៉ូប៊ីស៊ិន ត្រូវបានឧបត្ថម្ភមួយផ្នែកដោយក្រុមប្រឹក្សារដ្ឋញូជឺស៊ី ទទួលបន្ទុកសិល្បៈ/ក្រសួងការបរទេសនិងគណៈកម្មាធិការរៀបចំកម្មវិធីវប្បធម៌រ៉ាត់ហ្គ័រ-ញូវ៉ឹក ។ ការឧបត្ថម្ភសម្រាប់ប្រតិបត្តិការនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានឧបត្ថម្ភដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុីតដេន, ជំនួយផ្នែកផ្សព្វផ្សាយកម្មវិធីនេះត្រូវបានឧបត្ថម្ភដោយគណៈកម្មការញូជឺស៊ី ស្តីអំពីការអប់រំអំពើប្រល័យពូជសាសន៍ ។

សៀវភៅពិព័រណ៍រូបថតបង្ហាញនូវរូបភាពជ្រើសរើសជាពិសេសចេញពីបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ រូបថតនីមួយៗឆ្លុះបញ្ចាំងពីអំពើហិង្សានិងលទ្ធផលដែលបន្សល់ពីរបបកម្ពុជាប្រជាធិបតេយ្យ ។ រូបថតដែលជ្រើសរើសបានចោទជាសំណួរយ៉ាងច្រើនថាតើហេតុអ្វីអំពើហិង្សាបែបនេះត្រូវបណ្តោយឲ្យកើតមានឡើង តើជនរងគ្រោះគេចផុតពីការសម្លាប់រង្គាលនិងទុក្ខវេទនានេះដោយវិធីណា និងតើយើងត្រូវរក្សាចងចាំអំពើប្រល័យពូជសាសន៍ក្រោមរូបភាពណា? ក្នុងខណៈពេលដែលពិភពលោកទាំងមូលកំពុងទន្ទឹងរង់ចាំនូវសវនាការមួយដែលមានការចូលរួមពីសហគមន៍អន្តរជាតិដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលគ្រោងនឹងបើកសវនាការនៅក្នុងឆ្នាំនេះ ។ រូបថតពិព័រណ៍អាចជួយឲ្យយើងលើកជាសំណួរជាច្រើនទាក់ទងនិងបញ្ហាយុត្តិធម៌ ការទទួលខុសត្រូវសំណួរវែកញែកពីភាពខុសគ្នារវាង“ជនដៃដល់”និង“ជនរងគ្រោះ” ការស្តាបនាការពិតនិងការចងចាំ និងមូលហេតុដែលត្រូវចំណាយរយៈពេលអស់ជាង៣០ឆ្នាំក្នុងការនាំយកមេដឹកនាំខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសចំពោះអំពើប្រល័យពូជសាសន៍នៅក្នុងអំឡុងពេលកាន់អំណាច ។ អារម្ភកថានៅក្នុងសៀវភៅនេះត្រូវបានសរសេរជុំវិញមូលន័យនៃការតាំងពិព័រណ៍និងផ្តល់នូវសេចក្តីណែនាំជាសង្ខេបស្តីពីអំពើប្រល័យពូជសាសន៍និងលទ្ធផលបន្សល់ទុកពីរបបនេះ ។

នៅក្នុងការស្វែងរកអំពើហិង្សាជាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងលទ្ធផលរបស់របបនេះ ពិព័រណ៍រូបថតមិនត្រឹមតែចង់បង្ហាញអំពីទស្សនៈជាប្រវត្តិសាស្ត្រមួយនៃយុគសម័យភិតភ័យនៅក្នុងប្រវត្តិសាស្ត្រកម្ពុជានោះទេ ថែមទាំងផ្តល់នូវភស្តុតាងដ៏សំខាន់មួយសម្រាប់តុលាការចោទប្រកាន់មេដឹកនាំខ្មែរក្រហម ដែលអនុវត្តអំពើព្រៃផ្សៃនៅក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

សៀវភៅពិព័រណ៍រូបថតបានប្រាប់យើងអំពីរឿងរ៉ាវដ៏ជូរចត់ដែលខ្មែរក្រហមបានសម្លាប់មកលើជាតិសាសន៍ឯង នៅក្នុងទំព័រប្រវត្តិសាស្ត្រកម្ពុជាដ៏សែនអាក្រក់បំផុតដែលបានចាប់ផ្តើមឡើង

នៅថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ នៅពេលដែលកម្លាំងទ័ពខ្មែរក្រហមវាយលុកចូលទីក្រុងភ្នំពេញដោយជោគជ័យ បន្ទាប់ពីសង្គ្រាមរ៉ុាំរ៉ៃអស់រយៈកាលជាច្រើនឆ្នាំ ។ ជ័យជម្នះនេះបាននាំមកនូវការប៉ុនប៉ងអនុវត្តនូវផែនការសេដ្ឋកិច្ចនិងសង្គមផ្តាច់ការដែលនឹងកែប្រែមុខមាត់ប្រទេសកម្ពុជាទាំងមូល ។ ខ្មែរក្រហមបានអនុវត្តនូវគោលនយោបាយជាច្រើនក្នុងគោលបំណងបង្កើតនូវសង្គមបដិវត្តន៍ពិតប្រាកដមួយដែលមានឈ្មោះថា «កម្ពុជាប្រជាធិបតេយ្យ» ។ គោលនយោបាយនេះត្រូវបានអនុវត្តយ៉ាងគំហុកដើម្បីទទួលបានភាពសុខក្សេមក្សាន្តក្នុងប្រទេស ។ ប៉ុន្តែជាលទ្ធផលគោលនយោបាយនេះបានប្រែក្លាយប្រទេសកម្ពុជាឲ្យធ្លាក់ចូលទៅក្នុងមហន្តរាយដ៏ធំទៅវិញ ។ ប្រជាជនកម្ពុជាត្រូវបង្ខំឲ្យធ្វើការជាច្រើនម៉ោងដោយមានពេលវេលាសម្រាកនិងសិទ្ធិសេរីភាពតិចតួចបំផុត ។ ដោយការប៉ុនប៉ងបង្កើតសង្គមថ្មីមួយ ជាលទ្ធផលនៃបដិវត្តន៍ «បរិសុទ្ធ» ខ្មែរក្រហមខំប្រឹងពិនិត្យនិងតាមដានគ្រប់ពាក្យសម្តីសកម្មភាព និងចិត្តគំនិតរបស់ប្រជាជនដើម្បីចាប់កំហុស សូម្បីតែការគិតពីអតីតកាលក៏ត្រូវបានចាត់ទុកជាបទល្មើសដែរ ។ ភាពរន្ធត់និងការសម្លាប់ដែលកើតឡើងអស់រយៈពេលជិតបួនឆ្នាំនៃរបបនេះបានបំផ្លាញជីវិតមនុស្សអស់ជិត២លាននាក់ ដែលបណ្តាលមកពីជំងឺគ្មានថ្នាំព្យាបាល កង្វះអាហារ ការធ្វើការហួសកម្លាំង ការឃុំឃាំង និងការសម្លាប់ ។ ប្រជាជនដែលរស់រានមានជីវិតពីរបបនេះបានប្រឹងប្រែងតស៊ូរស់នៅលើទឹកដីដែលរងនូវការបំផ្លិចបំផ្លាញពីសង្គ្រាម និងសំណល់អគារបាក់បែក ដូចជា សាលារៀន វត្តអារាម មន្ទីរនិងក្រសួងជាដើម ។



គ្របមុខសៀវភៅ : «ភាពអន្ធការរបបខ្មែរក្រហម»

សៀវភៅពិព័រណ៍រូបថតនេះនឹងបំភ្លឺភាពងងឹតដែលគ្របដណ្តប់ប្រទេសកម្ពុជាអស់ជាច្រើនឆ្នាំ ។ ជាងនេះទៀតចំណាប់អារម្មណ៍ពិសេសនោះគឺផ្តោតសំខាន់ទៅលើមន្ទីរសន្តិសុខមជ្ឈិមជាន់ខ្ពស់ដែលមានឈ្មោះថា គុកទួលស្លែង ឬ«មន្ទីរស-២១» ។ រូបថតអ្នកទោសដែលត្រូវបានថតនៅមន្ទីរស-២១ មានមុខមាត់និងរូបរាងក្មេងៗ រូបថតអ្នកទោសខ្លះអាយុប្រមាណ៥ឆ្នាំប៉ុណ្ណោះ ដែលធ្វើអ្នកទស្សនាមានចម្ងល់ថា ហេតុអ្វីបានជាកុមារតូចៗនេះត្រូវបានចាត់ទុកជាអ្នកទោស ហើយទោសធ្ងន់ប៉ុណ្ណាបានជាត្រូវបញ្ជូនមកទួលស្លែង ឬក៏ទោសត្រឹមតែ«លួច»គ្រាប់អង្ករមកបំពេញក្រពះអាចចាត់ទុកថាជាបទឧក្រិដ្ឋដែរ?

នៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ មានអ្នកទោសប្រមាណ១ម៉ឺន៤ពាន់នាក់ត្រូវបានជាប់គុកនៅមន្ទីរស-២១ និងបានយកទៅសម្លាប់នៅវាលពិឃាតជើងឯក ។ មានតែអ្នកទោស១២នាក់ប៉ុណ្ណោះដែលបានរស់រានមានជីវិតពីមន្ទីរស-២១ នៅក្នុងចំណោមអ្នកទោសទាំងអស់នោះ ។

ពិព័រណ៍រូបថតបានផ្តល់ការយល់ដឹងច្រើនអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងបញ្ហាកំពុងប្រឈមមុខ ខណៈពេលដែលប្រទេសកម្ពុជាកំពុងតែព្យាយាមផ្សះផ្សារឿងរ៉ាវសោកនាដកម្មពីអតីតកាល ។ បច្ចុប្បន្ន ការពិតនៃព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកំពុងតែត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រជាជនសង្ឃឹមថា យុត្តិធម៌តាមផ្លូវច្បាប់នឹងបានចែកចាយដល់ពួកគាត់តាមរយៈសាលាក្តីនេះ ហើយយុត្តិធម៌តាមផ្លូវច្បាប់នឹងជួយឲ្យប្រទេសកម្ពុជាចាប់ផ្តើមជាសះស្បើយ និងមានការផ្សះផ្សាគ្នា ។

**លី សុផល**

# ប្រទេសស៊ុយអ៊ែត ផ្តល់ឯកសារខ្មែរក្រហមដល់មជ្ឈមណ្ឌលឯកសារកម្ពុជា

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារក្រដាសទាក់ទងនឹងរបបខ្មែរក្រហមចំនួន ៤០០គីឡូក្រាមស្មើនឹងចំនួន២៦ប្រអប់ពីរដ្ឋាភិបាលប្រទេសស៊ុយអ៊ែតតាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។

ឯកសារទាំងអស់នោះជាឯកសារនិយាយអំពីយុទ្ធនាការបរទេសរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកការគាំទ្រពីរដ្ឋាភិបាលក្រៅប្រទេសនៅក្នុងអំឡុងឆ្នាំ១៩៧៨ដល់ឆ្នាំ១៩៩០ ដែលឯកសារទាំងនោះរួមមានរូបថត អត្ថបទសុន្ទរកថា សៀវភៅនិងអត្ថបទកាសែត ដែលសរសេរជាភាសាខ្មែរ ភាសាអង់គ្លេស ភាសាបារាំង និងភាសាស៊ុយអ៊ែត ។ ដំបូងឡើយឯកសារទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់សមាគមមិត្តភាពកម្ពុជាស៊ុយអ៊ែត ដែលជាអតីតក្រុមធ្លាប់គាំទ្ររបបខ្មែរក្រហម ។ នៅឆ្នាំ២០០១ ឯកសារទាំងនោះត្រូវបានផ្ទេរទៅឲ្យសាកលវិទ្យាល័យលន់នៃប្រទេសស៊ុយអ៊ែតជាអ្នកថែរក្សាវិញ ។

កាលពីខែមេសា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារបានអំពាវនាវដល់ប្រទេសនានា អង្គការ ស្ថាប័ន និងបុគ្គលទាំងអស់ដែលធ្លាប់មានទំនាក់ទំនង ឬជាអ្នកបានឃ្លាំមើលចលនាតស៊ូរបស់អង្គការខ្មែរក្រហមឲ្យផ្តល់ឯកសារនិងសម្ភារដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំកំពូលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ រយៈពេលបីឆ្នាំកន្លងផុត ប្រទេសស៊ុយអ៊ែតជាប្រទេសទីមួយដែលបានផ្តល់នូវឯកសារដែលមានតម្លៃជាប្រវត្តិសាស្ត្រមកជូនប្រទេសកម្ពុជាវិញ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលស៊ុយអ៊ែតនិងសាកលវិទ្យាល័យលន់ ជាពិសេសម្ចាស់កម្មសិទ្ធិដើមនៃឯកសារទាំងនោះ ដែលបានចូលរួមចំណែកក្នុងការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងក្នុងដំណើរស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ឯកសារទាំងនេះមានតម្លៃជាប្រវត្តិសាស្ត្រចំពោះប្រជាជនកម្ពុជា ចំពោះកូនចៅជំនាន់ក្រោយនៃរបបវាលពិឃាត និងចំពោះអ្នកសិក្សាស្រាវជ្រាវដែលមានបំណងស្វែងយល់ពីអំពើប្រល័យពូជសាសន៍ដែលនាំឲ្យមានការបាត់បង់ជីវិតមនុស្សអស់ជិត២លាននាក់ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា រដ្ឋាភិបាលប្រទេសដទៃទៀតនិងស្ថាប័នឯកជននានា បាននិងកំពុងចាប់ផ្តើម និងបន្តស្វែងរកឯកសារដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីផ្តល់មកជូនប្រទេសកម្ពុជា ជាពិសេសជូនអង្គជំនុំវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើជាភ័ស្តុតាងដើម្បីធ្វើការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំទុកដាក់ឯកសារប្រវត្តិសាស្ត្រទាំងនោះដើម្បីបម្រើដល់ការសិក្សាស្រាវជ្រាវពីរបបកម្ពុជាប្រជាធិបតេយ្យជាសាធារណៈ និងរំពឹងថាឯកសារទាំងនោះនឹងជាពន្លឺមួយសម្រាប់ជំរុញឲ្យមានការដាក់ឲ្យទទួលខុសត្រូវដល់មេដឹកនាំខ្មែរក្រហមដែលនៅរស់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញឲ្យបានកាន់តែឆាប់ ។

**ណាយ សុផារី**





ឯកសារទាក់ទងនឹងរបបខ្មែរក្រហមដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពីប្រទេសស៊ុយអ៊ែត នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧



# អំពីស្ថានភាពនិងដំណើរការនៃសាលាក្តីខ្មែរក្រហម

*១) តើស្ថានភាពសាលាក្តីខ្មែរក្រហមបច្ចុប្បន្នដំណើរការទៅយ៉ាងដូចម្តេចទៅហើយ? តើសាលាក្តីនេះនឹងចាប់ផ្តើមនៅពេលដែរ?*

◆ ដំណើរឆ្ពោះទៅរកការជំនុំជម្រះក្តីឧក្រិដ្ឋកម្ម កំពុងតែដំណើរការទៅមុខៗ ច្បាប់ស្តីពីការបង្កើតសាលាក្តីខ្មែរក្រហមនេះត្រូវបានអនុម័ត អគារសវនាការក៏ត្រូវបានបង្កើតហើយដែរ ដែលមានទីតាំងនៅភាគខាងលិចទីក្រុងភ្នំពេញ។ ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការជាតិ និងអន្តរជាតិ ត្រូវបានតែងតាំង បច្ចុប្បន្នទាំងអ្នកទាំងនេះកំពុងតែរៀបចំសំណុំរឿង។ ក៏ប៉ុន្តែតុលាការនេះជាតុលាការថ្មីមួយ ហើយកិច្ចការដំណើរការសាលាក្តីនេះជួបការលំបាកច្រើន។ ឧបសគ្គចុងក្រោយបំផុតនោះ គឺភាពជាប់គាំងរវាងចៅក្រមក្នុងការព្រមព្រៀងគ្នាទៅលើវិធាននីតិវិធីគ្រប់គ្រងដំណើរការកាត់សេចក្តី។ ម្យ៉ាងទៀត មេធាវីក៏កំពុងតែពិភាក្សាគ្នាអំពីវគ្គបណ្តុះបណ្តាលមេធាវីខ្មែរនិងអន្តរជាតិមុនការជំនុំជម្រះក្តី។ បញ្ហាទាំងនេះនៅជាប់ជំពាក់នឹងចរិតលក្ខណៈនៃតុលាការចម្រុះរវាងកម្ពុជានិងអន្តរជាតិ ដែលនៅមានភាពមន្ទិលសង្ស័យលើប្រភពច្បាប់គ្រប់គ្រងដំណើរការកាត់ក្តី។ មន្ត្រីតុលាការនៅតែគ្រោងនឹងចាប់ផ្តើមការកាត់ក្តីនៅក្នុងឆ្នាំ២០០៧ ហើយគោលបំណងនេះនៅតែអាចសម្រេចបានប្រសិនបើចៅក្រមឯកភាពនឹងវិធាននីតិវិធីនេះនៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខ។

*២) តើលោកអាចពន្យល់លម្អិតជាងនេះបន្តិចបានទេថាតើឧក្រិដ្ឋជនណាខ្លះដែលនឹងត្រូវនាំយកមកកាត់ទោសនោះ? បើប្រៀបធៀបជាមួយអ្នកដែលជាប់គុកមួយចំនួន ស្ថានភាពនៃអតីតកម្មាភិបាលខ្មែរក្រហមហាក់ដូចជាខុសពីអ្នកជាប់គុកទាំងនោះ ដោយសារកម្មាភិបាលខ្មែរក្រហមមួយចំនួនត្រូវបានដោះលែងឲ្យរស់នៅយ៉ាងមានសេរីភាព។ តើអតីតមេដឹកនាំខ្មែរក្រហមទាំងអស់នឹងត្រូវធ្វើការកាត់ទោសឬយ៉ាងណា?*

◆ បញ្ហាដែលទាក់ទិននឹងជនដែលត្រូវកាត់ទោស ជាបញ្ហាដ៏ចម្រូងចម្រាសមួយ។ បន្ទាប់ពីការចរចាអស់រយៈពេលជាច្រើនឆ្នាំ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាថា តុលាការមិនអាចធ្វើការដាក់ទោសអតីតកម្មាភិបាលនិងមេដឹកនាំខ្មែរក្រហមទាំងអស់បាននោះទេ ពីព្រោះការដាក់ទោសធំបែបនេះអាចបញ្ឆេះសង្គ្រាមស៊ីវិលឡើងវិញ។ មន្ត្រីអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចធ្វើការកាត់ទោសត្រឹមតែមេដឹកនាំជាន់ខ្ពស់និងជនដែលទទួលខុសត្រូវខ្ពស់បំផុតនូវឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ នៅក្នុងព្រឹត្តិការណ៍នេះ ប្រហែលមានចុងចោទពី៥ទៅ១០នាក់នឹងត្រូវនាំយកមកធ្វើការកាត់ទោស ហើយជនដែលទំនងជានឹងត្រូវធ្វើការកាត់ទោសគឺ ឌុច ដែលជាអតីតប្រធានសន្តិសុខខ្មែរក្រហមនិងជាប្រធានមន្ទីរឃុំឃាំងទួលស្លែងដ៏ល្បីល្បាញ។ បច្ចុប្បន្ន ឌុច កំពុងតែជាប់នៅក្នុងគុករង់ចាំការចោទប្រកាន់អស់រយៈពេលជាច្រើនឆ្នាំ ហើយ ឌុច បានឆ្លើយសារភាពនូវអំពើឧក្រិដ្ឋកម្មរបស់ខ្លួនប្រាប់អ្នកសារព័ត៌មានម្នាក់ឈ្មោះ នេត ថៃយ័រ បន្ទាប់ពី ឌុច បានចូលជាគ្រិស្តសាសនិកដែលចាប់កំណើតម្តងទៀតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ចុងចោទដ៏ល្បីល្បាញពីររូបទៀតគឺ នួន ជា អតីតអនុលេខាបក្សកុម្មុយនិស្តកម្ពុជា និង ខៀវ សំផន អតីតប្រធាន គណៈប្រធានរដ្ឋ។ ជនទាំងពីរនេះបច្ចុប្បន្នរស់នៅទីក្រុងប៉ៃលិនជិតព្រំប្រទល់ថៃ ដែលជាសំបុកលាក់ខ្លួនធំរបស់ខ្មែរក្រហមអស់រយៈពេលជាយូរមកហើយ។ បើទោះជាអ្នកទាំងពីរត្រូវបានដោះលែងឲ្យរស់នៅយ៉ាងមានសេរីភាពក៏ដោយ នួន ជា និង ខៀវ សំផន អះអាងថាខ្លួនពុំមានទោសអ្វីទាំងអស់ ព្រមទាំងបង្ហាញឆន្ទៈធ្វើការបកស្រាយនៅចំពោះមុខតុលាការថែមទៀត។

អតីតឧបនាយករដ្ឋមន្ត្រី អៀង សារី ក៏ត្រូវនាំយកមកធ្វើការកាត់ទោសផងដែរ ក៏ប៉ុន្តែករណី អៀង សារី គឺមានលក្ខណៈចម្រូងចម្រាសច្រើនជាងបន្តិច។ នៅក្នុងឆ្នាំ១៩៩៦ ដោយជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបញ្ចប់សង្គ្រាមជាមួយខ្មែរក្រហម

ដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សា រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការលើកលែងទោសចំពោះ អៀង សារី ។ បច្ចុប្បន្ន អៀង សារី កំពុងរស់នៅយ៉ាងមានសេរីភាពនៅក្នុងភូមិគ្រឹះយ៉ាងធំស្កឹមស្កៃនៅក្នុងទីក្រុងភ្នំពេញ និងនៅមិនទាន់ដឹងច្បាស់លាស់នៅឡើយថាតើតុលាការនឹងពិចារណាលើករណីការលើកលែងទោសនេះដោយខានមិនបានឬយ៉ាងណា ។ ភរិយារបស់ អៀង សារី, អៀង ធីរិទ្ធ ដែលអតីតជាមន្ត្រីខុទ្ទកាល័យរបស់ខ្មែរក្រហមអាចនឹងត្រូវកាត់ទោសផងដែរ ។

ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើននៃការពន្យារពេលយ៉ាងយូររបស់សាលាក្តីខ្មែរក្រហមនោះ គឺអំពើឧក្រិដ្ឋជាច្រើនក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនទាន់ត្រូវបានធ្វើកាត់ទោសនៅឡើយ ។ មេដឹកនាំនៃរបបនោះ ប៉ុល ពត ស្លាប់នៅក្នុងឆ្នាំ១៩៩៨ ភ្លាមៗបន្ទាប់ពីការស្លាប់មន្ត្រីការពារជាតិ សុន សេន ។ ថ្មីៗនេះទៀត មេបញ្ជាការភូមិភាគរបស់ខ្មែរក្រហមចំនួនពីររូបទៀតក៏បានស្លាប់ ហើយនិងលែងឃើញបន្ទប់សវនាការទៀតហើយ គឺ កែ ពក និង តា ម៉ុក ដែលពិការជើងម្ខាង ដែលត្រូវបានឲ្យឈ្មោះថាជា“អ្នកកាប់ជ្រូក” ដោយសារតែវិធីដែល តាម៉ុក បានប្រព្រឹត្តមានភាពសាហាវព្រៃផ្សៃ ។

៣) តើជនរងគ្រោះនឹងត្រូវបានអនុញ្ញាតឲ្យធ្វើសាក្សីនៅក្នុងសវនាការដែរឬទេ?

◆ ពិតប្រាកដណាស់ តុលាការអនុញ្ញាតឲ្យជនរងគ្រោះមួយចំនួនធ្វើជាសាក្សីនៅក្នុងតុលាការ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងដឹកនាំប្រជាជនកម្ពុជាជាច្រើនក្រុមដើម្បីចូលរួមពិនិត្យមើលដំណើរការកាត់ក្តីនេះ ។ បន្ទាប់មក បុគ្គលិករបស់មជ្ឈមណ្ឌលនឹងដឹកអ្នកទាំងនោះត្រឡប់ទៅសហគមន៍របស់ខ្លួនវិញ និងរៀបចំឲ្យមានការជួបពិភាក្សាគ្នានៅតាមតំបន់ដើម្បីពិភាក្សាអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននឹងដើរតួនាទីសំខាន់ផងដែរក្នុងការផ្សព្វផ្សាយព័ត៌មានជូនសាធា-រណជនបានដឹងអំពីការកាត់ក្តីនេះ ហើយអង្គការក្រៅរដ្ឋាភិបាលក៏ជួយផ្សព្វផ្សាយឯកសារអប់រំផងដែរ ។ តុលាការអាចសម្រេចជោគជ័យទៅបានដរាបណាប្រជាពលរដ្ឋខ្មែរគ្រប់រូបសិក្សាប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលគួរឲ្យសោកសៅនិងឃើញយុត្តិធម៌ពិតប្រាកដ ។

៤) ទាក់ទិននឹងបញ្ហាលំបាកនៃពាក្យថា អំពើប្រល័យពូជសាសន៍ តើតុលាការអាចកំណត់បានឬទេ ថាអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ជាអំពើប្រល័យពូជសាសន៍?

ពិតប្រាកដណាស់ តុលាការនឹងមានអាជ្ញាកំណត់ថាតើជនណាខ្លះពាក់ព័ន្ធនៅក្នុងអំពើប្រល័យពូជសាសន៍ក្នុងរយៈកាលនោះ ។ រីឯបញ្ហានៃពាក្យអំពើប្រល័យពូជសាសន៍ ជាបញ្ហាមួយក្នុងចំណោមបញ្ហាដែលងាយនឹងប្រេះស្រាំបំផុតដែលនឹងកើតឡើងចំពោះមុខតុលាការ ។ ក្រោមការអនុវត្តច្បាប់អំពើប្រល័យពូជសាសន៍ សំដៅយកការបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធ សាសនា ឬពូជសាសន៍ណាមួយ ។ ដោយសារតែអំពើប្រល័យពូជសាសន៍ពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាល និងព្រឹត្តការណ៍ដែលបានកើតឡើងនៅក្នុងអតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដា អំពើប្រល័យពូជសាសន៍ត្រូវបានផ្តល់ឋានៈជា“ឧក្រិដ្ឋកម្មនៃឧក្រិដ្ឋកម្ម” ដែលអាក្រក់លើសអ្វីៗទាំងអស់ ។

ហេតុផលមួយអះអាងយ៉ាងច្បាស់ថា ខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍យ៉ាងពិតប្រាកដ ក៏ប៉ុន្តែ មានអំពើឧក្រិដ្ឋកម្មជាច្រើនដែលខ្មែរក្រហមបានប្រព្រឹត្តមិនត្រឹមត្រូវតាមនិយមន័យអំពើប្រល័យពូជសាសន៍នោះឡើយ ពីព្រោះខ្មែរក្រហមសម្លាប់ដោយសារហេតុផលនយោបាយ ហើយភាគច្រើននៃជនរងគ្រោះគឺជនដែលចេញពីក្រុមជាតិពន្ធនិងសាសនា ។ ប្រការនេះមិនត្រឹមតែធ្វើឲ្យឧក្រិដ្ឋកម្មទាំងនេះមានសភាពធ្ងន់ធ្ងរដែលស័ក្តិសមនឹងទទួលបាននូវយុត្តិធម៌ប៉ុណ្ណោះទេ តែថែមទាំងអាចធ្វើឲ្យឧក្រិដ្ឋកម្មទាំងនេះមិនត្រឹមត្រូវហ្មត់ចត់តាមការឲ្យនិយមន័យ“អំពើប្រល័យពូជសាសន៍”ទៀតផង ។ ប្រជាជនខ្មែរមួយចំនួនអាចនឹងមានអារម្មណ៍ថាខ្លួនត្រូវបានគេបោកបញ្ឆោតប្រសិនបើអំពើឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តត្រូវបានចាត់ចូលទៅក្នុងថ្នាក់ ឬប្រភេទណាមួយក្រៅពីអំពើប្រល័យពូជសាសន៍នោះ ។ ប្រជាជនខ្មែរគិតថាការឈឺចាប់របស់ខ្លួនមានភាពធ្ងន់ធ្ងរដូចគ្នាទៅនឹងការឈឺចាប់ដែលពិភពលោក

បាននិងកំពុងមើលឃើញដែរ និងខ្លះទៀតគិតថា ការដាក់ទោសអំពើប្រល័យពូជសាសន៍នេះគឺជាការទទួលស្គាល់នូវការពិត ។ សាលាក្តីនេះនិងអង្គការនានាដែលពាក់ព័ន្ធ មានភារកិច្ចអប់រំសាធារណជនឲ្យយល់ដឹងអំពីអត្ថន័យនៃពាក្យថា អំពើប្រល័យពូជសាសន៍និងច្បាប់សំខាន់ដទៃទៀត ដើម្បីធ្វើឲ្យអ្នកសង្កេតការណ៍អាចមានលទ្ធភាពក្នុងការវាយតម្លៃទៅលើការវិនិច្ឆ័យរបស់តុលាការ ។

**ចន ឆរធីអារី**

# លទ្ធភាពថវិកាវិភាគទានឯកជនផ្តល់ ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ១) សេចក្តីផ្តើម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលមូលនិធិឯកជនជាលើកដំបូងនៅថ្ងៃពុធ ទី១០ ខែមករា ឆ្នាំ២០០៧ ពីក្រុមហ៊ុនម៉ៃក្រូសូហ្វសាំងហ្កាពួរក្នុងទឹកប្រាក់ចំនួនដប់ម៉ឺនដុល្លារអាមេរិក ។ មូលនិធិបែបនេះ ដោយផ្តុំជាមួយនឹងការបន្តចរចារវាងមូលនិធិ បៀល និង មែលីនដា ហ្គេត (Bill and Melinda Gates) និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីការផ្តល់មូលនិធិឧបត្ថម្ភបន្ថែម អាចផ្តល់លទ្ធភាពដល់អង្គជំនុំជម្រះវិសាមញ្ញប្រើប្រាស់ថវិការបស់ប្រទេសម្ចាស់ជំនួយ ដើម្បីបំពេញបន្ថែមថវិកាដែលខ្វះរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

នៅក្នុងយុគសម័យនៃកំណើនសាកលភាវូបនីយកម្មនិងចំនួនទ្រព្យសម្បត្តិជាច្រើនក្នុងប្រទេសមួយចំនួន (និងក្នុងទឹកដែនមួយចំនួននៅក្នុងប្រទេសទាំងនោះ) វាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលដែលថាវិស័យឯកជនដើរតួនាទីសំខាន់នៅក្នុងកិច្ចការនយោបាយពិភពលោកនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ តួនាទីបែបនេះ ត្រូវតែពិនិត្យឲ្យបានហ្មត់ចត់ដើម្បីបញ្ជាក់ថាអង្គការនិងតុលាការអន្តរជាតិទាំងឡាយជាអ្នកទទួលខុសត្រូវចំពោះរដ្ឋជាសមាជិករបស់ខ្លួន ហើយមិនមែនចំពោះភាគីឯកជននោះទេ និងថាគ្រប់ការសម្រេចចិត្តត្រូវរក្សាភាពអព្យាក្រឹត ។ ដោយពុំមានគោលការណ៍ណែនាំច្បាស់លាស់ណាមួយនៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញត្រូវតែប្រុងប្រយ័ត្នក្នុងការទទួលយកថវិកាវិភាគទានឯកជននិងចាត់ចែងថវិកាទាំងនេះឲ្យបានត្រឹមត្រូវ ។

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញ មានបំណងចង់រៃអង្គាសវិភាគទានឯកជន អត្ថបទនេះបានលើកជាសំណើថា គួរតែបង្កើតភ្នាក់ងារមួយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញដើម្បីត្រួតពិនិត្យមើលលើការប្រើប្រាស់ថវិកានេះ ។ ភ្នាក់ងារនេះអាចប្រើប្រាស់ថវិកាវិភាគទានឯកជនទាំងអស់នេះដើម្បីបញ្ជាក់យ៉ាងច្បាស់ថាក្រុមហ៊ុនធំៗនឹងមិនប្រើប្រាស់ឥទ្ធិពលរបស់ខ្លួននៅក្នុងដំណើរការផ្ទៃក្នុងរបស់តុលាការបានឡើយ ព្រមទាំងទប់ស្កាត់វិភាគទានជាបុគ្គលពីការស៊ីសំណូកផ្ទាល់ខ្លួនថែមទៀត ។ ម្យ៉ាងទៀត ភ្នាក់ងារនេះក៏អាចអង្កេតពិនិត្យតាមដានពិនិត្យមើលលើការប្រើប្រាស់ថវិកាទាំងនេះផងដែរ ដោយផ្តល់តម្លាភាពនៅក្នុងសកម្មភាពការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ជាបឋម អត្ថបទនេះនឹងចាប់ផ្តើមដោយការពិនិត្យរចនាសម្ព័ន្ធហិរញ្ញវត្ថុបច្ចុប្បន្នរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយបកស្រាយអំពីសារជាតិតុលាការកូនកាត់ពិសេសនេះនិងវិធីដែលវិភាគទានឯកជននេះត្រឹមត្រូវតាមរចនាសម្ព័ន្ធហិរញ្ញវត្ថុ ។ ផ្នែកបន្ទាប់ទៀត អត្ថបទនេះនឹងពិនិត្យលើខនៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញដែលទាក់ទងនឹងថវិកាវិភាគទាន និងវិភាគបញ្ហាច្បាប់និងជម្លោះផលប្រយោជន៍ដ៏មានសក្តានុពលដទៃទៀត ។ ជាចុងក្រោយ អត្ថបទនេះនឹងដាក់សំណើសុំបង្កើតភ្នាក់ងារមួយ ដើម្បីទទួលថវិកាវិភាគទានឯកជន ។

## ២) មូលនិធិបច្ចុប្បន្ន

### ក) រចនាសម្ព័ន្ធមូលនិធិ

ថ្មីៗនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលថវិកាពីរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលបរទេស និងអង្គការអន្តរ

ជាតិនានា ។ ការរៀបចំហិរញ្ញវត្ថុសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ជាប្រភពនៃភាពជាប់គាំងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម និងជាប្រធានបទមួយក្នុងចំណោមប្រធានបទចម្បងជាច្រើនក្នុង អំឡុងពេលនៃការចរចារយៈពេលបួនឆ្នាំដែលបានប្រព្រឹត្តឡើង មុនពេលដែលរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបាន ព្រមព្រៀងគ្នាលើរចនាសម្ព័ន្ធហិរញ្ញវត្ថុអង្គជំនុំជម្រះវិសាមញ្ញ នេះ ។ ការព្រមព្រៀងគ្នាជាចុងក្រោយរវាងអង្គការសហប្រជា ជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបែងចែកការចំណាយ លើអង្គជំនុំជម្រះវិសាមញ្ញនេះ ក៏ប៉ុន្តែ រហូតមកទល់ពេលនេះ ភាគីទាំងពីរទើបតែទទួលបានថវិកាបដិភាគសំខាន់ៗរបស់ខ្លួនពី រដ្ឋាភិបាលបរទេសតែប៉ុណ្ណោះ ។ ក្រុមការងាររបស់រាជរដ្ឋាភិបាល កម្ពុជានិងក្រុមការងាររបស់អង្គការសហប្រជាជាតិទទួលបន្ទុក ជំនួយអង្គជំនុំជម្រះវិសាមញ្ញ **(UNAKRT)** គ្រប់គ្រង និងចាត់ចែង រួមគ្នានូវថវិកាអង្គជំនុំជម្រះវិសាមញ្ញ ។ ជាសរុប អង្គការសហ ប្រជាជាតិទទួលបានការសន្យាផ្តល់ថវិកាពីប្រទេសចំនួន១៨និង សហភាពអឺរ៉ុប (កំណត់សម្គាល់សហរដ្ឋអាមេរិក ពុំទាន់ផ្តល់ថវិកា របស់ខ្លួននៅឡើយទេ) ដែលមានចំនួនសរុប ៤២,៧៥៨,១៩០ ដុល្លារ ។ ជាមួយនឹងថវិកាវិភាគទានបន្ថែមថ្មីៗពីក្រុមហ៊ុនម៉ៃក្រូ-សូហ្វ១០ម៉ឺនដុល្លារចំនួនថវិកាសរុបនេះ កើនឡើងជិតទៅដល់ ចំនួនថវិកាបដិភាគសរុប៤៣លានដុល្លាររបស់អង្គការសហប្រជា ជាតិ ។

ថវិកាដែលជាចំណែករបស់ភាគីកម្ពុជាវិញ បាននិងកំពុង ដំណើរការទៅមុខដោយទទួលបានជោគជ័យយ៉ាងស្ទួចស្ទើង រហូតមកទល់ពេលនេះ ទើបតែមានចំនួន ៣៧២៥០០០ដុល្លារ នៃថវិកាបដិភាគចាំបាច់របស់ខ្លួនចំនួន ១៣៣០០០០០ដុល្លារ ប៉ុណ្ណោះ ។ កម្ពុជាបានទទួលថវិកាវិភាគទាន ដែលបំពេញបន្ថែម លើការងារហិរញ្ញវត្ថុរបស់ខ្លួនពីប្រទេសឥណ្ឌា ថៃ និងសហភាព អឺរ៉ុប ។ ខាងកម្ពុជាត្រូវចំណាយថវិកាផ្ទាល់ខ្លួនចំនួន ១,៥លាន ដុល្លារ ។ បច្ចុប្បន្ននេះ ភាគីកម្ពុជានៅខ្វះថវិកាចំនួន ៩៥៧៥០០០ ដុល្លារទៀត ។ គ្មានអ្វីចម្លែកទេដែលថាអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា ជាពិសេសប្រជាជនកម្ពុជាមានការភ្ញាក់ផ្អើល នឹងថវិកាវិភាគទានចុងក្រោយនេះ ។ ទោះបីជាថវិកានេះ ត្រូវ ផ្តល់ជូនខាងអង្គការសហប្រជាជាតិយ៉ាងណាក៏ដោយ គេសង្ឃឹម ថាថវិកានេះនឹងជាថវិកាវិភាគទានដំបូងបង្អស់ក្នុងចំណោមថវិកា វិភាគទានជាច្រើនដែលនឹងជួយសម្រួលទៅដល់បន្ទុកហិរញ្ញវត្ថុ របស់អង្គជំនុំជម្រះវិសាមញ្ញ ។

### ១) កង្វះថវិកា

បន្ទាប់ពីថវិកាចាំបាច់ទាំងអស់ត្រូវបានប្រមែប្រមូលរួចរាល់ ហើយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដំណើរការ (ហើយបច្ចុប្បន្នកំពុងតែដំណើរការ) លើគម្រោងថវិកា ៥៦,៣ លានដុល្លារ ។ ចំនួនថវិកាប៉ាន់ប្រមាណនេះ ដែលគេគ្រោងប្រើ ប្រាស់ក្នុងដំណើរការកាត់ក្តីរយៈពេលបីឆ្នាំ ដែលក្នុងមួយឆ្នាំ មិនអាចប្រើប្រាស់លើសពី២០លានដុល្លារបានទេ ។ ទោះបីជា ជាដំបូង គេគិតថាចំនួននេះហាក់ដូចជាច្រើនសម្រាប់តុលាការ នេះក៏ដោយ ក៏ថវិកានេះនៅមានចំនួនតិចតួចនៅឡើយ បើ ប្រៀបធៀបទៅនឹងតុលាការអន្តរជាតិដទៃទៀត ។ ជាឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរវ៉ាន់ដា ចំណាយថវិកាជាង១០០លានដុល្លារក្នុងមួយ ឆ្នាំៗ ។ ចំពោះតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនវិញ ថវិកាដំបូងរបស់ខ្លួនមានចំនួនប្រហាក់ប្រហែលនឹងចំនួនថវិកាអង្គ ជំនុំជម្រះវិសាមញ្ញគឺ ៥៧លានដុល្លារសម្រាប់រយៈពេលបីឆ្នាំ ហើយបច្ចុប្បន្នមានរយៈពេលប្រាំឆ្នាំហើយ និងបានចំណាយ ថវិកាអស់ជាង១០៧លានដុល្លាររួចទៅហើយ ។ តុលាការពិសេស នៅប្រទេសសៀរ៉ាឡេអូន បានប្រើប្រាស់ថវិកាច្រើនជាងថវិកា ដែលបានគ្រោងទុកពីដំបូង មិនមែនដោយសារតែការមើលរំលង មិនបានគិតនោះទេ តែដោយសារតែកិច្ចការដែលពាក់ព័ន្ធក្នុង តុលាការនេះត្រូវការចំណាយថវិកាច្រើនជាងការគិតទុកពីមុន ។

ដូចគ្នានេះដែរ អង្គជំនុំជម្រះវិសាមញ្ញ ត្រូវការថវិកាច្រើន ជាងនេះ មិនមែនដោយសារតែបញ្ហាអំពើពុករលួយ ឬការគ្រប់ គ្រងមិនត្រឹមត្រូវនោះទេ ក៏ប៉ុន្តែ ដោយសារតែថវិកាបច្ចុប្បន្នមិន អាចឆ្លើយតបតាមតម្រូវការចាំបាច់មួយចំនួន ។ នៅក្នុងខែតុលា ឆ្នាំ២០០៦ អង្គការគម្រោងយុត្តិធម៌សង្គមបានចុះបញ្ជីថវិកាដែល ខ្វះខាត ។ នៅក្នុងចំនួនថវិកាចំណាយផ្សេងៗ ពុំមានថវិកាសម្រាប់ ចំណាយទៅលើ ÷ ការកោះហៅចៅក្រមចូលរួមសម័យប្រជុំពេញ

អង្គមុនពេលដែលតុលាការចាប់ផ្តើមកាត់ក្តី ការធ្វើដំណើរសម្រាប់បុគ្គលិកអង្គការសហប្រជាជាតិដែលចូលរួមផ្សព្វផ្សាយព័ត៌មាន ការការពារសាក្សីជាអន្តរជាតិក្រៅពីការដឹកជញ្ជូនសាក្សី ការិយាល័យ(ឬមន្ត្រី) ដែលទទួលបន្ទុកយុទ្ធសាស្ត្របញ្ចប់ការជំនុំជម្រះ ឬកិត្តិនាមតុលាការ ការធ្វើដំណើរសម្រាប់ព្រះរាជអាជ្ញា ម៉ាស៊ីនស្កេនណឺ ម៉ាស៊ីនថតរូបឬថតសំឡេង និងប្រព័ន្ធទិន្នន័យកុំព្យូទ័រនៅលើគេហទំព័រ ដូចជាគេហទំព័រវេសឡ (Westlaw) ឬឡិចស៊ីស (Lexis) នោះឡើយ ។ ក្នុងស្ថានភាពកង្វះថវិកាបែបនេះ លទ្ធភាពនៃថវិកាវិភាគទានឯកជនមានសារសំខាន់យ៉ាងខ្លាំងនិងជាទីសង្ឃឹមនៃដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។

### ក) ភាពខុសគ្នានៃការផ្តល់មូលនិធិ

បើពិនិត្យកិច្ចការផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញវិញ បុគ្គលិកអង្គជំនុំជម្រះវិសាមញ្ញទទួលបានប្រាក់បៀវត្សរ៍ដែលផ្អែកទៅលើថាតើបុគ្គលិកទាំងនោះត្រូវបានជួយដោយរាជរដ្ឋាភិបាលកម្ពុជា ឬដោយអង្គការសហប្រជាជាតិ ។ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញចែងថា ការចំណាយចំពោះមន្ត្រីនិងបុគ្គលិកបរទេស ជាបន្ទុករបស់អង្គការសហប្រជាជាតិ ហើយការចំណាយចំពោះមន្ត្រីនិងបុគ្គលិកខ្មែរវិញ ជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា ។ មាត្រា៤៤នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា ÷

- ការចំណាយនិងប្រាក់បៀវត្សរ៍ចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកខ្មែរ ចំពោះចៅក្រមជំនុំជម្រះក្តីនិងចៅក្រមជំនុំជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេតនិងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញានិងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ ជាបន្ទុកថវិការាជរដ្ឋាភិបាលកម្ពុជា ។

- ការចំណាយចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេស ចៅក្រមជម្រះក្តី សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបរទេស ដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។

- ប្រាក់បៀវត្សរ៍របស់មន្ត្រីនិងបុគ្គលិកបរទេស សហចៅក្រមជម្រះក្តីបរទេស ចៅក្រមស៊ើបអង្កេតបរទេស និងសហព្រះរាជអាជ្ញាបរទេស ជាបន្ទុករបស់ប្រទេសដែលបានបញ្ជូនមកតាមសំណើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ទោះបីជាការបែងចែកថវិកាបែបនេះ ទំនងជាសមស្រប សម្រាប់តុលាការចម្រុះ (និងទូទៅនៅក្នុងតុលាការអន្តរជាតិដទៃ) ក៏ដោយ ការបែងចែកថវិកាបែបនេះ នាំមកដោយចៀសមិនបាននូវភាពខុសគ្នាលើប្រាក់បៀវត្សរ៍ជាមួយនឹងព្រះរាជអាជ្ញាខ្មែរដែលទទួលបានប្រាក់បៀវត្សរ៍តែត្រឹមពាក់កណ្តាលនៃប្រាក់បៀវត្សរ៍ព្រះរាជអាជ្ញាអន្តរជាតិ ។ ដូចដែលចៅក្រមខ្មែរអង្កេតឃើញថា គូបដិបក្ខអន្តរជាតិរបស់ខ្លួនដែលបំពេញការងារដូចគ្នា តែទទួលប្រាក់បៀវត្សរ៍ច្រើនជាងខ្លួនពីរដង ភាពមិនស្មើគ្នាលើប្រាក់បៀវត្សរ៍ញ៉ាំងឲ្យមានភាពខុសគ្នាទៅលើការផ្តល់ហេតុផល និងការផ្តល់តម្លៃផ្ទាល់ខ្លួន ។ មានមន្ទិលសង្ស័យថាតើសម្តីរបស់ព្រះរាជអាជ្ញាខ្មែរពិតដែរឬទេ ដែលថាជាមួយនឹងប្រាក់បៀវត្សរ៍ត្រឹមតែពាក់កណ្តាលប្រជាជនអាចសង្ឃឹមថានឹងទទួលបានយុត្តិធម៌តែពាក់កណ្តាលដែរ ។ ថវិកាវិភាគទានឯកជនអាចជួយច្រើនក្នុងការកាត់បន្ថយភាពខុសគ្នាលើបញ្ហាថវិកា (មិនត្រឹមតែបញ្ហាប្រាក់បៀវត្សរ៍ប៉ុណ្ណោះទេ) របស់បុគ្គលិកខ្មែរនិងអន្តរជាតិ ដែលជំរុញបន្ថែមផ្នែកផ្លូវចិត្តទៅដល់មន្ត្រីខ្មែរ ដោយបង្ហាញថា ពិភពលោកចូលរួមក្នុងកិច្ចការរបស់ពួកគេ ។

### ៣) ថវិកាវិភាគទានឯកជន

ក្នុងស្ថានភាពកង្វះខាតនិងភាពខុសគ្នាលើបញ្ហាថវិកាបែបនេះ លទ្ធភាពនៃថវិកាវិភាគទានឯកជន ជាជម្រើសដ៏មានសក្តានុពលមួយ ។ តាមទ្រឹស្តី ជម្រើសបែបនេះជាដំណោះស្រាយមួយដែលអាចទទួលយកបាន ហើយអង្គការនិងតុលាការអន្តរជាតិនានា បានទទួលយកថវិកាវិភាគទានឯកជនជាយូរមកហើយដែរ ។ តាមការអនុវត្តជាក់ស្តែង នីតិវិធីក្នុងការទទួលយកថវិកាវិភាគទានឯកជន នឹងនាំមកនូវភាពស្មុគស្មាញថ្មីៗជាច្រើន ពីព្រោះនឹងត្រូវបង្កើតទីភ្នាក់ងារនានាដើម្បីរៃអង្គាសថវិកា គ្រប់គ្រងជម្លោះផលប្រយោជន៍ និងរៃអង្គាសមូលនិធិផ្សេងៗ ។ ទោះបីជាយ៉ាងណាក៏ដោយ ទីភ្នាក់ងារបែបនេះ ក៏អាចនាំមកនូវផលប្រយោជន៍បន្ថែម ដូចជា ការរីកចម្រើន តម្លាភាពហិរញ្ញវត្ថុអង្គជំនុំជម្រះវិសាមញ្ញ និងឱកាសសម្រាប់ប្រជាជនតាមរយៈការ

វិនិយោគហិរញ្ញវត្ថុ ដែលត្រូវបានវិនិយោគផ្នែកស្មារតី ។

ជាក់ស្តែង ច្បាប់អង្គជំនុំជម្រះវិសាមញ្ញអនុញ្ញាតឲ្យមានការចូលរួមវិភាគទានរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងផ្នែកចំណាយរបស់ខ្លួន ។

ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀត ដូចជារដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ ។

ទោះបីជា«ខ»នេះអនុញ្ញាតឲ្យទទួលយកថវិកាវិភាគទានពីអង្គការមិនមែនរដ្ឋាភិបាល និងភាគីឯកជន«ខ»នេះមិនបានរារាំងមិនឲ្យទទួលយកថវិកាទាំងនេះឡើយ ។ ពាក្យដែលកំពុងប្រើប្រាស់ *«អាចទទួលយក»* មានន័យថា អង្គជំនុំជម្រះវិសាមញ្ញអាចប្រានចោលថវិកាវិភាគទាននេះ ប្រសិនបើការទទួលយករបស់អង្គជំនុំជម្រះវិសាមញ្ញ បង្កឲ្យមានជម្លោះផលប្រយោជន៍នោះ ។ ដោយធ្វើការប្រៀបធៀបទៅនឹងតុលាការពិសេសនៅអ៊ីរ៉ាក់ ក៏បានទទួលយកថវិកាវិភាគទានឯកជនដែរ ក៏ប៉ុន្តែ កង្វះលក្ខណៈវិនិច្ឆ័យចំពោះថវិកាវិភាគទានឯកជន មានន័យថា ថវិកាវិភាគទានអាចទទួលយកបាន ដរាបណាថវិកានេះមិនប៉ះពាល់ទៅដល់អព្យាក្រឹតភាពរបស់តុលាការដែលនឹងអាចរំលោភបំពានលើភាពមិនលម្អៀងនៃច្បាប់លក្ខន្តិកៈរបស់តុលាការ ។

បញ្ហាលំបាកជាងនេះទៀត គឺថាតើការកំណត់ថវិកាវិភាគទាន នឹងមានផលប៉ះពាល់ទៅដល់អព្យាក្រឹតភាពរបស់តុលាការដោយរបៀបណាដែរ? ថវិកាថ្មីៗរបស់ក្រុមហ៊ុនម៉ៃក្រូសូហ្វត្រូវបានរក្សាទុកប្រើប្រាស់សម្រាប់ថវិកាបដិភាគរបស់អង្គការសហប្រជាជាតិនៃថវិការបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទោះបីជាក្រុមហ៊ុនផ្តល់ថវិកានេះទុកប្រើប្រាស់ដើម្បីជួយកាត់បន្ថយបន្ទុកថវិកាបដិភាគរបស់អង្គការសហប្រជាជាតិ (ដោយខុសពីបន្ទុកថវិការបស់ភាគីកម្ពុជា) ក៏ដោយ អង្គការសហប្រជាជាតិ និងជាពិសេសអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែគ្រប់គ្រងដំណើរការចាត់ចែងវិធីដែលថវិកានេះត្រូវប្រើប្រាស់រហូតដល់ចប់ ។ ស្ថានភាពនេះ អាចមានភាពស្មុគស្មាញកាន់តែច្រើន ប្រសិនបើក្រុមហ៊ុនម៉ៃក្រូសូហ្វបង្គាប់ឲ្យប្រើប្រាស់ថវិកានេះសម្រាប់សកម្មភាពការងារជាក់ស្តែងរបស់អង្គជំនុំជម្រះវិសាមញ្ញ ដូចជាការការពារសាក្សីជាដើម ។ ទោះបីជាវិភាគទានបែបនេះ មិនត្រូវបានហាមប្រាមតាមផ្លូវច្បាប់ក៏ដោយ វិភាគទាននេះមានសក្តានុពលជះឥទ្ធិពលទៅដល់របៀបវារៈផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយផ្តល់អាទិភាពនូវសកម្មភាពមួយចំនួនផ្សេងៗគ្នាជាជាងដែលអង្គជំនុំជម្រះវិសាមញ្ញប្រើប្រាស់ថវិកាដែលត្រូវបានផ្តល់ឲ្យ ។ ប្រសិនបើវិភាគទាននេះកើតឡើងជាញឹកញាប់ អង្គការសហប្រជាជាតិ (និងអង្គជំនុំជម្រះវិសាមញ្ញ) ត្រូវផ្សារភ្ជាប់ជាមួយសេចក្តីប្រាថ្នារបស់ឯកជន ។

បញ្ហាព្រួយបារម្ភស្រដៀងគ្នាដែរ ទាក់ទិននឹងវិភាគទានឯកជនដែលផ្តល់ជូនអង្គការសហប្រជាជាតិ ។ នៅក្នុងឆ្នាំ១៩៩៧ លោក ធេដ ធឺណឺ បានសន្យាផ្តល់ថវិកាមួយពាន់លានដុល្លារទៅដល់អង្គការសហប្រជាជាតិ ហើយនេះ គឺជាថវិកាដ៏ធំបំផុតតែមួយគត់ដែលពុំធ្លាប់មានចំពោះអង្គការណាមួយឡើយ ។ ការព្រួយបារម្ភនេះគឺថា ប្រសិនបើអង្គការសហប្រជាជាតិពឹងផ្អែកទៅលើថវិកាឯកជននេះ វាហាក់ដូចជាថវិកាឯកជនជាបុគ្គលទទួលបន្ទុកច្រើនជាងរដ្ឋជាសមាជិក ។ ជាងនេះទៀត សកម្មភាពជំរុញឲ្យមានវិភាគទានជាបុគ្គលនេះ ត្រូវបានចាត់ទុកជាមធ្យោបាយមួយដែលអាចជួយសម្រាលដល់ការងារហិរញ្ញវត្ថុអង្គការសហប្រជាជាតិនៃរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ និងកាត់បន្ថយការទទួលខុសត្រូវរបស់រដ្ឋជាសមាជិក ។ ដើម្បីកាត់បន្ថយការព្រួយបារម្ភបែបនេះមួយផ្នែក លោក ធឺណឺ បានបង្កើតមូលនិធិអង្គការសហប្រជាជាតិមួយក្នុងការរួមចំណែកវិភាគទានរបស់លោកនៅក្នុងកំណើនប្រចាំឆ្នាំចំនួនមួយ១០០លានដុល្លារក្នុងរយៈពេល១០ឆ្នាំ ។ អង្គការសហប្រជាជាតិ ក៏បានបង្កើតមូលនិធិមួយដើម្បីទទួលថវិកាឧបត្ថម្ភដែលមានឈ្មោះថា ការិយាល័យមូលនិធិស្ម័គ្រចិត្តភាពជាដៃគូអន្តរជាតិរបស់អង្គការសហប្រជាជាតិ **(UNFIP)** ដែលជាអ្នកសម្រេចកម្មវិធីទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ថវិការបស់មូលនិធិអង្គការសហប្រជាជាតិ ។

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញ គ្រោងនឹងជំរុញឲ្យមានវិភាគទានឯកជនច្រើន មូលនិធិស្រដៀងគ្នានឹងត្រូវបង្កើតឡើង

ដើម្បីរៃអង្គាសថវិកា ។ ទោះបីជា ច្បាប់អង្គជំនុំជម្រះវិសាមញ្ញ ដែលខុសពីធម្មនុញ្ញអង្គការសហប្រជាជាតិអនុញ្ញាតឲ្យមានថវិកាវិភាគទានឯកជនយ៉ាងពិតប្រាកដក៏ដោយ ការបង្កើតភ្នាក់ងារមួយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងការចំណាយថវិកានេះ នឹងកាត់បន្ថយជាសារវន្តនូវឥទ្ធិពលដែលម្ចាស់ជំនួយជាបុគ្គលនឹងផ្តល់ថវិការបស់ខ្លួន ។ ទោះបីជាភ្នាក់ងារនេះ បំពេញការងារស្ថិតនៅក្រោមគោលការណ៍ណែនាំដ៏ទូលាយសម្រាប់ម្ចាស់ជំនួយ(ដូចជាសេចក្តីបង្គាប់របស់ក្រុមហ៊ុនម៉ៃក្រូសូហ្វក្នុងការផ្តល់ថវិកាទៅដល់ភាគីអង្គការសហប្រជាជាតិនៃតុលាការកូនកាត់នេះ) ក៏ដោយ ភ្នាក់ងារនេះអាចសហការជាមួយ (និងនៅក្នុង) អង្គជំនុំជម្រះវិសាមញ្ញដើម្បីបញ្ជាក់ថាថវិកានេះត្រូវបានចំណាយលើគម្រោងដែលអង្គជំនុំជម្រះវិសាមញ្ញផ្តល់សិទ្ធិអាទិភាព (និងមិនមែនលើគម្រោងដែលម្ចាស់ជំនួយជ្រើសរើសឡើយ) ។

ដើម្បីអះអាងបញ្ជាក់ម្ចាស់ជំនួយថាថវិការបស់ពួកគេត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនោះ ភ្នាក់ងារនេះ អាចរក្សាទុកកំណត់ហេតុស្តីពីវិធី ពេលវេលា និងទីកន្លែងដែលថវិកានេះត្រូវចំណាយ ។ ការរក្សាកំណត់ហេតុបែបនេះ នឹងឆ្លុះបញ្ចាំងពីការរីកចម្រើនតម្លាភាពហិរញ្ញវត្ថុរបស់ស្ថាប័ននេះ និងផ្តល់ទំនុកចិត្តលើកិច្ចការប្រចាំថ្ងៃរបស់ខ្លួន ។ កំណត់ហេតុហិរញ្ញវត្ថុដ៏ល្អិតល្អន់ អាចបង្ហាញប្រជាជនអំពីសមិទ្ធផលដែលកំពុងតែសម្រេចបានដោយការរាយការណ៍ប្រាប់អំពីគម្រោងដែលទទួលបានប្រាក់ឧបត្ថម្ភ ។

ម្យ៉ាងទៀត ភ្នាក់ងារអង្គជំនុំជម្រះវិសាមញ្ញដាច់ដោយឡែកមួយ អាចបំបាត់ភាពភ័យខ្លាចដែលក្រុមហ៊ុនឯកជនប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនមកលើសកម្មភាពការងាររបស់តុលាការ ។ បញ្ហាខុសគ្នាមួយទាក់ទិននឹងជម្លោះផលប្រយោជន៍ កើតឡើងនៅពេលដែលពិចារណាអំពីវិភាគទានដែលទទួលបានមកពីបុគ្គលជាឯកជន ។ ភាគីឯកជន ទំនងជាអាចមានចំណាប់អារម្មណ៍ចូលរួមផ្តល់វិភាគទានមិនមែន ដើម្បីអូសទាញអង្គការសហប្រជាជាតិដោះស្រាយបញ្ហាមួយចំនួនទេ ក៏ប៉ុន្តែថែមទាំងជះឥទ្ធិពលទៅដល់សេចក្តីសម្រេចចិត្តរបស់តុលាការក្នុងករណីពិសេសណាមួយ ។ ជាការពិតណាស់ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញមិនបានហាមប្រាមអ្នកចូលរួមក្នុងតុលាការនេះមិនឲ្យផ្តល់ថវិការបស់ខ្លួននោះទេ ប៉ុន្តែការរួមវិភាគទានបែបនេះនឹងត្រូវតុលាការប្រានចោល ។ មេធាវីចុងចោទ សាក្សី និងភាគីរដ្ឋប្បវេណី ត្រូវបានហាមប្រាមមិនផ្តល់វិភាគទានទៅដល់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីទប់ស្កាត់ការប៉ុនប៉ងស៊ីសំណូកយ៉ាងពិតប្រាកដណាមួយ ។ ទោះបីជាជនរងគ្រោះនៃរបបខ្មែរក្រហមជាច្រើនមានបំណងរួមវិភាគទានជួយអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីធានាឲ្យបានច្បាស់លាស់ថា តុលាការនេះសម្រេចបានជោគជ័យក៏ដោយ ក៏គំនិតនៃដើមបណ្តឹងដែលឧបត្ថម្ភចៅក្រមនិងព្រះរាជអាជ្ញាផ្ទាល់របស់ពួកគេ គឺមានលក្ខណៈផ្ទុយស្រឡះពីប្រព័ន្ធយុត្តិធម៌ដែលអង្គជំនុំជម្រះវិសាមញ្ញកំពុងតែអនុវត្ត ហើយដែលពុំមាននរណាម្នាក់អាចទិញយុត្តិធម៌បានឡើយ ។ ជាងនេះទៀត ដើម្បីឲ្យជនរងគ្រោះមានឱកាសទទួលបាននូវយុត្តិធម៌ ចៅក្រមត្រូវតែមានភាពមិនលម្អៀង ។ ការដែលធ្វើឲ្យជនរងគ្រោះចូលរួមវិភាគទានគាំទ្រតុលាការផ្ទាល់របស់ខ្លួន នឹងធ្វើឲ្យបាត់សេចក្តីជឿទុកចិត្តដែលតុលាការមាន ។

រឿងក្តីដ៏គួរស្មុគស្មាញជាងនេះមួយទៀត អាចនឹងកើតមានឡើង ប្រសិនបើបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឲ្យរួមគ្នាក្នុងការផ្តល់វិភាគទាន និងត្រូវបានសម្រេចឲ្យចូលរួមធ្វើបណ្តឹងក្នុងនាមជាភាគីរដ្ឋប្បវេណី ។ តើបុគ្គលម្នាក់ត្រូវបានហាមប្រាមមិនឲ្យដាក់ពាក្យបណ្តឹង (ជាពិសេស ការបាត់បង់នូវសិទ្ធិចូលរួមការជំនុំជម្រះ) ដោយសារតែបញ្ហាថវិកាពីមុនដែរឬទេ? ជាឧទាហរណ៍ សហរដ្ឋអាមេរិក មិនបានហាមប្រាមភាគីរដ្ឋប្បវេណីមិនឲ្យផ្តល់ថវិកាទៅដល់ការជ្រើសតាំងចៅក្រម និងមិនឲ្យបង្ហាញពីសំណុំរឿងទាំងឡាយដែលទាក់ទិនទៅនឹងចៅក្រមតែមួយដែលខ្លួនផ្តល់ថវិកាសម្រាប់យុទ្ធនាការរបស់ពួកគេ ។ ទោះបីជាស្ថានភាពខុសគ្នាបន្តិចបន្តួចក៏ដោយ សក្តានុពលភាពនៃជម្លោះផលប្រយោជន៍ គឺស្រដៀងគ្នាទៅនឹងការកាត់សេចក្តីរបស់ចៅក្រមពីភាគីដែលបានផ្តល់ប្រាក់ទៅចៅក្រម ។ ជាថ្មីម្តងទៀត ទោះបីជាគ្មានច្បាប់ហាមប្រាមក៏ដោយ លទ្ធភាពដែលជនរងគ្រោះប្រើប្រាស់ឥទ្ធិពលហិរញ្ញវត្ថុមកលើចៅក្រមរបស់ខ្លួន ហាក់ដូចជាបង្ហាញអំពីជម្លោះផលប្រយោជន៍ដ៏សំខាន់មួយ ។ ជម្លោះដ៏មានសក្តានុពលនេះអាចត្រូវការពិភាក្សា ពីព្រោះគេមិនទាន់ដឹងច្បាស់នៅឡើយថា តើអង្គជំនុំជម្រះវិសាមញ្ញនឹងអនុញ្ញាតឲ្យមានបណ្តឹងពីបុគ្គលជាលក្ខណៈ

ឯកជនដែរឬយ៉ាងណានោះទេ ។

ទោះបីជាយ៉ាងក៏ដោយ ក្នុងព្រឹត្តិការណ៍ដែលបណ្តឹងបែបនេះត្រូវបានអនុញ្ញាត ភ្នាក់ងារនេះអាចប្រើប្រាស់ការសម្រេចចិត្តរបស់ខ្លួនក្រោមច្បាប់អង្គជំនុំជម្រះវិសាមញ្ញនូវភាសាថា («អាចទទួលយក») ក្នុងការបដិសេធចំពោះថវិកាវិភាគទានពីភាគីដែលអាចមានផលប៉ះពាល់ទៅដល់អព្យាក្រឹតភាពរបស់តុលាការ ។ ក៏ប៉ុន្តែការរៀបចំបែបនេះ អាចមានផលប៉ះពាល់ទៅដល់ការរំលោភបំពានលើភាសានេះ ។ ដោយមានការជ្រើសរើស ភ្នាក់ងារនេះអាចរក្សាព័ត៌មានម្ចាស់ជំនួយទាំងអស់យ៉ាងសម្ងាត់ ហើយភ្នាក់ងារនេះក៏អាចគ្រប់គ្រងថវិកានិងកសាងកំផែងចិនដើម្បីការពារកុំឲ្យព្រះរាជអាជ្ញានិងចៅក្រមដឹងថា តើនរណាបានរួមវិភាគទានអ្វី ។

ជម្រើសមួយទៀតនោះគឺថា អង្គជំនុំជម្រះវិសាមញ្ញតម្រូវឲ្យម្ចាស់ជំនួយទាំងអស់ឧបត្ថម្ភជាសម្ភារផ្សេងៗសម្រាប់តុលាការប្រើប្រាស់មិនមែនជាថវិកានោះទេ ។ តុលាការអន្តរជាតិបានទទួលជោគជ័យក្នុងការទទួលយកជំនួយសប្បុរសជាច្រើនឆ្នាំមកហើយ ។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ២០០០ ក្រុមព្រះរាជអាជ្ញាអាមេរិក បានសហការជាមួយក្រុមហ៊ុន អាយ ប៊ី អ៊ឹម ដែលបានឧបត្ថម្ភថវិកាចំនួនបីលានដុល្លារជាសម្ភារកុំព្យូទ័រ បច្ចេកទេស និងវគ្គហ្វឹកហ្វឺនទៅដល់តុលាការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិនៅក្នុងប្រទេសបូស្នៀនិងរ៉្វាន់ដា ។ ការឧបត្ថម្ភនេះបានបង្ហាញពីថវិកាវិភាគទានឯកជនដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្រនៃតុលាការទាំងនោះ ។ ក៏ប៉ុន្តែ ការរឹតត្បិតទៅលើវិភាគទានបែបនេះ មិនបានផ្តល់នូវភាពល្អប្រសើរទៅដល់អង្គជំនុំជម្រះវិសាមញ្ញនិងម្ចាស់ជំនួយឡើយ ។ មានផលប្រយោជន៍ច្រើនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងការចំណាយថវិកាទៅតាមតម្រូវការរបស់ខ្លួន (ជាឧទាហរណ៍ លើគម្រោងបច្ចេកទេសនិងគម្រោងចុះផ្សព្វផ្សាយ) ។ ជាងនេះទៀត វាមានភាពងាយច្រើនសម្រាប់ក្រុមហ៊ុនឯកជននិងបុគ្គលក្នុងការផ្តល់ជាមូលប្បទានប័ត្រជាជាងការដឹកជញ្ជូនសម្ភារដែលមានតម្លៃថ្លៃពីក្រៅប្រទេស ។ បន្ថែមពីនេះទៀត ការទទួលវិភាគទានសប្បុរសផ្តល់ឱកាសច្រើនក្នុងការប្រើប្រាស់ថវិកាវិភាគទានដើម្បីជះឥទ្ធិពលលើតុលាការ ឬសូកប៉ាន់ចៅក្រម ។ ការទិញរថយន្តដែលមានតម្លៃថ្លៃសម្រាប់ព្រះរាជអាជ្ញា (មិនថារថយន្តទាំងនេះប្រើប្រាស់ចាំបាច់សម្រាប់ការដឹកជញ្ជូនអ្វីនោះទេ) អាចជាឧបករណ៍នៃអំពើពុករលួយដ៏មានអានុភាពដូចគ្នានឹងការបង់តម្លៃរថយន្តទាំងនេះជាសាច់ប្រាក់ដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ ការបង្កើតភ្នាក់ងារដូចដែលបានរៀបរាប់ពីមុនៗក្នុងការប្រយុទ្ធប្រឆាំងនឹងឥទ្ធិពលហិរញ្ញវត្ថុនៃប្រទេសជាម្ចាស់ជំនួយឯកជន អាចនឹងធ្វើឲ្យថវិកាវិភាគទានឯកជនទាំងអស់មានភាពអព្យាក្រឹតដូចៗគ្នា ។ ជម្លោះផលប្រយោជន៍អាចចៀសវាងទៅបានដោយតម្រូវជាចាំបាច់ឲ្យម្ចាស់ជំនួយឯកជនទាំងអស់ត្រូវផ្តល់តាមរយៈមូលនិធិឯករាជ្យមួយ ។ម្យ៉ាងទៀត មូលនិធិដែលនេះដែលជាអ្នកបែងចែកថវិកាដែលផ្តល់ដោយក្រុមហ៊ុនធំៗទៅឲ្យតុលាការ ក៏អាចទទួលយកនិងបែងចែកថវិកាវិភាគទានជាបុគ្គលបានផងដែរ ។ បន្ទាប់ពីការដាក់បញ្ចូលទៅក្នុងមូលនិធិថវិកាជាបុគ្គលនឹងជាផ្នែកមួយនៃហិបលុយដ៏ធំមួយដែលមានលក្ខណៈជាអនាមិក ។

### សំណើ

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញពិតជាមានបំណងចង់រៃអង្គាសថវិកាវិភាគទានឯកជនអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបង្កើតការិយាល័យផ្ទៃក្នុងដើម្បីទទួលនិងបែងចែកថវិកាទាំងនេះ ។

ទីភ្នាក់ងារនេះ គួរតែសហប្រតិបត្តិការជាមួយការិយាល័យគណនេយ្យអង្គជំនុំជម្រះវិសាមញ្ញដើម្បីរក្សាការផ្តល់ព័ត៌មាននូវចន្លោះខុះខាតនៅក្នុងថវិការបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ភ្នាក់ងារនេះ គួរតែធ្វើឲ្យតម្រូវការចាំបាច់ហិរញ្ញវត្ថុនៃអង្គជំនុំជម្រះវិសាមញ្ញមានលក្ខណៈស៊ីគ្នាទៅនឹងសេចក្តីណែនាំ (ឬការរឹតត្បិត) របស់ម្ចាស់ជំនួយ ។

ភ្នាក់ងារនេះ គួរតែមានរបាយការណ៍ត្រួតពិនិត្យបញ្ជីក្នុងការផ្តល់ព័ត៌មានទៅម្ចាស់ជំនួយនិងឲ្យសាធារណមតិបានដឹងអំពីចំនួនថវិកាដែលអង្គជំនុំជម្រះវិសាមញ្ញកំពុងតែចំណាយ ។

ក្នុងករណីដែលបណ្តឹងទាមទារឯកជនត្រូវបានអនុញ្ញាតថវិកាវិភាគទានរបស់ភាគីរដ្ឋប្បវេណីដែលជាប់ទាក់ទិននឹងរឿងក្តីអង្គជំនុំជម្រះវិសាមញ្ញ គួរតែត្រូវហាមប្រាមដាច់ខាត ឬត្រូវបានទទួលយកក្នុងលក្ខណៈជាវិភាគទានអនាមិកតាមរយៈទីភ្នាក់ងារនេះ ។

**អាលីសុន ខេមហាយ**

# ការបង្ហាញអំពីការរំលោភច្បាប់របស់ខ្មែរក្រហម ការប្រើប្រាស់និងការកំណត់ទៅលើភ័ស្តុតាងដែលមាន

*(តចប់)*

## *ការវាយប្រហារក្នុងទ្រង់ទ្រាយធំ*

ភ័ស្តុតាងដែលត្រូវបានបោះបង់ចោល និងដែលបានបង្ហាញអំពីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនូវទូទាំងប្រទេសដោយរបបកម្ពុជាប្រជាធិបតេយ្យ នឹងអាចយកមកប្រើប្រាស់បាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឧទាហរណ៍ សំបុត្រឆ្លើយឆ្លងរបស់បក្សកុម្មុយនីស្តកម្ពុជា ចម្លើយសារភាព និងអត្ថបទបទសម្ភាសន៍ ព្រមទាំងផែនទីរណ្តៅសាកសព គុក និងមជ្ឈមណ្ឌលធ្វើទារុណកម្ម សុទ្ធតែបានបង្ហាញពីទំហំនៃអំពើឧក្រិដ្ឋដ៏ធំធេងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ជាក់ស្តែងករណី នួន ជា បង្ហាញអំពីភាពអាចប្រើប្រាស់បាននៃភ័ស្តុតាងមួយចំនួន ដើម្បីកសាងសំណុំរឿងអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ភ័ស្តុតាងទាំងនោះអាចត្រូវបានប្រើដើម្បីបង្ហាញថា នួន ជា បានដឹងពីគោលនយោបាយកាប់សម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានអនុវត្តនូវទូទាំងប្រទេស ។ តួនាទីរបស់ នួន ជា ដែលជាអនុលេខាគណៈកម្មាធិការមជ្ឈិមនិងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបង្ហាញថា គាត់គឺជាមន្ត្រីជាន់ខ្ពស់ម្នាក់នៃរបបនេះ ។ ភ័ស្តុតាងបានបង្ហាញយ៉ាងច្បាស់ថា នៅក្នុងតំណែងនេះ នួន ជា គឺជាមេដឹកនាំម្នាក់ដែលបានដាក់ចេញនិងអនុវត្តគោលនយោបាយសម្លាប់រង្គាលរបស់កម្ពុជាប្រជាធិបតេយ្យ ។ អត្ថបទសម្ភាសន៍ក្រោយឆ្នាំ១៩៧៩ ជាមួយ ឌុច ដែលជាប្រធានមន្ទីរស-២១ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ អាចប្រើដើម្បីបង្ហាញថា នួន ជា ជាប់ពាក់ព័ន្ធច្រើនក្នុងការអនុវត្តគោលនយោបាយទាំងនោះ ។ ឧទាហរណ៍ ឌុច បាននិយាយនៅក្នុងបទសម្ភាសន៍ជាមួយអ្នកកាសែត នេត ថៃយ័រ ថា នួន ជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តផែនការវិសុទ្ធកម្មក្នុងទ្រង់ទ្រាយធំទៅលើសមាជិកបក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេស ។ ឌុច បានបន្ថែមថា នួន ជា, ប៉ុល ពត និង សុន សេន គឺជាអ្នកធ្វើសេចក្តីសម្រេចចិត្តចម្បងនៅក្នុងកិច្ចប្រជុំឆ្នាំ១៩៧៨ ដែលបានសម្រេចធ្វើវិសុទ្ធកម្មទៅលើកម្មាភិបាលភូមិភាគបូព៌ា ។ ឌុច បាននិយាយបន្តទៀតថា ក្រោយឆ្នាំ១៩៧៥ ប៉ុល ពត បានណែនាំឲ្យស៊ើបរកខ្មាំងផ្ទៃក្នុងបក្ស ប៉ុន្តែ ប៉ុល ពត បានប្រើប្រាស់ នួន ជា ក្នុងការចាប់ខ្លួនសមាជិកបក្សកុម្មុយនីស្តនៅតាមបណ្តាភូមិភាគជាច្រើន ។ ឌុច ក៏បាននិយាយដែរថា នួន ជា បានបញ្ជាឲ្យមានការសម្លាប់ដោយផ្ទាល់តាមរយៈ សុន សេន ឬ ឌុច ។ ឌុច បាននិយាយជាមួយ នេត ថៃយ័រ ថា នួន ជា បានបញ្ជាគាត់ផ្ទាល់ឲ្យសម្លាប់មន្ត្រីជាន់ខ្ពស់និងក្រុមមួយចំនួន ។ ឧទាហរណ៍ ឌុច និយាយថា នួន ជា បានបញ្ជាឲ្យខ្លួនសម្លាប់កងទ័ពខ្មែរក្រហម ៣០០នាក់ «មិនចាំបាច់សួរចម្លើយទេ សម្លាប់ពួកវាចោលទៅ» ។ ឌុច បានសារភាពថាខ្លួនបានធ្វើតាមការបញ្ជានេះ ។

ឌុច បានបន្តទៀតថា នួន ជា ទាមទារឲ្យបង្ហាញភ័ស្តុតាងពីការសម្លាប់មនុស្សមួយចំនួន ។ «ឧទាហរណ៍ នួន ជា បានទាមទារឲ្យខ្ញុំប្រគល់រូបថតសាកសពជាភ័ស្តុតាង ។ គាត់បានបញ្ជាឲ្យខ្ញុំយករូបថតទាំងនេះទៅឲ្យគាត់នៅការិយាល័យធ្វើការរបស់គាត់» ។ នៅពេលសាកសពមនុស្សសំខាន់ម្នាក់ត្រូវបានកប់មុនពេលថតរូប នួន ជា បានបញ្ជា ឌុច «ឲ្យគាស់សាកសព វ៉ន វេត ដើម្បីថតរូប ព្រោះ នួន ជា ត្រូវការភ័ស្តុតាងដែលបញ្ជាក់ថា វ៉ន វេត ពិតជាត្រូវបានសម្លាប់មែន» ។ ឧបមាថា ការអះអាងទាំងនេះត្រូវបានអនុញ្ញាតឲ្យប្រើជាភ័ស្តុតាង ឬថា ឌុច ផ្តល់កសិណសាក្សីប្រហាក់ប្រហែលនេះនៅក្នុងតុលាការ ភ័ស្តុតាងទាំងនេះនឹងជួយក្នុងការបញ្ជាក់ថា នួន ជា បានដឹងអំពីការសម្លាប់និងការធ្វើទារុណកម្មនៅក្នុងភូមិភាគមួយចំនួនដែលប្រហែលជាគ្រប់គ្រាន់ក្នុងការចោទគាត់ពីបទឧក្រិដ្ឋក្នុងទ្រង់ទ្រាយធំ ។

ការអនុវត្តយ៉ាងទូលំទូលាយនូវនយោបាយកាប់សម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្ហាញនៅក្នុងពាក្យបណ្តឹងរបស់អ្នកនៅរស់រានមានជីវិត ដែលសរសេរឡើងបន្ទាប់ពីការដួលរលំ

នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឧទាហរណ៍ ពាក្យបណ្តឹងដែលសរសេរដោយប្រជាពលរដ្ឋម្នាក់មកពីខេត្តសៀមរាបបានរៀបរាប់ថា ខ្មែរក្រហមបានសម្លាប់សមាជិកគ្រួសាររបស់គាត់ចំនួន៦០នាក់និងបំផ្លាញផ្ទះ១៧ខ្នង ។ ពាក្យបណ្តឹងពីខេត្តកណ្តាលបានកត់ត្រាថា ខ្មែរក្រហមសម្លាប់ប្រជាជន១២៨នាក់នៅក្នុងភូមិមួយ ដែលក្នុងនោះមានស្ត្រីមេម៉ាយ៦៥នាក់និងកូនក្មេង៨នាក់ ។ ពាក្យបណ្តឹងមួយទៀតសរសេរដោយប្រជាពលរដ្ឋមកពីខេត្តកណ្តាលបានរៀបរាប់ថា ប្រជាជន៨៤៧នាក់ក្នុងភូមិមួយត្រូវបានសម្លាប់ ហើយមនុស្ស២២នាក់ធ្លាក់ខ្លួនពិការនិងកុមារ៣៦នាក់ក្លាយជាក្មេងកំព្រា ។ អ្នកសរសេរពាក្យបណ្តឹងនេះ បានរៀបរាប់ពីវិធីដែលខ្មែរក្រហមសម្លាប់មនុស្ស ៖ «ពួកវាប្រើវិធីសាស្ត្រជាច្រើនក្នុងការសម្លាប់មនុស្ស ដូចជាវាយក្បាលនឹងចបឬដំបងឈើ អារ-កនឹងធាងត្នោត កប់ទាំងរស់ ប្រើទារុណកម្មដោយឆក់នឹងខ្សែភ្លើង ដកក្រចក កិនសម្លាប់នឹងត្រាក់ទ័រ និងវះពោះយកថ្លើម» ។ ពាក្យបណ្តឹងរបស់អ្នកនៅរស់រានមានជីវិតទាំងនេះនឹងពាក្យបណ្តឹងប្រហាក់ប្រហែលផ្សេងៗទៀត អាចប្រើដើម្បីបង្ហាញថា ខ្មែរក្រហមបានប្រព្រឹត្តបទឧក្រិដ្ឋនៅទូទាំងប្រទេសកម្ពុជា ។

## ការវាយប្រហារជាប្រព័ន្ធ

បន្ថែមលើការបង្ហាញថា នួន ជា បានដឹងពីឧក្រិដ្ឋកម្មដែលមានវិសាលភាពធំធេង ភ័ស្តុតាងផ្សេងៗទៀតអាចត្រូវបានប្រើដើម្បីបង្ហាញថា គាត់បានដឹងពីបទល្មើសដែលមានលក្ខណៈជាប្រព័ន្ធ ។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះអតីតមន្ត្រីរបស់រដ្ឋាភិបាល លន់ នល់ បាននាំដល់ការសម្លាប់បំផុតពូជនៃក្រុមនេះ ហើយគោលនយោបាយរបស់បក្សចំពោះដំណើរការរបស់មន្ទីរស-២១ និងវាលពិឃាតជើងឯក បាននាំទៅដល់ការសម្លាប់រង្គាលជាប្រព័ន្ធចំពោះជនស្ទើរគ្រប់រូបដែលត្រូវបានចាប់ខ្លួនបញ្ជូនចូលកន្លែងទាំងនេះ ។ ភ័ស្តុតាងជាឯកសារអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញថា នួន ជា គឺជាអ្នកដាក់ចេញនូវគោលនយោបាយទាក់ទិននឹងមន្ត្រីនៃរដ្ឋាភិបាល លន់ នល់ ហើយវាក៏បានបង្ហាញផងដែរថា យ៉ាងហោចណាស់ក៏ នួន ជា បានដឹងអំពីគោលនយោបាយនិងលទ្ធផលដែលបន្សល់ទុកនៅមន្ទីរស-២១និងវាលពិឃាតបឹងជើងឯក ។

ភ័ស្តុតាងឯកសារដែលបង្ហាញយ៉ាងច្បាស់អំពីការជាប់ពាក់ព័ន្ធរបស់ នួន ជា នៅក្នុងផែនការកម្ទេចជាប្រព័ន្ធមន្ត្រីរដ្ឋាភិបាល លន់ នល់ គឺរបាយការណ៍ស្តីពីសេចក្តីថ្លែងការណ៍របស់គាត់ក្នុងឱកាសមហាសន្និបាតបក្សឆ្នាំ១៩៧៥ ។ បទសម្ភាសន៍ចំនួនបីដែលធ្វើឡើងដោយអ្នកសិក្សាស្រាវជ្រាវខ្មែរជាន់ខ្ពស់មួយរូបបានរៀបរាប់ពីបទបញ្ជារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទៅកាន់អ្នកនៅក្រោមបង្គាប់ក្នុងការ«សម្លាប់» ឬ«បោសសម្អាត»មន្ត្រីរបស់រដ្ឋាភិបាលលន់នល់ដែលសេសសល់ ។ បន្ថែមពីលើបទបញ្ជាទាំងនោះ នួន ជា បានពន្យល់បន្ថែមថា«យើងត្រូវតែកម្ទេចអតីតទាហានពីរបបចាស់ចោល ។ ពួកវានឹងមិនកែគំនិតទេ ដូច្នេះយើងត្រូវតែកម្ទេចពួកវាចោល» ។ ក្នុងករណីដូចគ្នានេះ ចម្លើយសារភាពរបស់អតីតលេខាភូមិភាគបស្ចិមបានកត់ត្រាថា នៅឆ្នាំ១៩៧៦ នួន ជា បានទៅជួបគាត់ហើយ បានប្រាប់គាត់ឲ្យសម្លាប់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរទាំងអស់នៅក្នុងស្រុករបស់គាត់ «ព្រោះពួកវាមិនងាយបោះបង់ចោលគំនិតចាស់របស់ពួកវាទេ» ។ អត្ថបទសម្ភាសន៍និងចម្លើយសារភាពទាំងនេះបានចង្អុលបង្ហាញយ៉ាងច្បាស់ថា នួន ជា បានដឹកនាំការអនុវត្តគោលនយោបាយកាប់សម្លាប់ជាប្រព័ន្ធទៅលើមន្ត្រីនៃរដ្ឋាភិបាលលន់នល់ ហើយវានឹងជាភ័ស្តុតាងដ៏មានប្រសិទ្ធភាពក្នុងការកសាងសំណុំរឿងប្រឆាំងនឹង នួន ជា ។

អត្ថបទសម្ភាសន៍របស់ នេត ថៃយ៉េរ ជាមួយ ឌុច បានផ្តល់ជាភ័ស្តុតាងដ៏មានប្រយោជន៍ក្នុងការចោទប្រកាន់ នួន ជា ពីបទឧក្រិដ្ឋនៃការធ្វើទារុណកម្មនិងការសម្លាប់ជាប្រព័ន្ធដែលធ្វើឡើងនៅមន្ទីរស-២១ ។ យោងតាមសម្តីរបស់ ឌុច, នួន ជា បានបញ្ជាឲ្យធ្វើការសម្លាប់ជាញឹកញាប់ ។ ដូចដែលបានគូសបញ្ជាក់ខាងលើ នួន ជា បានបញ្ជាឲ្យ ឌុច ផ្តល់ភ័ស្តុតាងពីការសម្លាប់ទាំងឡាយនៅមន្ទីរស-២១ «ដោយបញ្ជាឲ្យ ឌុច យករូបថតសាកសពជនរងគ្រោះទៅមន្ទីររបស់គាត់» ។ អត្ថបទសម្ភាសន៍នេះនឹងផ្តល់ជាភ័ស្តុតាងសំខាន់ក្នុងការចោទប្រកាន់ នួន ជា ពីការរំលោភបំពានជាប្រព័ន្ធដែលកើតមានឡើងនៅមន្ទីរស-២១ ។

## ចេតនាក្នុងការវាយប្រហារក្រុមដែលត្រូវបានការពារ

ដូចដែលបានពិភាក្សានៅក្នុងជំពូកទី២ ដើម្បីបង្ហាញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រះរាជអាជ្ញាត្រូវតែបង្ហាញថា អំពើនោះត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមមួយដែលត្រូវបានការពារ ។ ព្រះរាជអាជ្ញាត្រូវតែបង្ហាញថា ការវាយប្រហារនេះត្រូវបានធ្វើឡើងដោយចេតនារើសអើងផ្អែកលើហេតុផលជាតិសាសន៍ ជនជាតិ ជាតិពន្ធុ ឬនយោបាយ ។ មានភ័ស្តុតាង ជាច្រើនដែលបង្ហាញថាខ្មែរក្រហមប្រព្រឹត្តបទឧក្រិដ្ឋដោយផ្អែកលើហេតុផលនយោបាយ ។ ភ័ស្តុតាងពីរដែលបានពិភាក្សារួចក៏បានបង្ហាញដែរថា នួន ជា មានចេតនារើសអើងដោយឈរលើហេតុផលនយោបាយ ។ ភ័ស្តុតាងទី១គឺសេចក្តីថ្លែងការណ៍របស់គាត់ដែលបានធ្វើឡើងនៅក្នុងមហាសន្និបាតបក្សឆ្នាំ១៩៧៥ ។ ការបញ្ជាឲ្យសម្លាប់អតីតមន្ត្រីនិងទាហាននៃរបប លន់ នល់ ដោយសារតែអ្នកទាំងនេះ“មិនព្រមផ្លាស់ប្តូរទស្សនៈ” គឺជាការផ្អែកហេតុផលនៃការសម្លាប់ទៅលើដំហរនយោបាយរបស់ជនរងគ្រោះ ។ ភ័ស្តុតាងទីពីរគឺ បទបញ្ជារបស់គាត់ទៅកាន់អ្នកនៅក្រោមបង្គាប់ឲ្យសម្លាប់អតីតទាហានសាធារណរដ្ឋខ្មែរទាំងអស់នៅក្នុងស្រុកមួយ ពីព្រោះទាហានទាំងនេះមិនអាច“ផ្លាស់ប្តូរទស្សនៈរបស់ខ្លួនបាន....” ។ ការបញ្ជាឲ្យសម្លាប់នេះក៏ផ្អែកលើដំហរនយោបាយរបស់ជនរងគ្រោះដែរ ។ ភ័ស្តុតាងផ្សេងទៀត ដែលបង្ហាញអំពីមូលដ្ឋានក្នុងការវាយប្រហារបែបនេះ នឹងពង្រឹងសំណុំរឿងនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រឆាំងនឹង នួន ជា ។ យ៉ាងណាមិញ ទោះបីជាភ័ស្តុតាងទាំងនេះមិនបានបង្ហាញឲ្យច្បាស់ដូចករណីឧក្រិដ្ឋកម្មនៃអំពើទារុណកម្មប្រឆាំងនឹង ឌុច ក៏វានឹងមិនអាចជាឧបសគ្គដែលមិនអាចជម្នះបានសម្រាប់ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ។

បទសម្ភាសន៍ថ្មីដែលធ្វើឡើងដោយបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយអតីតកម្មាភិបាលខ្មែរក្រហមក៏បានបង្ហាញថា ចេតនាក្នុងការកម្ទេចអ្នកដែលស្រលាញ់របបចាស់គឺ កើតចេញមកពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយបក្សកុម្មុយនីស្តកម្ពុជា ។ អតីតកម្មាភិបាលម្នាក់មកពីខេត្តតាកែវបានរាយការណ៍ថា អ្នកទាំងឡាយនៅក្នុងឃុំរបស់គាត់ដែលធ្លាប់មានតំណែងចាប់ពីថ្នាក់អនុសេនីយ៍ទោឬខ្ពស់ជាងនេះ ក្នុងជួរយោធារបស់ លន់ នល់ ត្រូវបានចោទថាជាអ្នក“មាននិន្នាការ” ហើយត្រូវបានសម្លាប់ ។ ទោះជាយ៉ាងនេះក្តី អតីតមន្ត្រីស៊ីវិលនិងទាហានថ្នាក់ទាបជាងនេះត្រូវបានយកទៅអប់រំ ។ អតីតកម្មាភិបាលម្នាក់ទៀតមកពីខេត្តកំពង់ចាមបាននិយាយថា ការសម្លាប់ភាគច្រើនកើតឡើងនៅថ្នាក់ស្រុក ។ គាត់បានបញ្ជាក់ថា ជនរងគ្រោះគឺជាមន្ត្រីនិងទាហានសាធារណរដ្ឋខ្មែរនិងក្រុមគ្រួសារ ។ អតីតកម្មាភិបាលម្នាក់ទៀតបាននិយាយថា នៅក្នុងភូមិរបស់គាត់នៅខេត្តតាកែវ ប្រជាជនទាំងឡាយណាដែលប្រវត្តិរូបរបស់ខ្លួនមានជាប់ពាក់ព័ន្ធនឹងឧត្តមសេនីយ៍នៃរបប លន់ នល់ ត្រូវបានចាប់ខ្លួនជាក្រុមពី១០ទៅ២០នាក់ ហើយយកទៅសម្លាប់ចោល ។ ទោះបីជាសេចក្តីរាយការណ៍ទាំងនេះមិនបានចោទប្រកាន់ នួន ជា ជាលក្ខណៈបុគ្គល ព្រះរាជអាជ្ញាអាចអះអាងថា ដោយសារ នួន ជា ជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា គាត់បានរួមចំណែកក្នុងផែនការដែលដាក់ចេញដោយអង្គការនេះ ។


ក្រុមសិល្បៈនៅក្នុងរបបខ្មែរក្រហម

## ឧទាហរណ៍ទី៣ : ការបង្ហាញពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ឧទាហរណ៍ទី៣បង្ហាញពីផលវិបាកមួយចំនួន ដែលព្រះរាជអាជ្ញានឹងជួបប្រទះក្នុងការបង្ហាញពីទោសកំហុសរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ចំពោះបទឧក្រិដ្ឋអន្តរជាតិដ៏ល្បីល្បាញមួយគឺឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានពិភាក្សាយ៉ាងលម្អិតនៅក្នុងជំពូកទី២ ។ ជា

ការសង្ខេប ដើម្បីបង្ហាញពីបទឧក្រិដ្ឋនេះ ព្រះរាជអាជ្ញាត្រូវរកឲ្យឃើញថា ១) អំពើឃោរឃៅដូចជាការសម្លាប់ ឬការបង្កឲ្យមានរបួសធ្ងន់ធ្ងរដល់រូបរាងកាយត្រូវបានប្រព្រឹត្តឡើង ២) ប្រឆាំងនឹង"ក្រុមជនជាតិ ក្រុមជាតិពន្ធ ក្រុមជាតិសាសន៍ និងក្រុមសាសនា" ៣) ដោយចេតនាបំផ្លាញក្រុមនោះ ទាំងស្រុងឬដោយផ្នែក ។ ទោះបីជាពាក្យ"ប្រល័យពូជសាសន៍"ត្រូវបានប្រើជាញឹកញាប់សំដៅទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏តាមការពិតវាមានការលំបាកក្នុងការបង្ហាញឧក្រិដ្ឋកម្មប្រភេទនេះនៅចំពោះមុខតុលាការ ។ ភស្តុតាងដែលថា កម្ពុជាប្រជាធិបតេយ្យប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ទៅលើជនជាតិភាគតិចមួយចំនួនដូចជាជនជាតិចាម ព្រះសង្ឃ អ្នកកាន់ពុទ្ធសាសនា និងជនជាតិវៀតណាម ប្រហែលជាមានទម្ងន់គ្រប់គ្រាន់សម្រាប់កាត់សេចក្ដីយ៉ាងហោចណាស់ចុងចោទមួយចំនួន ។ ប៉ុន្តែ ការស្វែងរកភស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីបង្ហាញពីចេតនាទាក់ទងនឹងការសម្លាប់រង្គាលជនជាតិខ្មែរទូទៅ ទោះបីជាអាចធ្វើទៅបានក៏នឹងជួបការលំបាកខ្លាំងណាស់ដែរ ។ វិសាលភាពតូចចង្អៀតនៃនិយមន័យនៃ "អំពើប្រល័យពូជសាសន៍" ក្រោមច្បាប់អន្តរជាតិនឹងមានន័យថា ចុងចោទមួយចំនួនតូចប៉ុណ្ណោះនឹងត្រូវបានធ្វើការកាត់ទោសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជនខ្មែរទូទៅ ។



ឧទាហរណ៍ចំពោះករណី អៀង សារី គូសបញ្ជាក់ពីភាពកម្រនៃភស្តុតាងក្នុងការបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានធ្វើសកម្មភាពប្រកបដោយចេតនាប្រល័យពូជសាសន៍ ដែលតម្រូវឲ្យបង្ហាញដោយអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ ។ អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ក៏ដូចជាសមាជិកគណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ។ ក្នុងតំណែងទាំងនេះ គាត់ត្រូវបានចោទប្រកាន់ថា មានហេតុផលយ៉ាងហោចណាស់អាចដឹងពីអំពើឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយរបបនេះ ទោះបីជាគាត់មិនបានចូលរួមក្នុងការធ្វើផែនការនិងអនុវត្តអំពើទាំងអស់នោះដោយខ្លួនគាត់ផ្ទាល់ក៏ដោយ ។ ជាងនេះទៅទៀត បុគ្គលិកជាច្រើននៅក្នុងក្រសួងរបស់គាត់ត្រូវបានចាប់ឃុំឃាំងនិងសម្លាប់ក្នុងអំឡុងពេលវិសុទ្ធកម្មនៅក្នុងបក្ស ។ តួនាទីរបស់ អៀង សារី នៅក្នុងរចនាសម្ព័ន្ធបក្សរួមជាមួយនឹងបរាជ័យរបស់គាត់ក្នុងការទប់ស្កាត់និងដាក់ទោសបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់បានបង្ហាញឲ្យឃើញច្បាស់ថា គាត់អាចត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំចំពោះឧក្រិដ្ឋកម្មជាច្រើន ។ ទោះជាយ៉ាងនេះក្ដី ថាតើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ស្ថិតក្នុងចំណោមឧក្រិដ្ឋកម្មទាំងនោះឬយ៉ាងណានោះគឺជាបញ្ហាមួយផ្សេងនិងពិបាកដោះស្រាយ ។

បទឧក្រិដ្ឋដែល អៀង សារី អាចត្រូវបានរកឃើញថា មានការទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំមានច្រើននិងផ្សេងៗគ្នា ។ មានភស្តុតាងជាច្រើនដែលបង្ហាញថា គាត់ពិតជាបានដឹងនិងថែមទាំងបានគាំទ្រនិងអនុវត្តគោលនយោបាយកាប់សម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជាទៀតផង ។ ឧទាហរណ៍ជាក់ស្ដែងពីរនៃភស្តុតាងដែលមានទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់ អៀង សារី ដែលបានបង្ហាញថាគាត់ពិតជាបានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ ។ នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៧ អៀង សារី បានធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈរំឭកខួបអនុស្សាវរីយ៍នៃថ្ងៃជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា ។ អៀង សារី បាននិយាយថា "សត្រូវ" បានព្យាយាម"បំផ្លាញ"គ្រាប់ពូជនៃជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ដើម្បីប្រឆាំងតបទៅនឹងឧបាយកលទាំងនោះ "ប្រជាជននិងកងទ័ពបដិវត្តន៍កម្ពុជាបានកម្ទេចរាល់ឧបាយកលរបស់ខ្មាំង បំផ្លាញបណ្ដាញស៊ើបការណ៍សម្ងាត់ និងទទួលជោគជ័យក្នុងការថែរក្សាឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដី និងគ្រាប់ពូជបដិវត្តន៍ដ៏ពិសិដ្ឋរបស់យើង" ។ នៅឆ្នាំដដែលនេះ អៀង សារី បានថ្លែងទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិដោយសង្កត់ធ្ងន់ថា "ខ្មាំងគ្រប់ប្រភេទបានព្យាយាមគ្រប់វិធីសាស្ត្រដើម្បីបំផ្លាញកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែការប៉ុនប៉ងរាល់ការធ្វើវិទ្ធង្សនាត្រូវបានបំផ្លាញទាំងស្រុង" ។ ដោយសារសេចក្ដីថ្លែង

ការណ៍ទាំងនេះត្រូវបានធ្វើឡើងក្នុងអំឡុងពេលដែលបក្សកុម្មុយនីស្តកម្ពុជាកំពុងប្រព្រឹត្តបទឧក្រិដ្ឋនៅទូទាំងប្រទេស សេចក្តីថ្លែងការណ៍ទាំងនេះមិនត្រឹមតែបានបញ្ជាក់ពីការយល់ដឹងទេ ថែមទាំងបង្ហាញថាបានជំរុញគោលនយោបាយឧក្រិដ្ឋទាំងនោះទៀតផង ។ នេះគឺជាឧទាហរណ៍ពីក្នុងចំណោមភស្តុតាងជាច្រើនដែលបង្ហាញថា អៀង សារី បានដឹងនិងបានចូលរួមក្នុងការអនុវត្តផែនការឧក្រិដ្ឋដែលប្រព្រឹត្តដោយបក្សកុម្មុយនីស្តកម្ពុជាទៀតផង ។ ដូច្នេះការបង្ហាញថា អៀង សារី មានជាប់ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍មិនមានការពិបាកទេ ។

កិច្ចការដែលលំបាកជាងនេះគឺការបង្ហាញថា អៀង សារី ក៏ដូចជាបក្សកុម្មុយនីស្តកម្ពុជាជាទូទៅ មានចេតនាក្នុងការប្រព្រឹត្តអំពើទាំងអស់នោះ ។ ប្រសិនបើ អៀង សារី ប្រព្រឹត្តអំពើណាមួយប៉ុន្តែមិនមែនសំដៅបំផ្លាញដល់ក្រុមដែលត្រូវបានការពារទាំងស្រុងឬដោយផ្នែកទេនោះ គាត់នឹងមិនអាចត្រូវបាននាំយកមកកាត់ទោសពីបទប្រល័យពូជសាសន៍បានឡើយ ។ ការកាត់ទោស អៀង សារី និងអ្នកដទៃទៀតពីបទប្រល័យពូជសាសន៍លើក្រុមជនជាតិភាគតិច ប្រហែលជាងាយស្រួលជាងការកាត់ទោសមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពីបទប្រល័យពូជសាសន៍លើជនជាតិខ្មែរជាទូទៅ ។

## អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងក្រុមជនជាតិភាគតិច

យោងតាមអ្នកស្រាវជ្រាវនិងអ្នកនៅរស់រានមានជីវិតជាច្រើននៃរបបនេះ ខ្មែរក្រហមចម្រាញ់និងធ្វើទុក្ខបុកម្នេញយ៉ាងឃោរឃៅទៅលើជនជាតិចាម ព្រះសង្ឃ ជនជាតិវៀតណាម និងក្រុមជនជាតិភាគតិចដទៃទៀត ។ អំពើនេះគឺជាគម្រុយក្នុងការស្វែងរកការប៉ុនប៉ងកម្ទេចចោលក្រុមទាំងនោះ ។ ទោះបីមានការលំបាកក្នុងការស្វែងរកភស្តុតាងដើម្បីបង្ហាញថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យសំដៅប្រល័យពូជសាសន៍ជនជាតិភាគតិចខ្មែរ ភស្តុតាងទាំងនោះបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យមានបំណងសំដៅប្រល័យពូជសាសន៍ក្រុមជនជាតិភាគតិចវៀតណាម ។

ជាមួយនឹងការបង្ហាញពីធម្មជាតិចំពោះការវាយប្រហារលើជនជាតិភាគតិចវៀតណាម វាប្រហែលជាការពិតដែលថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដឹងពីទម្រង់នៃការវាយប្រហារ ។ ការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជាបង្ហាញអំពីគោលគំនិតនិងបញ្ជាក់ពីគោលនយោបាយរបស់ថ្នាក់ដឹកនាំនៃរបបនេះទៅលើជនជាតិវៀតណាម ។ ការឃោសនារបស់កម្ពុជាប្រជាធិប-តេយ្យមួយបានចាត់ទុកវៀតណាមថា ជា“សត្រូវដែលអាក្រក់បំផុត”របស់ខ្លួន នៅពេលការឃោសនាមួយទៀតនិយាយថា “ពួកវាមានកេរ្តិ៍ឈ្មោះស្អុយអសោច ហើយនឹងត្រូវរលាយសាបសូន្យ” ។ សេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបង្ហាញថារបបនេះបានដៅគោលគំនិតបែបនេះទៅក្នុងគោលការណ៍កាប់សម្លាប់ ។ ឯកសារទាំងនេះជាដំបូងបានបង្ហាញថាវៀតណាមគឺជាសត្រូវទីមួយរបស់បដិវត្តន៍ ហើយបន្ទាប់មកបានដាក់បទបញ្ជាថា សត្រូវទាំងអស់ត្រូវតែសម្លាប់ចោល ។ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើសេចក្តីថ្លែងការណ៍ពីផែនការរបស់ខ្លួនចំពោះជនជាតិវៀតណាមជាសាធារណៈ តាមរយៈវិទ្យុក្រុងភ្នំពេញនៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៧៨ ។ “យើងម្នាក់ៗត្រូវសម្លាប់យួន ៣០នាក់...តាំងពីដើមមកយើងទទួលបានជោគជ័យ...យើងត្រូវការមនុស្សតែពីរលាននាក់ដើម្បីកម្ទេចយួន៥០លាននាក់ ហើយយើងនៅសល់ប្រជាជន៦លាននាក់ទៀត....” ។

ដោយសំអាងទៅលើតួនាទីរបស់ខ្លួនក្នុងជួរដឹកនាំបក្សកុម្មុយនីស្តកម្ពុជា អៀង សារី ពិតជាបានដឹងនូវគំនិតនិងគោលនយោបាយនៃរបបនេះចំពោះជនជាតិវៀតណាម ។ ដោយសារតែមិនមានភស្តុតាងណាមួយបង្ហាញថា អៀង សារី បានចាត់វិធានការក្នុងការការពារ ឬដាក់ទោសចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាម ភស្តុតាងដែលបានពិភាក្សាខាងលើនឹងគ្រប់គ្រាន់សម្រាប់ចោទប្រកាន់ អៀង សារី ពីបទប្រល័យពូជសាសន៍ទៅលើក្រុមជនជាតិភាគតិច ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំ ។

## អំពើប្រល័យពូជសាសន៍ប្រឆាំងជនជាតិខ្មែរកាន់ព្រះពុទ្ធសាសនា

អំពើប្រល័យពូជសាសន៍ចំពោះជនជាតិខ្មែរកាន់ព្រះពុទ្ធសាសនាស្ថិតក្នុងចំណោមបទឧក្រិដ្ឋដែលមានការលំបាកក្នុងការបង្ហាញនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ក្នុងការចោទប្រកាន់ អៀង សារី ឬចុងចោទដទៃទៀត ។ ប្រជាជនខ្មែរពិតជាស្ថិតក្នុងជំពូកក្រុម

ជនជាតិដែលត្រូវបានការពារដោយអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងក៏ដូចជាក្រុមអ្នកកាន់ព្រះពុទ្ធសាសនាដែរ ។ ដូចដែលបានពិភាក្សាពីខាងលើវាជារឿងដែលមិនអាចប្រកែកបានដែលថា បក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តអំពើឧក្រិដ្ឋឃោរឃៅជាច្រើនប្រឆាំងនឹងជនជាតិខ្មែរនិងក្រុមអ្នកកាន់ពុទ្ធសាសនា ។ ការលំបាកគឺការបង្ហាញឲ្យឃើញថា បក្សកុម្មុយនីស្តកម្ពុជាសំដៅបំផ្លាញជនជាតិខ្មែរភាគច្រើនដែលកាន់ព្រះពុទ្ធសាសនានៅកម្ពុជាដោយឈរលើហេតុផលដែលថាអ្នកទាំងនេះ ជាសមាជិកនៃក្រុមនេះ និងមានបំណងបំផ្លាញក្រុមនេះទាំងស្រុង ឬដោយផ្នែក ។

មានភ័ស្តុតាងតិចតួចណាស់ដែលបង្ហាញថា បំណងបែបនេះពិតជាកើតមានឡើង ។ ផ្ទុយទៅវិញ ភ័ស្តុតាងភាគច្រើនបង្ហាញថាគោលនយោបាយកាប់សម្លាប់ទៅលើជនជាតិខ្មែរត្រូវបានអនុវត្តឡើង ដោយសារហេតុផលនយោបាយ ឬផែនការដ៏ឆ្គួតលេលា ។ បក្សកុម្មុយនីស្តកម្ពុជាព្យាយាមបង្កើតរដ្ឋកុម្មុយនីស្តមួយដោយធ្វើវិសុទ្ធកម្មទៅលើជនទាំងឡាយណាដែលមានជំហរនយោបាយផ្ទុយ ។ របាយការណ៍ដែលផ្ញើទៅគណៈអចិន្ត្រៃយ៍ ដែលមាន អៀង សារី ជាសមាជិក គឺជាឧទាហរណ៍នៃភ័ស្តុតាងដែលបង្ហាញពីហេតុផលនយោបាយនេះ ។ របាយការណ៍មួយចំនួនរួមមានសំណើសុំការអនុញ្ញាតសម្លាប់ជនទាំងឡាយណាដែលត្រូវបានកំណត់ថាជា "ខ្មាំង" ។ ដូចបានរៀបរាប់ពីខាងលើពាក្យនេះ សំដៅជនទាំងឡាយណាដែលត្រូវបានចាត់ទុកថាជាគូបដិបក្ខនយោបាយ ។ មួយរយៈកាលកន្លងទៅបក្សកុម្មុយនីស្តកម្ពុជាជឿជាក់ថា បក្សត្រូវបានជ្រៀតចូល ហើយផែនការរបស់បក្សត្រូវបានបំផ្លាញដោយ "សត្រូវ" "ជនក្បត់" និងបក្សពួក ។ សេចក្តីថ្លែងការណ៍របស់ អៀង សារី ដែលបានពិភាក្សាពីខាងលើ គឺជាឧទាហរណ៍នៃភ័ស្តុតាងដែលបង្ហាញអំពីការសង្ស័យទាំងនោះ ។ មានភ័ស្តុតាងប្រហាក់ប្រហែលនេះជាច្រើនទៀត ប៉ុន្តែព្រះរាជអាជ្ញានឹងជួបការលំបាកយ៉ាងខ្លាំងក្នុងការប្រមូលភ័ស្តុតាងដែលបង្ហាញពីហេតុផលនៃការកម្ទេចជនជាតិខ្មែរក្នុងនាមជាក្រុមជនជាតិមួយដោយផ្អែកទៅលើសមាជិកភាពរបស់ខ្លួននៃក្រុមនោះ ។

## សេចក្តីសន្និដ្ឋាន

### ហេតុអ្វីបានជាបទឧក្រិដ្ឋមួយចំនួនមានការពិបាកក្នុងការបង្ហាញ

បក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តបទឧក្រិដ្ឋដ៏ឃោរឃៅបំផុតនៅទូទាំងប្រទេស ។ អំពើឧក្រិដ្ឋទាំងអស់នេះមានទំហំធំធេងដែលធ្វើឲ្យគ្រួសារខ្មែរទាំងអស់ទទួលរងការឈឺចាប់ ។ ទោះបីជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានព្យាយាមលាក់អត្តសញ្ញាណរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំក៏ដោយ ក៏ឥឡូវអ្នកទាំងនេះត្រូវបានស្គាល់នៅទូទាំងពិភពលោក ។ ទោះជាយ៉ាងណាក៏ដោយសាលាក្តីខ្មែរក្រហមនឹងធ្វើការវិនិច្ឆ័យតែទៅលើមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា ។ វាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលទេដែលថា អំពើឧក្រិដ្ឋដ៏ធំធេងនិងដ៏គួរឲ្យរន្ធត់ប្រព្រឹត្តឡើងដោយក្រុមមួយដែលដឹកនាំដោយមនុស្សមួយក្តាប់តូចដែលមានអំណាចបំផុតក្នុងរយៈកាលនោះ នឹងធ្វើឲ្យប្រជាជនមានជំនឿថា បទឧក្រិដ្ឋជាច្រើននឹងអាចត្រូវបានបង្ហាញ ។ ភ័ស្តុតាងមាននៅគ្រប់ទីកន្លែងទាំងអស់ ។ មានរណ្តៅសាកសពជាច្រើនកន្លែង ។ អ្នកនៅរស់រានមានជីវិតអាចធ្វើកសិណសាក្សីចំពោះការឈឺចាប់ទាំងឡាយដែលខ្លួនបានឆ្លងកាត់ ហើយប្រហែលជាអាចបង្ហាញអត្តសញ្ញាណអ្នកដែលប្រព្រឹត្តអំពើនោះទៀតផង ។ អ្នកកាសែតនិងអ្នកសិក្សាស្រាវជ្រាវជាច្រើនបានរក្សាទុកអត្ថបទសម្ភាសន៍ដែលនៅក្នុងបទសម្ភាសន៍មួយចំនួនចុងចោទបានសារភាពពីកំហុសរបស់ខ្លួន ។ ផ្អែកលើភ័ស្តុតាងទាំងនេះ ពិភពលោកបានសន្មតពីទោសកំហុសរបស់មនុស្សមួយចំនួនធំដែលនឹងត្រូវនាំយកទៅកាត់ទោស ។ ទោះជាយ៉ាងនេះក្តី ការកាត់ទោសនឹងមិនប្រព្រឹត្តទៅដោយស្រួលបែបនោះទេ ប្រសិនបើការកាត់ទោសនេះត្រូវធ្វើឡើងដោយយុត្តិធម៌ ហើយជនជាប់ចោទទទួលបាននូវសិទ្ធិរបស់ខ្លួនដើម្បីឲ្យស្របទៅតាមបទដ្ឋានអន្តរជាតិ ។ ច្បាប់អន្តរជាតិនិងនីតិវិធីសម្រាប់សាលាក្តីនឹងដាក់កំហិត និងដែនកំណត់ក្នុងគោលបំណងធានាឲ្យបាននូវភាពស្របគ្នានិងយុត្តធម៌ដែលនេះគឺជាកិច្ចការមួយដ៏លំបាកសម្រាប់ព្រះរាជអាជ្ញា ។

ដោយផ្អែកទៅលើប្រព័ន្ធតុលាការបទដ្ឋាននៃការអនុញ្ញាតឲ្យប្រើប្រាស់ភ័ស្តុតាងអាចបង្កជាឧបសគ្គដល់ការបង្កើតឲ្យមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ។ តុលាការទំនងជានឹងប្រើប្រាស់បទដ្ឋាននៃការអនុញ្ញាតឲ្យប្រើប្រាស់បែបសេរី ហើយមានភ័ស្តុតាងជាច្រើនដែលព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ ។

ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានបង្ហាញនៅក្នុងជំពូកនេះ មានចំណុចសំខាន់ជាច្រើនដែលទាក់ទិននឹងភ័ស្តុតាង ដូចជាកសិណ ឬឯកសារជំនាញជាដើម ត្រូវបានចាត់ទុកថាជាពាក្យចចាមអារ៉ាម ។ ប្រសិនបើភ័ស្តុតាងបែបនេះមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់នោះ នឹងមានការលំបាកច្រើនដល់ការបង្ហាញបទឧក្រិដ្ឋមួយចំនួន ។

បញ្ហាលំបាកមួយទៀតដែលព្រះរាជអាជ្ញានឹងជួបប្រទះគឺការបង្ហាញធាតុចេតនា ។ រាល់បទឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ សុទ្ធតែមានធាតុអំពើ ព្រមទាំងធាតុចេតនា ហើយការដាក់ទោសអាស្រ័យលើព្រះរាជអាជ្ញាដែលជាអ្នកបង្ហាញធាតុទាំងពីរនេះ ។ ដូចដែលបានពិភាក្សាខាងលើ បើផ្អែកតាមនិយមន័យអំពើប្រល័យពូជសាសន៍ ធាតុចេតនា ជាធាតុមួយដែលមានការលំបាកច្រើនក្នុងការបង្ហាញ ពីព្រោះមានភ័ស្តុតាងតិចតួចបំផុតដែលបង្ហាញពីគោលគំនិតទូទៅដែលទាក់ទិនអំពើបែបនេះ ។ ជាទូទៅ ប្រជាជនខ្មែរមិនបានកត់ត្រា ឬរៀបរាប់ប្រាប់ជនដទៃទៀតអំពីមូលហេតុដែលពួកគាត់ធ្វើនោះឡើយ ដោយហេតុនេះបានជាចង់ឲ្យមានការសន្និដ្ឋានធាតុចេតនាចេញពីសកម្មភាព ជាពិសេស នៅពេលដែលអំពើពិសេសណាមួយត្រូវបានដឹងពុគ្រប់ៗគ្នានិងមានទំហំធំ ។ ទោះបីជាយ៉ាងណាក៏ដោយ តាមទស្សនៈរបស់ព្រះរាជអាជ្ញា វាជាការគួរឲ្យពេញចិត្តច្រើនជាងក្នុងការប្រើប្រាស់ភ័ស្តុតាងដោយផ្ទាល់ដែលអាចទទួលយកបាន ។

ជាចុងក្រោយ និយមន័យឧក្រិដ្ឋកម្មនៅក្រោមច្បាប់អន្តរជាតិមិនបានឆ្លុះបញ្ចាំងអំពីអត្ថន័យនៃពាក្យដូចគ្នាដែលប្រើប្រាស់ក្នុងការនិយាយទេ ។ ការកំណត់និយមន័យតាមផ្លូវច្បាប់មួយចំនួន ដែលប្រើប្រាស់ក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវបានដាក់កម្រិតច្រើនជាងការប្រើប្រាស់ពាក្យធម្មតាដែលធ្វើឲ្យមានការលំបាកក្នុងការបង្ហាញបទឧក្រិដ្ឋកម្មទាំងនេះច្រើនជាងការគិតរបស់សាធារណជនទូទៅ ។ អំពើប្រល័យពូជសាសន៍បង្ហាញយ៉ាងច្បាស់អំពីការលំបាកនេះ ។ ទោះបីជាពាក្យ«អំពើប្រល័យពូជសាសន៍»គឺជាពាក្យដែលគេប្រើប្រាស់សំដៅយកសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ មានភ័ស្តុតាងតិចតួចណាស់ដែលបង្ហាញថាចុងចោទមានចេតនាប្រព្រឹត្តអំពើឧក្រិដ្ឋកម្មដ៏គួរឲ្យស្អប់ខ្ពើម ។

អង្គជំនុំជម្រះវិសាមញ្ញមានសិទ្ធិអំណាចប្រើប្រាស់ភ័ស្តុតាងជាច្រើន ក៏ប៉ុន្តែសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតត្រូវស្វែងរកភ័ស្តុតាងបន្ថែម ។ ទោះបីជាព្រះរាជអាជ្ញាអាចធានាការដាក់ទោសចុងចោទចំពោះបទចោទប្រកាន់មួយចំនួនដែលទាក់ទិននឹងភ័ស្តុតាងដែលមានស្រាប់ កសិណដែលផ្តល់ដោយសាក្សីសាមញ្ញនិងជំនាញអាចប្រើប្រាស់បំពេញចន្លោះខ្វះខាតនិងបង្ហាញសំណុំរឿងក្តីមួយចំនួន ។ ក៏ប៉ុន្តែ ចំពោះបទចោទប្រកាន់មួយចំនួនអាចនឹងពុំមានភ័ស្តុតាងគ្រប់គ្រាន់ឡើយ ។ ភ័ស្តុតាងដែលថាជនជាតិខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា មិនអាចបង្ហាញពីវិធីដែលអំពើប្រល័យពូជសាសន៍ត្រូវបានឲ្យនិយមន័យនៅក្នុងច្បាប់អន្តរជាតិមិនត្រឹមត្រូវដូចគ្នានឹងស្ថានភាពចងចាំយ៉ាងច្បាស់នូវអំពើសាហាវព្រៃផ្សៃដ៏ធំធេងនោះឡើយ ។ **ឌូលា ហ្វ្រមហូលស៍**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុFM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុFM១០៣.២៥MHz ខេត្តបាត់ដំបងរៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ប៉ាង ពីច័ន**

# ឧបសគ្គអ្វីខ្លះដែលធ្វើឱ្យការកាត់សេចក្ដីពន្យារពេល

បន្ទាប់ពីបញ្ចប់ការជួបជុំជាមួយអ្នកភូមិប្រមាណ៩០នាក់ នៅឯទីស្នាក់ការឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបងកាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៧ ក្នុងគោលបំណងជម្រាបអ្នកភូមិឲ្យបានដឹង អំពីការវិវត្តន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោកជំទប់ទី១ ឃុំរកា បាននិយាយថា «ឥឡូវនេះអ្នកភូមិរបស់គាត់សឹងតែអស់ជំនឿលើការកាត់ទោសមេដឹកនាំខ្មែរក្រហមហើយ ពីព្រោះឮថាកាត់ទោសនេះរាប់ឆ្នាំមកហើយ ប៉ុន្តែមកទល់ពេលនេះមិនទាន់ឃើញកាត់ទោសទៀត» ។

ឆ្លើយតបនឹងចម្ងល់នេះ ខ្ញុំបានលើកយកមូលហេតុជាច្រើនមកពន្យល់ថា ៈ

១) ដោយសាររបបនេះបានកន្លងអស់រយៈ២៨ឆ្នាំ ទើបមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ការរង់ចាំក្នុងរយៈពេលយូរបែបនេះ បានធ្វើឲ្យជនរងគ្រោះនឿយណាយនិងបាត់បង់អស់នូវសេចក្ដីសង្ឃឹម ។ នៅខែមិថុនា ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំអង្គការសហប្រជាជាតិឲ្យជួយនាំមេដឹកនាំកម្ពុជាប្រជាធិបតេយ្យទៅកាត់ទោសនៅចំពោះមុខតុលាការដែលធ្វើឲ្យរបស់ជនរងគ្រោះចាប់ផ្ដើមមានក្ដីសង្ឃឹមឡើងវិញ ។

២) ចាប់ពីឆ្នាំ១៩៩៧ដល់ខែមករាឆ្នាំ២០០៧ មានរឿងរ៉ាវជាច្រើនបានកើតឡើងជុំវិញដំណើរការនៃការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មតិខ្លះចង់ឲ្យមានការកាត់ទោសនៅក្រៅប្រទេសកម្ពុជា ដោយលើកហេតុផលនៃអំពើពុករលួយនិងខ្វះសមត្ថភាពរបស់តុលាការកម្ពុជា ។ មតិខ្លះទៀតថា តុលាការត្រូវធ្វើឡើងនៅក្នុងស្រុកពីព្រោះបទឧក្រិដ្ឋដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា អ្នកដែលប្រព្រឹត្តជាជនជាតិកម្ពុជា ហើយជនរងគ្រោះភាគច្រើនលើសលប់កំពុងរស់នៅក្នុងប្រទេសកម្ពុជា ។ (នៅក្នុងខណៈនោះ ខ្ញុំបានសុំឲ្យលោកជំទប់ទី១អានអត្ថបទមួយរបស់លោកនាយក ឆាំង យុ ស្ដីអំពី«ស្វែងរកយុត្តិធម៌នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម» ដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្ដីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ៨៣ ខែវិច្ឆិកា ឆ្នាំ២០០៦) ។ ការចរចារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិត្រូវចំណាយអស់រយៈពេលជិត៦ឆ្នាំទើបឈានដល់ការបង្កើតឲ្យមានកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលចុះហត្ថលេខាដោយឯកឧត្តម សុខ អាន និង លោក ហេន កូរែល នៅសាលចតុមុខ នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ។

៣) ក្រោយពីច្បាប់និងកិច្ចព្រមព្រៀងអនុម័តរួចហើយ បញ្ហាទាក់ទិននឹងថវិកាបានកើតមានឡើង ។ អង្គការសហប្រជាជាតិដែលទទួលបន្ទុកចំណាយថវិកាចំនួន៤៣លានដុល្លារសហរដ្ឋអាមេរិកបានចេញសេចក្ដីថ្លែងការណ៍កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ដោយបញ្ជាក់ថា ការសន្យារបស់រដ្ឋជាសមាជិកក្នុងការផ្ដល់ថវិកាគឺបានបំពេញហើយ មានន័យថា អង្គការសហប្រជាជាតិមានថវិកាគ្រប់គ្រាន់ដើម្បីដំណើរការងារកាត់សេចក្ដីនេះ ។ ចំណែកឯរាជរដ្ឋាភិបាលកម្ពុជាដែលទទួលបន្ទុកលើចំណាយថវិកាប្រហែល១៣លាន៣សែនដុល្លារនោះ គឺនៅមានកង្វះខាតនៅឡើយ ដែលរហូតមកដល់ពេលនេះ កង្វះខាតថវិកាធ្លាក់មកនៅត្រឹមកម្រិតមួយទាប ដែលមានចំនួនប្រហែលជាង៤លានដុល្លារប៉ុណ្ណោះ ហើយរាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំស្វែងរកជំនួយដើម្បីយកមកបំពេញបន្ថែម ។

៤) ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាប់ផ្ដើមដំណើរការនៅក្នុងខែមករា ឆ្នាំ២០០៦ ដែលការិយាល័យនេះដឹកនាំដោយប្រធានជាជនជាតិខ្មែរគឺ ឯកឧត្តម ស៊ាន វិសុទ្ធ និងអនុប្រធានជាជនជាតិបរទេសគឺ លោកស្រី មីសែល លី ។

៥) ចៅក្រម សហព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតកម្ពុជា និងបរទេសបានស្បថចូលកាន់តំណែងរបស់ខ្លួននៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦ ។ នៅក្នុងខែកក្កដាដដែល សហព្រះរាជ

អាជ្ញាជាតិនិងអន្តរជាតិគឺ អ្នកស្រី ជា លាង និង លោក រ៉ូប៊ីត ពេទីត (ជនជាតិកាណាដា) បានចាប់ផ្តើមធ្វើការស៊ើបអង្កេត ប្រមូលភ័ស្តុតាង សម្ភាសន៍សាក្សី ដើម្បីកសាងសំណុំរឿងចោទប្រកាន់ ។ សំណុំរឿងចោទប្រកាន់នឹងត្រូវបញ្ជូនបន្តទៅឲ្យចៅក្រមស៊ើបអង្កេត ដើម្បីបន្តការស៊ើបអង្កេតជាបន្តទៀត មុននឹងការចោទប្រកាន់ធ្វើឡើងជាស្ថាពរ រួចហើយបញ្ជូនសំណុំរឿងទៅឲ្យចៅក្រមជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូងដែលមានចៅក្រមជាតិ៣រូបនិងអន្តរជាតិ២រូបធ្វើការបើកសវនាការ ។ ថ្ងៃបើកសវនាការនេះហើយដែលជនរងគ្រោះរង់ចាំដោយអន្ទះសា ហើយការចោទសួរអំពីកាលបរិច្ឆេទជាក់លាក់មិនទាន់ត្រូវឆ្លើយយកជាការបាននៅឡើយទេ ។ យោងតាមសម្តីរបស់មន្ត្រីតុលាការថា ថ្ងៃបើកសវនាការដំបូងនឹងធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ២០០៧ ខាងមុខនេះ ។

លើសពីនេះខ្ញុំបានពន្យល់បន្ថែមថា មិនមែនជនរងគ្រោះទាំងអស់សុទ្ធតែបានយល់ដឹងអំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងអស់គ្នានោះទេ ហើយការផ្សព្វផ្សាយក៏ធ្វើឡើងមិនបានឲ្យពេញលេញនឹងរៀងរាល់ថ្ងៃដែរ ។ ម្យ៉ាងទៀត ជនរងគ្រោះភាគច្រើនមមាញឹកក្នុងការរករចិញ្ចឹមជីវិតប្រចាំថ្ងៃ ដែលធ្វើគាត់ខកខានមិនបានស្តាប់និងតាមដានអំពីដំណើរការរបស់អង្គជំនុំជម្រះនេះ ហើយការិយាល័យកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានមនុស្សធ្វើការតែ៤នាក់ប៉ុណ្ណោះ ដែលទទួលខុសត្រូវលើកិច្ចការជាច្រើនរួមទាំងកិច្ចការផ្សព្វផ្សាយផងដែរ ។ ដូច្នេះការផ្សព្វផ្សាយគឺពឹងលើការជួយជ្រោមជ្រែងពីអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត ។

ក្រោយពីស្តាប់បានហេតុផលខាងលើ លោកជំទប់ទី១បានងក់ក្បាលទទួលយកការពន្យល់នេះ ។

នៅក្នុងដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ កន្លងទៅនេះ លោកតំណាងក្រុមប្រឹក្សាឃុំមកពីខេត្តព្រះវិហារ បានសួរសំណួរដ៏មានសារសំខាន់មួយទៀតថា តើនៅខ្វះភ័ស្តុតាងពិសេសអ្វីខ្លះទៀតដែលមិនអាចធ្វើការកាត់ទោសបាន?

ខ្ញុំបានឆ្លើយថា រហូតមកទល់ពេលនេះ ម៉ោងនេះ បញ្ហាកង្វះខាតភ័ស្តុតាងមិនទាន់ដឹងនៅឡើយទេ ។ សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិកំពុងធ្វើកិច្ចការយ៉ាងមមាញឹកក្នុងការបើកការស៊ើបអង្កេតបឋម ប្រមូលភ័ស្តុតាងផ្សេងៗ មានដូចជាឯកសារជាប្រភេទក្រដាស បទសម្ភាសន៍ និងឯកសារផ្សេងៗទៀតជាច្រើន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានផ្តល់ឯកសារដល់ការិយាល័យសហព្រះរាជអាជ្ញាយ៉ាងច្រើនសន្ធឹកសន្ធាប់តាមការស្នើសុំរបស់សហព្រះរាជអាជ្ញា ហើយការស្នើសុំនេះនឹងធ្វើឡើងជាបន្តបន្ទាប់ទៀត ។ តាមការឲ្យដឹងពីមន្ត្រីដែលធ្វើការងារនៅឯអង្គជំនុំជម្រះវិសាមញ្ញ ការចាប់ផ្តើមស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញាទាំងពីរគឺធ្វើឡើងតាំងតែពីខែកក្កដា ឆ្នាំ២០០៦ ។

នៅពេលដែលសហព្រះរាជអាជ្ញាបញ្ចប់ការស៊ើបអង្កេតបឋមរបស់ខ្លួន សហព្រះរាជអាជ្ញានឹងអាចចេញដីកាចោទប្រកាន់ចុងចោទបាន រួចហើយបញ្ជូនសំណុំរឿងចោទប្រកាន់នោះទៅឲ្យសហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការស៊ើបអង្កេតតាមការចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាបន្តទៀត ដែលហៅថាការបញ្ជូនដីកាសន្និដ្ឋានឲ្យស៊ើបសួរ ។

យោងតាមមាត្រា១នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ ត្រូវបានផ្តល់អំណាចឲ្យធ្វើការចោទប្រកាន់ទៅលើបុគ្គលជាមនុស្សពីរប្រភេទប៉ុណ្ណោះគឺ “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម...” ។ ទៀតសោតច្បាប់នេះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាចោទប្រកាន់លើបទល្មើសដែលចែងក្នុងមាត្រា៣ដល់មាត្រា៨ រួមមាន មនុស្សឃាត ទារុណកម្ម ការវាយប្រហារលើសាសនា (យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (យោងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដូចជា អំពើប្រឆាំងមនុស្សឬទ្រព្យសម្បត្តិដែលត្រូវការពារដោយបទបញ្ញត្តិនៃអនុ-

សញ្ញានេះ ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ (យោងអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីអំពីការការពារសម្បត្តិវប្បធម៌នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ) និងឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ (យោងអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត) ។ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិអាចចោទប្រកាន់លើបទល្មើសខាងលើនេះបានលុះត្រាតែបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ។

ដោយឡែក ការបញ្ជូនដីកាសន្និដ្ឋានឲ្យស៊ើបសួរបែបនេះ មិនអាចធ្វើទៅរួចទេ ប្រសិនបើវិធានផ្ទៃក្នុងពុំទាន់ត្រូវបានអនុម័តឲ្យប្រើប្រាស់ ពីព្រោះថា ចៅក្រមជំនុំជម្រះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ត្រូវការវិធានផ្ទៃក្នុងជាចាំបាច់ក្នុងការអនុវត្តន៍កិច្ចការរបស់ខ្លួនរៀងៗខ្លួន ។

កាលពីខែវិច្ឆិកា ឆ្នាំ២០០៦ គណៈកម្មការនីតិវិធីនិងបទបញ្ជាផ្ទៃក្នុងដែលធ្វើសេចក្តីព្រាង វិធានផ្ទៃក្នុងបានធ្វើការពិភាក្សាគ្នាម្តងរួចហើយទៅលើវិធានសរុបទាំងអស់១១៣ ។ កាលណោះ គណៈកម្មការនេះមានសមាជិកជាចៅក្រមជាតិនិងអន្តរជាតិចំនួន ៥រូប ក៏ប៉ុន្តែគណៈកម្មការនេះមិនអាចឈានដល់ការអនុម័តវិធានផ្ទៃក្នុងនេះបានទេ ដោយសារមូលហេតុថា ពេលវេលាមួយសប្តាហ៍សម្រាប់កិច្ចការដ៏សំខាន់នេះគឺ មិនអាចធ្វើទៅបាន ហើយគណៈកម្មការបានរកឃើញថា មានការខ្វែងគំនិតគ្នាលើច្រើនចំណុច ។ នៅថ្ងៃទី២៦ ខែដដែលនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទម្លាយឲ្យដឹងអំពីចំណុចខ្វែងគំនិតគ្នាតាមរយៈការចេញសេចក្តីថ្លែងការណ៍រួមគ្នាមួយ ។ ចំណុចខ្វែងគ្នាទាំងនោះរួមមានការប្របាច់បញ្ចូលគ្នារវាងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិនៅក្នុងបទបញ្ជាផ្ទៃក្នុងតួនាទីរបស់អង្គភាពគាំទ្រនិងការពារចុងចោទ ដែលក្នុងនោះមានបញ្ហាទាក់ទិននឹងសំណួរចោទថា តើមេធាវីការពារក្តីនឹងត្រូវជ្រើសរើសតាមលក្ខណៈសម្បត្តិយ៉ាងដូចម្តេច? តួនាទីរបស់សហព្រះរាជអាជ្ញានិងផលប៉ះពាល់នៃវិធីសម្រេចរបស់ខ្លួន ហើយនិងបញ្ហាថា តើអង្គជំនុំជម្រះវិសាមញ្ញនឹងប្រព្រឹត្តទៅនៅក្នុងប្រព័ន្ធតុលាការកម្ពុជាយ៉ាងដូចម្តេច?

នៅក្នុងខែមករា ឆ្នាំនេះ គណៈកម្មការពិនិត្យបទបញ្ជាផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកការពិភាក្សារយៈពេល២សប្តាហ៍ទៀត ដើម្បីដោះស្រាយបញ្ហាដែលបានរកឃើញនៅក្នុងកិច្ចប្រជុំពិភាក្សាគ្នាកាលពីខែវិច្ឆិកា ឆ្នាំកន្លងទៅ ។ គណៈកម្មការនេះបានបន្ថែមសមាជិកជាចៅក្រមជាតិ និងអន្តរជាតិដល់ទៅ៩រូប ។ លទ្ធផលចេញពីកិច្ចប្រជុំពិភាក្សាត្រូវបានប្រកាសឲ្យដឹងនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ថា "មានការជឿនលឿនទៅមុខច្រើន" ក៏ប៉ុន្តែនៅមានបញ្ហាសំខាន់ៗជាច្រើនទៀតដែលត្រូវដោះស្រាយ ។ បញ្ហាទាំងនោះទាក់ទិននឹងការស្វែងរកវិធីធ្វើយ៉ាងណាដើម្បីអាចច្របាច់បញ្ចូលគ្នារវាងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិចូលទៅក្នុងវិធានផ្ទៃក្នុងដើម្បីធានាឲ្យបាននូវដំណើរការក្តីដែលមានតម្លាភាពនិងប្រសិទ្ធភាព ។ បន្ថែមពីលើបញ្ហានេះគឺសិទ្ធិពេញលេញរបស់មេធាវីបរទេសក្នុងការការពារក្តីចុងចោទនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក៏មិនទាន់ត្រូវបានដោះស្រាយឲ្យជ្រះស្រឡះដែរ ។ សេចក្តីថ្លែងការណ៍របស់គណៈកម្មការពិនិត្យវិធានផ្ទៃក្នុងបានឲ្យដឹងថា នៅក្នុងខែមីនា ខាងមុខគណៈកម្មការនេះនឹងជួបពិភាក្សាគ្នាម្តងទៀត ដើម្បីសម្រេចឲ្យបាននូវការអនុម័តលើវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីព្រោះថា សមាជិករបស់គណៈកម្មាធិការដែលមានចៅក្រមជាតិនិងអន្តរជាតិបានដឹងយ៉ាងច្បាស់អំពីតម្រូវការចាំបាច់ក្នុងការឲ្យមានវិធានផ្ទៃក្នុងដើម្បីធានាដល់អង្គសវនាការដែលមានលក្ខណៈត្រឹមត្រូវនិងតម្លាភាពសម្រាប់ជាប្រយោជន៍ដល់ជនរងគ្រោះទាំងអស់គ្នា ។ បើទោះបីជាមិនទាន់បានអនុម័តលើវិធានផ្ទៃក្នុងនាពេលនេះក៏ដោយ ចៅក្រមជាតិនិងអន្តរជាតិបានប្តេជ្ញាថានឹងធ្វើឲ្យបានសម្រេចនូវគោលដៅរបស់ជនរងគ្រោះដែលទាមទារចង់បានយុត្តិធម៌ ។

**ម៉ាន់ថាន់ ពៅដារ៉ា**

## ពាក្យស្លោកខ្មែរក្រហម

- ស្លាប់ក្នុងសង្គ្រាមប្រសើរជាងស្លាប់ក្នុងភាពថ្លៃថ្នូរ?

# សេចក្ដីប្រកាសព័ត៌មានពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧

គណៈកម្មាធិការត្រួតពិនិត្យឡើងវិញនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់កិច្ចសម័យប្រជុំពេញអង្គរបស់ខ្លួន រួចហើយដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១៦ មីនា ឆ្នាំ ២០០៧ នៅអគារការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជានាទីក្រុងភ្នំពេញ ។ ភារកិច្ចរបស់គណៈកម្មាធិការគឺបន្តធ្វើការពិភាក្សាលើសេចក្ដីព្រាងវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានចាប់ផ្ដើម នៅក្នុងកិច្ចប្រជុំពេញអង្គរបស់តុលាការកាលពីខែវិច្ឆិកាឆ្នាំមុនកន្លងទៅនេះ ។ នៅមុនពេលចាប់ផ្ដើមកិច្ចប្រជុំរបស់គណៈកម្មាធិការត្រួតពិនិត្យឡើងវិញនាពេលដ៏ខ្លី ការពិភាក្សាដំបូងនឹងត្រូវបានរៀបចំឡើងរវាងចៅក្រមអន្តរជាតិទាំងអស់នាទីក្រុងបាងកក និងរវាងចៅក្រមកម្ពុជាទាំងអស់នៅទីក្រុងភ្នំពេញ ។

កិច្ចប្រជុំពេញអង្គនៃគណៈកម្មាធិការត្រួតពិនិត្យឡើងវិញលើកទី១ ត្រូវបានរៀបចំឡើងម្ដងកន្លងមកហើយកាលពីខែមករា ដើមឆ្នាំ២០០៧ ដែលនៅក្នុងនោះមានការយល់ស្របជាគោលការណ៍លើចំណុចមិនចុះសម្រុងគ្នាមួយចំនួនធំដែលកើតមានឡើងកាលពីកិច្ចប្រជុំពេញអង្គនៃតុលាការនាខែវិច្ឆកាឆ្នាំ២០០៦ ។ ចាប់តាំងពីពេលនោះមក សមាជិកគណៈកម្មាធិការដែលប្រចាំការនាទីក្រុងភ្នំពេញ រួមជាមួយនឹងបុគ្គលិកជំនួយការបានធ្វើការពេញម៉ោងដើម្បីធ្វើការតាក់តែងវិធានដាក់លាក់នានាដែលបានឯកភាពគ្នាជាគោលការណ៍ ហើយក៏បានធ្វើការដោះស្រាយនូវចំណុចដែលមិនទាន់ចុះសម្រុងគ្នាជាច្រើន ។ ជាការពិតណាស់ ក្នុងដំណាក់កាលនេះ ខ្លឹមសារនៃការពិភាក្សាបែបនេះត្រូវតែរក្សាទុកជាការសម្ងាត់ ។

ការងាររបស់គណៈកម្មាធិការត្រួតពិនិត្យឡើងវិញគឺជាកិច្ចការដែលមានលក្ខណៈលំបាកជាខ្លាំង ដោយសារថាចៅក្រម ត្រូវធ្វើដាក់ច្បាស់ថាមានភាពស្របគ្នារវាងនីតិវិធីរបស់កម្ពុជាដែលមានជាមួយនឹងបទដ្ឋានអន្តរជាតិដោយគិតគូទៅដល់លក្ខណៈនិងរចនាសម្ព័ន្ធពិសេសតែមួយគត់របស់អង្គជំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលក្នុងទិដ្ឋភាពជាច្រើនមានលក្ខណៈខុសគ្នាទៅនឹងតុលាការអន្តរជាតិឬតុលាការចម្រុះដទៃទៀតដែលមាន ។

ចៅក្រមទាំងអស់យល់ឃើញថា កិច្ចប្រជុំពេញអង្គនៃគណៈកម្មាធិការត្រួតពិនិត្យឡើងវិញនាពេលខាងមុខនេះគឺមានសារសំខាន់ណាស់ ដោយសារថាកិច្ចប្រជុំនេះត្រូវស្វែងរកឲ្យបាននូវដំណោះស្រាយនៃរាល់ភាពខុសគ្នាជាមូលដ្ឋានទាំងអស់ និងយល់ស្របលើសេចក្ដីព្រាងអត្ថបទនៃវិធានផ្ទៃក្នុងដែលនឹងត្រូវដាក់ជូនសម័យប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការពិចារណា និងអនុម័តដោយចៅក្រមទាំងអស់នាពេលខាងមុខនេះ ។ ចៅក្រមទាំងអស់ក៏យល់ច្បាស់ដែរថាពេលវេលាគឺមានសារសំខាន់បំផុត ។

ប្រសិនបើគណៈកម្មាធិការត្រួតឡើងវិញបានទទួលជោគជ័យ កិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងប្រព្រឹត្តទៅក្នុងខែមេសាខាងមុខនេះ ហើយសំណុំរឿងក្ដីទីមួយនឹងអាចត្រូវគេបញ្ជូនពីសហព្រះរាជអាជ្ញាទៅសហចៅក្រមស៊ើបអង្កេតភ្លាមៗបន្ទាន់មកនោះដែរ ។

គណៈកម្មាធិការនីតិវិធីផ្ទៃក្នុងមានសមាជិកជាចៅក្រមកម្ពុជាចំនួន៣រូបនិងចៅក្រមអន្តរជាតិចំនួន២រូបមាន ÷ លោកសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង, លោកចៅក្រម ម៉ុង មុន្នីចរិយា, លោកចៅក្រម ប្រាក់ គឹមសាន, លោកស្រីចៅក្រម Agnieszka Klonowiecka-Milart លោកសហចៅក្រមស៊ើបអង្កេត Marcel Lemonde ។ សម្រាប់ក្នុងគោលបំណងធ្វើការត្រួតពិនិត្យឡើងវិញ មានសមាជិកចំនួនបួនរូបត្រូវបានបញ្ចូលបន្ថែមរួមមាន ÷ លោកចៅក្រម គង់ ស្រ៊ីម, លោកចៅក្រម ស៊ិន រិទ្ធ, លោកស្រីចៅក្រមអន្តរជាតិ Silvia Cartwrights, លោកស្រីចៅក្រមអន្តរជាតិ Claudia Fenz សរុបមានចៅក្រមចំនួន៩រូប ។

# ប្រវត្តិគ្រួសារខ្ញុំ

ខ្ញុំបាទឈ្មោះ អៀ ហុង មានឋានៈវរសេនីយ៍ទោធ្វើការនៅអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំសូមរួមចំណែកចែករំលែកនូវរឿងរ៉ាវជីវិតដែលខ្ញុំបានឆ្លងកាត់ជាពិសេសក្នុងរបបប្រល័យពូជសាសន៍ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។

ឈ្មោះក្នុងបញ្ជីជាតិរបស់ខ្ញុំគឺ យី លាងហុង កើតថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៦១ ។ ខ្ញុំមានបងប្អូនបង្កើត៣នាក់ ស្រី២នាក់ (បងស្រីនិងប្អូនស្រី) ស្រុកកំណើតនៅភូមិសន្ទុក ក្រៅឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ ។ ឪពុកខ្ញុំឈ្មោះ យី ប៊ុនហួរ ម្តាយឈ្មោះ គឹម ឡេង ។ ឪពុកខ្ញុំមានបងប្អូន២នាក់ បងប្រុសរបស់គាត់ឈ្មោះ យី ហុងនី ។ ខ្ញុំនៅចាំបានថា ក្នុងជំនាន់សង្គមរាស្ត្រនិយមឪពុកធំខ្ញុំធ្លាប់ធ្វើជាស្មៀនឃុំកកោះ ក្រៅពីនេះគាត់ធ្វើស្រែនិងលេងភ្លេងខ្មែរ ។ ឪពុកធំខ្ញុំមានជំនាញខាងលេងឧបករណ៍ម៉ុងដូលីននិងឧបករណ៍ជាច្រើនមុខទៀត ។ ប្រពន្ធរបស់គាត់ឈ្មោះ សំ ឌី ដែលជាអ្នកស្រុកភូមិកំណើតរបស់ខ្ញុំដែរ ។

ប្រហែលនៅឆ្នាំ១៩៦៤ ឪពុកខ្ញុំបានលែងលះម្តាយខ្ញុំ ។ ប៉ុន្មានឆ្នាំក្រោយមក ដោយមានការជួយជ្រោមជ្រែងពីប្រពន្ធរបស់ឪពុកធំខ្ញុំ ឪពុកខ្ញុំបានរៀបការប្រពន្ធថ្មីឈ្មោះ ឡាយ សាឃីម ដែលជាស្ត្រីមេម៉ាយកូនមួយនិងជាក្មួយថ្លៃរបស់ឪពុកធំខ្ញុំ ។ ឪពុកខ្ញុំប្រកបរបបធ្វើស្រែនិងនេសាទត្រី ។ ជីតាខ្ញុំឈ្មោះ យី អៀ ជាកូនចិនឆៅ ។ ជីដូនខ្ញុំឈ្មោះ ហេង ហៀង ជាកូនចៅចិន ស្រុកកំណើតនៅស្រុកស្អាង គាត់ទាំងពីរមករស់នៅខេត្តកំពង់ធំ តាំងពីសម័យសង្គ្រាមលោកលើកទីពីរ ហើយត្រូវបារាំងកែនឲ្យលើកផ្លូវជាតិលេខ៦ ។ ជីតាខ្ញុំរានដីបានចំនួនពីរប្លង់នៅជាប់ផ្លូវជាតិ ហើយបង់ពន្ធឲ្យបារាំងរាល់ឆ្នាំ ។ ក្រោយមកជីតាខ្ញុំបានចែកដីនោះឲ្យឪពុកធំនិងឪពុកខ្ញុំម្នាក់មួយប្លង់ ។ ឪពុកខ្ញុំពូកែធ្វើស្រែណាស់ ថ្វីដ្បិតតែគាត់ជាកូនចៅចិនក៏ដោយ ។ មុនឆ្នាំ១៩៧០ គាត់សង់ផ្ទះឈើបានបីខ្នងប្រក់សង្ក័សី ។ ចំណែកឪពុកធំខ្ញុំពុំសូវមានពេលធ្វើស្រែឡើយ ប៉ុន្តែជីវភាពរស់នៅរបស់គាត់មធ្យម ។ គាត់មានកង់តួស្រីថ្មី១គ្រឿង ឪពុកខ្ញុំក៏មានកង់តួប្រុស១គ្រឿងដែរ ។

ប្រហែលក្នុងឆ្នាំ១៩៦៩ ខ្ញុំបានឮចាស់ៗនិយាយថា ស្រុកទេសជិតកើតសង្គ្រាម ដោយសារប្រទេសកម្ពុជាទទួលមនោគមវិជ្ជាពីលោកសេរីផងនិងកុម្មុយនីស្តផង ។ នៅមុនឆ្នាំ១៩៦៩ ខ្ញុំបានឮសន្ធឹកដូចផ្គរលាន់មកពីទិសខាងកើត ។ ខ្ញុំឆ្ងល់ថាខែប្រាំងសោះ ហេតុម្តេចមានផ្គរ? ជីតាខ្ញុំប្រាប់ថាស្នូរផ្ទុះគ្រាប់បែកទម្លាក់របស់ពួកអាមេរិកកាំងនៅព្រំដែនខ្មែរ-វៀតណាម ។ មិនយូរប៉ុន្មាន ខ្ញុំបានឃើញកងទ័ពវៀតណាមចូលមកដល់ស្រុកកំណើតរបស់ខ្ញុំ ។ ក្រោយពីឪពុកម្តាយខ្ញុំលែងលះគ្នា បងប្អូនខ្ញុំត្រូវរស់នៅជាមួយជីដូនជីតាខាងឪពុក ។ ប្អូនស្រីខ្ញុំរស់នៅជាមួយប្អូនស្រីជីតាខ្ញុំនៅស្រុកស្អាង ខេត្តកណ្តាល ។ ចំណែកខ្ញុំត្រូវឪពុកធំយកមកចិញ្ចឹមធ្វើជាកូន (គាត់គ្មានកូន) និងឲ្យរៀនសូត្រធម្មតា ។

នៅខែមីនា ឆ្នាំ១៩៧០ មានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ហើយគ្រប់គ្រងអំណាចដោយសេនាប្រមុខ លន់ នល់ ។ មិនយូរប៉ុន្មានប្រទេសកម្ពុជាក៏ត្រូវបានបែងចែកជាតំបន់ត្រួតត្រា ។ មួយផ្នែកធំគ្រប់គ្រងដោយក្រុមអ្នកគាំទ្ររបបសាធារណរដ្ឋខ្មែរ និងនៅតំបន់ដាច់ស្រយាលមួយចំនួនគ្រប់គ្រងកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាតំបន់នោះហៅថាតំបន់រំដោះ ដែលកងទ័ពរណសិរ្សដណ្តើមបានពីរបប លន់ នល់ ។

ខ្ញុំនៅចាំបានថា ជីតាខ្ញុំស្រឡាញ់សម្តេចឪណាស់ ពិសេសប្រជាជនស្ទើរទាំងអស់ដែលរស់នៅក្នុងតំបន់រំដោះគោរពស្រឡាញ់របបសង្គមរាស្ត្រនិយមដែលដឹកនាំដោយសម្តេចឪណាស់ ។ ក្រោយពីមានសេចក្តីអំពាវនាវរបស់សម្តេចឪតាមវិទ្យុប៉េកាំង និងប្រពន្ធ័ឃោសនាដទៃទៀតឲ្យប្រជាជនចូលរួមរំដោះប្រទេសជាតិ ឪពុកធំ ឪពុកខ្ញុំ និងប្រជាពលរដ្ឋជាច្រើនទៀតបានស្ម័គ្រចិត្តចូលរួមជាមួយក្រុមចលនាតស៊ូដើម្បីប្រយុទ្ធប្រឆាំងជាមួយកងទ័ពរបបសាធារណរដ្ឋខ្មែរ ។ ឪពុកធំនិងឪពុកខ្ញុំ ចូលបដិវត្តន៍ក្នុងថ្ងៃជាមួយគ្នា អង្គភាពជាមួយគ្នា និងឡើងសមរភូមិប្រយុទ្ធជាមួយគ្នាទៀត ។ គាត់ទាំងពីរប្រយុទ្ធនៅសមរភូមិស្រុកស្ទឹងត្រង់

ខេត្តកំពង់ចាមរយៈពេលពីប្រហែល៤ខែ ទើបត្រឡប់មកផ្ទះម្តង ។ ពេលត្រឡប់មកផ្ទះម្តងៗ គាត់ទាំងពីរជិះម៉ូតូម៉ាកសេអ៊ិលនិងស្ពាយកាំភ្លើងខ្លី១ដើមម្នាក់ ។ គាត់ទាំងពីរជាអ្នកស្នេហាបដិវត្តន៍ណាហ្ស៊ី ។ ឪពុកធំខ្ញុំស្រឡាញ់ខ្ញុំណាស់ មុនចូលសម្រាន្តម្តងៗគាត់តែងលេងភ្លេងម៉ុងដូលីន ឬបង់ហ្សូ បំពេញឲ្យខ្ញុំបានគេងលក់ ។ ក្រោយមកឮថាគាត់ឡើងឋានៈជាប្រធានកស្តុភារវរសេនាធំ ។

ប៉ុន្តែមុនពេលដែលរបបលន់នល់បើកសមរភូមិប្រត្តិបត្តិការសឹកចេនឡាពីរ ប្រមាណរយៈពេល៣ខែ ខ្ញុំបានឃើញគាត់ទាំងពីរត្រឡប់មកផ្ទះវិញទាំងទឹកមុខស្រពាប់ស្រពោន ។ ជីតាខ្ញុំបានសួរគាត់ ហើយគាត់ឆ្លើយតបថា គាត់ឈប់ធ្វើបដិវត្តន៍ទៀតហើយ ។ ពូលី ដែលជាប្អូនរបស់ជីដូនខ្ញុំក៏ត្រឡប់មកវិញដែរ ។ ប៉ុន្តែខ្ញុំឃើញគាត់ទាំងបីនាក់ខសង្សាហ៍ទៅចូលរួមប្រជុំនៅស្នាក់ការឃុំកោះដែលមានទីតាំង នៅភូមិបុស្សធំ ជាប់ផ្លូវជាតិលេខ៦ ក្បែរជើងភ្នំសន្ទុក ។ នៅថ្ងៃចុងក្រោយគឺនៅថ្ងៃប្រតិបត្តិការចេនឡាពីរប្រហែលក្នុងឆ្នាំ១៩៧៣ ខ្ញុំបានឃើញកងឈ្លបម្នាក់ជិះកង់មកហៅគាត់ទៅប្រជុំទៀត ។ ឪពុកចិញ្ចឹមខ្ញុំនិង ពូលី បានឌុបគ្នាចេញទៅប្រហែលម៉ោង៥ៈ៣០ល្ងាច (ខ្ញុំមិនចាំថ្ងៃខែច្បាស់លាស់) ចំណែកឪពុកបង្កើតខ្ញុំមិនបានទៅជាមួយទេ ព្រោះគាត់រវល់ទៅមើលស្រែក្រោម ។ លើកនេះឪពុកចិញ្ចឹមខ្ញុំនិងពូលីមិនបានត្រឡប់មកផ្ទះវិញឡើយ ។ លុះព្រឹកឡើងម្តាយចិញ្ចឹមខ្ញុំបានទៅរកគាត់នៅទីស្នាក់ការ "បុស្សធំ" ដើម្បីសួរនាំដំណឹងពីអ្នកទាំងពីរ ។ ប្រធានទីស្នាក់ការឈ្មោះ សេង អុន បានប្រាប់ម្តាយចិញ្ចឹមខ្ញុំថា ឪពុកចិញ្ចឹមខ្ញុំនិង ពូលី ក្បត់បដិវត្តន៍រត់ទៅចុះចូលទាហាន លន់ នល់ នៅកំពង់ធំកាលពីយប់មិញហើយ នៅសល់តែកង់ទេ ។ ពេលនោះម្តាយខ្ញុំបានសុំយកកង់មកផ្ទះវិញ ប៉ុន្តែ សេង អុន មិនអនុញ្ញាតហើយនិយាយទៀតថា នេះជាទ្រព្យជ័យភណ្ឌ ។ តាមការពិតម្តាយខ្ញុំដឹងថា អ្នកទាំងពីរត្រូវបានសម្លាប់តាំងពីយប់មិញបាត់ទៅហើយ ។ គាត់យំរាល់ថ្ងៃ ។ ក្រោយមកឪពុកបង្កើតខ្ញុំដឹងថាគេបម្រុងតាមចាប់គាត់ គាត់ក៏បាននាំប្រពន្ធកូនភៀសខ្លួនចូលខាងទាហានលន់នល់ក្នុងទីរួមខេត្តកំពង់ធំ ។ ដោយពុំមានមុខរបរច្បាស់លាស់ គាត់ក៏បានចូលបម្រើទាហានលន់នល់ក្នុងវរសេនាធំ២៨៧ ដែលមាន ឈ្មោះ ចាយ ជាប្រធាន ។

ពេលពួកចេនឡាពីរចូលជិតមកដល់ ក្រុមអ្នកតស៊ូបដិវត្តន៍បានកៀរប្រជាជននៅតាមដងផ្លូវជាតិលេខ៦ ពិសេសប្រជាជនដែលរស់នៅខាងកើតផ្លូវត្រូវដេញឲ្យឡើងភ្នំ ឬឡើងទៅស្រុកលើ (ស្រុកកំណើតខ្ញុំ ភូមិឃុំដែលស្ថិតនៅខាងកើតផ្លូវជាតិចាប់ពី១០គីឡូម៉ែត្រទៅ ប្រជាជនបានឯកភាពគ្នាហៅថាស្រុកលើៗ) ។ ប្រសិនបើគ្រួសារណាមិនព្រមទៅតាមការណែនាំទេ គ្រួសារនោះនឹងត្រូវកងទ័ពបដិវត្តន៍ចោទប្រកាន់ថា គាំទ្រឬជាគិញ្ចរបស់ពួកលន់នល់ ហើយគ្រួសារនោះនឹងត្រូវគំរាមកំហែងដល់ជីវិតទៀតផង ។ ម្តាយចិញ្ចឹមខ្ញុំបានភៀសខ្លួនទៅតាមទិសដែលកងទ័ពបដិវត្តន៍កំណត់ ។ ពេលទៅដល់ភូមិទីពោធិ៍ គាត់បានពឹងចាស់ព្រឹទ្ធាចារ្យម្នាក់ឲ្យជូនមករកខ្សែត្រៀមទាហានលន់នល់នៅទីប្រជុំជនតាំង-ក្រសាំង ។ ពួកយើងបានធ្វើដំណើរកាត់វាលស្រែអស់រយៈពេលមួយព្រឹកធំទើបមកដល់តាំងក្រសាំង ។ ស្នាក់នៅទីនោះបានបីថ្ងៃម្តាយចិញ្ចឹមខ្ញុំបានទាក់ទងរថយន្តអ្នកការសែតទាហានលន់នល់ដើម្បីធ្វើដំណើរមកទីក្រុងភ្នំពេញ ។ ពេលមកដល់ភ្នំពេញ ម្តាយចិញ្ចឹមខ្ញុំបានស្វះស្វែងរកសាលាឲ្យខ្ញុំរៀនសូត្របន្ត ព្រោះខ្ញុំទើបតែរៀនបានថ្នាក់អាទិកដ្ឋាន(ថ្នាក់ទី១០)ប៉ុណ្ណោះ ។ ប៉ុន្តែ គ្មានសាលារៀនណាទទួលឈ្មោះខ្ញុំឲ្យចូលរៀនទេ ពីព្រោះខ្ញុំគ្មានសៀវភៅបញ្ជីជាតិ ។ បញ្ជីជាតិរបស់ខ្ញុំបានជ្រុះបាត់នៅពេលរត់ភៀសខ្លួន ។ ដោយមូលហេតុនេះ ម្តាយចិញ្ចឹមខ្ញុំក៏បានទិញសំបុត្រយន្តហោះធ្វើដំណើរពីភ្នំពេញទៅរស់នៅខេត្តកំពង់ធំវិញ ។ នៅទីនោះ ខ្ញុំបានជួបជីដូនជីតា បងស្រីខ្ញុំ ឪពុកបង្កើត ម្តាយចុងនិងប្អូនៗខ្ញុំ ឪពុកជាមួយម្តាយដោយខ្លួន ។ ខ្ញុំក៏បានចូលរៀនបន្តទៀតយ៉ាងសប្បាយរីករាយ ។ ទីកដីទីរួមខេត្តកំពង់ធំដែលកាប់កាប់ដោយទាហានលន់នល់ដែលមានទំហំប្រហែល១០គីឡូម៉ែត្របួនជ្រុង បានទទួលរងនូវការបាញ់ផ្លោងដោយក្រុមចលនាតស៊ូខ្មែរនូវគ្រាប់រ៉ុក្កែតគ្រប់ធុនទាំងយប់ទាំងថ្ងៃ ។ ថ្ងៃណាក៏មានប្រជាពលរដ្ឋស្លាប់និងរងរបួសដែរ ។ ប្រហែលចុងនៅឆ្នាំ១៩៧២ បងស្រីខ្ញុំ ដែលមានអាយុ១៥ឆ្នាំបានស្លាប់ដោយសារគ្រាប់ផ្លោង ។ ក្រោយពេលបងស្រីខ្ញុំស្លាប់ជីដូនជីតាខ្ញុំ បានសុំខ្ញុំឲ្យទៅរស់នៅជាមួយគាត់វិញ គ្រាន់ជួយបម្រើទឹកក្តៅទឹកត្រជាក់ ។ ម្តាយចិញ្ចឹមខ្ញុំបានបំពេញបំណងជីដូនជីតារបស់ខ្ញុំ ចំណែករូប

គាត់ក៏លួចចេញទៅតំបន់រំដោះបាត់ ។ ឪពុកបង្កើតខ្ញុំបានប្រមែលប្រមូលថវិកា ដែលគាត់សន្សំបានមកសង់ផ្ទះគៀមមួយ ធ្វើអំពីឈើក្នុងរបងសាលាខេត្តកំពង់ធំដើម្បីឲ្យជីដូនជីតានិងខ្ញុំបានស្នាក់នៅ ។

ធ្មេចបើក១ ថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ក៏បានមកដល់ពួកយើងនិងប្រជាជនទូទាំងប្រទេសសប្បាយរីករាយឥតឧបមា សង្ឃឹមថាស្រុកទេសបានសុខសន្តិភាព ។ យើងចេញមកទទួលកម្មាភិបាល យុទ្ធជនខ្មែរក្រហមទាំងទឹកមុខរីករាយរាក់ទាក់ ។ កងទ័ពបដិវត្តន៍បានចូលមកដល់ខេត្តកំពង់ធំនៅថ្ងៃទី២២ មេសា ១៩៧៥ ហើយបានកោះប្រជុំមេទាហាន ប៉ូលិស មន្ត្រីរដ្ឋការធំឲ្យមកជួបជុំគ្នានៅទីធ្លាសាលាខេត្តដែលនៅមិនឆ្ងាយប៉ុន្មានពីផ្ទះរបស់ខ្ញុំ ។ ខ្ញុំឈរមើលកម្មាភិបាលបដិវត្តន៍ តើមានរូបរាងសណ្ឋានយ៉ាងដូចម្តេច? បុរសម្នាក់មានមាឌធំ សម្បុរជ្រះ សម្លៀកបំពាក់ពណ៌ខ្មៅ ក្រមាសូត្របង់ក ពាក់មួកកន្តិបពណ៌ត្រួយចេក ពាក់ស្បែកជើងកង់ឡានមានក្រវាត់អាវុធខ្លីនៅចង្កេះ និងអង្គរក្ស៤-៥នាក់ដែលមានឯកសណ្ឋានពណ៌ត្រួយចេកឈមអមពីក្រោយ ។ បុរសនោះបានអង្គុយលើកៅអីនៅពីមុខមន្ត្រីរដ្ឋការ មេទាហាន ប៉ូលិស ដែលកំពុងអង្គុយផ្ទាល់ដី ហើយបានបន្លឺតាមឧត្បោសនសព្ទថា ៖ «សមមិត្តទាំងអស់គ្នា! ថ្ងៃនេះប្រទេសកម្ពុជាយើងបានប្រយុទ្ធឈ្នះពួកចក្រពត្តិប្រតិកិរិយា» ។ បុរសម្នាក់នោះនិយាយជាច្រើនទៀត ប៉ុន្តែខ្ញុំស្តាប់ពុំយល់នូវទ្រឹស្តីបដិវត្តន៍ដូចជាពាក្យថា ៖ «ការបង្ហូរសាច់ស្រស់ ឈាមស្រស់ យុទ្ធមិត្ត បានពលី អង្គការស្អាតស្អំ បដិវត្តន៍ភ្លឺថ្លាដ៏មហិមា» ។ បន្ទាប់មកអង្គប្រជុំនោះក៏ត្រូវបានរំសាយ ។ ខ្ញុំបានសង្កេតឃើញមន្ត្រីទាហាន ប៉ូលិសទាំងនោះទម្លាក់ទឹកមុខជ្រប់ ប្រែជាស្រពាប់ស្រពោន បន្ទាប់មក អង្គរក្ស ឬកងការពារបុរសអាវខ្មៅនោះ បញ្ជាឲ្យមេទាហានប៉ូលិសឡើងរថយន្ត GMC ៤គ្រឿង ដែលកំពុងរង់ចាំជាស្រេច ហើយដឹកចេញទៅបាត់ស្រមោលពុំដឹងទៅកាន់ទីណា ។

ពេលខ្ញុំត្រឡប់មកដល់ផ្ទះវិញពុជីតាខ្ញុំនិយាយប្រាប់ឪពុកខ្ញុំថា ៖ ឯងត្រូវតែនាំប្រពន្ធកូនទៅកាន់ខេត្តសៀមរាប ពីព្រោះតាមឪពុកសង្កេតឃើញកងទ័ពខ្មែរក្រហមនេះមានចរិតកោងកាចណាស់ ឯងនៅចាំបានទេ? បងប្រុសឯងត្រូវគេសម្លាប់ ដោយគ្មានមូលហេតុ ចុះទម្រាំឯងជាទាហានលន់នល់ ឪពុកខ្លាចពួកគេមានការគុំកួន ។ ម្យ៉ាងទៀត ក្រោយពីបងរបស់ឯងត្រូវគេសម្លាប់ ឯងបានរត់គៀសខ្លួន ហើយគេចោទប្រកាន់ឯងថា បានចលនាប្រជាជនមួយភូមិសន្ទុក ដូច្នេះកូនត្រូវប្រុងប្រយ័ត្នឲ្យមែនទែន ព្រោះអ្នកស្រុកមួយចំនួនច្រណែនឯងដែលពូកែរកស៊ីកន្លងមក ។ ឪពុកខ្ញុំស្តាប់ជីតាខ្ញុំនិយាយមិនទាន់ចប់ស្រួលបួលផង ស្រាប់តែពួកកងទ័ពខ្មែរក្រហមប្រកាសប្រមូលផ្តុំមន្ត្រីរដ្ឋការលន់នល់នៅវត្តក្តីសែន ឬសំរោងសែន ដើម្បីកត់ឈ្មោះទៅរៀនសូត្រនិងរៀបចំឲ្យធ្វើការឡើងវិញតាមតួនាទីនិងឋានៈ ។ ឪពុកខ្ញុំក្ដូច្នោះក៏ប្រញាប់ជិះកង់ទៅទាំងស្លៀកពាក់ឯកសណ្ឋានទាហាន ហើយឆ្លៀតងាកមកផ្តាំប្រពន្ធគាត់ថា រៀបចំអីវ៉ាន់ទៅ ខ្ញុំទៅតែមួយសន្ទុះទេត្រឡប់មកវិញហើយ ។ បន្ទាប់ពីនោះ កងទ័ពខ្មែរក្រហមបានដើរដេញប្រជាជនឲ្យចេញពីផ្ទះដើម្បីទុកឲ្យអង្គការរៀបចំទីក្រុងឡើងវិញ ។ តាំងពីពេលនោះ ខ្ញុំលែងបានឃើញមុខនិងស្តាប់សំឡេងឪពុកខ្ញុំរហូត ។

ក្រោយពីរង់ចាំឪពុកខ្ញុំពុំឃើញត្រឡប់មកវិញ ពួកយើងបានចាកចេញពីទីក្រុងកំពង់ធំមកកាន់ស្រុកកំណើត ព្រោះគិតថាមកស្រុកកំណើតស្គាល់ញាតិមិត្តច្រើនប្រហែលជាងាយស្រួលរស់នៅជាង ។ ចម្ងាយផ្លូវពីកំពង់ធំមកស្រុកកំណើតខ្ញុំមានប្រវែងប្រហែល ២០គីឡូម៉ែត្រ ពួកយើងធ្វើដំណើរអស់រយៈពេល៤៨ម៉ោង ដោយថ្មើរជើង ខ្លះទូល ខ្លះរែក ខ្លះរុញ ខ្លះសែងលី ។ ពួកយើងមកស្រុកកំណើតមិនទាន់បានមួយថ្ងៃស្រួលបួលផង អង្គការបានចុះមកស្រង់ឈ្មោះធ្វើស្ថិតិ ។ ខ្ញុំនៅចាំបានថា ក្រោយថ្ងៃ ១៧មេសា ឆ្នាំ១៩៧៥ អ្នកភូមិមានការរើសអើងមែនទែន ។ ដោយយល់ថានៅទីនោះមានការរើសអើងរវាងប្រជាជនចាស់និងប្រជាជនថ្មី ដូច្នេះជីតាខ្ញុំក៏បានសម្រេចចិត្តផ្លាស់ទីលំនៅមកនៅភូមិជ័យរត (បច្ចុប្បន្នហៅថាភូមិស្តុកស្តម្ភ) ព្រោះក្មួយជីដូនមួយរបស់ជីតាខ្ញុំជាអ្នកមូលដ្ឋានស្រាប់ ។ មកដល់ទីនោះ ខ្ញុំក៏បានជួបម្តាយបង្កើតរបស់ខ្ញុំ ដែលគាត់ជាប្រជាជនមូលដ្ឋានដែរ ។ ខ្ទមស្លឹករបស់ឪពុកមាខ្ញុំនិងម្តាយខ្ញុំបង្កើតនៅក្រុមជាមួយគ្នា ស្ថិតនៅខាងកើតថ្នល់ជាតិលេខ៦ ប្រមាណ១គីឡូម៉ែត្រ ។ នៅទីនោះ ពួកយើងមានភាពកក់ក្តៅជាងស្រុកកំណើត ប៉ុន្តែរស់នៅមិនបានប៉ុន្មាន

អាទិត្យផង អង្គការបានចុះស្រង់ស្ថិតិប្រជាជន១៧មេសា ដែលមានតែគ្រួសារខ្ញុំប៉ុណ្ណោះ ។ ប៉ុន្មានថ្ងៃក្រោយមក អង្គការតម្រូវឲ្យគ្រួសារខ្ញុំចាកចេញពីភូមិជ័យរតទៅរស់នៅភូមិត្រពាំងត្រុម ដែលមានចម្ងាយប្រហែល៦គីឡូម៉ែត្រពីភូមិជ័យរត ដែលនៅទីនោះមានសុទ្ធតែប្រជាជន១៧មេសារស់នៅ ។ អង្គការបានបែងចែកប្រជាជនរស់នៅជាក្រុមៗ ហើយសាងសង់ជម្រកតាមលទ្ធភាពរបស់គ្រួសារនីមួយៗ ។ មុនពេលចាកចេញពីភូមិជ័យរត ក្មួយប្រុសរបស់ជីតាខ្ញុំបានឲ្យគ្រឿងឧបភោគបរិភោគមួយចំនួន និងក្តារចំនួន៦បន្ទះ ។ ជីតាខ្ញុំបានទៅកាប់កូនឈើផ្តិជាមួយក្តារទាំង៦បន្ទះនោះសង់បានកូនខ្ទម១ទំហំប្រហែលទទឹង២,៥ម៉ែត្រ និងបណ្តោយ៤ម៉ែត្រប្រក់ស្លឹកត្នោត ។ កាលនោះអង្គការមិនទាន់មានផែនការហូបរួមនៅឡើយ ។ យើងនៅទីនោះបានរយៈពេលមួយខែ ឪពុកមានិងម្តាយបង្កើតខ្ញុំបានសុំអង្គការឲ្យពួកយើងបានត្រឡប់មកនៅភូមិជ័យរតវិញ ។

នៅភូមិជ័យរតបានប៉ុន្មានខែ ឪពុកមាខ្ញុំបានសុំអង្គការត្រឡប់ទៅរស់នៅស្រុកកំណើតរបស់គាត់ នៅឯស្រុកស្អាង ខេត្តកណ្តាល ហើយគាត់បានប្រគល់ខ្ទមស្លឹកទំហំប្រហែល៥x៤ម មកឲ្យគ្រួសារខ្ញុំរស់នៅ ។ ជីវភាពរបស់យើងនៅទីនោះពីមួយថ្ងៃទៅមួយថ្ងៃកាន់តែចុះដុនដាបទៅៗ ។ ជីតាខ្ញុំខិតខំកាន់កាប់ដីដាំដំណាំ ជីដូនខ្ញុំមានជំងឺដុះសាច់ដុំពោះតាំងពីគាត់សម្រាលបានឪពុកខ្ញុំម្ល៉េះ ។ ពីដើមជីដូនខ្ញុំខ្ពើមសាច់គោ សាច់ក្របី សូម្បីតែត្រីរ៉ំអិលក៏គាត់មិនដែលពិសាដែរ ប៉ុន្តែមកដល់ជំនាន់ ប៉ុល ពត គាត់ពិសាគ្មានរើសមុខ ខ្ញុំអាណិតគាត់ខ្លាំងណាស់ ប៉ុន្តែពុំដឹងធ្វើដូចម្តេច ។ ប្រហែលជាខែសីហា ឆ្នាំ១៩៧៥ ជីដូនខ្ញុំកើតជំងឺខ្យល់គ ហើយក៏បានលាកចាកលោកទាំងបិទភ្នែកមិនជិត ។ ខ្ញុំយំឱបសាកសពជីដូនខ្ញុំរហូតទល់ភ្លឺទើបមានចាស់ទុំក្នុងភូមិមកជួយបញ្ចុះសាកសពគាត់ ។ ពួកយើងរស់នៅតែពីរនាក់ជីតានិងចៅយ៉ាងកណ្តោចកណ្តែង ។ មុនពេលឪពុកមាខ្ញុំទៅស្រុកកំណើត គាត់បានបបួលជីតាខ្ញុំទៅដែរ ប៉ុន្តែជីតាខ្ញុំពោលថា គាត់រង់ចាំកូនប្រុសគាត់ត្រឡប់មកវិញ ។ ជីតាខ្ញុំសង្ឃឹមថាឪពុកខ្ញុំពិតជាត្រឡប់មកវិញ ប៉ុន្តែការទន្ទឹងរង់ចាំរបស់ជីតាខ្ញុំក្លាយទៅជាគ្មានន័យ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៦ រូបខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យចូលជាកងចល័តយុវជន ដែលមានតែរូបខ្ញុំម្នាក់ប៉ុណ្ណោះមានអាយុតិចជាងគេ ។ នៅដើមឆ្នាំ១៩៧៧ ជីតាខ្ញុំបានធ្លាក់ខ្លួនឈឺដោយរោគចាស់ជរានិងរោគផ្លូវចិត្ត (ខ្ញុំដឹងដំណឹងតាមអ្នកដឹកស្បៀងម្នាក់លួចប្រាប់ខ្ញុំ) ខ្ញុំពុំត្រូវអនុញ្ញាតឲ្យទៅសួរសុខទុក្ខគាត់ឡើយ ។ ទីបំផុតជីតាខ្ញុំបានស្លាប់យ៉ាងវេទនា ទាំងគ្មានញាតិសន្តានណាម្នាក់នៅក្បែរ ។ សាកសពរបស់ជីតាខ្ញុំត្រូវបានអ្នកជាំស្លូចិត្តសប្បុរសម្នាក់សុំអង្គការយកទៅបញ្ចុះក្នុងព្រៃក្រោយភូមិ ។ ចំណែកម្តាយចុងខ្ញុំនិងកូនគាត់បីនាក់ទៀតត្រូវអង្គការយកទៅសម្លាប់នៅចុងឆ្នាំ១៩៧៦ ដោយកុហកគាត់ថាទៅធ្វើត្រីនៅទន្លេសាប ។ ប៉ុន្តែការពិតពួកគាត់ត្រូវបានសម្លាប់នៅក្រោយវត្តស្វាយកាលក្បែរជើងភ្នំសន្ទុក ។ ចំណែកកូនទី៣របស់គាត់បានលោតចុះពីរទេះគោ និងរស់រានមានជីវិតរហូតដល់បច្ចុប្បន្ន ។

ខ្ញុំស្គាល់ឃាតករនោះច្បាស់ណាស់ ប៉ុន្តែពុំដាច់ចិត្តធ្វើការសងសឹក ។

ខ្ញុំសង្ឃឹមថាសាលាកាត់ក្តីខ្មែរក្រហមនឹងមានដំណើរការល្អ ។ ខ្ញុំគ្រាន់តែចង់ស្វែងរកយុត្តិធម៌ជូនអ្នកដែលស្លាប់ទាំងអស់ក្នុងជំនាន់ប្រល័យពូជសាសន៍ ហើយខ្ញុំសង្ឃឹមថាវិញ្ញាណក្ខន្ធពួកគាត់នឹងទៅកាន់សុគតិភពដោយស្ងប់ស្ងាត់ បន្ទាប់ពីសាលាក្តីត្រូវបានបញ្ចប់ដោយជោគជ័យ ។

សូមលោកនិពន្ធនាយកនិងសហការីទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

**អៀ ហុង**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# លិខិតពីមិត្តអ្នកអាន

កម្មវត្ថុ ៖ លិខិតថ្លែងអំណរគុណនិងការសុំបន្តការឧបត្ថម្ភនូវទស្សនាវដ្ដី«ស្វែងរកការពិត»សម្រាប់ឆ្នាំ២០០៧ដល់បណ្ណាល័យហ៊ុនសែននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកនាយកគ្រប់គ្រងបន្ថែមទៀតថា ទីចាត់ការទស្សនាវដ្ដីរបស់លោកបានជួយឧបត្ថម្ភជាអំណោយសប្បុរសនូវទស្សនាវដ្ដី«ស្វែងរកការពិត» ជាទៀងទាត់រៀងរាល់លេខចំនួន១០ច្បាប់ក្នុងលេខនីមួយៗចាប់ពីខែមករា ឆ្នាំ២០០០ ដល់ ខែកញ្ញា ឆ្នាំ២០០៦ដើម្បីជួយអភិវឌ្ឍន៍បណ្ណាល័យហ៊ុនសែន ។ កន្លងមកនេះក្នុងមួយថ្ងៃៗអ្នកអានស្រាវជ្រាវក្នុងបណ្ណាល័យហ៊ុនសែនមានចំនួនពី៥០០ទៅ៦០០នាក់បានមកសិក្សាស្រាវជ្រាវមុខវិជ្ជាផ្សេងៗ និងមានអ្នកខ្លះទៀតក្នុងចំណោមនោះបានអានទស្សនាវដ្ដី«ស្វែងរកការពិត» បានជ្រួតជ្រាបនូវខ្លឹមសារប្រវត្តិសាស្ត្រដូរចត់និងបានថ្លែងអំណរគុណដឹងគុណនិងសម្ដែងការគោរពយ៉ាងជ្រាលជ្រៅចំពោះកាយវិការប្រកបដោយសប្បុរសធម៌របស់លោកនាយក ។

អាស្រ័យហេតុនេះសម្រាប់ឆ្នាំ២០០៧ សូមលោកនាយកមេត្តាពិនិត្យលទ្ធភាពអនុញ្ញាតបន្តការឧបត្ថម្ភជាអំណោយសប្បុរសនូវទស្សនាវដ្ដី«ស្វែងរកការពិត»ដល់បណ្ណាល័យហ៊ុនសែនជាបន្តទៅទៀតដោយក្ដីអនុគ្រោះ ។

នៅឱកាសឆ្នាំថ្មី ឆ្នាំសាកល២០០៧នេះ យើងខ្ញុំសូមគោរពជូនពរ បវរថ្លៃថ្លា មហាប្រសើរកើតមានដល់លោកនាយកគ្រប់គ្រងនិងសមាជិកទាំងអស់ក្នុងអង្គភាពនិងសូមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

**ប្រធានបណ្ណាល័យហ៊ុនសែននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

**សេន សេង**

# ដំណឹងសួររកកូនប្រុសឈ្មោះ ដួង ទុយ

នាងខ្ញុំឈ្មោះ ឈឿន អ៊ុយ អាយុ៨៣ឆ្នាំ ពីដើមរស់នៅភូមិស្វាយចេក ឃុំស្វាយចេក ស្រុកពួក ខេត្តសៀមរាប បច្ចុប្បន្នរស់នៅភូមិស្វាយចេក ឃុំតាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប សូមសួររកកូនប្រុសឈ្មោះ ដួង ទុយ ដែលបានចូលបម្រើក្នុងក្រុមសិល្បៈរបស់ខ្មែរក្រហម ហើយបាត់ខ្លួននៅឆ្នាំ១៩៧៣ ។ ទុយ ជាកូនទី៣ ក្នុងចំណោមកូន៧នាក់ ។ ទុយ ធ្លាប់រៀនដល់ថ្នាក់ទី១១ពីសង្គម ។ នៅឆ្នាំ១៩៧០ ទុយ ចូលធ្វើឈ្លបខ្មែរក្រហមនិងដើរយាមល្បាតនៅក្នុងភូមិ ។ បន្ទាប់មកអង្គការប្រកាសជ្រើសរើសក្រុមសិល្បៈ ហើយ ទុយ ក៏ចូលក្រុមសិល្បៈនោះតែម្ដង ។ នៅឆ្នាំ១៩៧៣ ក្រុមគ្រួសាររបស់នាងខ្ញុំត្រូវអង្គការជម្លៀសទៅស្រុកស្វាយលើ ហើយក៏ដាច់ការទាក់ទងជាមួយ ទុយ តាំងពីពេលនោះមក ។ នៅដើមឆ្នាំ១៩៧៩ ក្រុមគ្រួសាររបស់នាងខ្ញុំបានត្រឡប់មកស្រុកកំណើតវិញ ហើយឮដំណឹងតាមអ្នកភូមិថា ទុយ បានចូលធ្វើការក្នុងក្រុមសិល្បៈនិងមាននាទីជាប្រធានក្រុមសិល្បៈចល័ត ។

ដូច្នេះបើបងប្អូនណាបានដឹងដំណឹងពីឈ្មោះខាងលើ ឬកូនរស់នៅទីណានោះសូមមករកម្ដាយតាមអាសយដ្ឋានខាងលើ ។ សូមអរគុណ ។

# ដំណឹងសួររកកូនប្រុសឈ្មោះ ហេង ហួយ

ខ្ញុំបាទឈ្មោះ គីម ហេង អាយុ៨៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិតាត្រាវ ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប សូមសួររកកូនប្រុសឈ្មោះ ហេង ហួយ ដែលបានបាត់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ហួយ បានឈប់រៀនត្រឹម ថ្នាក់ទី១២ដើម្បីចូលបម្រើបដិវត្តន៍ ។ នៅឆ្នាំ១៩៧៥ ហួយ ត្រូវអង្គការបញ្ជូនឲ្យទៅភ្នំពេញ ធ្វើការនៅតាមផ្លូវជាតិលេខ៦ និងបន្ទាប់មក ហួយ ត្រូវបានផ្លាស់ឲ្យមកធ្វើការនៅខេត្តសៀមរាប ហើយក៏បាត់ដំណឹងរហូតមក ។

ប្រសិនបើបងប្អូនណាបានឮដំណឹងអំពីឈ្មោះនេះសូមមេត្តាជួយផ្ដល់ព័ត៌មានមកនាងខ្ញុំតាមអាសយដ្ឋានដូចបានរៀបរាប់ខាងលើ ។ សូមអរគុណ ។




យុវសិស្ស ជា សុធារ៉ា ចាប់អារម្មណ៍ចំពោះអដ្ឋិធាតុរបស់ជនរងគ្រោះ នៅវាលពិឃាតបឹងជើងឯក

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 86, February 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.